**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**

**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

## សារណាបញ្ចប់ការសិក្សា

# នយោបាយពាណិជ្ជកម្មអន្តរជាតិរបស់ប្រទេសកម្ពុជា ជាមួយនឹងប្រទេសសមាជិកអាស៊ាន

**( ករណីសិក្សា ប្រទេសថៃ វៀតណាម និងឡាវ )**

ស្រាវជ្រាវពីថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០២១ ដល់ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០២១

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **រស់ សុរៈវឌ្ឍនៈ**

**ហាន់ គឹមហ័ង**

សាស្ត្រាចារ្យណែនាំ

**ឡុង ម៉ាមីឌី**

ថ្នាក់បរិញ្ញាបត្រ សេដ្ឋកិច្ចអភិវឌ្ឍន៍

ជំនាន់ទី ០៥

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **រស់ សុរះខន្ធនៈ** និង **ហាន់ គឹមហ័ង** ជានិស្សិតជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ ឆ្នាំទី ៤ ជំនាន់ទី ០៥ នៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងខ្ពង់ខ្ពស់ចំពោះ**

- **លោកអ្នកមានគុណទាំងពីរ** របស់យើងខ្ញុំដែលបានផ្តល់កំណើត និងខិតខំចិញ្ចឹមបីបាច់ថែរក្សាយើងខ្ញុំតាំងពីតូចក្រូចឆ្មា រហូតដល់ធំដឹងក្តីដោយគ្មានការត្អូញត្អែរ ព្រមទាំងបានធ្វើការអប់រំទូន្មានប្រៀនប្រដៅយ៉ាងច្រើនដល់យើងខ្ញុំ និងបានផ្តល់នូវឱកាសដ៏ធំធេងក្នុងការសិក្សារៀនសូត្រតាំងពីថ្នាក់មត្តេយ្យ រហូតដល់ថ្នាក់បរិញ្ញាបត្រនេះ។ លើសពីនេះទៅទៀត លោកទាំងពីរបានផ្តល់នូវសេចក្តីស្រលាញ់ ព្រមទាំងលះបង់ទាំងកម្លាំងកាយ និងកម្លាំងចិត្តដ៏ធំមហិមាក្នុងការចិញ្ចឹមបីបាច់ថែរក្សា ព្រមទាំងបានផ្គត់ផ្គង់នូវរាល់សេចក្តីត្រូវការទាំងឡាយ។
- **លោកគ្រូ អ្នកគ្រូ គ្រប់កម្រិតថ្នាក់** ដែលបានខិតខំបង្រៀន និងផ្តល់ជាចំណេះដឹង ប្រៀនប្រដៅណែនាំអោយដើរក្នុងផ្លូវល្អ និងជៀសឆ្ងាយពីអំពើអបាយមុខទាំងឡាយ។
- **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ប្រធាន និងអនុប្រធានការិយាល័យសិក្សា និងស្រាវជ្រាវ ព្រមទាំងលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ** គ្រប់មុខវិជ្ជានៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចដែលបានដឹកនាំ និងរៀបចំ បង្ហាត់បង្រៀន និងផ្តល់នូវចំណេះដឹងយ៉ាងច្រើនក្រៃលែងដល់យើងខ្ញុំអោយទទួលបាននូវផ្លែផ្កាក្នុងការសិក្សារៀនសូត្រកន្លងមក។
- លោកស្រី **សាស្ត្រាចារ្យ ឡុង ម៉ារីឌី** ដែលជាសាស្រ្តាចារ្យក្នុងការណែនាំដល់ក្រុមយើងខ្ញុំ ដោយបានចំណាយទាំងពេលវេលាដ៏មានតម្លៃក្នុងការណែនាំ និងបង្ហាត់បង្ហាញពីរបៀបរបបក្នុងការស្រាវជ្រាវ ព្រមទាំងផ្តល់ជាគំនិតយោបល់ល្អដែលជាជំនួយក្នុងការសិក្សាស្រាវជ្រាវរបស់ក្រុមយើងខ្ញុំ។ លើសពីនេះទៅទៀត លោកស្រីក៏បានផ្តល់នូវអនុសាសន៍ល្អៗបន្ថែមទៀត និងកែលំអនូវរាល់ចំណុចខ្វះខាតរបស់ក្រុមយើងខ្ញុំ ដើម្បីធ្វើអោយកាន់តែមានភាពប្រសើរឡើងវិញ។

ជាចុងក្រោយ យើងខ្ញុំសូមជូនពរលោកអ្នកមានគុណទាំងពីរ ឯកឧត្តម លោក លោកស្រី សាស្ត្រាចារ្យគ្រប់កម្រិតថ្នាក់ទាំងអស់ សូមអោយមានសេរីសួស្តីជ័យមង្គល វិបុលសុខ បវរមហាប្រសើរ និងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ពាណិជ្ជកម្មអន្តរជាតិ គឺជាកាតាលីករមួយយ៉ាងសំខាន់ក្នុងការជម្រុញល្បឿនសេដ្ឋកិច្ចរបស់គ្រប់បណ្តាប្រទេសនៅលើសកលលោក។ មិនថាប្រទេសអភិវឌ្ឍន៍ ឬកំពុងអភិវឌ្ឍន៍ក្តី បាននឹងកំពុងនាំគ្នាជ្រៀតខ្លួនចូលទៅក្នុងទីផ្សារអន្តរជាតិ ដើម្បីដោះដូរទំនិញ និងសេវាកម្មគ្នាទៅវិញទៅមក ក្នុងគោលបំណងស្វែងរកផលចំណេញសេដ្ឋកិច្ច និងពង្រីកទីផ្សារពាណិជ្ជកម្មរបស់ខ្លួន។ ជាក់ស្តែង នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះប្រទេសកម្ពុជាកំពុងមានភាពរីកចម្រើន និងមានទំនាក់ទំនងល្អជាមួយនឹងបណ្តាប្រទេសជិតខាង ហើយនឹងកំពុងប្រែក្លាយទៅជាប្រទេសអភិវឌ្ឍន៍នាពេលអនាគត ដោយសារតែកំណើននៃការធ្វើពាណិជ្ជកម្មមានការកើនឡើងជាបន្តបន្ទាប់។

រយៈពេល២២ឆ្នាំមកហើយដែលប្រទេសកម្ពុជាបានចូលជាសមាជិកអាស៊ាន ហើយប្រទេសជាសមាជិកអាស៊ានទាំង១០បានចូលរួមក្នុងការសម្របសម្រួលកិច្ចព្រមព្រៀងពាណិជ្ជកម្ម ធ្វើយ៉ាងណាអោយមានភាពងាយស្រួល និងមានកំណើនក្នុងការដោះដូរ។ តួយ៉ាងការធ្វើពាណិជ្ជកម្មជាមួយនឹងប្រទេសដែលមានព្រំប្រទល់ជាប់ ជាមួយនឹងប្រទេសកម្ពុជា ហើយស្ថិតនៅក្នុងសមាជិកអាស៊ាន រួមមានថៃ វៀតណាម ឡាវ ក៏ជាចំណែកមួយយ៉ាងសំខាន់បំផុតក្នុងការជ្រោមជ្រែង ធ្វើអោយសេដ្ឋកិច្ចពាណិជ្ជកម្មរបស់ប្រទេសកម្ពុជាមានភាពរីកចម្រើនផងដែរ។ ជាការពិតណាស់ ការធ្វើពាណិជ្ជកម្មមានអត្ថប្រយោជន៍ចំពោះគ្នាទៅវិញទៅមកបានលុះត្រាតែគេមានគោលការណ៍ កិច្ចព្រមព្រៀង និងគោលនយោបាយរួមមួយចំនួនដើម្បីគ្រប់គ្រងសកម្មភាពពាណិជ្ជកម្មទាំងនោះ។ ហេតុដូច្នេះទើបក្រុមរបស់យើងខ្ញុំសម្រេចចិត្តលើកយកប្រធានបទស្តីនយោបាយពាណិជ្ជកម្មរបស់កម្ពុជាជាមួយនឹងប្រទេសសមាជិកអាស៊ានមកធ្វើការបង្ហាញ។

ជាចុងក្រោយ ក្រុមរបស់យើងខ្ញុំសូមអភ័យទោសទុកជាមុនពីសំណាក់ លោក-លោកស្រី សាស្ត្រាចារ្យ និងមិត្តអ្នកអាន ព្រមទាំងនិស្សិតទាំងអស់ជាទីគោរពនូវរាល់កំហុសខុសឆ្គង និងចំណុចខ្វះខាតទាំងឡាយដែលកើតមានឡើងនៅក្នុងសៀវភៅមួយក្បាលនេះ។ ក្រុមរបស់ខ្ញុំមានសេចក្តីសោមនស្សរីករាយ ក្នុងការទទួលយកនូវមតិរិះគន់ ដើម្បីស្ថាបនា ព្រមទាំងបំពេញទៅលើកំហុស និងចំណុចខ្វះខាតដែលកើតមានឡើង។ យើងខ្ញុំសូមប្រសិទ្ធពរជ័យ សិរីប្រសើរគ្រប់ប្រការចូលកើតមានដល់អស់លោក លោកស្រីទាំងអស់ សូមអោយសម្រេចបាននូវជោគជ័យក្នុងការប្រកបការងារ និងមានសុខសុវត្ថិភាព ព្រមទាំងមានសុខភាពល្អ និងសុភមង្គលនៅក្នុងគ្រួសារជានិរន្តរ៍។

# មាតិកា


អក្សរកាត់....................................................................................................................v
បញ្ជីតារាង ...................................................................................................................vii
បញ្ជីក្រាប ....................................................................................................................viii
បញ្ជីរូបភាព....................................................................................................................ix
បញ្ជីឧបសម្ព័ន្ធ ...................................................................................................................x


## សេចក្តីផ្តើម


១.លំនាំ និងចំណូលបញ្ហា ........................................................................................... ១
២.ចំណោទបញ្ហានៃការស្រាវជ្រាវ.................................................................................. ១
៣.គោលបំណងនៃការស្រាវជ្រាវ......................................................................................២
៤.សារៈសំខាន់នៃការស្រាវជ្រាវ ....................................................................................២
៥.ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ .........................................................................២
៦.វិធីសាស្ត្រនៃការស្រាវជ្រាវ ..........................................................................................៣
៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ....................................................................................... ៤


## ជំពូកទី ១
## រំលឹកទ្រឹស្តី


១.១.និយមន័យពាណិជ្ជកម្មអន្តរជាតិ.............................................................................. ៥
១.២.ទ្រឹស្តីពាណិជ្ជកម្មអន្តរជាតិ ....................................................................................... ៥
១.២.១.ទ្រឹស្តីបែបក្លាសិុក.......................................................................................... ៥
១.២.២.ទ្រឹស្តីបែបក្លាសិុកថ្មី........................................................................................ ៦
១.៣.នយោបាយពាណិជ្ជកម្ម ..............................................................................................៧
១.៣.១.នយោបាយពាណិជ្ជកម្មជាតិ ...........................................................................៧
១.៣.២.នយោបាយពាណិជ្ជកម្មទ្វេភាគី........................................................................៧
១.៣.៣.នយោបាយពាណិជ្ជកម្មអន្តរជាតិ .................................................................... ៨
១.៤.កិច្ចព្រមព្រៀងពាណិជ្ជកម្មអន្តរជាតិ.............................................................................. ៨
១.៤.១.កិច្ចព្រមព្រៀងទូទៅស្តីពីពន្ធនិងពាណិជ្ជកម្ម(GATT) ............................................ ៨
១.៤.២.កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTAs) ............................................................. ៩

១.៤.៣.កិច្ចព្រមព្រៀងពាណិជ្ជកម្មលើការអនុគ្រោះពន្ធ(PTAs) ..... ១០
១.៥.ឧបករណ៍នៃនយោបាយពាណិជ្ជកម្មអន្តរជាតិ ..... ១០
១.៥.១.ពន្ធនាំចូល ..... ១០
១.៥.២.ពន្ធនាំចេញ ..... ១០
១.៥.៣.កូតានាំចូល ..... ១១
១.៥.៤.ឧបត្ថម្ភធនចំពោះការនាំចេញ ..... ១១
១.៥.៥.ការរឹតបន្តឹងនាំចេញដោយស្ម័គ្រចិត្ត ..... ១៣
១.៥.៦.ការបង្កើនការនាំចូលដោយស្ម័គ្រចិត្ត ..... ១៣
១.៥.៧.នយោបាយពាណិជ្ជកម្មផ្សេងៗទៀត ..... ១៤
១.៦.អ្វីទៅជាអាស៊ាន ..... ១៥
១.៦.១.ប្រវត្តិនៃការកកើតអាស៊ាន ..... ១៥
១.៦.២.មូលដ្ឋាន និងអត្តសញ្ញាណអាស៊ាន ..... ១៦
១.៦.៣.និមិត្តសញ្ញានិងទង់អាស៊ាន ..... ១៦
១.៦.៤.លក្ខខណ្ឌនៃការចូលជាសមាជិកអាស៊ាន ..... ១៧
១.៦.៥.ចក្ខុវិស័យ បេសកកម្ម និង គោលបំណងនៃការបង្កើតអាស៊ាន ..... ១៨
១.៧.តំបន់ពាណិជ្ជកម្មសេរីអាស៊ាន ( AFTA ) ..... ១៩
១.៧.១.ការផ្តួចផ្តើមគំនិតសម្រាប់កិច្ចសម្រួលពាណិជ្ជកម្ម ..... ២០
១.៧.២.ការរៀបចំពាណិជ្ជកម្មផ្អែកលើបទបញ្ញត្តិ ..... ២១
១.៧.៣.គោលដៅចុងក្រោយនៃ AFTA ..... ២១
១.៧.៤.ការតភ្ជាប់សេដ្ឋកិច្ចក្រៅតំបន់ ..... ២២
១.៨.សមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ាន ..... ២៣

## ជំពូកទី ២

## លទ្ធផលនៃការស្រាវជ្រាវ

២.១.ស្ថានភាពទូទៅរបស់ប្រទេសកម្ពុជា ..... ២៤
២.១.១.ស្ថានភាពពាណិជ្ជកម្មក្នុងស្រុក ..... ២៥
២.១.២.ស្ថានភាពពាណិជ្ជកម្មជាលក្ខណៈអន្តរជាតិ ..... ២៦
២.២.ស្ថានភាពទូទៅរបស់ប្រទេសថៃ ..... ២៨

២.២.១.កិច្ចព្រមព្រៀងពាណិជ្ជកម្មជាមួយថៃ ..................................................... ២៨
២.២.២.ការនាំចូលទំនិញពីប្រទេសថៃ ..................................................... ២៩
២.២.៣.ការដាក់ពន្ធទំនិញនាំចូលពីប្រទេសថៃ ..................................................... ៣១
២.២.៤.ការនាំចេញទំនិញទៅប្រទេសថៃ ..................................................... ៣២
២.២.៥.ការវិនិយោគផ្ទាល់ពីប្រទេសថៃ ..................................................... ៣៤
២.៣.ស្ថានភាពទូទៅរបស់ប្រទេសវៀតណាម ..................................................... ៣៥
២.៣.១.កិច្ចព្រមព្រៀងពាណិជ្ជកម្មជាមួយវៀតណាម ..................................................... ៣៦
២.៣.២.ការនាំចូលទំនិញពីប្រទេសវៀតណាម ..................................................... ៣៦
២.៣.៣.ការដាក់ពន្ធទំនិញនាំចូលពីប្រទេសវៀតណាម ..................................................... ៣៨
២.៣.៤.ការនាំចេញទំនិញទៅប្រទេសវៀតណាម ..................................................... ៣៩
២.៣.៥.ការអនុគ្រោះពន្ធក្នុងការនាំចូលទៅប្រទេសវៀតណាម ..................................................... ៤១
២.៣.៦.ការវិនិយោគផ្ទាល់ពីវៀតណាម ..................................................... ៤១
២.៤.ស្ថានភាពទូទៅរបស់ប្រទេសឡាវ ..................................................... ៤២
២.៤.១.ការធ្វើពាណិជ្ជកម្មអន្តរជាតិរបស់កម្ពុជាជាមួយឡាវ ..................................................... ៤៣
២.៤.២.ការនាំចូលទំនិញពីប្រទេសឡាវ. ..................................................... ៤៣
២.៤.៣.ការនាំចេញទំនិញទៅប្រទេសឡាវ ..................................................... ៤៤
២.៥.ច្រកពាណិជ្ជកម្មសំខាន់ៗ ..................................................... ៤៥
២.៥.១.ច្រកបាវិត ..................................................... ៤៦
២.៥.២.ច្រកប៉ោយប៉ែត ..................................................... ៤៧
២.៥.៣.ច្រកត្រពាំងគ្រៀល ..................................................... ៤៨
២.៦.មធ្យោបាយនៃការដឹកជញ្ជូននៅក្នុងការធ្វើពាណិជ្ជកម្ម ..................................................... ៥០
២.៦.១.ប្រភេទនៃមធ្យោបាយដឹកជញ្ជូន ..................................................... ៥១
២.៦.២.ទំហំនៃការដឹកជញ្ជូន ..................................................... ៥៥
២.៦.៣.បញ្ហានៃមធ្យោបាយដឹកជញ្ជូន ..................................................... ៥៦
២.៦.៤.ផែនការអភិវឌ្ឍន៍ប្រព័ន្ធដឹកជញ្ជូននៅកម្ពុជា ..................................................... ៥៧
២.៧.លក្ខខណ្ឌពិសេសទៅលើទំនិញក្នុងការធ្វើពាណិជ្ជកម្ម ..................................................... ៥៩
២.៧.១.ទំនិញដែលត្រូវបានលើកលែងពន្ធ និងអាករ ..................................................... ៥៩

២.៧.២.ការគ្រប់គ្រងទំនិញដែលបានលើកលែងពន្ធ និងអាករ ........ ៦០
២.៧.៣.គោលបំណងក្នុងការហាមឃាត់ការនាំចេញ និងនាំចូល ........ ៦១
២.៨.ឥទ្ធិពលនៃការធ្វើពាណិជ្ជកម្មអន្តរជាតិជាមួយនឹងអាស៊ាន ........ ៦២
២.៨.១.ឥទ្ធិពលវិជ្ជមាន ........ ៦២
២.៨.២.ឥទ្ធិពលអវិជ្ជមាន ........ ៦៤

## ជំពូកទី ៣

## ពិភាក្សា និងវិភាគលទ្ធផល

៣.១.ការកំណត់ និងពន្យល់អថេរវិភាគ ........ ៦៦
៣.២.ការវិភាគទិន្នន័យ ........ ៦៦
៣.៣.១.វិភាគទំហំពាណិជ្ជកម្មរបស់កម្ពុជាជាមួយបណ្ដាប្រទេសទាំងបី ........ ៦៦
៣.៣.២.វិភាគទំហំពាណិជ្ជកម្មជាមួយប្រទេសទាំងបី ជាមួយនឹងទំហំពាណិជ្ជកម្មសរុបរបស់កម្ពុជា.. ៦៩
៣.៣.៣.ការវិភាគពាណិជ្ជកម្មជាមួយប្រទេសទាំងបីជាមួយពាណិជ្ជកម្មសរុបរបស់អាស៊ាន ........ ៧០
៣.៤.ឥទ្ធិពលនៃកូវីត-១៩មកលើពាណិជ្ជកម្មកម្ពុជា ........ ៧១

## សេចក្ដីសន្និដ្ឋាន និងការផ្ដល់អនុសាសន៍

១.សេចក្ដីសន្និដ្ឋាន ........ ៧៤
២.ការផ្ដល់អនុសាសន៍ ........ ៧៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# អក្សរកាត់

| | |
|---|---|
| GDP | Gross Domestic Product (ផលិតផលក្នុងស្រុកសរុប) |
| MDG | Millennium Development Goals (គោលដៅអភិវឌ្ឍន៍សហសវត្សន៍) |
| AEC | Asean Economics Community (សហគមន៍សេដ្ឋកិច្ចអាស៊ាន) |
| OECD | Organization for Economic Co-operation Development (អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍ) |
| WTO | World Trade Organization (អង្គការពាណិជ្ជកម្មពិភពលោក) |
| IMF | International Monetary Fund (មូលនិធិរូបិយវត្ថុអន្តរជាតិ) |
| ITO | International Trade Organization (អង្គការពាណិជ្ជកម្មអន្តរជាតិ) |
| GATT | General Agreement on Tariffs and Trade (កិច្ចព្រមព្រៀងទូទៅស្តីពីពន្ធ និងពាណិជ្ជកម្ម |
| FTA | Free Trade Agreement (កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី) |
| PTAs | Preferential Trade Agreement (កិច្ចព្រមព្រៀងពាណិជ្ជកម្មលើការអនុគ្រោះពន្ធ) |
| VERs | Voluntary Export Restraint (ការរឹតបន្តឹងការនាំចេញដោយស្ម័គ្រចិត្ត) |
| VIE | Voluntary Import Expansion (ការបង្កើនការនាំចូលដោយស្ម័គ្រចិត្ត) |
| ASA | Association of Southeast Asia (សមាគមអាស៊ីអាគ្នេយ៍) |
| ACC | Asean Chess Confederation (ក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន) |
| AFTA | Asean Free Trade Agreement (កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន) |
| CEPT | Common Effective Preferential Tariff (កិច្ចព្រមព្រៀងអនុគ្រោះពន្ធគយប្រកបដោយសុវត្ថិភាព) |
| ASEAN | Association of Southeast Asian Nations (សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍) |
| ISO | International Organization for Standardization (អង្គការស្តង់ដាអន្តរជាតិ) |
| IEC | International Electro Technical Commission (គណៈកម្មាធិការបច្ចេកវិទ្យាអេឡិចត្រូនិកអន្តរជាតិ) |
| ITU | International Telecommunication Union (សហភាពទូរគមនាគមន៍អន្តរជាតិ) |
| GSP | Generalized System of Preference (ប្រព័ន្ធអនុគ្រោះទូទៅ) |
| EU | European Union (សហភាពអឺរ៉ុប) |
| EBA | Everything but Arms (អ្វីៗគ្រប់យ៉ាងលើកលែងតែអាវុធ) |
| ACMECS | Ayeyawady-Chao Praya-Mekong Economic Cooperation Strategy (ក្រុមប្រឹក្សាធុរកិច្ចនៃយុទ្ធសាស្ត្រសេដ្ឋកិច្ចតំបន់ទន្លេមេគង្គ) |
| IAI | Initiative for Asean Integration (គំនិតផ្តួចផ្តើមសម្រាប់សមាហរណកម្មអាស៊ាន) |
| AISP | Asean Integrated System of Preference (ប្រព័ន្ធសមាហរណកម្មអាស៊ាន) |
| BPA | Bilateral Payment Arrangement (កិច្ចព្រមព្រៀងទូទាត់ទ្វេភាគី) |

| | |
|---|---|
| CD | Custom Duty (កាតព្វកិច្ចគយ) |
| ST | Special Tax (ពន្ធពិសេស) |
| VAT | Value added Tax (ពន្ធបន្ថែម) |
| AHTN | Asean Harmonized Tariff Nomenclature (បញ្ជីពន្ធស្មើភាពគ្នារបស់អាស៊ាន) |
| ATIGA | the Asean Trade in Good Agreement (កិច្ចព្រមព្រៀងពាណិជ្ជកម្មលើទំនិញរបស់អាស៊ាន) |
| GMS | The Greater Mekong Sub region Program (កម្មវិធីមហាអនុតំបន់មេគង្គ) |
| MPWT | Ministry of Public Work and Transport (ក្រសួងសាធារណការ និងដឹកជញ្ជូន) |
| PPAP | Phnom Penh Autonomous Port (កំពង់ផែស្វយ័តភ្នំពេញ) |
| TEUs | Twenty-foot Equivalent Unit (ឯកតារង្វាស់មួយដែលត្រូវបានប្រើដើម្បីកំណត់សមត្ថភាពដឹកទំនិញ សម្រាប់កប៉ាល់កុងតឺន័រ) |
| EMC | Emerging Markets Consulting (ក្រុមប្រឹក្សាយោបល់អំពីទីផ្សារកំពុងរីកចម្រើន) |

# បញ្ជីតារាង

តារាងទី២.១ ៖ សន្ទស្សន៍ថ្លៃទំនិញមួយចំនួនដែលចាំបាច់សម្រាប់ជីវភាពរស់នៅរបស់ប្រជាជន ............... ២៦
តារាងទី២.២ ៖ បង្ហាញទំនិញនាំចូលពីប្រទេសថៃ ចូលមកប្រទេសកម្ពុជាចាប់ពីឆ្នាំ ២០១៧ ដល់ ២០១៩.. ៣០
តារាងទី២.៣ ៖ បង្ហាញពីទំហំទឹកប្រាក់ផលិតផលនីមួយៗនៃការនាំចេញផលិតផលរបស់កម្ពុជាទៅកាន់ប្រទេសថៃពីឆ្នាំ ២០១៧ ដល់ ឆ្នាំ ២០១៩ ........................................................................................... ៣៣
តារាងទី២.៤ ៖ បង្ហាញពីទិន្នន័យនៃទឹកប្រាក់ទៅតាមមុខទំនិញនីមួយៗដែលនាំចូលពីប្រទេសវៀតណាមមកកាន់ប្រទេសកម្ពុជា ................................................................................................ ៣៧
តារាងទី២.៥ ៖ ទិន្នន័យនៃការនាំចេញរបស់កម្ពុជាទៅប្រទេសវៀតណាម ............................................ ៤០
តារាងទី២.៦ ៖ ទិន្នន័យនៃការនាំចូលទំនិញពីប្រទេសឡាវពីឆ្នាំ ២០១៧ ដល់ ២០១៩ .......................... ៤៤
តារាងទី២.៧ ៖ មុខទំនិញនិងទំហំទឹកប្រាក់ក្នុងការនាំចេញរបស់កម្ពុជាទៅប្រទេសឡាវពីឆ្នាំ២០១៧ដល់២០១៩ ......................................................................................................... ៤៥
តារាងទី២.៨ ៖បង្ហាញពីទំហំនៃការដឹកជញ្ជូនរបស់ប្រទេសជិតខាង ................................................... ៥៥
តារាងទី៣.១ ៖ ទិន្នន័យនៃការនាំចេញ និងនាំចូលសរុបរបស់កម្ពុជាជាមួយនឹងប្រទេសថៃ ...................... ៦៦
តារាងទី៣.២ ៖ ទិន្នន័យនៃការនាំចេញ និងនាំចូលសរុបរបស់កម្ពុជាជាមួយនឹងប្រទេសវៀតណាម............ ៦៧
តារាងទី៣.៣ ៖ ទិន្នន័យនៃការនាំចេញ និងនាំចូលសរុបរបស់កម្ពុជាជាមួយនឹងប្រទេសឡាវ.................... ៦៨

# បញ្ជីក្រាប

ក្រាបទី១.១ ៖ បង្ហាញពី GDP, GDP per capita និងប្រជាជនរបស់ប្រទេសនៅតំបន់អាស៊ាន................១៥
ក្រាបទី២.១ ៖ បង្ហាញពីការនាំចូលពីប្រទេសវៀតណាមមកកម្ពុជា ....................................................៣៨

# បញ្ជីរូបភាព


រូបភាពទី១.១ ៖ សមាជិកចំនួន ២៣ ប្រទេសដំបូងនៃការបង្កើត GATT ..... ៩

រូបភាពទី១.២ ៖ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីមួយចំនួននៅលើពិភពលោក ..... ៩

រូបភាពទី២.១ ៖ ទិដ្ឋភាពទូទៅនៃបណ្តាញផ្លូវនៅក្នុងប្រទេសកម្ពុជា ..... ៥១

រូបភាពទី២.២ ៖ ស្ថានភាពរថភ្លើងនៅកម្ពុជា ..... ៥៣

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១ ៖ កិច្ចព្រមព្រៀងពាណិជ្ជកម្មរបស់ប្រទេសកម្ពុជាជាមួយប្រទេសថៃ
ឧបសម្ព័ន្ធទី២ ៖ កិច្ចព្រមព្រៀងពាណិជ្ជកម្មរបស់ប្រទេសកម្ពុជាជាមួយប្រទេសវៀតណាម
ឧបសម្ព័ន្ធទី៣ ៖ មុខបញ្ជីទំនិញទាំង៣១មុខដែលបានអនុគ្រោះពន្ធសូន្យភាគរយក្នុងការនាំចូលទៅប្រទេសវៀតណាម
ឧបសម្ព័ន្ធទី៤ ៖ បញ្ជីរាយនាមទំនិញនិងលេខកូដដែលទទួលបានការអនុគ្រោះពន្ធសូន្យភាគរយក្នុងការនាំទំនិញពីប្រទេសវៀតណាមចូលមកកម្ពុជា
ឧបសម្ព័ន្ធទី៥ ៖ បញ្ជីរាយទំនិញដែលហាមឃាត់ក្នុងការនាំចូល
ឧបសម្ព័ន្ធទី៦ ៖ ទិន្នន័យសរុបនៃការនាំចេញ នាំចូលសរុបរបស់កម្ពុជាជាមួយប្រទេសទាំងបី
ឧបសម្ព័ន្ធទី៧ ៖ GDP សរុបរបស់ប្រទេសកម្ពុជាចាប់ពីឆ្នាំ ២០១០ ដល់ ២០២០
ឧបសម្ព័ន្ធទី៨ ៖ បង្ហាញពីទំហំពាណិជ្ជកម្មសរុបរបស់ប្រទេសកម្ពុជាពីឆ្នាំ ២០១០ ដល់ ២០២០
ឧបសម្ព័ន្ធទី៩ ៖ បង្ហាញពីទំហំពាណិជ្ជកម្មសរុបរបស់អាស៊ានពីឆ្នាំ ២០១០ ដល់ ២០១៩

# សេចក្តីផ្តើម

## ១.លំនាំ និងចំណោទបញ្ហា

ការធ្វើពាណិជ្ជកម្មអន្តរជាតិ បានធ្វើអោយមាននូវចរន្តចេញ ចូលនៃទំនិញ និងសេវាកម្ម ពីដែនដីមួយទៅកាន់ដែនដីមួយផ្សេងទៀត ហើយប្រទេសភាគច្រើនបានចាត់ទុកថាពាណិជ្ជកម្មអន្តរជាតិនេះជាចំណែកមួយដ៏សំខាន់នៃGDP។ ពាណិជ្ជកម្មអន្តរជាតិមានទំហំកើនឡើងជារៀងរាល់ឆ្នាំគឺបានកើនឡើងចំនួន ១៤.៨៩% នៅឆ្នាំ ២០២០ បើធៀបនឹងឆ្នាំ ២០១០។ [1]

បើក្រឡេកមកមើលបរិបទនៃប្រទេសកម្ពុជាវិញ គឺបានដាក់ស្នើសុំចូលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោកនៅឆ្នាំ ១៩៩៤ ហើយកម្ពុជាផ្ទាល់បានចូលជាសមាជិករបស់អាស៊ាននៅឆ្នាំ ១៩៩៩។ ការចូលខ្លួនទៅក្នុងទីផ្សារអន្តរជាតិរបស់ប្រទេសកម្ពុជា គឺដើម្បីពង្រីកនូវវិសាលភាពពាណិជ្ជកម្មរបស់ខ្លួន និងធ្វើអោយសេដ្ឋកិច្ចរបស់ប្រទេសកាន់តែមានភាពរីកចម្រើនទៅមុខបន្ថែមទៀត។ ការអភិវឌ្ឍវិស័យពាណិជ្ជកម្មអាស៊ាន គឺជាយន្តការដ៏សំខាន់មួយនៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រជារួមរបស់កម្ពុជា និងវត្ថុបំណងនៃគោលដៅអភិវឌ្ឍន៍សហសវត្សន៍ ( MDG ) ដូចបានចែងក្នុងយុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។

ការធ្វើពាណិជ្ជកម្មជាមួយនឹងប្រទេសអាស៊ាន ជាពិសេសជាមួយនឹងបណ្តាប្រទេសដែលជាប់ព្រំប្រទល់ជាមួយប្រទេសកម្ពុជាបានជួយជម្រុញដល់កំណើនសេដ្ឋកិច្ចមួយផ្នែក និងបង្កើនកិច្ចសហប្រតិបត្តិទ្វេភាគីអោយកាន់តែប្រសើរឡើង។ បើទោះបីជាផលិតកម្មរបស់ប្រទេសទាំងបី មានលក្ខណៈប្រហាក់ប្រហែលគ្នាជាមួយប្រទេសកម្ពុជាក៏ពិតមែន ក៏ប៉ុន្តែប្រទេសទាំងនេះនៅតែជម្រុញអោយមានការដោះដូរពាណិជ្ជកម្មទៅវិញទៅមក។ មួយវិញទៀត ការប្រើប្រាស់នយោបាយពាណិជ្ជកម្មគឺជាកូនសោរមួយយ៉ាងសំខាន់ នៅក្នុងការដោះស្រាយនូវរាល់គ្រប់បញ្ហាក្នុងការនាំចេញ និងនាំចូលពីប្រទេសមួយទៅប្រទេសមួយ និងជួយសម្រួលដល់ស្ថានភាពសេដ្ឋកិច្ចពាណិជ្ជកម្មរបស់ប្រទេសទាំងនោះផងដែរ។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

ប្រទេសជាច្រើននៅលើសកលលោក កំពុងតែទទួលបាននូវផលប្រយោជន៍យ៉ាងច្រើនពីការធ្វើពាណិជ្ជកម្ម ខណៈពេលដែលប្រទេសមួយចំនួនទទួលបាននូវផលប្រយោជន៍តិចតួច ដោយហេតុថាប្រទេសទាំងនោះពុំទាន់មានសមត្ថភាពគ្រប់គ្រាន់ ក្នុងការផលិតទំនិញ និងសេវាកម្ម ដើម្បីធ្វើការប្រកួតប្រជែងនៅលើទីផ្សារអន្តរជាតិ ព្រមទាំងមិនបានប្រើប្រាស់នូវនយោបាយពាណិជ្ជកម្មត្រឹមត្រូវ ដែលអាចប្រឈមមុខនឹងការខាតបង់សេដ្ឋកិច្ច ហេតុនេះហើយ ការប្រើប្រាស់នូវនយោបាយពាណិជ្ជកម្មអន្តរជាតិពិតជាមានសារៈសំខាន់ណាស់សម្រាប់

[1] ដកស្រង់ចេញពី គេហទំព័រ WTO, data.wto.org, 2021

អ្នកសិក្សាស្រាវជ្រាវ និងអ្នកដែលប្រើប្រាស់គោលនយោបាយ ព្រោះវាជះឥទ្ធិពលទៅលើការនាំចេញ នាំចូល ទំនាក់ទំនងពាណិជ្ជកម្ម និងកំណើនសេដ្ឋកិច្ច។

តាមរយៈបញ្ហាដែលបានរៀបរាប់ខាងលើនេះ ទើបក្រុមរបស់យើងខ្ញុំបានលើកយកនូវប្រធានបទ "**នយោបាយពាណិជ្ជកម្មអន្តរជាតិរបស់ប្រទេសកម្ពុជាជាមួយនឹងប្រទេសសមាជិកអាស៊ាន**" មកធ្វើការស្រាវជ្រាវ និងបកស្រាយដោយផ្អែកលើសំណួរស្រាវជ្រាវគឺ ៖

- តើនយោបាយពាណិជ្ជកម្មអន្តរជាតិរបស់ប្រទេសកម្ពុជាជាមួយនឹងប្រទេសសមាជិកអាស៊ានទាំងបីមានដំណើរការដូចម្តេចខ្លះ?
- តើពាណិជ្ជកម្មរវាងប្រទេសកម្ពុជាជាមួយនឹងប្រទេសសមាជិកអាស៊ានទាំងបី បានចូលរួមចំណែកយ៉ាងណាខ្លះនៅក្នុងទំហំពាណិជ្ជកម្មសរុបរបស់ប្រទេសកម្ពុជា?

## ៣.គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះត្រូវបានធ្វើឡើងក្នុងគោលបំណងដូចតទៅ ៖

- ស្វែងយល់ពីនយោបាយពាណិជ្ជកម្មរបស់កម្ពុជាជាមួយនឹងអាស៊ាន
- ពិនិត្យមើលទៅលើទំហំនៃការនាំចេញ នាំចូលរបស់កម្ពុជាជាមួយអាស៊ាន
- សិក្សាទៅលើឥទ្ធិពលនៃពាណិជ្ជកម្មមកលើសេដ្ឋកិច្ចកម្ពុជា

## ៤.សារៈសំខាន់នៃការស្រាវជ្រាវ

ដោយសារតែ ការធ្វើពាណិជ្ជកម្មរបស់ប្រទេសកម្ពុជាមួយផ្នែកធំ ទាក់ទងនឹងបណ្តាប្រទេសអាស៊ានរួមមាន ថៃ ឡាវ និងវៀតណាម ដូចនេះការស្រាវជ្រាវនេះមានសារៈសំខាន់ដូចខាងក្រោម ៖

- ចែករំលែកនូវចំណេះដឹងពាក់ព័ន្ធនឹងនយោបាយពាណិជ្ជកម្មជាមួយអាស៊ាន
- ដឹងពីឥទ្ធិពលរបស់ពាណិជ្ជកម្មអន្តរជាតិមកលើសេដ្ឋកិច្ចប្រទេសកម្ពុជា
- បង្ហាញពីទិន្នន័យនៃការនាំចេញ នាំចូលរបស់ប្រទេសនីមួយៗ
- បង្ហាញពីវិធីសាស្ត្រក្នុងការវិភាគទិន្នន័យ
- ផ្តល់ជាឯកសារជំនួយសម្រាប់ការស្រាវជ្រាវក្រោយៗទៀត ដែលពាក់ព័ន្ធនឹងការធ្វើពាណិជ្ជកម្មអន្តរជាតិជាមួយនឹងអាស៊ាន

## ៥.ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ចំពោះការសិក្សាស្រាវជ្រាវនៃប្រធានបទខាងលើនេះ គឺការពាក់ព័ន្ធទៅនឹងការនាំចេញ នាំចូលរបស់កម្ពុជា ជាមួយនឹងអាស៊ាន។ អាស៊ានមានចំនួន ១០ ប្រទេស ហើយត្រូវបានបែងចែកជា ប្រទេសដើមអាស៊ាន ប្រទេសចូលអាស៊ានបន្ទាប់ ប្រទេសដែលមានសេដ្ឋកិច្ចរីកចម្រើនខ្លាំង ប្រទេសមានសេដ្ឋកិច្ចមធ្យម។ ដូចនេះ

យើងនឹងលើកយកនូវការធ្វើពាណិជ្ជកម្មជាមួយនឹង ថៃ ឡាវ វៀតណាម ដោយប្រទេសទាំងបីមានព្រំប្រទល់ជាប់ជាមួយនឹងប្រទេសកម្ពុជា។ (សាម៉ុត, 2015)

ចំពោះទំហំ និងដែនកំណត់របស់ការសិក្សាស្រាវជ្រាវនេះ មានដូចខាងក្រោម ៖

- សិក្សាទៅលើនយោបាយពាណិជ្ជកម្មអន្តរជាតិដូចជា ពាណិជ្ជកម្មសេរី របាំងពន្ធគយ របាំងមិនមែនពន្ធគយជាដើម
- សិក្សាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគីជាមួយប្រទេសថៃ វៀតណាម និងឡាវ
- សិក្សាទៅលើការនាំចេញ នាំចូលរបស់កម្ពុជា ជាមួយប្រទេសទាំងបី
- រយៈពេលក្នុងការសិក្សាទៅលើប្រធានបទគឺចាប់ពីឆ្នាំ ២០១០ ដល់ ២០២០

## ៦.វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះនឹងធ្វើការប្រើប្រាស់នូវវិធីសាស្ត្រ បរិមាណវិស័យ ( Quantitative Approach ) ដែលត្រូវបានស្គាល់ថាជាផែនការស្រាវជ្រាវបរិមាណ ដែលសង្កត់ធ្ងន់ទៅលើការប្រើប្រាស់ចំនួនតួលេខ និងស្ថិតិសម្រាប់វិភាគ និងពន្យល់ព្រឹត្តិការណ៍សង្គម និងដើម្បីធ្វើការបកស្រាយនូវចំណោទបញ្ហា និងគោលបំណងនៃការសិក្សា។ (Creswell, 2013)

ការប្រមូលទិន្នន័យសម្រាប់ការស្រាវជ្រាវនេះបានមកពី ៖

- ទិន្នន័យដែលបានប្រើប្រាស់ក្នុងការបកស្រាយ សុទ្ធសឹងតែជាទិន្នន័យទី ២ ( Secondary Data ) ដែលដកស្រង់ចេញពីប្រភពផ្សេងៗជាច្រើន។
- ប្រភេទទិន្នន័យដែលយកមកសិក្សាមានដូចជា ៖ ឯកសារនៅតាមបណ្ដាវេបសាយនានា Journal Article, Research paper, ឯកសារផ្សព្វផ្សាយជាសាធារណៈ និងទិន្នន័យស្ថិតិ
- ឯកសារដែលមានប្រភពនៅតាម ស្ថាប័នរដ្ឋ ( ដូចជា ៖ ក្រសួងពាណិជ្ជកម្ម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងព័ត៌មាន ក្រសួងសាធារណការ និងដឹកជញ្ជូន នាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ) និងបណ្ដាប្រសួងស្ថាប័នមួយចំនួនទៀត
- បណ្ដាញផ្សព្វផ្សាយសង្គមដូចជា សារព័ត៌មាន កាសែត ជាដើម

ចំណែកឯការវិភាគទិន្នន័យវិញយើងការវិភាគទិន្នន័យផ្ដោតសំខាន់លើ ៖

- ប្រៀបធៀបពីទំហំពាណិជ្ជកម្មសរុបរបស់កម្ពុជា ជាមួយនឹងទំហំពាណិជ្ជកម្មដែលកម្ពុជាសម្រេចបានជាមួយនឹងប្រទេសទាំងបី
- បង្ហាញថាពាណិជ្ជកម្មជាមួយប្រទេសទាំងបី បានជះឥទ្ធិពលយ៉ាងដូចម្ដេចខ្លះទៅលើ GDP របស់ប្រទេសកម្ពុជា

- ប្រៀបធៀបទំហំពាណិជ្ជកម្មដែលកម្ពុជាសម្រេចបានជាមួយប្រទេសទាំងបី ទៅនឹងទំហំពាណិជ្ជកម្មសរុបរបស់អាស៊ាន។

## ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

អត្ថបទសារណាបញ្ចប់ការសិក្សា ក្រោមប្រធានបទ "**នយោបាយពាណិជ្ជកម្មអន្តរជាតិរបស់ប្រទេសកម្ពុជាជាមួយនឹងអាស៊ាន( ប្រទេសថៃ ឡាវ និងវៀតណាម )**" ត្រូវបានបែងចែកជា ៥ ផ្នែកធំៗ ៖

- **សេចក្តីផ្តើម ៖** ជាផ្នែកដែលបង្ហាញពី លំនាំបញ្ហា ចំណោទបញ្ហា ទំហំ និងដែនកំណត់ គោលបំណងនៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ វិធីសាស្ត្រស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។
- **ជំពូកទី ១ ៖ រំលឹកទ្រឹស្តី** ផ្នែកនេះពន្យល់អំពីទ្រឹស្តីមួយចំនួនដែលទាក់ទងទៅនឹង ពាណិជ្ជកម្មអន្តរជាតិ កិច្ចព្រមព្រៀងពាណិជ្ជកម្ម ឧបករណ៍នយោបាយពាណិជ្ជកម្មអន្តរជាតិ អាស៊ាននិមិត្តសញ្ញា ការចូលរួមក្នុងអាស៊ាន ការធ្វើពាណិជ្ជកម្មរបស់អាស៊ាន និងសមាហរណកម្មអាស៊ានជាដើម។
- **ជំពូកទី ២ ៖ លទ្ធផលនៃការស្រាវជ្រាវ** ផ្នែកនេះបកស្រាយទៅលើស្ថានភាពទូទៅនៃពាណិជ្ជកម្មរបស់កម្ពុជា រួមបញ្ចូលទាំងការនាំចេញ នាំចូលជាលក្ខណៈអន្តរជាតិនៃទំនិញ និងសេវាកម្មជាមួយនឹងថៃ ឡាវ និងវៀតណាម។
- **ជំពូកទី ៣ ៖ ពិភាក្សា និងវិភាគលទ្ធផល** ផ្នែកនេះនឹងធ្វើការបង្ហាញនូវទិន្នន័យ និងវិភាគទៅលើឥទ្ធិពលនៃការពាណិជ្ជកម្មជាមួយនឹងអាស៊ានមកលើសេដ្ឋកិច្ចកម្ពុជា ដោយភ្ជាប់ជាមួយនឹងការបកស្រាយនូវលទ្ធផលដែលទទួលបាន
- **សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ៖** ផ្នែកចុងក្រោយនៃអត្ថបទសារណានេះ នឹងធ្វើការប្រចាប់បញ្ចូលនូវលទ្ធផលដើម្បីទាញយកការសន្និដ្ឋានមួយឆ្លើយតមទៅនឹងចំណោទបញ្ហានៃការស្រាវជ្រាវ រួមទាំងផ្តល់ជាអនុសាសន៍នៅក្នុងក្របខ័ណ្ឌនៃការស្រាវជ្រាវនេះផងដែរ។

# ជំពូកទី ១
# រំលឹកទ្រឹស្តី

## ១.១.និយមន័យពាណិជ្ជកម្មអន្តរជាតិ

ពាណិជ្ជកម្មអន្តរជាតិ ជាចម្មតាសំដៅទៅលើការដោះដូរទំនិញ និងសេវាកម្មឆ្លងកាត់ព្រំដែន ឬទឹកដីអន្តរជាតិ។ សម្រាប់ប្រទេសនីមួយៗ ការធ្វើពាណិជ្ជកម្មអន្តរជាតិនេះ គឺជាចំណែកមួយដ៏សំខាន់នៃផលិតផលក្នុងស្រុកសរុប[2]។ មិនតែប៉ុណ្ណោះ វាគឺជាគន្លឹះនៃការកើនឡើងរបស់សេដ្ឋកិច្ចពិភពលោក ហើយនៅក្នុងសេដ្ឋកិច្ចពិភពលោកផ្តោតសំខាន់ទៅលើការផ្គត់ផ្គង់ និងតំរូវការ ហេតុដូច្នេះហើយការធ្វើពាណិជ្ជកម្មនឹងត្រូវបានរងផលប៉ះពាល់ដោយព្រឹត្តិការណ៍សកល។

## ១.២.ទ្រឹស្តីពាណិជ្ជកម្មអន្តរជាតិ

### ១.២.១.ទ្រឹស្តីបែបក្លាស៊ិក

**ក.ទ្រឹស្តីប្រយោជន៍ដាច់ខាត** ( Absolute Advantage Theory )

ប្រទេសមួយចង់ចូលរួមក្នុងទីផ្សារអន្តរជាតិ ត្រូវមានមូលដ្ឋានផលិតកម្មរឹងមាំដែលអាចប្រកួតប្រជែងជាមួយបណ្តាប្រទេសផ្សេងៗទៀត។ គន្លឹះក្នុងការជោគជ័យក្នុងទីផ្សារអន្តរជាតិ គឺជាការផលិតដើម្បីធ្វើការនាំចេញ ដោយផ្តោតទៅលើឯកទេសកម្មក្នុងការផលិត។ ឯកទេសកម្មនៅក្នុងការផលិតកើតចេញពីឯកទេសកម្មក្នុងស្រុក និងការឈានជើងចូលទៅក្នុងទីផ្សារអន្តរជាតិ[3]។ សេដ្ឋវិទូ Adam Smith បានលើកឡើងថា “ ដើម្បីចូលរួមនៅក្នុងទីផ្សារអន្តរជាតិ គឺប្រទេសនីមួយៗត្រូវមានប្រយោជន៍ដាច់ខាតក្នុងផលិតកម្មណាមួយដែលប្រយោជន៍ដាច់ខាត ” មានន័យថា ប្រទេសមួយមានប្រយោជន៍ដាច់ខាតក្នុងផលិតកម្មមួយ នៅពេលដែលប្រទេសនោះមានសមត្ថភាពអាចផលិតផលិតផលនោះអស់ថ្លៃដើមទាបជាង ឬទទួលបានផលិតផលច្រើនជាងប្រទេសផ្សេងទៀតដែលផលិតនូវផលិតផលដូចគ្នា។ [4]

**ខ.ទ្រឹស្តីប្រយោជន៍ប្រៀបធៀប** ( Comparative Advantage Theory )

ទ្រឹស្តីប្រយោជន៍ប្រៀបធៀបរបស់លោក David Ricardo បានកើតឡើងក្រោយទ្រឹស្តីរបស់លោក Adam Smith ដែលទ្រឹស្តីរបស់លោក Smith គឺអោយតម្លៃទៅលើការនាំចេញណាដែលមានប្រយោជន៍ដាច់ខាត ចុះក្នុងករណីប្រទេសដែលមិនមានប្រយោជន៍ដាច់ខាត ហើយចង់ចូលក្នុងទីផ្សារអន្តរជាតិ គឺត្រូវធ្វើដូច

[2] Source : Sen Sunanda ( Levy Economics Institute of Bard College) November 2010

[3] ដកស្រង់ពីសៀវភៅ របស់សាស្ត្រាចារ្យ ឡុង ម៉ាមីឌី, ២០១៣ សេដ្ឋកិច្ចអន្តរជាតិ, ( មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី២, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច )

[4] Source : SCHUMACHER, University of Potsdam, Germany (Adam Smith's theory of absolute advantage)

ម្តេច ? ហេតុដូចនេះហើយបានជាទ្រឹស្តីបទរបស់លោក Ricardo លើកឡើងថា ប្រទេសដែលគ្មានប្រយោជន៍ដាច់ខាតអាចមានប្រៀបក្នុងផលិតកម្មមួយដែលមានប្រៀបជាងផលិតកម្មមួយផ្សេងទៀត[5]។ ប្រទេសមួយអាចមានប្រយោជន៍ប្រៀបធៀបក្នុងផលិតផលណាមួយ ឬផលិតកម្មណាមួយធៀបនឹងប្រទេសផ្សេងទៀតលុះត្រាតែប្រទេសនោះអាចផលិតអស់ថ្លៃឱកាសទាបជាង។

ទ្រឹស្តីប្រយោជន៍ប្រៀបធៀបរបស់លោក David Ricardo ត្រូវបានផ្តោតសំខាន់ទៅលើពីរចំណុច ៖

- ច្បាប់នេះនឹងពន្យល់អំពីហេតុផលនៃការធ្វើពាណិជ្ជកម្មអន្តរជាតិ តាមរយៈការប្រើប្រាស់នូវគោលការណ៍ប្រយោជន៍ប្រៀបធៀបដែលជួយពន្យល់ថា តើហេតុអ្វីបានជាប្រទេសមួយចាំបាច់ត្រូវតែផ្តោតសំខាន់លើការផលិតទំនិញតែមួយមុខព្រមទាំងបកស្រាយថា តើហេតុអ្វីប្រទេសមួយធ្វើការនាំចេញផលិតផលតែមួយ និងនាំចូលផលិតផលផ្សេងទៀត
- ទ្រឹស្តីរបស់លោក Ricardo នឹងបង្ហាញថាការធ្វើពាណិជ្ជកម្មអន្តរជាតិបានជួយអោយមានការរីកចម្រើនសម្រាប់ប្រទេសទាំងអស់ ហើយការធ្វើពាណិជ្ជកម្មសេរីតាមរយៈច្បាប់ប្រយោជន៍ប្រៀបធៀប នឹងទទួលបានអត្ថប្រយោជន៍ទាំងអស់គ្នា។

### ១.២.២.ទ្រឹស្តីបែបក្លាស៊ិកថ្មី

#### ក.ទ្រឹស្តីរបស់លោក Heckscher-Ohlin

ទ្រឹស្តីរបស់ Smith និង Ricardo មិនបានជួយប្រទេសនានាក្នុងការកំនត់ថា តើផលិតផលមួយណាដែលផ្តល់អត្ថប្រយោជន៍ដល់ប្រទេសនោះទេ។ ទ្រឹស្តីទាំងពីរបានសន្មតថាទីផ្សារសេរី និងបើកចំហនឹងនាំប្រទេសរួមទាំងអ្នកផលិតកំណត់ ថាទំនិញណាដែលពួកគេអាចផលិតបានកាន់តែមានប្រសិទ្ធភាព។ នៅដើមទសវត្សឆ្នាំ ១៩០០ សេដ្ឋវិទូជនជាតិស៊ុយអែតពីររូបគឺ Heckscher-Ohlin និង Bertil Ohlin បានផ្តោតការយកចិត្តទុកដាក់របស់ពួកគេលើរបៀបដែលប្រទេសមួយអាចទទួលបានអត្ថប្រយោជន៍ប្រៀបធៀបដោយផលិតផលិតផលដែលប្រើប្រាស់កត្តាណាដែលមានច្រើនបំផុតនៅក្នុងប្រទេស។ ទ្រឹស្តីរបស់ពួកគេផ្អែកលើកត្តាផលិតកម្មរបស់ប្រទេសមួយដូចជា ដីធ្លី កម្លាំងពលកម្ម និងដើមទុនដែលផ្តល់ថវិកាសម្រាប់ការវិនិយោគលើដំណាំ និងឧបករណ៍។ ពួកគេបានកំណត់ថាថ្លៃដើមនៃកត្តា ឬធនធានណាមួយ គឺជាមុខងារនៃការផ្គត់ផ្គង់និងតម្រូវការ។ កត្តាដែលផ្គត់ផ្គង់ច្រើនទាក់ទងនឹងតម្រូវការនឹងមានតម្លៃថោក ហើយកត្តាដែលមានតម្រូវការខ្ពស់ទាក់ទងនឹងការផ្គត់ផ្គង់នឹងថ្លៃជាង ទ្រឹស្តីរបស់ពួកគេដែលត្រូវបានគេហៅថាទ្រឹស្តី ( the factor proportions theory ) បញ្ជាក់ថាប្រទេសនានានឹងផលិត ហើយនាំចេញទំនិញដែលត្រូវការធនធាន ឬកត្តាដែលមានការផ្គត់

[5] Source : Keuschnigg, (Comparative Advantage in International Trade )

ផ្គង់ច្រើន ដូច្នេះកត្តាផលិតកម្មមានតម្លៃថោក។ [6]

**ខ.ទ្រឹស្តីរបស់លោក** Leontief Paradox

នៅដើមទសវត្សឆ្នាំ ១៩៥០ អ្នកសេដ្ឋកិច្ចអាមេរិកាំង ដើមកំណើតរុស្ស៊ីលោក Wassily W. Leontief បានសិក្សាពីសេដ្ឋកិច្ចអាមេរិកយ៉ាងជិតដល់ ហើយបានកត់សម្គាល់ថាសហរដ្ឋអាមេរិកសម្បូរទៅដោយដើមទុន ដូច្នេះគួរតែនាំចេញទំនិញដែលពឹងផ្អែកលើដើមទុនបន្ថែមទៀត។ ទោះជាយ៉ាងណាក៏ដោយការស្រាវជ្រាវរបស់គាត់ដោយប្រើទិន្នន័យជាក់ស្តែងបានបង្ហាញផ្ទុយពីនេះ គឺសហរដ្ឋអាមេរិកកំពុងនាំចូលទំនិញដែលមានដើមទុនច្រើន។ យោងទៅតាមទ្រឹស្តីសមាមាត្រកត្តា ( the factor proportions theory ) សហរដ្ឋអាមេរិកគួរតែត្រូវបាននាំចូលទំនិញដែលពឹងផ្អែកលើកម្លាំងពលកម្ម ប៉ុន្តែបែរជាត្រូវនាំចេញទំនិញដែលពឹងផ្អែកលើកម្លាំងពលកម្មច្រើនទៅវិញ។ ការវិភាគរបស់គាត់ត្រូវបានគេស្គាល់ថា Leontief Paradox ពីព្រោះវាជាបញ្ច្រាសនូវអ្វីដែលបានរំពឹងទុកដោយទ្រឹស្តី។ នៅក្នុងឆ្នាំបន្តបន្ទាប់អ្នកសេដ្ឋកិច្ចបានកត់សម្គាល់ជាប្រវត្តិសាស្ត្រដែលនៅពេលនោះកម្លាំងពលកម្មនៅសហរដ្ឋអាមេរិកមានទាំងការផ្គត់ផ្គង់ថេរ និងមានផលិតភាពច្រើនជាងនៅប្រទេសផ្សេងទៀត ដូច្នេះវាសមហេតុផលក្នុងការនាំចេញទំនិញដែលពឹងផ្អែកលើកម្លាំងពលកម្ម។[7]

## ១.៣.នយោបាយពាណិជ្ជកម្ម

### ១.៣.១.នយោបាយពាណិជ្ជកម្មជាតិ

នយោបាយពាណិជ្ជកម្មជាតិ គឺជានយោបាយដែលប្រទេសនីមួយៗបង្កើតឡើងដើម្បីការពារផលប្រយោជន៍ល្អបំផុតនៃពាណិជ្ជកម្ម និងពលរដ្ឋរបស់ខ្លួន។ នយោបាយនេះ គឺស្របទៅនឹងនយោបាយការបរទេសរបស់ជាតិ។ គោលនយោបាយពាណិជ្ជកម្មជាតិ ផ្តោតលើទិដ្ឋភាពអភិវឌ្ឍន៍យ៉ាងជាក់លាក់ ហើយរួមទាំងការអភិវឌ្ឍប្រកបដោយចីរភាពដោយផ្តល់ឱកាសសម្រាប់ការបង្កើតទ្រព្យសម្បត្តិ តាមរយៈការបង្កើតប្រាក់ចំណូលការបង្កើនការងារ ភាពប្រកួតប្រជែង និងសុខុមាលភាពសេដ្ឋកិច្ចនិងសង្គម។

### ១.៣.២.នយោបាយពាណិជ្ជកម្មទ្វេភាគី

នយោបាយពាណិជ្ជកម្មទ្វេភាគី គឺជាការដោះដូរទំនិញរវាងប្រទេសទាំងពីរដើម្បីជំរុញពាណិជ្ជកម្ម និងវិនិយោគ។ ប្រទេសទាំងពីរនឹងកាត់បន្ថយ ឬលុបបំបាត់ពន្ធគយ កូតាការនាំចេញ ការរឹតត្បិតការនាំចេញនិងរបាំងពាណិជ្ជកម្មដទៃទៀត ដើម្បីជំរុញពាណិជ្ជកម្មនិងការវិនិយោគ។

គោលដៅនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគី គឺដើម្បីពង្រីកការចូលទៅកាន់ទីផ្សារប្រទេសទាំងពីរ និងបង្កើនកំណើនសេដ្ឋកិច្ចរបស់ខ្លួន។ ប្រតិបត្តិការអាជីវកម្មដែលមានលក្ខណៈស្តង់ដារនៅក្នុងតំបន់នឹងត្រូវរារាំង

[6] ដកស្រង់ពីគេហទំព័រ https://saylordotorg.github.io/, 2011) International Trade Theory, Chapter 2 ( International Trade and FDI )

[7] ដកស្រង់ពីគេហទំព័រ Slideshare.net, Leontief Paradox ( International Economics )

ប្រទេសមួយពីការលួចចម្លងផលិតផលច្នៃប្រឌិតថ្មី លុបបំបាត់រាល់ទំនិញលក់ក្រោមថ្លៃដើម ឬប្រើប្រាស់ការឧបត្ថម្ភមិនយុត្តិធម៌។ កិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគីធ្វើឱ្យមានស្តង់ដារបទប្បញ្ញត្តិ និងបទដ្ឋានការងារ។

### ១.៣.៣.នយោបាយពាណិជ្ជកម្មអន្តរជាតិ

នយោបាយពាណិជ្ជកម្មអន្តរជាតិត្រូវបានកំណត់ដោយអង្គការសេដ្ឋកិច្ចអន្តរជាតិ ដូចជាអង្គការសហប្រតិបត្តិការសេដ្ឋកិច្ចនិងការអភិវឌ្ឍ (OECD) អង្គការពាណិជ្ជកម្មពិភពលោក (WTO) និងមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ដោយកំណត់គោលការណ៍ពាណិជ្ជកម្មអន្តរជាតិក្រោមធម្មនុញ្ញរបស់ពួកគេ។ គោលនយោបាយគាំទ្រទាំងនោះ គឺដើម្បីផ្តល់នូវផលប្រយោជន៍ល្អបំផុតទៅដល់ប្រទេសអភិវឌ្ឍន៍និងប្រទេសកំពុងអភិវឌ្ឍន៍។ ទោះយ៉ាងណាក៏ដោយនៅតែមានបញ្ហាប្រឈមផ្នែកប្រតិបត្តិការ និងការអនុវត្តន៍ផ្សេងៗគ្នាតែនយោបាយពាណិជ្ជកម្មរមែងតែងផ្តល់អោយប្រទេសដែលមានជម្លោះនូវដំណោះស្រាយយ៉ាងល្អប្រសើរ។

## ១.៤.កិច្ចព្រមព្រៀងពាណិជ្ជកម្មអន្តរជាតិ

### ១.៤.១.កិច្ចព្រមព្រៀងទូទៅស្តីពីពន្ធ និងពាណិជ្ជកម្ម ( GATT )

នៅពេលសង្គ្រាមលោកលើកទី២បានបញ្ចប់ ប្រទេសទាំងអស់លើសកលលោកចាប់ផ្តើមចង់ធ្វើអោយមានការដោះដូរពាណិជ្ជកម្មឡើងវិញដោយបានធ្វើការចរចាគ្នាដើម្បីបង្កើតអង្គការពាណិជ្ជកម្មអន្តជាតិ ITO មូលនិធិរូបិយវត្ថុពិភពលោក និងធនាគារពិភពលោក។ ប៉ុន្តែដោយសារតែការចរចាអូសបន្លាយរយៈពេលយូរពេក នៅឆ្នាំ ១៩៤៧ មានប្រទេសចំនួន២៣ បានសម្រេចចិត្ត បង្កើតគោលការណ៍ដោះដូរពាណិជ្ជកម្មបណ្តោះអាសន្នមួយដែលមានឈ្មោះថា GATT។ GATT គឺជាកិច្ចព្រមព្រៀងពាណិជ្ជកម្ម ហើយប្រទេសដែចូលរួមត្រូវបានគេហៅថា "ភាគីកិច្ចសន្យា" មានលេខាធិការនៅទីក្រុងសែនែវប្រទេសស្វីស[8]។ GATT មានភាពបត់បែនខ្ពស់ មានគោលបំណងជម្រុញអោយមានពាណិជ្ជកម្មសេរី កាត់បន្ថយពន្ធគយ លុបបំបាត់នូវកូតាជាដើម។ គោលបំណងក្នុងការបង្កើត GATT គឺកាត់បន្ថយនូវអត្រាពន្ធគយ និងកាត់បន្ថយរាល់របាំងពាណិជ្ជកម្មនានា តាមរយៈយុទ្ធាការពហុភាគីដើម្បីកាត់បន្ថយឧបសគ្គក្នុងការដោះដូរ ។លទ្ធផលដែលទទួលបានតាមរយៈការបង្កើតGATTអស់រយៈពេល៥០ឆ្នាំមកនេះ គឺអត្រាពន្ធគយថយចុះ ពី ៤០% មកនៅត្រឹម ៤% ទំហំពាណិជ្ជកម្មពិភពលោកកើនឡើង ២០ដង ឯផលិតកម្មក្នុងពិភពលោកកើនឡើង ៧ដង។

[8] ដកស្រង់ពីគេហទំព័រ (www.wto.org, 2021)

រូបភាពទី១.១ ៖ សមាជិកចំនួន ២៣ ប្រទេសដំបូងនៃការបង្កើត GATT

**23 Founding member countries of the GATT:**

| | | | |
|---|---|---|---|
| United States, | | Canada, Cuba, | Brazil, |
| Chile, | Australia, | New Zealand, | China, |
| **India**, | Myanmar, | Sri Lanka, | Pakistan, |
| Syria, | Lebanon, | South Africa, | Zimbabwe, |
| United Kingdom, | France, | Belgium, | Luxembourg, |
| Netherlands, | Norway, | Czechoslovakia | |

ប្រភព ៖ (Ahmad, 2011)

### **១.៤.២.កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី** ( FTAs )

កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី គឺជាកិច្ចព្រមព្រៀងរវាងប្រទេសពីរ ឬច្រើនដើម្បីកាត់បន្ថយឧបសគ្គចំពោះការនាំចូល និងនាំចេញក្នុងសម្រាប់ប្រទេសទាំងនោះ។ ក្រោមគោលនយោបាយពាណិជ្ជកម្មសេរីទំនិញ និងសេវាកម្មអាចត្រូវបានទិញ និងលក់ឆ្លងកាត់ព្រំដែនអន្តរជាតិត្រូវបានកំណត់ពន្ធតិចតួចដោយរដ្ឋាភិបាល ការដាក់កូតា រួមទាំងប្រាក់ឧបត្ថម្ភធនជាដើម។ បណ្តាប្រទេសជាដៃគូអាចជួយអោយសហគ្រាស ឬក្រុមហ៊ុនឱ្យចូល និងប្រកួតប្រជែងបានកាន់តែងាយស្រួលនៅក្នុងទីផ្សារពិភពលោកតាមរយៈរបាំងពាណិជ្ជកម្មដែលកាត់បន្ថយ។ ការដែលទទួលបាននូវកិច្ចព្រមព្រៀងនេះពិតជាទទួលបាននូវសារៈសំខាន់ជាច្រើន ដែលអាចធ្វើអោយទំនិញដែលនៅលើទីផ្សារកាន់តែមានភាពសម្បូរបែប និងទទួលបាននូវទំនិញថ្មីៗជាច្រើនមុខ។ ទោះបីជាយ៉ាងណាក៏ដោយក៏វាផ្តល់នូវផលអវិជ្ជមានមួយចំនួននៅក្នុងពាណិជ្ជកម្មផងដែរ។

រូបភាពទី១.២ ៖ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីមួយចំនួននៅលើពិភពលោក

**EXAMPLES OF FTA**

- ASEAN Free Trade Area (AFTA)
- Asia-Pacific Trade Agreement (APTA)
- Central American Integration System (SICA)
- Central European Free Trade Agreement (CEFTA)
- Common Market for Eastern and Southern Africa (COMESA)
- G-3 Free Trade Agreement (G-3)
- Greater Arab Free Trade Area (GAFTA)
- Dominican Republic–Central America Free Trade Agreement (DR-CAFTA)
- Gulf Cooperation Council (GCC)
- North American Free Trade Agreement (NAFTA)
- Pacific Alliance
- South Asia Free Trade Agreement (SAFTA)
- Southern African Development Community (SADC)
- Southern Common Market (MERCOSUR)
- Trans-Pacific Strategic Economic Partnership (TPP)

ប្រភពមកពី ៖ (Jisunfoo, 2014)

**១.៤.៣.កិច្ចព្រមព្រៀងពាណិជ្ជកម្មលើការអនុគ្រោះពន្ធ** ( PTAs )

កិច្ចព្រមព្រៀងពាណិជ្ជកម្មលើការអនុគ្រោះពន្ធ (PTAs) បានក្លាយជាឧបករណ៍ស្នូលនៃសមាហរណកម្មតំបន់នៅគ្រប់តំបន់ទាំងអស់នៃពិភពលោក មិនតែប៉ុណ្ណោះកិច្ចព្រមព្រៀងនេះបានលុបចោលឧបសគ្គនានាចំពោះពាណិជ្ជកម្មរវាងសមាជិក និងផ្តល់ការចូលទៅកាន់ទីផ្សារ ដោយឈរលើមូលដ្ឋានទៅវិញទៅមក។ ក្រៅពីពាណិជ្ជកម្មទំនិញ និងពាណិជ្ជកម្មសេវាកម្ម និងសម្រាប់បទប្បញ្ញត្តិវិនិយោគក៏បានដកចេញនូវរបាំងពន្ធ និងអាករដែលមិនមែនជាពន្ធគយក្នុងពាណិជ្ជកម្ម។ ពួកគេក៏អាចរួមបញ្ចូលនូវបទប្បញ្ញត្តិជាច្រើនស្តីពីកិច្ចសហប្រតិបត្តិការគយ និងការសម្របសម្រួលពាណិជ្ជកម្ម ក៏ដូចជាធ្វើឱ្យមានស្តង់ដារចុះសម្រុង និងលើកទឹកចិត្តដល់កិច្ចសហប្រតិបត្តិការដែលមានបទប្បញ្ញត្តិនៅក្នុងវិស័យផ្សេងៗ។ ក្រៅពីការចូលទៅកាន់ទីផ្សារ និងការលុបបំបាត់ឧបសគ្គជាបណ្តើរៗនៅតាមព្រំដែន កិច្ចព្រមព្រៀងនេះ ត្រូវបានគេប្រើកាន់តែច្រើនឡើងដើម្បីដោះស្រាយបញ្ហាជាច្រើនដែលត្រូវបានគេស្គាល់ថា ជាបញ្ហាសមាហរណកម្មស៊ីជម្រៅ ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការនៅក្នុងវិស័យវិនិយោគ។

## ១.៥.ឧបករណ៍នៃនយោបាយពាណិជ្ជកម្មអន្តរជាតិ

**១.៥.១.ពន្ធនាំចូល** ( Import Tariff )

ពន្ធនាំចូល ជាពន្ធដែលត្រូវបានដាក់ទៅលើផលិតផលដែលនាំចូល។ ពន្ធនាំចូល គឺជានយោបាយពាណិជ្ជកម្មដ៏ពេញនិយមមួយដែលត្រូវបានគេប្រើច្រើនជាងគេ បើទោះបីជាពេលនេះមានប្រទេសមួយចំនួនបានកាត់បន្ថយក៏ដោយ។ ពន្ធនាំចូលត្រូវបានគេដាក់ទៅលើផលិតផលមួយចំនួនដែលប៉ះពាល់ដល់ សុខភាពប្រជាពលរដ្ឋដូចជា ស្រា បារី ជាដើម។ ពន្ធនាំចូលត្រូវបានគេបែងចែកជា ២គឺ ៖

- ពន្ធនាំចូលថេរ ( Fixed tariff or Specific tariff ) ជាពន្ធនាំចូលមួយដែលត្រូវបានកំណត់យកតម្លៃថេរមួយក្នុងមួយឯកតាផលិតផល។
- ពន្ធនាំចូលជាភាគរយ ( Ad Valorem tariffs ) ជាពន្ធនាំចូលដែលកំណត់យកអត្រាមួយជាក់លាក់នៃផលិតផលនាំចូល។

ការដាក់ពន្ធនេះបានធ្វើអោយថ្លៃកើនឡើងនឹងកាត់បន្ថយការនាំចូល ប៉ុន្តែបានជួយដល់ឧស្សាហកម្មក្នុងស្រុកពីការនាំចូលដោយតម្លៃថោកជាង ហើយក៏បានផ្តល់នូវចំណូលដល់រដ្ឋាភិបាលផងដែរ។

**១.៥.២.ពន្ធនាំចេញ** (Export Tariffs )

ពន្ធនាំចេញ ជាពន្ធដែលត្រូវបានកំណត់ទៅលើផលិតផលដែលត្រូវបាននាំចេញពីប្រទេសមួយ។ ការដាក់ពន្ធនាំចេញនេះស្ទើរតែលែងត្រូវបានប្រើទៅហើយក្នុងពាណិជ្ជកម្មអន្តរជាតិ ពីព្រោះវាបានប៉ះពាល់ទៅដល់ការអភិវឌ្ឍសេដ្ឋកិច្ចរយៈពេលខ្លី ឬវែង។ ពន្ធនាំចេញត្រូវបានគេបែងចែកជា ២ ដូចពន្ធនាំចូលដែរ គឺមានដូចជា

- ពន្ធនាំចេញជាតម្លៃថេរ ជាពន្ធនាំចេញដែលគេកំណត់ថ្លៃក្នុងមួយឯកតាផលិតផលនាំចេញ
- ពន្ធនាំចេញជាភាគរយ ជាពន្ធនាំចេញដោយកំណត់ភាគរយជាក់លាក់ណាមួយនៃតម្លៃរបស់ផលិតផលនាំចេញ។

  ការដាក់នូវពន្ធនាំចេញនេះមានគោលបំណងសំខាន់ៗចំនួន ២ គឺ ៖
- ជាប្រភពចំណូលសម្រាប់រដ្ឋតាមរយៈការបង់ពន្ធរបស់ក្រុមហ៊ុននាំចេញ
- ការពារនូវការហូរចេញនូវផលិតផលមួយចំនួនពីក្នុងស្រុក។

**១.៥.៣.កូតានាំចូល** ( Import Quota )

កូតានាំចូល ជាការកំណត់ដោយផ្ទាល់លើបរិមាណនៃទំនិញដែលនាំចូល ក្នុងរយៈពេលកំណត់ណាមួយ។ ការដាក់កំហិតនេះក្រោមទម្រង់ជាអាជ្ញាប័ណ្ណដែលត្រូវផ្តល់អោយក្រុមហ៊ុននោះ ហើយអាជ្ញាធរមានសិទ្ធក្នុងការកំណត់បរិមាណនាំចូល ឬនាំចេញក្នុងកម្រិតអតិបរមារបស់ទំនិញទៅតាមឆ្នាំនីមួយៗ។ ការដាក់នូវ quota នេះបានធ្វើអោយមាននូវផលអវិជ្ជមានដោយបានធ្វើអោយទំនិញមានតម្លៃថ្លៃជាងមុន ហើយរដ្ឋាភិបាលនឹងបាត់បង់នូវចំណូលមួយចំនួន។ មិនត្រឹមតែប៉ុណ្ណោះការផ្តល់នូវអាជ្ញាប័ណ្ណនេះធ្វើអោយក្រុមហ៊ុនទទួលបានចំណេញដោយសារតម្លៃក្នុងស្រុកមានភាពខុសគ្នាពីតម្លៃក្នុងទីផ្សារសេរីទៅតាមបរិមាណដែលគេនាំចូល។ កូតានាំចូលត្រូវបានចែកចេញជាច្រើនដូចជា ៖

- កូតារឹតបណ្តឹង ជាការកំណត់បរិមាណកូតាដែលទាបជាងបរិមាណនាំចូលដោយសេរី
- កូតាបន្ធូរបន្ថយ ជាការកំណត់បរិមាណកូតាដែលស្មើ ឬច្រើនជាងបរិមាណនាំចូលដោយសេរី
- កូតាដោយឡែក ជាកូតាដែលដាក់ចេញនូវបរិមាណនាំចូលដោយចំពោះប្រទេសនីមួយៗ និងដោយចំនួនរៀងៗខ្លួន
- កូតាសកល ជាកូតាដែលកំណត់ការនាំចូលដោយចំនួនមួយសម្រាប់រយៈពេលមួយជាក់លាក់ចំពោះផលិតផលជាក់លាក់មួយ ដោយមិនចំពោះប្រទេសណាមួយនោះទេ
- កូតាជាក់លាក់ ជាការកំណត់បរិមាណនាំចូលដោយចំនួនមួយជាក់លាក់ក្នុងកំឡុងពេលមួយជាក់លាក់ទៅលើផលិតផលមួយជាក់លាក់
- កូតាអត្រាពន្ធ ជាការកំណត់បរិមាណនាំចូលដោយចំនួនមួយដែលទទួលបានការអនុគ្រោះពន្ធនាំចូល។

**១.៥.៤.ឧបត្ថម្ភធនចំពោះការនាំចេញ** ( Export Subsidies )

ឧបត្ថម្ភធនចំពោះការនាំចេញ ជាការឧបត្ថម្ភធននាំចេញ ដែលមានលក្ខណៈផ្ទុយពី Tariffs។ ការឧបត្ថម្ភធននាំចេញគឺប្រើដើម្បីជម្រុញក្នុងការនាំចេញទំនិញ ដែលជាហេតុធ្វើអោយថ្លៃទំនិញរបស់ប្រទេសនាំ

ចូលមានតម្លៃទាប ហើយធ្វើអោយទំនិញក្នុងប្រទេសមានតម្លៃថ្លៃ។ ការធ្វើឧបត្ថម្ភធនបែបនេះមានផ្តល់នូវអត្ថប្រយោជន៍យ៉ាងច្រើនដល់ឧស្សាហកម្មក្នុងស្រុក។ ការឧបត្ថម្ភធននាំចេញនេះ ជាគោលនយោបាយដែលបង្កើតឡើងដោយរដ្ឋាភិបាល ដើម្បីជម្រុញអោយក្រុមហ៊ុនក្នុងស្រុកធ្វើការនាំចេញអោយបានច្រើន។ ការឧបត្ថម្ភធននាំចេញ គឺជាគោលនយោបាយរបស់រដ្ឋាភិបាលក្នុងការលើកទឹកចិត្តដល់ការនាំចេញទំនិញនិងបង្អាក់ការលក់ទំនិញនៅលើទីផ្សារក្នុងស្រុកតាមរយៈប្រាក់កម្ចីដែលមានតម្លៃថោកឬការបន្ធូរបន្ថយពន្ធសម្រាប់អ្នកនាំចេញឬរដ្ឋាភិបាលផ្តល់ហិរញ្ញប្បទានដល់ការផ្សាយពាណិជ្ជកម្មអន្តរជាតិ ឬស្រាវជ្រាវ និងអភិវឌ្ឍន៍។

ចំពោះការនាំចេញកាន់តែច្រើន វាបានជួយដល់សេដ្ឋកិច្ចរបស់ប្រទេសក្នុងរយៈពេលខ្លី ឬវែងដោយអាស្រ័យទៅលើសេដ្ឋកិច្ចរបស់ប្រទេសនោះផ្ទាល់។ រដ្ឋាភិបាលបានចំណាយនូវថវិកាសម្រាប់ក្រុមហ៊ុន ឬសហគ្រាសដើម្បីធ្វើការនាំចេញ ហើយនយោបាយនេះជាទូទៅគេធ្វើឡើងក្រោមរូបរាង ២ គឺ ៖

- ការជម្រុញការនាំចេញដោយផ្ទាល់ ដែលវិធីនេះត្រូវបានគេបែងចែកជា ២ទៀតគឺការឧបត្ថម្ភការនាំចេញដោយតម្លៃថេរ និងការឧបត្ថម្ភធនដោយភាគរយ។ ការឧបត្ថម្ភការនាំចេញដោយតម្លៃថេរនេះមានន័យថា រដ្ឋាភិបាលនឹងចំណាយថវិកាជាក់លាក់ក្នុង ១ ឯកតាផលិតផលនាំចេញដើម្បីជម្រុញការនាំចេញផលិតផល ដូចនេះបើក្រុមហ៊ុន ឬសហគ្រាសនាំចេញកាន់តែច្រើននោះរដ្ឋាភិបាលនឹងចំណាយកាន់តែច្រើនដែរ។ មួយវិញទៀត ការឧបត្ថម្ភការនាំចេញជាភាគរយ គឺជាការជម្រុញការនាំចេញ ដោយរដ្ឋាភិបាលផ្តល់ជាភាគរយទៅលើផលិតផលនាំចេញ។
- ការជម្រុញការនាំចេញដោយប្រយោល គឺរដ្ឋាភិបាលជាអ្នកជួយឧបត្ថម្ភ ឬជួយសម្រួលទៅដល់សកម្មភាពផលិតកម្ម ការបន្ធូរបន្ថយថ្លៃដើមផលិតកម្ម ដើម្បីជួយអោយដំណើរការផលិតកម្មដំណើរការបានរលូន និងពង្រីកដល់ការនាំចេញផងដែរ។ មិនតែប៉ុណ្ណោះរដ្ឋាភិបាលក៏បានធ្វើការផ្តល់នូវកម្ចីជាមួយនឹងអត្រាការប្រាក់ទាប ការកាត់បន្ថយពន្ធនានាដើម្បីជម្រុញការនាំចេញអោយបានកាន់តែច្រើនផងដែរ។

សរុបមកការឧបត្ថម្ភធនការនាំចេញ មិនថាដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី គឺសុទ្ធតែមានគោលដៅសំខាន់ដើម្បីជម្រុញការនាំចេញ ហើយសំខាន់បំផុតនោះ គឺជួយដល់ផលិតករក្នុងស្រុកដើម្បីប្រកួតប្រជែងនៅលើទីផ្សារអន្តរជាតិ។ នយោបាយមួយនេះផ្តល់នូវផលចំណេញជាច្រើនសម្រាប់ប្រទេសនាំចេញដូចជា ៖

- ផ្តល់ឱកាសដល់ប្រជាជនក្នុងស្រុក អោយមានការងារធ្វើដើម្បីលើកស្ទួយជីវភាពអោយកាន់តែប្រសើរឡើងមួយកម្រិតថែមទៀត
- សម្រាប់ក្រុមហ៊ុន ឬសហគ្រាសដែលទើបបង្កើតថ្មីដែលនៅមានលក្ខណៈទន់ខ្សោយនៅឡើយ គឺទទួលបាននូវការជ្រោមជ្រែងពីសំណាក់រដ្ឋាភិបាល

- ផ្តល់ឱកាសដល់ក្រុមហ៊ុន ឬសហគ្រាសអោយលក់ចេញបានច្រើនជាងមុន ទទួលបានចំណូលច្រើន និងបង្កើននូវប្រាក់ចំណេញ។

សម្រាប់ប្រទេសនាំចូលវិញក៏ទទួលបាននូវផលចំណេញដូចជា ៖

- ប្រជាជនអាចធ្វើការទិញនូវទំនិញបានច្រើនមុខ និងសម្បូរបែបដោយសារតែទំនិញនាំចូលមានបរិមាណច្រើន
- កាលណាទំនិញនាំចូលច្រើន ហើយមានការឧបត្ថម្ភធន នោះប្រជាជនរបស់ប្រទេសនាំចូលអាចទិញនូវទំនិញដែលមានតម្លៃថោក។

បើទោះបីជាទទួលបាននូវផលប្រយោជន៍ច្រើនយ៉ាងណាក៏ដោយ ក៏ប្រទេសនាំចេញ និងប្រទេសនាំចូលនឹងជួបប្រទះនូវបញ្ហាមួយចំនួន។ រដ្ឋាភិបាលរបស់ប្រទេសនាំចេញនឹងត្រូវបានប្រទះជួបបញ្ហាដោយសារតែការជួយទំនុកបម្រុងខ្លាំងពេក ដែលអាចធ្វើអោយប៉ះពាល់ដល់ថវិការបស់រដ្ឋ។ ដោយឡែកសម្រាប់ប្រទេសនាំចូលវិញ គឺនឹងជួបការខាតបង់ដោយសារតែការហូរចូលនូវទំនិញបរទេសដែលធ្វើអោយសហគ្រាស ឬក្រុមហ៊ុនក្នុងស្រុកពិបាកក្នុងការប្រកួតប្រជែង។

**១.៥.៥.ការរឹតបន្តឹងការនាំចេញដោយស្ម័គ្រចិត្ត** ( VERs )

គ្រប់បណ្តាប្រទេសនៅលើសកលលោក បើសិនជាការនាំចេញមានចំនួនច្រើននោះ វាជាសញ្ញាមួយយ៉ាងល្អ ដែលបង្ហាញថាសេដ្ឋកិច្ចរបស់ប្រទេសនោះមានការរីកចម្រើន។ ប៉ុន្តែនៅក្នុងការធ្វើពាណិជ្ជកម្មអន្តរជាតិការប្រើប្រាស់នូវនយោបាយមានភាពស្មុគស្មាញ ដែលវានឹងធ្វើការប្រែប្រួលទៅតាមកាលៈទេសៈ។ នៅពេលដែលប្រទេសនាំចូលជួបនឹងវិបត្តិ ដោយសារតែការហូរចូលនូវទំនិញពីបរទេស នោះគេនឹងងាកមកប្រើប្រាស់នូវនយោបាយមួយដែលមានឈ្មោះថា **ការរឹតបន្តឹងការនាំចេញដោយស្ម័គ្រចិត្ត។**

ការរឹតបន្តឹងការនាំចេញដោយស្ម័គ្រចិត្ត ជានយោបាយរឹតបន្តឹងរបស់រដ្ឋាភិបាលប្រទេសនាំចូលចំពោះទំនិញដែលបានធ្វើការនាំចេញពីប្រទេសមួយក្នុងកំឡុងពេលជាក់លាក់ណាមួយ។ មូលហេតុចម្បងនៃការប្រើប្រាស់នយោបាយនេះដោយសារតែ ប្រទេសនាំចូលមានបញ្ហាជាមួយនឹងការប្រកួតប្រជែងទីផ្សារជាមួយបរទេសដែលតម្រូវអោយប្រទេសទាំងពីរបើកកិច្ចចរចារមួយ ដើម្បីទប់ស្កាត់ការហូរចូលទំនិញដែលអាចធ្វើអោយប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ប្រទេសនាំចូល។

**១.៥.៦.ការបង្កើនការនាំចូលដោយស្ម័គ្រចិត្ត** ( VIEs )

នៅពេលដែលមានការនាំចូលនូវទំនិញ ឬសេវាកម្មចូលទៅក្នុងប្រទេសមួយ វាអាចផ្តល់នូវផលប្រយោជន៍ ក៏ដូចជាផលវិបាកផងដែរ។ ដោយឡែកសម្រាប់ការបង្កើនការនាំចូលដោយស្ម័គ្រចិត្តនេះ គឺប្រព្រឹត្តទៅតាមការស្នើសុំរបស់ប្រទេសនាំចេញ ដោយយើងអាចនិយាយបានថា វាជាកិច្ចព្រមព្រៀងក្នុងការបង្កើននូវការ

នាំចូលនៃផលិតផលណាមួយ ឬមួយចំនួនក្នុងកំឡុងពេលមួយជាក់លាក់។ មកទល់ពេលនេះ គេសឹងតែលែងប្រើប្រាស់នូវនយោបាយនេះទៀតហើយ ដោយសារតែមានអង្គការពាណិជ្ជកម្មពិភពលោក ( WTO ) និងអង្គការជាច្រើនទៀតដែលអាចជួយជ្រោមជ្រែងនៅក្នុងការធ្វើពាណិជ្ជកម្មអន្តរជាតិ។ គេអាចនិយាយបានថា នយោបាយនេះមានលក្ខណៈស្ម័គ្រចិត្ត ប៉ុន្តែនៅក្រោយការស្ម័គ្រចិត្តក៏អាចកើតមានឡើងនូវនៅការគំរាមគំហែងពីសំណាក់ប្រទេសមានអំណាច ដែលធ្វើអោយនយោបាយមួយនេះស្ទើតែបាត់បង់ទៅហើយ។

**១.៥.៧.នយោបាយពាណិជ្ជកម្មផ្សេងៗទៀត**

ក្រៅពីនយោបាយដែលបានរៀបរាប់ខាងលើនេះ គឺមាននយោបាយមួយចំនួនទៀតដែលជះឥទ្ធិពលមកលើការនាំចេញ នាំចូលផងដែរនោះរួមមាន ៖

- Safeguard measure ប្រើសម្រាប់ហាមឃាត់ទំនិញណាមួយជាបណ្តោះអាសន្ន ដើម្បីការពារឧស្សាហកម្មក្នុងស្រុកណាមួយជាក់លាក់។
- An anti-dumping duty ជារបាំងការពារដែលប្រឆាំងទៅនឹងការលក់ក្រោមថ្លៃដើម ដើម្បីទប់ស្កាត់ទំនិញនាំចូលដែលលក់ក្រោមថ្លៃទីផ្សារ ធ្វើអោយមានឧត្តមភាពថ្លៃឡើងវិញ ព្រោះទំនិញដែលនាំចូលទាំងនោះលក់ទាបជាងថ្លៃដែលគេលក់ក្នុងស្រុកទៅទៀត។
- Countervailing duties ប្រើទៅលើទំនិញនាំចូល ដែលដាក់ក្នុងក្របខ័ណ្ឌរបស់អង្គការ WTO ដើម្បីលុបបំបាត់នូវឥទ្ធិពលនៃការឧបត្ថម្ភធន។
- Technical barriers to trade ការប្រើប្រាស់របាំងបច្ចេកទេស តាមរយៈ ស្តង់ដារសុខភាព សុវត្ថិភាព គាំពារបរិស្ថាន និងបញ្ចៀសការបន្លំ ឬបោកបញ្ឆោត ដើម្បីការពារអ្នកប្រើប្រាស់ក្នុងស្រុក និងធ្វើអោយទំនិញក្នុងស្រុកមានឧត្តមភាព។
- Voluntary export restrain (VER) គឺជាការដាក់កូតា ឬកំណត់ទំហំទៅលើទំនិញនាំចេញដោយខ្លួនឯងផ្ទាល់ ទៅប្រទេសនាំចូល។
- Red tape ជារបាំងរដ្ឋបាល ដែលដាក់ដើម្បីគ្រប់គ្រង និងត្រួតពិនិត្យលើដំណើរការនាំចេញ នាំចូលតាមច្រកព្រំដែនរបស់ប្រទេសនីមួយៗ។
- Local content requirement (LCR) ជាគោលនយោបាយដែលត្រូវការទំនិញពាក់កណ្តាលសម្រេចក្នុងចំណែកណាមួយ ដែលចូលរួមក្នុងដំណើរការផលិតកម្មនៃទំនិញនោះពីឧស្សាហកម្មក្នុងស្រុក។
- Rules of origin គឺជាគោលនយោបាយដែលកំណត់ និងត្រួតពិនិត្យយ៉ាងច្បាស់ពីប្រភពដើមនៃទំនិញ ដើម្បីជៀសវាងការក្លែងបន្លំ នាំអោយប៉ះពាល់ដល់គុណភាព និងកេរ្តិ៍ឈ្មោះ។

## ១.៦.អ្វីទៅជាអាស៊ាន

អាស៊ាន ជាសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ អាចនិយាយបានថាជាក្រុមនៅក្នុងតំបន់ដែលជំរុញកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច នយោបាយ និងសន្តិសុខក្នុងចំណោមសមាជិកទាំង ១០ ប្រទេសដែលរួមមានប្រទេសប្រ៊ុយណេ កម្ពុជា ឥណ្ឌូនេស៊ី ឡាវ ម៉ាឡេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន សិង្ហបុរី ថៃ និងវៀតណាម។ បណ្តាប្រទេសនៅក្នុង អាស៊ាន មានប្រជាជនសរុបចំនួន ៦៥០ លាននាក់ និងមានផលិតផលក្នុងស្រុកសរុបមានចំនួន ២,៨ ពាន់ពាន់លានដុល្លារអាមេរិក។ ក្រុមនេះបានដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើសមាហរណកម្មសេដ្ឋកិច្ចអាស៊ី ដោយនាំមុខក្នុងការចរចាក្នុងចំណោមប្រទេសអាស៊ី-ប៉ាស៊ីហ្វិក ដើម្បីបង្កើតជាប្លុកពាណិជ្ជកម្មសេរីធំបំផុតមួយរបស់ពិភពលោក និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីចំនួន៦ ជាមួយសេដ្ឋកិច្ចក្នុងតំបន់ផ្សេងទៀត។ (Albert, 2020)

ក្រាហ្វិកទី២.១ ៖ បង្ហាញពី GDP, GDP per capita និងប្រជាជនរបស់ប្រទេសនៅតំបន់អាស៊ាន




ប្រភព ៖ (https://www.cfr.org/, 2020)

### ១.៦.១.ប្រវត្តិនៃការកកើតអាស៊ាន

អាស៊ាន ត្រូវបានបង្កើតឡើងដំបូងបង្អស់ក្នុងឆ្នាំ១៩៦១ ដែលមានទម្រង់ជាអង្គភាព និងមាន ឈ្មោះថា "សមាគមអាស៊ីអាគ្នេយ៍" (Association of Southeast Asia "ASA) និងមានប្រទេសចូលរួម ចំនួន៣ ប៉ុណ្ណោះ គឺសាធារណរដ្ឋហ្វីលីពីន សហព័ន្ធម៉ាឡេស៊ី និងព្រះរាជាណាចក្រថៃឡង់ដ៍។ រហូតដល់ថ្ងៃទី ០៨ ខែសីហា ឆ្នាំ ១៩៦៧ រដ្ឋមន្ត្រីការបរទេស នៃបណ្តាប្រទេសចំនួន៥ ជាសមាជិក ហត្ថលេខី គឺព្រះរាជាណាចក្រថៃឡង់ដ៍ សហព័ន្ធម៉ាឡេស៊ី សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋ ហ្វីលីពីន និងសាធារណរដ្ឋសិង្ហបុរី បានចុះហត្ថលេខាលើសន្ធិសញ្ញាអាស៊ាន ដែលត្រូវបានគេស្គាល់ ថាជា "សន្ធិសញ្ញាក្រុងបាងកក" ក្នុងការបង្កើត និងប្តូរឈ្មោះពី "សមាគមអាស៊ីអាគ្នេយ៍ (ASA)" ទៅជា "សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍" (Association of Southeast Asia Nation "ASEAN") នៅរាជធានីបាងកក ព្រះរាជាណាចក្រថៃឡង់ដ៍ ដែលមានគោលបំណងដំបូងគឺ "ជំរុញការ

អភិវឌ្ឍសេដ្ឋកិច្ច និងប្រឆាំងនឹងលទ្ធិកុម្មុយនិស្ត។ សមាគមប្រជាជាតិនេះសម្រេចបាននូវការរួបរួមគ្នាកាន់តែខ្លាំងនៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៧០ បន្ទាប់ពីការផ្លាស់ប្តូរតុល្យភាពអំណាចបន្ទាប់ពីការបញ្ចប់សង្គ្រាមវៀតណាមនៅឆ្នាំ ១៩៧៥។ កំណើនសេដ្ឋកិច្ចបានរីកចម្រើនប្រកបដោយភាពរឹងមាំរបស់តំបន់ក្នុងអំឡុងទសវត្សឆ្នាំ ១៩៧០។(ក្រសួងពាណិជ្ជកម្ម ន.)

### ១.៦.២.មូលដ្ឋាន និងអត្តសញ្ញាណអាស៊ាន

**ចក្ខុវិស័យមួយ អត្តសញ្ញាណមួយ សហគមន៍មួយ** One Vision, One Identity, One Community គឺជាបាវចនារបស់អាស៊ាន។ អាស៊ាន មិនខុសពីជាតិមួយ ដែលមានទង់ជាតិ និងភ្លេងជាតិផ្ទាល់ខ្លួន ពោលគឺ អាស៊ានក៏មានទង់អាស៊ាន និងភ្លេងអាស៊ានផងដែរ។ ភ្លេងអាស៊ាន ក៏បានបង្ហាញអំពីសាមគ្គីភាពរវាងប្រទេសសមាជិក និងការលើកកម្ពស់អត្តសញ្ញាណរបស់ខ្លួន ប៉ុន្តែភ្លេងនេះប្រគុំតែក្នុងកិច្ចប្រជុំធំៗ និង ទិវាអាស៊ានតែប៉ុណ្ណោះ។

មូលដ្ឋានអាស៊ាន អគ្គលេខាធិការដ្ឋានអាស៊ាន មានមូលដ្ឋាននៅទីក្រុងហ្សាកាតាប្រទេសឥណ្ឌូណេស៊ី ដែលមានអគ្គលេខាធិការទទួលបន្ទុកសម្របសម្រួល និងអនុវត្តសកម្មភាពនានារបស់អាស៊ានហើយអគ្គលេខាធិការនោះត្រូវតែងតាំងដោយកិច្ចប្រជុំកំពូលអាស៊ានមានអាណត្តិ ៥ឆ្នាំ និងប្តូរវេនទៅ តាមលំដាប់អក្សរជាភាសាអង់គ្លេសរបស់រដ្ឋជាសមាជិក។ ម្យ៉ាងទៀតការជ្រើសរើសអគ្គលេខាធិការ ត្រូវផ្អែកលើ ធម្មនុញ្ញអាស៊ាន ដែលកំណត់លក្ខខណ្ឌដូចជា សុចរិត បទពិសោធន៍ការងារ សមត្ថភាព និងសមភាពយេនឌ័រ។

### ១.៦.៣.និមិត្តសញ្ញា និងទង់អាស៊ាន

និមិត្តសញ្ញាអាស៊ាន តំណាងឲ្យស្ថិរភាព សន្តិភាព ការរួបរួម និងថាមពល។ ក្នុងនិមិត្តសញ្ញានេះ មានពណ៌ចំនួន ៤ គឺពណ៌ខៀវ ក្រហម ស និង លឿង ដែលតំណាងឲ្យពណ៌សំខាន់ៗនៃគ្រប់ទង់ជាតិរបស់រដ្ឋជាសមាជិកទាំងអស់ និងតំណាងអត្ថន័យតាមពណ៌នីមួយៗ ដូចជា ពណ៌ខៀវ តំណាងឲ្យសន្តិភាព និងស្ថិរភាព។

ពណ៌ក្រហម បង្កប់អត្ថន័យនៃភាពក្លាហាន និងថាមពល។ ពណ៌ស តំណាងឲ្យភាពបរិសុទ្ធ ស្អាតស្អំ និងពណ៌លឿង តំណាងឲ្យនិមិត្តរូបនៃវិបុលភាព។ រូបកួរស្រូវ (បាច់១០ដើម) តំណាងឲ្យសុបិន្តរបស់បិតាស្ថាបនិកអាស៊ាន ដែលចង់បានអាស៊ានមួយមានគ្រប់ប្រទេសទាំងអស់ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ រួបរួមគ្នាក្នុងមិត្តភាព និងសាមគ្គីភាព ។ ចំណែក រង្វង់ តំណាងឲ្យការឯកភាពរបស់អាស៊ាន។




ទង់អាស៊ាន តំណាងឲ្យសហគមន៍អាស៊ានមួយ ដែលពោរពេញដោយស្ថិរភាព សន្តិភាព ការរួបរួម និងថាមពល ។ ពណ៌របស់ទង់អាស៊ានមាន៖ ពណ៌លឿង ក្រហម ខៀវ និងស ដែលតំណាងឲ្យពណ៌សំខាន់ៗ នៃគ្រប់ទង់ជាតិរបស់ប្រទេសជាសមាជិកអាស៊ាន ។ ទង់អាស៊ាន គឺត្រូវបានរក្សាសិទ្ធិស្របច្បាប់ដោយអាស៊ានទាំងអស់ ។

ប្រភព៖ (Asean, 2017)

ទង់អាស៊ាន គឺជានិមិត្តរូបនៃការរួបរួមរដ្ឋជាសមាជិក ក្នុងការគាំទ្រនូវគោលការណ៍ និងការខិតខំប្រឹងប្រែងរបស់អាស៊ាន និងដើម្បីជំរុញការយល់ដឹងអំពី អាស៊ាន និងរួបរួមគ្នាកាន់តែខ្លាំងឡើង។

### ១.៦.៤.លក្ខខណ្ឌនៃការចូលជាសមាជិកអាស៊ាន

លក្ខណៈវិនិច្ឆ័យសំខាន់បំផុត គឺភាពសំខាន់បំផុតនៃភូមិសាស្ត្រ។ សមាជិកអនាគតត្រូវតែមានទីតាំងភូមិសាស្ត្រនៅអាស៊ីអាគ្នេយ៍។ សេចក្តីប្រកាសអាស៊ានឆ្នាំ ១៩៦៧ សំដៅទៅលើ "រដ្ឋទាំងអស់នៅតំបន់អាស៊ីអាគ្នេយ៍" ហើយភ្ជាប់ទៅនឹងគោលដៅ និងគោលបំណងរបស់អាស៊ាន។ ទាំងនេះ គឺជាលក្ខណៈវិនិច្ឆ័យតែមួយគត់សម្រាប់សមាជិកភាពនៅពេលប្រទេសមីយ៉ាន់ម៉ា ប្រទេសឡាវ និងកម្ពុជាបានដាក់ពាក្យចូលជាសមាជិកអាស៊ាន[9]។ ជាឧទាហរណ៍ ការពិចារណាភូមិសាស្ត្រ គឺជាចំណុចសំខាន់មួយសម្រាប់ប្រទេសមីយ៉ាន់ម៉ា ដែលបានប្រកាសខ្លួនថាជាប្រទេសរបស់អាស៊ីអាគ្នេយ៍ ដែលល្អជាជាងស្ថិតនៅលើភាពមិនច្បាស់នៅលើរបងរវាងចិន និងប្រទេសឥណ្ឌា។ ប្រទេសភូមាបានក្លាយជាប្រទេសមួយនៃសមាជិកស្ថាបនិកអាស៊ានស្ថិតក្រោមការដឹកនាំរបស់ឧត្តមសេនីយ៍ Ne-Win។ ប្រទេសតែមួយគត់ដែលត្រូវបានអញ្ជើញឱ្យចូលរួមក្នុងអាស៊ាន គឺប្រទេសកម្ពុជា ហើយព្រះបាទនរោត្តមសីហនុក៏បានបដិសេធការផ្តល់ជូននៅពេលនោះដែរ ដោយកង្វល់ភូមិសាស្ត្រនយោបាយស្រដៀងគ្នា។ ទីតាំងភូមិសាស្ត្រក៏ជាការពិចារណាដ៏សំខាន់ផងដែរចំពោះការបដិសេធឥតឈប់ឈររបស់អាស៊ានចំពោះសំណើរបស់ Papua New Guinea's និងប្រទេសស្រីលង្កា។ ធម្មនុញ្ញអាស៊ាន (ដែលចូលជាធរមានក្នុងឆ្នាំ ២០០៨) បានកំណត់លក្ខណៈវិនិច្ឆ័យទូលំទូលាយសម្រាប់សមាជិកភាពអាស៊ានក្នុងមាត្រា ៦[10]៖

- ទីតាំងនៅក្នុងតំបន់ភូមិសាស្ត្រដែលត្រូវបានគេទទួលស្គាល់ថានៅអាស៊ីអាគ្នេយ៍
- ការទទួលស្គាល់ដោយរដ្ឋរបស់សមាជិកអាស៊ានទាំងអស់

[9] Source : (Thuzar, 2017), Researchers At Iseas – Yusof Ishak Institute Analyse Current Events, Singapore

[10] Association of Southeast Asian Nations (ASEAN), Charter of the Association of Southeast Asian Nations, 20 November 2007, (ASEAN, 2012)

- កិច្ចព្រមព្រៀងដែលត្រូវចងភ្ជាប់ដោយធម្មនុញ្ញអាស៊ាន និង
- សមត្ថភាព និងឆន្ទៈក្នុងការអនុវត្តកាតព្វកិច្ចជាសមាជិក។

សេចក្តីសំរេចចុងក្រោយត្រូវបានធ្វើឡើង ដោយការមូលមតិគ្នានៅឯកិច្ចប្រជុំកំពូលអាស៊ាន អនុសាសន៍របស់ក្រុមប្រឹក្សាសំរបសំរួលអាស៊ាន (ACC) ដែលមានសមាជិកបរទេសរដ្ឋមន្ត្រីនៃសមាជិកអាស៊ានទាំងអស់ចូលរួម ដើម្បីបញ្ជាក់ថាអាចចូលជាសមាជិកបាន។

**១.៦.៥.ចក្ខុវិស័យ បេសកកម្ម និង គោលបំណងនៃការបង្កើតអាស៊ាន**

ចក្ខុវិស័យ គឺអាស៊ានរួបរួមជាប្រជាជាតិអាស៊ីអាគ្នេយ៍តែមួយ សម្លឹងឆ្ពោះទៅមុខរស់នៅក្នុង សន្តិភាព ស្ថិរភាព និងវិបុលភាព សហការគ្នាជាដៃគូអភិវឌ្ឍន៍ដ៏រឹងមាំ និងជាសហគមន៍តែមួយគត់ នៃសង្គមចេះយកអាសារគ្នា។ គោលបំណង ដើម្បីជំរុញកិច្ចសហប្រតិបត្តិការក្នុងតំបន់អាស៊ីអាគ្នេយ៍ ក្នុងកិច្ចប្រឹងប្រែងក្នុងស្មារតីសមភាព ភាពជាដៃគូ និងដើម្បីរួមចំណែកឆ្ពោះទៅរកសន្តិភាព វឌ្ឍនភាព និងវិបុលភាពក្នុងតំបន់។

ដូចបានកំណត់ក្នុងសេចក្តីប្រកាសអាស៊ាន គោលបំណង និងគោលដៅនៃអាស៊ានគឺ៖

- ជំរុញការអភិវឌ្ឍសេដ្ឋកិច្ច វឌ្ឍនភាពសង្គម រក្សាសន្តិភាព និងស្ថិរភាពក្នុងតំបន់
- ពង្រឹង និងពង្រីកសហប្រតិបត្តិការជួយគ្នាទៅវិញទៅមក ដើម្បីផលប្រយោជន៍រួម នៃបណ្តាប្រទេសក្នុងតំបន់
- បម្រើការជាវេទិកាមួយសម្រាប់ដោះស្រាយការខ្វែងយោបល់គ្នានៅក្នុងតំបន់

ជាធៀងដរាបមក អាស៊ានបានរក្សានូវគោលការណ៍គ្រឹះរបស់ខ្លួនរួមមាន៖

- គោរពគ្នាទៅវិញទៅមកនូវឯករាជ្យភាព អធិបតេយ្យភាព បូរណភាពទឹកដី និងអត្តសញ្ញាណរបស់ប្រជាជាតិសមាជិកនីមួយៗ
- មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់ប្រទេសសមាជិក
- ដោះស្រាយទំនាស់ ឬវិវាទ ដោយសន្តិវិធី
- លះបង់ចោលនូវការរំលោភបំពាន និងការគំរាមកំហែង ឬការប្រើប្រាស់កម្លាំងទ័ព
- គោរពដោយខ្ជាប់ខ្ជួននូវគោលការណ៍ច្បាប់អន្តរជាតិ ដែលទាក់ទងនឹងទំនាក់ទំនងជាមិត្តភាព និងកិច្ចសហប្រតិបត្តិការក្នុងចំណោមប្រទេសជាសមាជិក
- គោរពសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានសម្រាប់មនុស្សគ្រប់រូប
- គោរពវប្បធម៌ផ្សេងៗគ្នា ភាសា និងសាសនារបស់ប្រជាជនអាស៊ាន ដោយសង្កត់ធ្ងន់ទៅលើតម្លៃរួម ក្នុងស្មារតីភាពឯកភាពក្នុងពហុភាព

- ភាពជាស្នូលរបស់អាស៊ាន ក្នុងទំនាក់ទំនងនយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌ ក្រៅតំបន់ ដោយរក្សាការចូលរួមដ៏សកម្ម ការសម្លឹងមើលឆ្ពោះទៅខាងក្រៅ ភាពរួមបញ្ចូល និងមានភាពមិនរើសអើង និង
- ប្រកាន់ខ្ជាប់នូវវិធានពាណិជ្ជកម្មពហុភាគី និងរបបផ្អែកលើមូលដ្ឋានច្បាប់របស់អាស៊ាន ដើម្បីអនុវត្តន៍ប្រកបដោយប្រសិទ្ធភាពនូវកិច្ចខិតខំប្រឹងប្រែងផ្អែកសេដ្ឋកិច្ច និងកាត់បន្ថយជាវិជ្ជមានឆ្ពោះទៅលុបបំបាត់របាំងទាំងស្រុង សម្រាប់សមាហរណកម្មសេដ្ឋកិច្ចតំបន់ សេដ្ឋកិច្ចទីផ្សារ។

### **១.៧.តំបន់ពាណិជ្ជកម្មសេរីអាស៊ាន** ( AFTA )

បច្ចុប្បន្ន ប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ គឺជាតំបន់ពាណិជ្ជកម្មសេរី។ ភាគីហត្ថលេខីដំបូង ទាំង៦ (ព្រះរាជាណាចក្រប្រ៊ុយណេដារ៉ូសាឡឹម សាធារណរដ្ឋឥណ្ឌូណេស៊ី សហព័ន្ធម៉ាឡេស៊ី សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី និងព្រះរាជាណាចក្រថៃឡង់ដ៍ ) តម្រូវឲ្យអនុវត្តគម្រោង ប្រព័ន្ធអនុគ្រោះពន្ធគយទូទៅ សម្រាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ានមុនគេ ដើម្បីកាត់បន្ថយពន្ធគយលើ ពាណិជ្ជកម្មក្នុងតំបន់ មិនឲ្យលើសពី ៥% (ប្រាំភាគរយ) លើផលិតផលស្ទើគ្រប់មុខ ដែលមានចែងក្នុងបញ្ជីមុខទំនិញរួម ឬលុបចោលទាំងស្រុងលើពន្ធគយ។[11]

គួររំឭកឡើងវិញតំបន់ពាណិជ្ជកម្មសេរីអាស៊ាន គឺត្រូវបានបង្កើតឡើងក្នុងខែមករា ឆ្នាំ១៩៩២ ក្នុងគោលបំណងលុបបំបាត់របាំងពន្ធគយ លើបណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍ ដោយពិនិត្យមើលលើ ការធ្វើសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន ទៅជាមូលដ្ឋានផលិតកម្មតែមួយ និងបង្កើតទីផ្សារក្នុងតំបន់ សម្រាប់ប្រជាជនចំនួន ៦៣៤.៥លាននាក់។ កិច្ចព្រមព្រៀងស្តីពីគម្រោងអនុគ្រោះពន្ធគយប្រកបដោយប្រសិទ្ធភាព (CEPT) សម្រាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន តម្រូវឲ្យកំណត់អត្រាពន្ធក្នុងការកាត់បន្ថយពន្ធគយមិនឲ្យលើសពី ៥% ( ប្រាំភាគរយ) លើចំណាត់ថ្នាក់ផលិតផលដែលបានចរាចរក្នុងតំបន់ រីឯការរឹតត្បិតបរិមាណ និងរបាំងមិនមែនពន្ធគយដទៃទៀតវិញ ក៏នឹងត្រូវលុបបំបាត់។ តាមពេលវេលាដែលបានកំណត់ បានឲ្យដឹងថា នៅឆ្នាំ២០០៨ គោលដៅនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន គឺត្រូវបន្តទៅមុខឥតឈប់ឈរ។

ការលុបបំបាត់របាំងពន្ធគយ និងរបាំងមិនមែនពន្ធគយ ក្នុងចំណោមសមាជិកអាស៊ាន ត្រូវបាន ដើរតួនាទីជាកាតាលីករជំរុញឲ្យមានប្រសិទ្ធភាពផលិតកម្ម និងការប្រកួតប្រជែង។ បន្ថែមពីនេះការកាត់បន្ថយរបាំងពាណិជ្ជកម្មក្នុងតំបន់អាស៊ាន ផ្តល់ឲ្យអ្នកប្រើប្រាស់នូវជម្រើសសម្បូរបែបលើគុណភាពដ៏ប្រសើរដល់អ្នកប្រើប្រាស់ផលិតផល។ ចាប់តាំងពីឆ្នាំ ២០០២ មកមានតែទំនិញប្រមាណ ៣.៨% ស្មើនឹង ១,៦៨៣ មុខលើ ៤៤,០៦០មុខប៉ុណ្ណោះ នៃផលិតផលដែលមានក្នុងបញ្ជីទំនិញរួមនៃCEPT នៃភាគី ហត្ថលេខីទាំង៦ដំបូង នៅ

[11] ដកស្រង់ពីសៀវភៅ The ASEAN Free Trade Area (AFTA)

គិតពន្ធលើស៥%។ ប្រទេសជាសមាជិកទាំង០៦ រួមមាន ប្រទេសឥណ្ឌូណេស៊ី ប្រ៊ុយណាយដារូសាឡឹម ម៉ាឡេស៊ី ហ្វីលីពីន សិង្ហបុរី និងប្រទេសថៃ ត្រូវបានអនុវត្តកិច្ចព្រមព្រៀង CEPT នៅឆ្នាំ២០០២ ហើយប្រទេសចំនួន៤ទៀតត្រូវបានអនុគ្រោះដល់ការអនុវត្តនាឆ្នាំ២០០៦ សម្រាប់ ប្រទេសវៀតណាមបានអនុវត្ត រីឯប្រទេសឡាវ និងមីយ៉ាន់ម៉ា អនុវត្តឆ្នាំ២០០៨ និងប្រទេសកម្ពុជា អនុវត្តក្រោយគេនៅឆ្នាំ២០១០។ តំបន់ពាណិជ្ជកម្មសេរីបានគ្របដណ្តប់លើគ្រប់ផលិតផលកសិកម្ម និងផលិតផលនានា បញ្ជីទូទៅចំនួន ៧៣៥បន្ទាត់ គឺត្រូវបានដកចេញនូវពន្ធគយជាអចិន្ត្រៃយ៍ពីកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរី ផ្អែកលើហេតុផលដូចជា សន្តិសុខជាតិ ការការពារនៃមនុស្សជាតិ ជីវិតសត្វពាហនៈ ឬរុក្ខជាតិ សុខភាព កេរដំណែលសិល្បៈ ប្រវត្តិសាស្ត្រ និងបុរាណវិទ្យា ដែលស្មើនឹង ១.០៩ ភាគរយ នៃបន្ទាត់ពន្ធគយសរុបក្នុងសហគមន៍អាស៊ាន។ [12]

កម្ពុជាបានក្លាយជាសមាជិកទី១០របស់អាស៊ាននៅខែមេសាឆ្នាំ១៩៩៩។ រាជរដ្ឋាភិបាលរបស់កម្ពុជាក៏បានបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីបំពេញឱ្យបានទៅតាមការទាមទារជាសមាជិកភាពរបស់អាស៊ានចាប់តាំងពីការផ្លាស់ប្តូរច្បាប់ រហូតដល់ការកែសម្រួលប្រព័ន្ធហិរញ្ញវត្ថុ វិនិយោគ និង ពាណិជ្ជកម្ម ដើម្បីឱ្យស៊ីគ្នាជាមួយនឹងស្តង់ដារអាស៊ាន។ នៅក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន កម្ពុជាបានប្តេជ្ញាចិត្តយ៉ាងមុតមាំ ដើម្បីធ្វើការកាត់បន្ថយបន្ទាត់ពន្ធគយរបស់ខ្លួន ឱ្យដល់៥ភាគរយ និងទាបជាងនេះនៅឆ្នាំ២០១០ ហើយបន្ទាត់ពន្ធគយដទៃទៀតដែលនៅសល់ (ដែលភាគច្រើន ជាផលិតផលកសិកម្មដែលមានលក្ខណៈ រសើប) នៅឆ្នាំ ២០១៧ នៅក្នុងក្របខ័ណ្ឌ កិច្ចព្រមព្រៀងស្តីពីការអនុវត្តអត្រាពន្ធគយអនុគ្រោះរួម (CEPT)។ [13]

### ១.៧.១.ការផ្តួចផ្តើមគំនិតសម្រាប់កិច្ចសម្រួលពាណិជ្ជកម្ម

ASEAN បានផ្តោតការយកចិត្តទុកដាក់ខ្ពស់លើកិច្ចសម្រួលពាណិជ្ជកម្មក្នុងតំបន់ ដោយផ្តោត សំខាន់លើពន្ធគយ និងការលុបបំបាត់របាំងបច្ចេកទេសពាណិជ្ជកម្ម ធ្វើយ៉ាងណាឲ្យថ្លៃដើមទាបក្នុងការធ្វើពាណិជ្ជកម្មក្នុងតំបន់។ កិច្ចខិតខំប្រឹងប្រែងរបស់អាស៊ាន ត្រូវបានផ្តល់ភាពងាយស្រួល និង សុខដុមនីយកម្មនៃនីតិវិធីគយជាពិសេសតាមរយៈវិធានការផ្សេងៗរួមមាន៖ ការធ្វើឲ្យមានសុខដុមភាពនូវមុខទំនិញរួចពន្ធគយ និងបានពន្លឿនការអនុវត្តកិច្ចព្រមព្រៀងវាយតម្លៃពន្ធគយរបស់អង្គការពាណិជ្ជកម្មពិភពលោក(WTO Valuation Agreement) សហគមន៍សេដ្ឋកិច្ចអាស៊ានបានអនុម័តរួចរាល់លើការ ធ្វើឲ្យមានសុខដុមនីយកម្មនៃមុខទំនិញរួចពន្ធគយក្នុងអាស៊ាន។

អាស៊ាន បាននឹងកំពុងខិតខំប្រឹងប្រែងរៀបចំឲ្យមានការទទួលស្គាល់រវាងគ្នានឹងគ្នាជារួមលើការវាយតម្លៃផលិតផលជាក់លាក់។ ដូច្នេះបទប្បញ្ញត្តិនិងស្តង់ដារនានារបស់ផលិតផលពាក់ព័ន្ធ នឹងមិនក្លាយជារបាំង

[12] ទិដ្ឋភាពទូទៅនៃតំបន់ពាណិជ្ជកម្មសេរី ( Overview of AFTA )

[13] ដកស្រង់ពីសៀវភៅរបស់ លោករដ្ឋមន្ត្រីក្រសួងអប់រំ ហង់ ជួនណារ៉ុន ( សេដ្ឋកិច្ចកម្ពុជា ២០១៥ )

បច្ចេកទេសពាណិជ្ជកម្មបន្តទៀត ហើយគ្រឿងបរិក្ខារទូរគមនាគមន៍ ក៏ត្រូវបានលើកឡើងឲ្យមានការទទួលស្គាល់ទៅវិញទៅមករួចដែរ។ ការចរចា ក៏កំពុងបន្តនីតិវិធីបន្ថែមទៀតនៅក្នុងតំបន់ លើផលិតផលគ្រឿងសម្អាងវេជ្ជសាស្ត្រ អគ្គីសនី និងអេឡិចត្រូនិក។ បន្ថែមពីនេះ អាស៊ានបានព្រមព្រៀងលើការធ្វើសុខដុមនីយកម្ម រវាងស្តង់ដារជាតិជាមួយស្តង់ដារអន្តរជាតិ ដូចជាអង្គការស្តង់ដារអន្តរជាតិ (ISO) គណៈកម្មាធិការបច្ចេកវិទ្យាអេឡិចត្រូនិកអន្តរជាតិ (IEC) និងសហភាពទូរគមនាគមន៍អន្តរជាតិ (ITU) សម្រាប់ក្រុមផលិតផលអាទិភាព ២០មុខ។

ក្រុមនៃផលិតផលទាំង២០មុខនោះ សំដៅលើផលិតផលដែលកំពុងចរាចរយ៉ាងទូលំទូលាយ បំផុតនៅក្នុងតំបន់ ដោយរួមបញ្ចូលទាំងទំនិញប្រើប្រាស់រយៈពេលវែង ដូចជា វិទ្យុ ឈុតនៃទូរទស្សន៍ ទូរទឹកកក ម៉ាស៊ីនត្រជាក់ និងទូរស័ព្ទ បន្ថែមពីលើក្រុមផលិតផលទាំង២០មុខនោះ អាស៊ានក៏បានធ្វើឲ្យ ស៊ីគ្នាទៅនឹងស្តង់ដារសុវត្ថិភាពចំនួន៧២ និងស្តង់ដារអេឡិកត្រូម៉ាញេទិចទាំង១០ ផ្សេងទៀត។

**១.៧.២.ការរៀបចំពាណិជ្ជកម្មផ្អែកលើបទប្បញ្ញត្តិ**

អាស៊ាន បានអនុម័តយន្តការដោះស្រាយវិវាទ (ភាគច្រើនអនុលោមតាមការយោគយល់គ្នាដោះស្រាយវិវាទរបស់អង្គការ WTO) ដែលមានវិសាលភាពគ្របដណ្តប់លើកិច្ចព្រមព្រៀងសេដ្ឋកិច្ចទាំងអស់។ ការដាក់ចេញនូវយន្តការខាងលើនេះ គឺសម្រាប់ដោះស្រាយបញ្ហាមួយចំនួនដែលកើតចេញពីការអនុវត្ត កិច្ចព្រមព្រៀងសេដ្ឋកិច្ចខ្លះៗក្នុងតំបន់។ បទប្បញ្ញត្តិ ស្តីពីការចាត់វិធានការបន្ទាន់ ក្រោមកិច្ចព្រមព្រៀង CEPT ត្រូវបានពង្រឹង ដើម្បីធ្វើឲ្យសមស្របជាមួយនឹងកិច្ចព្រមព្រៀង WTO ស្តីពី ការចាត់វិធានការការពារ។ ពិធីសារមួយ ស្តីពីនីតិវិធីជូនដំណឹង ក៏ត្រូវបានដាក់ចេញ ដែលតម្រូវឲ្យមានការជូនដំណឹងជាមុនលើសកម្មភាព ឬការចាត់វិធានការណាមួយដែលអាចផ្តល់ផលប៉ះពាល់ជាអវិជ្ជមានលើការផ្តល់ឧបត្ថម្ភសម្បទាន ក្រោមកិច្ចព្រមព្រៀងអាស៊ានដែលមានស្រាប់។ បន្ថែមពីនេះក៏បានព្រមព្រៀងលើ ពិធីសារទាក់ទងនឹងការអនុវត្តគម្រោងCEPT លើបញ្ជីលើកលែងបណ្តោះអាសន្ន ដែលមានបំណង ផ្តល់ភាពបត់បែនដល់ប្រទេសដែលកំពុងជួបប្រទះនូវបញ្ហាប្រឈម លើវិធីសាស្ត្រដោះស្រាយចុងក្រោយនៃផលិតផលដែលបានផលិតក្នុងបញ្ជីលើកលែងបណ្តោះអាសន្ន។ ពិធីសារនេះក៏ត្រូវបានអនុញ្ញាតឲ្យប្រទេសទាំងអស់ពន្យាពេលបណ្តោះអាសន្ន ក្នុងការផ្ទេរផលិតផលបញ្ជីលើកលែងបណ្តោះអាសន្ន ឬផ្អាកការផ្តល់លើផលិតផលក្នុងបញ្ជីលើកលែងបណ្តោះអាសន្ន ដែលផ្ទេររួចរាល់ទៅក្នុងបញ្ជីរួម (Inclusion List)។

**១.៧.៣.គោលដៅចុងក្រោយនៃ AFTA**

ថ្នាក់ដឹកនាំអាស៊ាន បានព្រមព្រៀងលើការលុបបំបាត់ទាំងស្រុងលើពន្ធនាំចូល នៅឆ្នាំ២០១០ សម្រាប់រដ្ឋជាសមាជិកស្ថាបនិកអាស៊ានទាំង៦ប្រទេស និងឆ្នាំ២០១៥ សម្រាប់សមាជិកថ្មី ៤ផ្សេងទៀត។ កន្លងទៅនេះ បន្ទាត់ពន្ធគយចំនួន ២០,៧០១ ស្មើនឹង ៣៨ភាគរយនៃបញ្ជីរួម គឺត្រូវបាន លុបពន្ធទាំងស្រុង ដោយរំឭកកាលពី

ឆ្នាំ២០០៣ គឺប្រទេសសហស្ថាបនិកនីមួយៗចំនួន ៦ ត្រូវអនុវត្ត ការលុបពន្ធឲ្យបានត្រឹម ៦០ភាគរយនៃបញ្ជីរួម និងដោយឡែកប្រទេសជាសមាជិក ៤ផ្សេងទៀត រួមមាន ប្រទេសវៀតណាម ត្រូវអនុវត្តការលុបពន្ធនៅឆ្នាំ ២០០៦ ចំនួន ៣៥.៣៧ភាគរយនៃបញ្ជីរួម ខណៈពេលដែលប្រទេសឡាវ និងប្រទេសមីយ៉ាន់ម៉ា កាលពីឆ្នាំ ២០០៨ បានលុបពន្ធនាំចូលចំនួន ៨៧.៦ភាគរយ និងមានចំនួន៣.៩ភាគរយជាបន្តបន្ទាប់នៃបញ្ជីរួម រីឯប្រទេសកម្ពុជាក៏បានលុបចោលពន្ធគយចំនួន ៧.៦៤ភាគរយ ក្នុងបញ្ជីរួមផងដែរ។[14]

**១.៧.៤.ការតភ្ជាប់សេដ្ឋកិច្ចក្រៅតំបន់**

ការសម្រេចបាននូវតំបន់ពាណិជ្ជកម្មសេរីអាស៊ាន ដែលពោរពេញទៅដោយសារៈប្រយោជន៍ដល់ ដៃគូសេដ្ឋកិច្ចអាស៊ាន គឺត្រូវបានរកដំណោះស្រាយក្នុងការជំរុញការតភ្ជាប់សេដ្ឋកិច្ច តាមបណ្តាប្រទេស អាស៊ីបូព៌ា ឆ្ពោះទៅកាន់ការធ្វើសមាហរណកម្មតំបន់អាស៊ាន ជាមួយប្រទេសចិន ប្រទេសជប៉ុន និង ប្រទេសកូរ៉េខាងត្បូង ដែលបានសម្រេចជារួមដោយមេដឹកនាំប្រទេសអាស៊ានក្នុងកិច្ចប្រជុំកំពូលនៅ ទីក្រុងបង់ដាសេរីបេហ្គាវ៉ាន់ កាលពីថ្ងៃទី៥-៦ ខែ វិច្ឆិកា ឆ្នាំ២០០១។

មេដឹកនាំអាស៊ាននិងចិន បានពិចារណាលើរបាយការណ៍របស់ក្រុមជំនាញការអាស៊ាន-ចិន លើ កិច្ចប្រតិបត្តិការសេដ្ឋកិច្ច នៅក្នុងកិច្ចប្រជុំនាប្រទេសសឹង្ហបុរី។ មេដឹកនាំអាស៊ាន-ចិនគាំទ្រនូវសំណើ សម្រាប់ក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបានព្រមព្រៀងបង្កើតនូវតំបន់ពាណិជ្ជកម្មសេរី អាស៊ាន-ចិន រយៈពេល១០ឆ្នាំ ជាមួយនឹងប្រព្រឹត្តកម្មផ្សេងៗ ជាពិសេសសម្រាប់សមាជិកអាស៊ានថ្មីៗ។ ក្រៅពីនេះ អាស៊ានកំពុងចរចា ដើម្បីបង្កើតតំបន់ពាណិជ្ជកម្មសេរីជាមួយបណ្តាប្រទេសដៃគូសន្ទនា របស់ខ្លួនរួមមាន៖

- តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន (ASEAN - China FTA) នៅឆ្នាំ២០១០ សម្រាប់សមាជិកទាំង៦ ប្រទេសរបស់អាស៊ានមាន (ប្រ៊ុយណេ ឥណ្ឌូណេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សឹង្ហបុរី និងថៃឡង់ដ៍) និងឆ្នាំ ២០១៥ សម្រាប់កម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម។
- តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ជប៉ុន (ASEAN-Japan FTA) នៅឆ្នាំ២០១២ សម្រាប់ សមាជិកទាំង៦ ប្រទេសរបស់អាស៊ានមាន (ប្រ៊ុយណេ ឥណ្ឌូណេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សឹង្ហបុរី និងថៃឡង់ដ៍) ហើយ៤ ប្រទេសទៀត នៅឆ្នាំ២០១៧ មាន កម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម។
- តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ (ASEAN - Korea FTA) នៅឆ្នាំ២០១០ សម្រាប់ សមាជិកទាំង៦ ប្រទេសរបស់អាស៊ានមាន (ប្រ៊ុយណេ ឥណ្ឌូណេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សឹង្ហបុរី និងថៃឡង់ដ៍) ជាមួយ វៀតណាមនៅឆ្នាំ២០១៦ និងជាមួយកម្ពុជា ឡាវ មីយ៉ាន់ម៉ា នៅឆ្នាំ២០១៨។

[14] ដកស្រង់ពីរបាយការណ៍ តំបន់ពាណិជ្ជកម្មសេរីអាស៊ាន

- កិច្ចព្រមព្រៀងពាណិជ្ជកម្មសេដ្ឋកិច្ចជិតស្និទ្ធនៃប្រទេសអូស្ត្រាលី ញូហ្សីឡែន ត្រូវបានរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន ចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះកាលពីឆ្នាំ២០០២ (Australia - New Zealand closer Economic Relations Trade Agreement - CER) និងសេចក្តីថ្លែងការថ្នាក់រដ្ឋមន្ត្រីស្តីពី Ministerial Declaration on FTA-CER។[15]

## ១.៨.សមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ាន

ការបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) នៅចុងឆ្នាំ២០១៥ គឺជាសមិទ្ធផលដ៏ធំបំផុតមួយ ដែលអាស៊ានសម្រេចបានក្នុងគោលបំណង ដើម្បី ៖

- សម្រេចបាននូវទីផ្សារ និងមូលដ្ឋានផលិតកម្មតែមួយ
- ចំណុចទីពីរ គឺជាតំបន់សេដ្ឋកិច្ចដែលមានការប្រកួតប្រជែងខ្ពស់
- ចំណុចទីបី គឺជាតំបន់មួយដែលមានការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយសមធម៌ និង
- ទីបួន គឺជាតំបន់មួយដែលរួមបញ្ចូលគ្នាយ៉ាងពេញលេញនៅក្នុងសេដ្ឋកិច្ចពិភពលោក។

ផែនការសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០២៥ បាននឹងកំពុងផ្តល់ទិសដៅ និងវិធានការយុទ្ធសាស្ត្រទូលំទូលាយ ដើម្បីឈានទៅសម្រេចបាននូវសហគមន៍មួយ ដែលមានកម្រិតសមាហរណកម្មខ្ពស់ ស្របគ្នានឹងផែនការសហគមន៍នយោបាយ-សន្តិសុខអាស៊ានឆ្នាំ២០២៥ និងផែនការសហគមន៍សង្គម-វប្បធម៌អាស៊ានឆ្នាំ ២០២៥ ។ ដូចនេះ ផែនការសហគមន៍សេដ្ឋកិច្ចអាស៊ាន គឺឈរលើសសរស្តម្ភចំនួន០៤ ដែលមានទំនាក់ទំនងគ្នាទៅវិញទៅមកដូចជា ៖

ក)-ទីផ្សារ និងផលិតកម្មមូលដ្ឋានតែមួយ

ខ)-តំបន់សេដ្ឋកិច្ច ដែលមានការប្រកួតប្រជែងខ្ពស់

គ)-តំបន់អភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយសមធម៌ និង

ឃ)-សមាហរណកម្មតំបន់ពេញលេញទៅក្នុងសេដ្ឋកិច្ចសកល។

[15] Source : Pushpanathan, 2020 Deputy Secretary-General of ASEAN for ASEAN Economic Community

# ជំពូកទី ២

# លទ្ធផលនៃការស្រាវជ្រាវ

## ២.១.ស្ថានភាពប្រទេសកម្ពុជា

ប្រទេសកម្ពុជា គឺជាប្រទេសមួយស្ថិតនៅផ្នែកខាងត្បូងនៃឧបទ្វីបឥណ្ឌូចិន ក្នុងអនុតំបន់អាស៊ីអាគ្នេយ៍។ ប្រទេសកម្ពុជាមានផ្ទៃក្រឡាសរុប ១៨១,០៣៥ គីឡូម៉ែតការ៉េ លាតសន្ធឹងក្នុងរាងពហុកោណស្ទើរស្មើជ្រុង មានព្រំប្រទល់ជាប់ប្រទេសថៃនៅភាគខាងលិចនិងពាយ័ព្យ ប្រទេសឡាវនៅភាគឦសាន្ត ប្រទេសវៀតណាមនៅភាគខាងកើត និងឈូងសមុទ្រថៃនៅភាគនិរតី[16]។ ប្រទេសកម្ពុជាមានប្រជាជនជាង ១៥ លាននាក់នៅក្នុងឆ្នាំ ២០១៥ និងមានចំនួនជាង ១៦ លាននាក់នៅក្នុងឆ្នាំ ២០២០ ហើយកម្ពុជាស្ថិតក្នុងលំដាប់ទី៧២ក្នុងលោក ទី២៧ក្នុងទ្វីបអាស៊ី និងទី៧ក្នុងអាស៊ីអាគ្នេយ៍[17]។ ប្រជាជនជិតពាក់កណ្ដាលប្រមូលផ្ដុំកុះករនៅតំបន់វាលរាប ទំហំប្រហែល ១៤% នៃផ្ទៃសរុប។ សាសនាជាផ្លូវការ គឺ ព្រះពុទ្ធសាសនាថេរវាទ ដែលកាន់ដោយប្រជាជនប្រហែល ៩០%។ ជនជាតិភាគតិចក្នុងប្រទេសនេះ រួមមាន: ជនជាតិវៀតណាម ចិន ចាម និងកុលសម្ព័ន្ធភ្នំ ៣០ ជនជាតិផ្សេងៗទៀត។ រាជធានី និង ទីក្រុងធំបំផុតគឺ ភ្នំពេញ ដែលជាមជ្ឈមណ្ឌលនយោបាយ សេដ្ឋកិច្ច និង វប្បធម៌នៃកម្ពុជា។ កម្ពុជាជារដ្ឋឯកភាព ក្រោមរបបរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ និងរបបរដ្ឋសភាប្រជាធិបតេយ្យ ដែលមានព្រះបាទនរោត្តម សីហមុនី ជ្រើសតាំងដោយក្រុមប្រឹក្សារាជសម្បត្តិ ជាព្រះមហាក្សត្រ និងជាព្រះប្រមុខរដ្ឋ។

ចំណែកឯសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាបច្ចុប្បន្នដើរតាមប្រព័ន្ធទីផ្សារបើកចំហ (សេដ្ឋកិច្ចទីផ្សារ) និងមានការរីកចម្រើនផ្នែកសេដ្ឋកិច្ចយ៉ាងឆាប់រហ័សនៅក្នុងទសវត្សចុងក្រោយនេះ។ ប្រទេសកម្ពុជាមានផលិតផលក្នុងស្រុកសរុបចំនួន ២៤.៥៧ ពាន់លានដុល្លារក្នុងឆ្នាំ ២០១៨[18]។ ប្រាក់ចំណូលរបស់មនុស្សម្នាក់ទោះបីមានការកើនឡើងយ៉ាងឆាប់រហ័សក៏ដោយក៏នៅមានកំរិតទាបបើប្រៀបធៀបជាមួយប្រទេសជិតខាងភាគច្រើន។ សម្រាប់ប្រទេសកម្ពុជា ឧស្សាហកម្មធំបំផុតពីររបស់កម្ពុជាគឺវាយនភណ្ឌនិងទេសចរណ៍ខណៈដែលសកម្មភាពកសិកម្មនៅតែជាប្រភពចំណូលដ៏សំខាន់សម្រាប់ប្រជាជនកម្ពុជាជាច្រើនដែលរស់នៅតាមតំបន់ជនបទ។ រីឯវិស័យសេវាកម្មត្រូវបានផ្ដោតអារម្មណ៍យ៉ាងខ្លាំងទៅលើសកម្មភាពពាណិជ្ជកម្ម និងសេវាកម្មទាក់ទងនឹងការផ្គត់ផ្គង់ម្ហូបអាហារ។ នៅពេលថ្មីៗនេះប្រទេសកម្ពុជាបានរាយការណ៍ថាប្រេង និងឧស្ម័នបម្រុងត្រូវបានរកឃើញនៅឯនាយឆ្នេរ។ កម្ពុជាមានវិស័យសំខាន់ៗចំនួន ៤ ដែលកំពុងតែរុញច្រានកំណើនសេដ្ឋកិច្ចកម្ពុជាឲ្យក្លាយជា«កូន

---

[16] ដកស្រង់ពី Wekipedia.com

[17] ដកស្រង់ចេញពី Worldometer.com ថ្ងៃទី ២៩ កក្កដា ឆ្នាំ ២០២០

[18] ដកស្រង់ចេញពី data.Worldbank.org

ខ្លាសេដ្ឋកិច្ច»នៅក្នុងតំបន់អាស៊ាន។ វិស័យដែលសំខាន់ៗដែលជាឆ្អឹងកងសម្រាប់សេដ្ឋកិច្ចទាំងបួននោះមានដូចជាវិស័យទេសចរណ៍ វិស័យកសិកម្មឧស្សាហកម្មវិស័យសំណង់និង អចលនទ្រព្យ។ ក្រៅពីវិស័យទាំង៤ខាងលើក៏នៅមានផងដែរនូវធាតុផ្សំសំខាន់ៗផ្សេងទៀត ដែលធ្វើឲ្យកម្ពុជារឹងមាំក្នុងការឈានទៅរកកំណើនសេដ្ឋកិច្ចខ្លាំងក្លានៅក្នុងតំបន់។[19]

ការកំណត់ភាពរីកចម្រើននៃកំណើនសេដ្ឋកិច្ចនេះគឺផ្អែកលើកត្តាសំខាន់ៗ ដូចជា ស្ថិរភាពនយោបាយ និងបរិស្ថានអាជីវកម្មមានលក្ខណៈប្រសើរជាងកាលពីឆ្នាំកន្លងមក ដែលធ្វើឲ្យវិនិយោគិនមានទំនុកចិត្ត។ ការផ្សព្វផ្សាយព័ត៌មានពីឱកាសវិនិយោគមានភាពទូលាយចំពោះវិនិយោគិនបរទេស និងសមាហរណកម្មសេដ្ឋកិច្ចអាស៊ានក៏ជាចំណុចសំខាន់ល្អមួយផងដែរសម្រាប់កម្ពុជា។ជាពិសេសជាងនេះទៅទៀត វិនិយោគបរទេសកាន់តែមើលឃើញពីការបើកទូលាយសម្រាប់ការវិនិយោគ ដោយមាននីតិវិធីច្បាប់រឹងមាំជាងឆ្នាំមុនៗ និងមានការអភិវឌ្ឍធនធានមនុស្ស ដែលមានកម្លាំងស្ទួលយុវជនវ័យក្មេងជាច្រើន ចំណុចទាំងអស់នេះហើយដែលធ្វើឲ្យវិនិយោគបរទេសកំពុងតែងាកមករកការបណ្ដាក់ទុននៅប្រទេសកម្ពុជាជាច្រើន។

### ២.១.១.ស្ថានភាពពាណិជ្ជកម្មក្នុងស្រុក

ពាណិជ្ជកម្មនៅក្នុងស្រុក គឺសំដៅទៅលើការចរាចរណ៍នូវទំនិញ ឬការដោះដូរនូវទំនិញដែលប្រព្រឹត្តិឡើងនៅក្នុងស្រុក[20]។ ជាក់ស្តែងដូចប្រទេសកម្ពុជាយើងសព្វថ្ងៃ គឺមានដោះដូរនូវទំនិញជាប្រចាំពីខេត្តមកកាន់រាជធានី ឬពីខេត្តមួយទៅខេត្តមួយ និងពីស្រុកមួយទៅស្រុកមួយ។ នៅក្នុងរាជធានីភ្នំពេញ ផ្សារដែលពេញនិយមសម្រាប់ប្រជាពលរដ្ឋ គឺផ្សារទួលទំពូង និងផ្សារធំថ្មី ដោយសារតែផ្សារទាំងពីរសម្បូរទៅដោយទំនិញរាប់រយមុខសម្រាប់បំពេញនូវតម្រូវការរបស់ប្រជាពលរដ្ឋប្រចាំថ្ងៃ និងជាផ្សារដែលទាក់ទាញសម្រាប់ជនបរទេសផងដែរ[21]។ ទំនិញសំខាន់ៗភាគច្រើនដែលត្រូវបានគេចរាចរណ៍នាំមកកាន់ផ្សារទាំងពីរនេះរួមមាន បន្លែ ត្រី សាច់ ម្ហូបអាហារ បង្អែម ក្រម៉ា ក្រណាត់សូត្រ គ្រឿងអលង្ការធ្វើពីដៃ និងវត្ថុអនុស្សាវរីយ៍ជាច្រើនប្រភេទទៀតអាចរកទិញបាននៅទីនេះដែរ។

ភាគច្រើននៃជនបរទេសគឺមកទិញអីវ៉ាន់នៅក្នុងផ្សារទាំងនេះ មុនពេលដែលពួកគេត្រឡប់ទៅប្រទេសរបស់ខ្លួនវិញ។ បច្ចុប្បន្ននៅក្នុងតំបន់នៃផ្សារទួលទំពូងមានជនបរទេសជាច្រើនបានមករស់នៅ ចំណែកភ្ញៀវទេសចរក៏បានមកដើរកំសាន្តនៅតំបន់នេះផងដែរ ពួកគេអាចមកទិញវត្ថុអនុស្សាវរីយ៍ និងញ៉ាំអាហារច្រើនប្រភេទ មានអាហារបែបខ្មែរ ហើយក៏មានភោជនីយដ្ឋានបែបអឺរ៉ុប ដែលមានជម្រើសច្រើនបែបងាយស្រួល

[19] ដកស្រង់ចេញពី Cambonist.com

[20] ដកស្រង់ពីគេហទំព័រ Investopedia.com 2021

[21] ដកស្រង់ពីគេហទំព័រ Realestate.com.kh 2017

សម្រាប់ជនបរទេសដែលមិនចេះញ៉ាំអាហារខ្មែរ ហើយពួកគេក៏អាចរីករាយជាមួយការទទួលទានស្រាបៀរបានទៀតផង។ ទោះបីជាយ៉ាងណាក៏ដោយរាល់មុខទំនិញដែលលក់នៅក្នុងរាជធានីភ្នំពេញតែងតែមានការប្រែប្រួលឡើងចុះជាប្រចាំ ដោយសារតែការរងនូវឥទ្ធិពលពីសេដ្ឋកិច្ច ពោលគឺនៅថ្ងៃខ្លះគេអាចទិញទំនិញក្នុងតម្លៃថោក ហើយថ្ងៃខ្លះអាចទិញបានក្នុងតម្លៃថ្លៃ។ គួរបញ្ជាក់ផងដែរថា រាល់ទំនិញដែលប្រែប្រួលជាប្រចាំនោះ គឺសុទ្ធតែជាទំនិញដែលមានតម្រូវការចាំបាច់របស់ប្រជាជន តែការឡើងឡើងថ្លៃ ឬថយចុះគឺមានគម្លាតតិចតួចប៉ុណ្ណោះ។ ទោះបីជាមានការប្រែប្រួលយ៉ាងណាក៏ដោយ ក៏គេសង្កេតឃើញថាប្រជាជននៅតែមានចរាចរយ៉ាងមមាញឹកនៅក្នុងរាជធានីភ្នំពេញ ដែលត្រូវបានគេស្គាល់ថាជាតំបន់សេដ្ឋកិច្ចពិសេស សំបូរទៅដោយតំបន់ពាណិជ្ជកម្មជាច្រើន ដែលស្ថិតនៅពាសពេញរាជធានីភ្នំពេញ។

តារាងទី ២.១ ៖ សន្ទស្សន៍ថ្លៃទំនិញមួយចំនួនដែលចាំបាច់សម្រាប់ជីវភាពរស់នៅរបស់ប្រជាជន

| សន្ទស្សន៍ថ្លៃទំនិញ ចាំបាច់ប្រចាំជីវភាពលើទីផ្សារភ្នំពេញ (ប្រចាំសប្តាហ៍ទី០៣ ខែមេសា ឆ្នាំ២០២១) | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| រាយមុខទំនិញ | Items | ឯកតា | ថ្លៃគ្រាគោល | ថ្លៃ (តាមផ្សារ) | | | | | មធ្យម | ភាគរយ |
| | | Unit | ប្តាហ៍ទី១-២០២ | ផ្សារធំថ្មី | ផ្សារអំពៅ | ដើមគរ | អូឬស្សី | កណ្ដាល | Average | (%) |
| 2 | | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 10/4 |
| ក- ម្ហូបអាហារ គ្រាប់ធញ្ញជាតិ បន្លែ ផ្លែឈើ (Food - Cereal - Vegetable - Fruits) | | | | | | | | | | |
| អង្ករផ្កាម្លិះ ឬប្រហាក់ប្រហែល | Rice 1 | R/Kg | 3,740 | - | - | - | - | - | - | - |
| អង្ករផ្កាខ្ញី ឬប្រហាក់ប្រហែល | Rice 2 | - | 2,880 | - | - | - | - | - | - | - |
| អង្ករនាងមិញ ឬប្រហាក់ប្រហែល | Rice 3 | - | 2,360 | - | - | - | - | - | - | - |
| ស្រូវចំរុះ | Paddy | - | 1,867 | - | - | - | - | - | - | - |
| សណ្ដែកបាយ | Mung Bean | - | 6,500 | - | - | - | - | - | - | - |
| សណ្ដែកសៀង | Bean | - | 4,200 | - | - | - | - | - | - | - |
| សណ្ដែកដីគ្រាប់ | Peanuts | - | 8,800 | - | - | - | - | - | - | - |
| ពោតស (គ្រាប់) | Maize 1 | - | 3,000 | - | - | - | - | - | - | - |
| ពោតក្រហម (គ្រាប់) | Maize 2 | - | 2,600 | - | - | - | - | - | - | - |
| ម្សៅមី (លេខ ១) | Flour 1 | - | 4,260 | - | - | - | - | - | - | - |
| ល្ង ស | White Sesame | - | 13,200 | - | - | - | - | - | - | - |
| ល្ង ខ្មៅ | Black Sesame | - | 13,200 | - | - | - | - | - | - | - |
| ខ្ទឹម ស | Garlic | R/kg | 6,600 | - | - | - | - | - | - | - |
| ខ្ទឹម ក្រហម | Red Garlic | R/kg | 5,400 | - | - | - | - | - | - | - |
| ខ្ទឹម បារាំង | Onion | R/kg | 3,800 | - | - | - | - | - | - | - |
| គ្រាប់ស្វាយចាន់ទីបករួច | Cashew nut | R/Kg | 45,000 | - | - | - | - | - | - | - |
| ម្រេច | Pepper | - | 40,600 | - | - | - | - | - | - | - |
| សាច់គោ | Beef | - | 39,600 | - | - | - | - | - | - | - |
| សាច់ជ្រូក (សាច់សុទ្ធ) | Pork | - | 24,800 | - | - | - | - | - | - | - |
| សាច់ជ្រូកបីជាន់ | Bacon | - | 23,600 | - | - | - | - | - | - | - |
| សាច់មាន់ | Chicken | - | 28,000 | - | - | - | - | - | - | - |
| សាច់ទា | Duck | - | 15,600 | - | - | - | - | - | - | - |

ប្រភព ៖ (ក្រសួងពាណិជ្ជកម្ម, 2021)

### ២.១.២.ស្ថានភាពពាណិជ្ជកម្មជាលក្ខណៈអន្តរជាតិ

ពាណិជ្ជកម្មក្រៅប្រទេស បានជួយឱ្យប្រទេសកម្ពុជាទទួលបានឱកាសលើសពីអ្វីដែលអាចវាយតម្លៃដោយផ្អែកទៅលើតែលក្ខខណ្ឌទីផ្សារក្នុងស្រុក។ ជាពិសេសការនាំចេញធ្វើឱ្យការប្រើប្រាស់ដីធ្លី និងកម្លាំងពលកម្មមានប្រសិទ្ធភាព ដែលមកដល់ពេលនេះមិនទាន់បានប្រើប្រាស់អស់លទ្ធភាព ដោយសារតែតម្រូវការក្នុង

ស្រុកនៅខ្សោយ។ ការនាំចូលបានធ្វើឱ្យអ្នកប្រើប្រាស់កម្ពុជាអាចទិញផលិតផលមានគុណភាពខ្ពស់ ក្នុង តម្លៃថោកជាង ហេតុដូចនេះវាបានបង្កើនសុខុមាលភាពសេដ្ឋកិច្ច។

ពាណិជ្ជកម្មក្រៅប្រទេសបានជួយឱ្យវិស័យឯកជនរីកដុះដាល និង ជាអ្នកផ្តល់ការងារដ៏សំខាន់នៅក្នុងតំបន់ទីក្រុង ប៉ុន្តែអាចដើរតួនាទីមួយដ៏ខ្លាំងក្លាជាងមុនក្នុងការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា។ យុទ្ធសាស្ត្រនានា គួរឆ្លើយតបទៅនឹងបញ្ហានានា ដូចជាការធ្វើឱ្យប្រព័ន្ធព័ត៌មានសម្រាប់ទីផ្សារប្រសើរឡើង ការធ្វើពិពិធកម្ម[22]ទីផ្សារនៃផលិតផលនាំចេញនាំចូលភាពអាចរកបានប្រសើរជាងមុន សម្រាប់អ្នកប្រើប្រាស់ចំពោះទំនិញសំខាន់ៗជាមូលដ្ឋាន ការបង្កើននិងរួមចំណែកពីវិស័យឯកជនក្នុងការរកទីផ្សារសម្រាប់ទំនិញនិងសេវាកម្ម ដែលបានផលិតក្នុងស្រុក។ ការបើកទូលាយជាងមុនចំពោះបច្ចេកវិទ្យាទំនើប បាននឹងកំពុងតែធ្វើឱ្យកម្ពុជាទទួលបានអត្ថប្រយោជន៍ដ៏សំខាន់ក្នុងលទ្ធភាពផលិតកម្មតាមរយៈការផ្ទេរបច្ចេកវិទ្យា ដោយមិនចាំបាច់ពឹងផ្អែកតែទៅលើធនធានក្នុងស្រុកសម្រាប់ការកែច្នៃ និងការអភិវឌ្ឍបច្ចេកវិទ្យា។ ក្នុងឆ្នាំ១៩៩៦ ក្រោយពេលកំណែទម្រង់សេរីដែលធ្វើឡើងដោយរាជរដ្ឋាភិបាលកម្ពុជា និង ក្រោយការភ្ជាប់ទំនាក់ទំនងក្រៅប្រទេសឡើងវិញ សហរដ្ឋអាមេរិកបានផ្តល់ឱ្យកម្ពុជានូវឋានៈជាប្រទេសទទួលការអនុគ្រោះបំផុត។

ចាប់តាំងពីឆ្នាំ១៩៩៧កម្ពុជាក៏បានទទួលផលប្រយោជន៍ ពីប្រព័ន្ធអនុគ្រោះទូទៅ (GSP) ផងដែរ។ កម្ពុជាមិនបានទទួលនូវផលប្រយោជន៍ដែលបានពីការផ្តល់អត្រាពន្ធសូន្យភាគរយ ដូចដែលអាមេរិកផ្តល់ឱ្យទៅបណ្តាប្រទេសនៃទ្វីបអាហ្វ្រិក និងតំបន់ការ៉ាប់ប៊ីនៅឡើយទេ។ កម្ពុជាក៏បានពង្រឹងទំនាក់ទំនងពាណិជ្ជកម្មជាមួយ សហគមន៍អឺរ៉ុប (EU) ផងដែរដែលបានផ្តល់ឱ្យ កម្ពុជានូវប្រព័ន្ធអនុគ្រោះទូទៅ (GSP) ក្នុងឆ្នាំ១៩៩៤ និង បានធ្វើឱ្យកម្ពុជាទទួលផលប្រយោជន៍ពីគំនិតផ្តួចផ្តើម ហើយការអនុគ្រោះរាល់ទំនិញនាំចូលលើកលែងតែសព្វាវុធ (EBA) ក្នុងឆ្នាំ២០០១។ កិច្ចព្រមព្រៀងទាំងនេះ បានធ្វើឱ្យកម្ពុជាទទួលបានការបន្ថយពន្ធគយ ២០% លើការនាំចេញសម្លៀកបំពាក់ទៅសហគមន៍អឺរ៉ុបដែល ត្រូវបានអនុវត្តស្របតាមបទបញ្ញត្តិប្រភពដើមនៃទំនិញជាក់លាក់មួយចំនួន។ ឧស្សាហកម្មនាំចេញសម្លៀក បំពាក់របស់កម្ពុជាដែលក្រណាត់ គឺជាវត្ថុធាតុដើមសំខាន់មួយមិនអាចទទួលផលប្រយោជន៍ទេ ដោយសារតែតម្រូវការនៃបទបញ្ញត្តិប្រភពដើមទំនិញ។ ដើម្បីទទួលបានអត្ថប្រយោជន៍ពីបទបញ្ញត្តិប្រភពដើមទំនិញរបស់សហគមន៍អឺរ៉ុប កម្ពុជាចាំបាច់ត្រូវតែផលិតក្រណាត់ផងដែរ (តម្បាញចាក់ និង សម្រេច) មានតែប្រហែល ២៧% នៃការនាំចេញរបស់កម្ពុជា ដែលទទួលបានការផ្តល់អត្រាពន្ធសូន្យភាគរយ ក្នុងការនាំចូលទៅទីផ្សារ សហគមន៍អឺរ៉ុប។ ឧទាហរណ៍ចាប់តាំងពីខែកញ្ញា ឆ្នាំ ២០០៩ ការនាំចេញអង្ករពីប្រទេសកម្ពុជាទទួលបាន ការផ្តល់អត្រាពន្ធសូន្យភាគរយ ក្នុងការនាំចូលទៅទីផ្សារសហគមន៍អឺរ៉ុប ។ (ជួនណារ៉ុន, ២០១៥)

[22] ពិពិធកម្ម ជាការពង្រីកមុខព្រួញក្នុងវិស័យទីផ្សារ ដើម្បីព្យាយាមទាញយកផលចំណេញអតិបរមា តាមលទ្ធភាពដែលអាចធ្វើបាន

## ២.២.ស្ថានភាពប្រទេសថៃ

ព្រះរាជាណាចក្រថៃគឺជាប្រទេសមួយនៅអាស៊ីអាគ្នេយ៍ ដែលមានទីតាំងស្ថិតនៅកណ្តាលឧបទ្វីបឥណ្ឌូចិនដែលមានទំហំ ៥១៣.១២០ គីឡូម៉ែត្រក្រឡា ដែលមានប្រជាជនជាង ៦៦លាននាក់នៅឆ្នាំ ២០០៩[23] ប្រទេសថៃ មានព្រំប្រទល់ជាប់នឹងភាគខាងជើងជាប់ប្រទេសមីយ៉ាន់ម៉ានិងប្រទេសឡាវនៅទិសខាងកើតជាប់ប្រទេសឡាវនិងប្រទេសកម្ពុជា នៅខាងត្បូងជាប់ឈូងសមុទ្រថៃ និងម៉ាឡេស៊ី និងនៅភាគខាងលិចជាប់សមុទ្រអាន់ដាម៉ាន់និងភាគខាងត្បូងប្រទេសមីយ៉ាន់ម៉ា។ ប្រទេសថៃក៏មានព្រំដែនសមុទ្រជាមួយវៀតណាមនៅឈូងសមុទ្រថៃនៅភាគអាគ្នេយ៍និងឥណ្ឌូនេស៊ី និងឥណ្ឌានៅលើសមុទ្រអាន់ដាម៉ាន់នៅភាគនិរតី។ ទីក្រុងបាងកកគឺជារដ្ឋធានីនិងទីក្រុងធំបំផុតរបស់ប្រទេស។

សេដ្ឋកិច្ចរបស់ប្រទេសថៃបានពឹងផ្អែកលើការនាំចេញយ៉ាងខ្លាំងដោយលើការនាំចេញមានចំនួនច្រើនជាងពីរភាគបីនៃផលិតផលក្នុងស្រុកសរុប។ ប្រទេសថៃនាំចេញទំនិញនិងសេវាកម្មដែលមានតម្លៃជាង ១០៥ ពាន់លានដុល្លារជារៀងរាល់ឆ្នាំ។ ការនាំចេញសំខាន់ៗរួមមានរថយន្តកុំព្យូទ័រឧបករណ៍អគ្គិសនីអង្ករវាយនភ័ណ្ឌនិងស្បែកជើងផលិតផលជលផលកៅស៊ូនិងគ្រឿងអលង្ការ[24]។ ប្រទេសថៃគឺជាប្រទេសកំពុងរីកចម្រើនសេដ្ឋកិច្ចនិងត្រូវបានគេចាត់ទុកថាជាប្រទេសឧស្សាហកម្មដែលទើបនឹងចាប់ផ្តើម។ ប្រទេសថៃមាន GDP សរុបនៅឆ្នាំ ២០១៧ ចំនួន ១,២៣៦ ពាន់ពាន់លានដុល្លារអាមេរិក[25]។ ថៃជាប្រទេសមានសេដ្ឋកិច្ចធំទី ២ នៅអាស៊ីអាគ្នេយ៍បន្ទាប់ពីឥណ្ឌូណេស៊ី។ ប្រទេសថៃជាប់ចំណាត់ថ្នាក់ពាក់កណ្តាលនៃការរីករាលដាលនៃទ្រព្យសម្បត្តិនៅអាស៊ីអាគ្នេយ៍ព្រោះថាប្រទេសនេះជាប្រទេសមានជាងគេទី ៤ យោងតាមផលិតផលក្នុងស្រុកសរុប (GDP) សម្រាប់មនុស្សម្នាក់បន្ទាប់ពីប្រទេសសិង្ហបុរីព្រុយណេនិងម៉ាឡេស៊ី។ ប្រទេសថៃដើរតួនាទីជាសេដ្ឋកិច្ចយុថ្កាមួយសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ជិតខាងគឺឡាវមីយ៉ាន់ម៉ានិងកម្ពុជា។ នៅក្នុងត្រីមាសទី ៣ នៃឆ្នាំ ២០១៤ អត្រាគ្មានការងារធ្វើនៅក្នុងប្រទេសថៃមានចំនួន 0,៨៤% នេះបើយោងតាមក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមរបស់ប្រទេសថៃ (NESDB) ។

### ២.២.១.កិច្ចព្រមព្រៀងពាណិជ្ជកម្មជាមួយថៃ

ប្រទេសថៃ ជាប្រទេសមួយដែលមានស្ថិតនៅតំបន់អាស៊ីអាគ្នេយ៍ និងមានព្រំប្រទល់ជាប់ជាមួយនឹងប្រទេសកម្ពុជា។ កត្តាភូមិសាស្ត្រក៏បានបង្កនូវលក្ខណៈងាយស្រួលក្នុងការធ្វើពាណិជ្ជកម្មរវាងប្រទេសទាំងពីរ។ ក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះប្រទេសកម្ពុជា និងប្រទេសថៃបានបង្កើននូវទំហំពាណិជ្ជកម្មយ៉ាងច្រើន

---

[23] ដកស្រង់ចេញពី Wekipedia.com, Demographic of Thailand 2009

[24] ដកស្រង់ពី The World Factbook

[25] ដកស្រង់ចេញពី NIKKIE Asia សរសេរដោយ YUKAKO ONO ១៨ កុម្ភៈ ២០១៨

ដែលបានជួយជ្រោមជ្រែងដល់សេដ្ឋកិច្ចរបស់ប្រទេសទាំងពីរអោយកាន់តែរីកចម្រើនទៅមុខថែមទៀតផងដែរ។ ក្នុងការធ្វើពាណិជ្ជកម្មនេះ ប្រទេសកម្ពុជា និងប្រទេសថៃក៏ធ្លាប់បានចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគីម្តងដែរ កាលពីឆ្នាំ ២០០៦ ដើម្បីរឹតចំណងពាណិជ្ជកម្មរបស់ប្រទេសទាំងពីរអោយកាន់តែប្រសើរឡើង។

នៅក្នុងកិច្ចព្រមព្រៀងនេះមានគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរដូចជា ការជំរុញពាណិជ្ជកម្មតាមព្រំដែន ធ្វើឱ្យប្រសើរឡើងសម្រាប់ប្រទេសទាំងពីរក្នុងវិស័យកសិកម្មឧស្សាហកម្មនិងសេវាកម្ម ធ្វើឲ្យប្រសើរឡើងនូវការប្រកួតប្រជែងរវាងប្រទេសទាំងពីរលើវិស័យផលិតកម្មពាណិជ្ជកម្ម ការវិនិយោគនិងសេវាកម្ម ព្រមទាំងជួយកាត់បន្ថយភាពក្រីក្រក្នុងចំណោមប្រជាជននៃប្រទេសទាំងពីរនៅតំបន់ព្រំដែនតាមរយៈការបង្កើតអោយមានការងារសម្រាប់ប្រជាជន និងដើម្បីភាពរឹងមាំនៃកិច្ចព្រមព្រៀងនេះភាគីទាំងពីរគួរតែធ្វើការរួមគ្នាណែនាំ និងអនុវត្តវិធានការណ៍ប្រកបដោយប្រសិទ្ធភាពផ្សេងៗគ្នាក្នុងគោលបំណងជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចតាមរយៈពាណិជ្ជកម្មតាមព្រំដែនទ្វេភាគី។ ចំណែកឯទីផ្សារលក់ដុំភាគីនានា ត្រូវសហការគ្នាក្នុងការបង្កើតទីផ្សារលក់ដុំផលិតផលកសិកម្មទំនិញនិងផលិតផលផ្សេងទៀត ដើម្បីជំរុញការផ្លាស់ប្តូរទំនិញរវាងប្រទេសទាំងពីរក៏ដូចជាការផ្ទេរទំនិញទៅប្រទេសទីបី ហើយកិច្ចព្រមព្រៀងនេះអាចត្រូវបានពិនិត្យឡើងវិញជាទៀងទាត់ដោយមានការយល់ព្រមពីភាគីទាំងពីរដើម្បីធានាឱ្យបាននូវការអនុវត្តប្រកបដោយជោគជ័យ ហើយអាចត្រូវបានធ្វើវិសោធនកម្មដោយកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សររបស់ភាគីទាំងពីរ។ ការធ្វើវិសោធនកម្មបែបនេះនឹងចូលជាធរមានចាប់ពីកាលបរិច្ឆេទដែលអាចត្រូវបានព្រមព្រៀងគ្នារវាងពួកគេ។

បើសិនជាកើតមានការដោះស្រាយវិវាទការខ្វែងគំនិតគ្នា ឬវិវាទណាមួយដែលកើតចេញពីការអនុវត្តការបកស្រាយ ឬការអនុវត្តបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះនឹងត្រូវបានដោះស្រាយដោយសណ្តានចិត្តតាមរយៈការពិគ្រោះយោបល់ឬការចរចារវាងភាគីនានា។ ( ពិនិត្យលំអិតក្នុងឧបសម្ព័ន្ធទី ១ )

### ២.២.២.ការនាំចូលទំនិញពីប្រទេសថៃ

ទំនិញដែលនាំចូលមកពីប្រទេសថៃ ភាគច្រើនសុទ្ធសឹងតែជាទំនិញដែលពេញនិយម និងមានតម្រូវការច្រើនពីសំណាក់ប្រជាជនខ្មែរ ដែលកត្តានេះបានធ្វើអោយប្រទេសថៃបន្ត និងពង្រីកការធ្វើពាណិជ្ជកម្មជាមួយនឹងប្រទេសកម្ពុជា។

បរិមាណនាំចូល និងនាំចេញសរុបរបស់កម្ពុជាមានទំហំទឹកប្រាក់ចំនួន ៣៦,៧ ពាន់លានដុល្លារអាមេរិកក្នុងឆ្នាំ ២០១៩ [26]។ ការនាំចូលរបស់ខ្លួនមានចំនួន ២២,១៩ ពាន់លានដុល្លារ ពោលគឺកើនឡើង ១៨,៦ ភាគរយពីមួយឆ្នាំទៅមួយឆ្នាំ។ ទន្ទឹមនឹងនេះដែរ ប្រទេសកម្ពុជាក៏បាននាំចូលមកវិញនូវវត្ថុធាតុដើមសម្រាប់វិស័យកាត់ដេរ រថយន្ត ប្រេង គ្រឿងសំណង់ និងផលិតផលប្រើប្រាស់ប្រចាំថ្ងៃ ដែលភាគច្រើនមកពីប្រទេសចិន ថៃ

[26] ដកស្រង់ចេញពី ធនាគារជាតិនៃកម្ពុជា ឆ្នាំ 2019

វៀតណាម ជប៉ុន និងកូរ៉េខាងត្បូងជាដើម។ ប្រទេសកម្ពុជា មានទំនាក់ទំនងយ៉ាងល្អក្នុងការធ្វើពាណិជ្ជកម្មជាមួយប្រទេសថៃក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ ដោយមានការកើនឡើងជាបន្តបន្ទាប់។ ការធ្វើពាណិជ្ជកម្មរវាងប្រទេសទាំងពីរ ក្នុងការនាំចូលនូវទំនិញពីប្រទេសថៃគេសង្កេតឃើញថា ទំនិញដែលមានទំហំធំជាងគេក្នុងការនាំចូលជា Consumer goods ( ទំនិញប្រើប្រាស់ប្រចាំថ្ងៃ ) Capital goods ( ទំនិញដែលគេប្រើដើម្បីផលិតទំនិញផ្សេងទៀត ) និង Intermediate goods ( ទំនិញពាក់កណ្តាលសម្រេច )។

តារាងទី២.២៖បង្ហាញទំនិញនាំចូលពីប្រទេសថៃ ចូលមកប្រទេសកម្ពុជាចាប់ពីឆ្នាំ ២០១៧ ដល់ ២០១៩

| | 2017 | 2018 | 2019 |
|---|---|---|---|
| Product Group | Import (US$ Thousand) | | |
| Capital goods | 612538.82 | 733982.35 | 918412.41 |
| Consumer goods | 1091088.44 | 1609523.07 | 1567701.61 |
| Intermediate goods | 613500.41 | 828519.21 | 689308.16 |
| Raw materials | 36963.24 | 49910.26 | 58918.66 |
| Animal | 24405.58 | 29549.33 | 32276.38 |
| Chemicals | 163612.96 | 215265.53 | 219138.96 |
| Food Products | 314829.35 | 349466.91 | 376879.57 |
| Footwear | 2943.87 | 3830.92 | 3853.23 |
| Fuels | 403263.62 | 835542.79 | 770888.28 |
| Hides and Skins | 14915.98 | 19335.94 | 17265.71 |
| Mach and Elec | 335574.07 | 388061.4 | 405402.21 |
| Metals | 59054.2 | 84444.17 | 74322.22 |
| Minerals | 92602.87 | 97655.49 | 135608.6 |
| Miscellaneous | 26863.43 | 28742.13 | 26584.45 |
| Plastic or Rubber | 109144.75 | 121350.61 | 122785.08 |
| Stone and Glass | 217872.39 | 311344.86 | 114153.92 |
| Textiles and Clothing | 112040.63 | 157866.3 | 157901.5 |
| Transportation | 390072.25 | 485091.56 | 680179.6 |
| Vegetable | 18562.94 | 16209.21 | 13690.91 |
| Wood | 68400.76 | 78331.44 | 83500.94 |

ប្រភព ៖ (Worldbank)

តាមរយៈតារាងខាងលើគេសង្កេតឃើញថា Consumer goods មានទំហំនាំចូលច្រើនជាងគេដែលមានប្រមាណ ១,០៩១,០៨៨.៤៤ ពាន់ដុល្លារ ដែលស្មើនឹង ៤៦.៥% នៃទំនិញសរុប នៅឆ្នាំ ២០១៧ ហើយវាបានកើនឡើងដល់ ៤៨.៤៧% នៅឆ្នាំ ២០១៩។ ចំណែកឯទំនិញពាក់កណ្តាលសម្រេចវិញគេឃើញមានការកើនឡើងចំនួន ៧៥៩០៧.៧៥ ពាន់ដុល្លារ នៅឆ្នាំ ២០១៩ បើធៀបនឹងឆ្នាំ ២០១៧ ហើយចំនួននេះបានកើនឡើងប្រមាណ ១២.៣%។ មួយវិញទៀតសម្រាប់ Capital goods គឺមានការកើនឡើងយ៉ាងច្រើនសន្ធឹកសន្ធាប់

ពោលគឺកើនពី ៦១២៥៣៨.៨២ ពាន់ដុល្លារ នៅឆ្នាំ ២០១៧ ដល់ ៩១៨៤១២.៤១ ពាន់ដុល្លារ នៅឆ្នាំ ២០១៩ ដែលការកើនឡើងនេះមានប្រមាណជា ៤៩.៩៣%។

### ២.២.៣.ការដាក់ពន្ធទំនិញនាំចូលពីប្រទេសថៃ

សព្វថ្ងៃនេះ គេសង្កេតឃើញថាទំនិញថៃជាច្រើនប្រភេទកំពុងតែចរាចរនៅក្នុងទីផ្សារកម្ពុជា។ ទំហំនៃការប្រើប្រាស់ទំនិញថៃនៅតែបន្តកើនឡើងខ្លាំង ខណៈដែលការធ្វើពាណិជ្ជកម្មរវាងប្រទេសទាំងពីរក៏បន្តមានភាពល្អប្រសើរ។ យោងតាមទិន្នន័យពីស្ថានទូតថៃប្រចាំនៅកម្ពុជាបង្ហាញថា ទំហំពាណិជ្ជកម្មរវាងកម្ពុជានិងថៃកាលពីឆ្នាំ២០១៦ សម្រេចបានទឹកប្រាក់ ៥ពាន់៦០០លានដុល្លារ ពោលគឺមានការថយចុះ៦ភាគរយ បើធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន[27]។ ទន្ទឹមនឹងនេះ ថៃក៏នៅតែបន្តជំរុញទំនាក់ទំនងពាណិជ្ជកម្មជាមួយ កម្ពុជាតាមរយៈការនាំចូលទំនិញជាច្រើនប្រភេទមកដាក់តាំងលក់នៅក្នុងពិព័រណ៍ពាណិជ្ជកម្មថៃនៅកម្ពុជា។

ពលរដ្ឋខ្មែរមួយចំនួនតែងតែនិយមចូលចិត្តប្រើប្រាស់ផលិតផលថៃ ដោយបានអះអាងថា ផលិតផលថៃមានគុណភាពល្អ និងមានតម្លៃសមរម្យ។ កម្ពុជាគឺជាទីផ្សារសំខាន់សម្រាប់ការនាំចេញរបស់ថៃ ហើយកម្ពុជាមានតម្រូវការខ្ពស់លើទំនិញឧស្សាហកម្ម និងទំនិញមូលដ្ឋានផ្សេងទៀត។ ថៃបាននាំចេញទំនិញជាច្រើនប្រភេទមកកម្ពុជាដូចជា ម្ហូបអាហារ យានជំនិះ ផលិតផលកសិកម្ម ភេសជ្ជៈ គ្រឿងសំអាង ប្រេងឥន្ធនៈ គ្រឿងសង្ហារិម ផលិតផលសម្លៀកបំពាក់ ស្បែកជើង និងឧបករណ៍ប្រើប្រាស់ក្នុងផ្ទះមួយចំនួនទៀត។ ការតាំងពិព័រណ៍ថៃនៅកម្ពុជា បានបង្ហាញឱ្យឃើញពីទំនាក់ទំនងពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជា ថៃមានភាពកាន់តែប្រសើរ ជាពិសេស ពាណិជ្ជកម្មនៃប្រទេសទាំងពីរ។ ដូច្នេះ តាមរយៈការបង្កើតព្រឹត្តការណ៍តាំងពិព័រណ៍ពាណិជ្ជកម្ម ថៃនិងកម្ពុជា រំពឹងថា ទំហំពាណិជ្ជកម្មប្រទេសទាំងពីរនឹងកាន់តែមានការកើនឡើងថែមទៀត។ ការដែលប្រទេសកម្ពុជាមានទំនាក់ទំនងល្អជាមួយប្រទេសថៃនេះ គឺបានបន្តទាក់ទាញក្រុមហ៊ុនថៃមួយចំនួនអោយមកចាប់អារម្មណ៍ក្នុងការរកស៊ីជាមួយនឹងកម្ពុជា ដែលនេះជាសញ្ញាល្អអាចធ្វើអោយសេដ្ឋកិច្ចកម្ពុជារីកលូតលាស់បន្ថែមទៀតនាពេលអនាគតខាងមុខនេះ។

ទោះបីជាយ៉ាងណាក៏ដោយ ក៏រាជរដ្ឋាភិបាលរបស់ប្រទេសកម្ពុជាអាចកំណត់បានដោយអនុក្រឹត្យចាត់វិធានការចាំបាច់នានា រាប់បញ្ចូលទាំងការដំឡើង អត្រាពន្ធ ដើម្បីការពារផលិតករកម្ពុជា នៅពេលដែលផលិតករក្នុងស្រុកត្រូវទទួលរងគ្រោះដោយកំណើន នៃការនាំចូល ឬ ដោយឧបត្ថម្ភធនដែលបានផ្តល់ដោយរដ្ឋាភិបាលនៃប្រទេសផ្សេងទៀត ចំពោះការនាំចូលផលិតផលរបស់ខ្លួនមកកម្ពុជា ឬដោយការលក់បង្ខូចថ្លៃទំនិញនៅលើទីផ្សារកម្ពុជា ដែលនេះជាវិធីសាស្ត្រមួយដ៏ល្អសម្រាប់ប្រទេសដែលកំពុងអភិវឌ្ឍន៍ដូចកម្ពុជា។ ការដាក់ពន្ធលើ

[27] Cambonomist.com ( ចុះផ្សាយថ្ងៃ ១៩ កុម្ភៈ ២០១៧ )

ទំនិញនាំចូលនេះ បានជួយជ្រៀមជ្រែង និងសម្រួលដល់ផលិតករក្នុងស្រុក ដើម្បីជៀសវាងការធ្វើអោយប៉ះពាល់ និងរងការខាតបង់ពីការនាំផលិតផលចូលក្នុងស្រុក។

**ក.ផលិតផលកសិកម្ម**

កសិកម្ម នៅតែជាវិស័យសំខាន់បំផុតនៃសេដ្ឋកិច្ចកម្ពុជាទាក់ទងនឹងចំណែកផលិតផលក្នុងស្រុកសរុបរបស់ខ្លួនហើយវិស័យនេះប្រើប្រាស់កម្លាំងពលកម្មភាគច្រើន។ ស្រូវគឺជាដំណាំសំខាន់របស់ប្រទេសកម្ពុជាដែលជាស្បៀងអាហារចម្បងរបស់ខ្លួនហើយនៅពេលមានសន្តិភាពទំនិញនាំចេញសំខាន់បំផុត។ ក្រៅពីអង្ករ ផលិតផលម្ហូបអាហារផ្សេងទៀតរួមមានដំឡូងមីពោត (ពោត) អំពៅសណ្តែកសៀងនិងដូង។ ដំណាំផ្លែឈើសំខាន់ដែលទាំងអស់នេះត្រូវបានគេប្រើប្រាស់ក្នុងស្រុករួមមានចេកក្រូចនិងស្វាយហើយត្រូវបានបំពេញបន្ថែមដោយផ្លែឈើត្រូពិកផ្សេងៗគ្នារួមមានផ្លែធុរេនមង្ឃុតនិងផ្លែល្ហុង។

ក្នុងការនាំចូលនូវផលិតផលកសិកម្ម ចូលក្នុងប្រទេសកម្ពុជាគឺតម្រូវអោយមានការបង់ពន្ធអាករផ្សេងៗដើម្បីការពារផលិរករនៅក្នុងស្រុក។ ផលិតផលកសិកម្មដែលមានដូចជា ស្រូវ បន្លែ ផ្លែឈើ ត្រី សាច់ជាដើមនោះ គឺបានកំណត់អោយមានការបង់ពន្ធ។ សម្រាប់ប្រទេសកម្ពុជាបានធ្វើការកំណត់យកពន្ធយ៉ាងច្រើនបំផុតត្រឹម ៣៥% និងអាចមានចំនួនតិចជាងនេះ ដោយអាស្រ័យទៅលើប្រភេទ និងបរិមាណផងដែរ មិនតែប៉ុណ្ណោះកម្ពុជាក៏បានកំណត់អោយមានការនាំចូលត្រឹមបរិមាណកំណត់មួយ ដើម្បីជៀសវាងក្នុងការផ្តល់នូវផលប៉ះពាល់ទៅដល់ប្រជាកសិករខ្មែរ[28]។

**ខ.ផលិតផលឧស្សាហកម្ម**

ចំណែកឯផលិតផលឧស្សាហកម្មវិញ ក៏មិនខុសគ្នាពីផលិតផលកសិកម្មប៉ុន្មានដែរ ពោលគឺតម្រូវអោយមានការបង់ពន្ធដូចគ្នា។ ទំនិញឧស្សាហកម្មជាទំនិញដែលត្រូវបានទិញ និងប្រើប្រាស់សម្រាប់ការប្រើប្រាស់ឧស្សាហកម្មនិងអាជីវកម្ម។ ទំនិញទាំងនេះត្រូវបានបង្កើតឡើងដោយគ្រឿងម៉ាស៊ីន រោងចក្រផលិតវត្ថុធាតុដើម និងរបស់ល្អ ឬសមាសធាតុផ្សេងទៀតដែលត្រូវបានប្រើប្រាស់ដោយឧស្សាហកម្មឬក្រុមហ៊ុន។ ទំនិញប្រើប្រាស់បានត្រៀមរួចជាស្រេចសម្រាប់ការប្រើប្រាស់និងការពេញចិត្តនៃតំរូវការរបស់មនុស្ស។

ផលិតផលឧស្សាហកម្មដែលមានដូចជា សម្លៀកបំពាក់ គ្រឿងអេឡិចត្រូនិច សម្ភារៈសំណង់ សម្ភារៈប្រើប្រាស់ ចំណីអាហារ ជាដើមត្រូវបង់ពន្ធស្ថិតនៅចន្លោះពី ៧%ដល់ ៣៥% និងមានពន្ធបន្ថែម VAT ចំនួន ១០%ផងដែរ ។ (ក្រសួងពាណិជ្ជកម្ម, 2021)

**២.២.៤.ការនាំចេញទំនិញទៅប្រទេសថៃ**

ការនាំចេញទំនិញរបស់កម្ពុជា ទៅកាន់ប្រទេសថៃគឺមានទំហំតូចជាងការនាំចូលដោយសារតែប្រទេស

[28] ដកស្រង់ចេញពី ក្រសួងពាណិជ្ជកម្ម, 2021

កម្ពុជាមានទំនិញប្រហាក់ប្រហែលនឹងប្រទេសថៃ ដែលជាហេតុបណ្តាលអោយការនាំចេញមានតិចតួចប៉ុន្តែទោះបីជាយ៉ាងណាក៏ការធ្វើពាណិជ្ជកម្មរវាងប្រទេសទាំងពីរបានដំណើរការទៅយ៉ាងរលូន។ ចំពោះមុខទំនិញដែលប្រទេសកម្ពុជាបាននាំចេញទៅកាន់ប្រទេសថៃ មានដូចជា ទំនិញប្រើប្រាស់ប្រចាំថ្ងៃ វត្ថុធាតុដើម ទំនិញពាក់កណ្តាលសម្រេច សាច់សត្វ ថ្នាំ ស្បែកជើង ដែក រ៉ែ ប្លាស្ទិក បន្លែ ផ្លែឈើ ។ល។

តារាងទី២.៣ ៖ បង្ហាញពីទំហំទឹកប្រាក់ផលិតផលនីមួយៗ នៃការនាំចេញផលិតផលរបស់កម្ពុជាទៅកាន់ប្រទេសថៃពីឆ្នាំ ២០១៧ ដល់ ឆ្នាំ ២០១៩

| Product Group | Export (US$ Thousand) | | |
|---|---|---|---|
| Capital goods | 99933.03 | 122460.87 | 135593.38 |
| Consumer goods | 190705.94 | 161224.64 | 176536.2 |
| Intermediate goods | 120521.41 | 24572.74 | 184374.39 |
| Raw materials | 18747.03 | 5122.77 | 10936.64 |
| Animal | 226.81 | 364.12 | 278.65 |
| Chemicals | 44837.21 | 3036.47 | 190.31 |
| Food Products | 2551.54 | 2676.79 | 3366.3 |
| Footwear | 3819.35 | 3518.16 | 5027.72 |
| Hides and Skins | 2582.91 | 2446.98 | 2653.52 |
| Mach and Elec | 192202.62 | 2246.98 | 229913.36 |
| Metals | 6428.64 | 216630.27 | 34004.43 |
| Minerals | 248.63 | 14630.78 | 150.46 |
| Miscellaneous | 3723.36 | 9596.01 | 13122.14 |
| Plastic or Rubber | 4026.71 | 4456.5 | 4171.44 |
| Stone and Glass | 111089.88 | 8762.65 | 164026 |
| Textiles and Clothing | 31753.93 | 33118.4 | 37635.31 |
| Transportation | 7504.16 | 8607.06 | 8295.2 |
| Vegetable | 17251.58 | 4539.78 | 4033.61 |
| Wood | 1696.81 | 1256.01 | 624.81 |

ប្រភព ៖ (Worldbank)

តាមរយៈទិន្នន័យខាងលើ គេសង្កេតឃើញថា Capital goods ( ទំនិញដែលគេប្រើដើម្បីផលិតទំនិញផ្សេងទៀត ) គឺមានការកើនឡើងក្នុងរយៈពេល ៣ ឆ្នាំនេះពោលគឺមានការកើនឡើង ១០.៧២% នៅឆ្នាំ ២០១៩ ធៀបនឹងឆ្នាំ ២០១៨ ហើយមានការកើនឡើងចំនួន ៣៥.៦៨% ធៀបនឹងឆ្នាំ ២០១៧។ មួយវិញទៀតសម្រាប់ផលិតផលអាហារក៏មានការកើនឡើងដែរ ក៏ប៉ុន្តែវាកើនឡើងក្នុងទំហំតិចតួចប៉ុណ្ណោះដោយនៅឆ្នាំ ២០១៧ មានទំហំ ២៥៥១.៥៤ ពាន់ដុល្លារ ហើយបានកើនដល់ ២៦៧៦.៧៩ ពាន់ដុល្លារក្នុងឆ្នាំ ២០១៨ ហើយចំនួននេះបានបន្តកើនដល់ ៣៣៦៦.៣ ពាន់ដុល្លារក្នុងឆ្នាំ ២០១៩។ អ្វីដែលសំខាន់ជាងនេះទៅទៀត ផលិតផលស្បែកជើង

និងសម្លៀកបំពាក់មានការកើនឡើងយ៉ាងខ្លាំងគួរអោយកត់សម្គាល់ ( តាមរយៈទិន្នន័យបង្ហាញខាងលើ ) នេះក៏ដោយសារតែប្រទេសកម្ពុជាមានការរីកចម្រើនខាងវិស័យឧស្សាហកម្មកាត់ដេរ និងមានការវិនិយោគយ៉ាងច្រើនពីសំណាក់បរទេស ទើបបានធ្វើអោយវិស័យមួយនេះកាន់តែរីកចម្រើន។

តាមការព្យាករណ៍ ទំហំហំពាណិជ្ជកម្មទ្វេភាគីកម្ពុជា-ថៃ ឆ្នាំ២០២០ សម្រេចបានទឹកប្រាក់៧.២៥ ពាន់លានដុល្លារ ធ្លាក់ចុះ ២៣ភាគរយ បើធៀបនឹងឆ្នាំ២០១៩ ដែលមានទឹកប្រាក់ ៩.៤៣ពាន់លានដុល្លារអាមេរិក។ ក្នុងទំហំពាណិជ្ជកម្មនេះ ការនាំចេញរបស់កម្ពុជាទៅថៃ មានតម្លៃ១.១៥ពាន់លានដុល្លារ ធ្លាក់ចុះ ៤៩% ធៀបនឹងឆ្នាំ២០១៩ មានតម្លៃ ២.២៧ពាន់លានដុល្លារ។ តួលេខនេះបណ្តាលឲ្យមានឱនភាពជញ្ជីងពាណិជ្ជកម្មដល់ទៅ ៤.៩៥ ពាន់លានដុល្លារ [29]។

### ២.២.៥.ការវិនិយោគផ្ទាល់ពីប្រទេសថៃ

ទំហំទុនវិនិយោគរបស់ថៃនៅកម្ពុជា បានកើនឡើងជាង៦៦លានដុល្លារ។ វិនិយោគទាំងនោះ ផ្តោតលើភោជនីយដ្ឋាន បរិក្ខារម៉ាស៊ីនត្រជាក់ គ្រឿងអេឡិចត្រូនិក សំណង់ និងរោងចក្រកែច្នៃផ្លែឈើ ជាដើម។ ក្រុមហ៊ុននិងពាណិជ្ជកររបស់ប្រទេសថៃជាច្រើនបានត្រៀមបោះទុនវិនិយោគដោយផ្ទាល់លើវិស័យជាច្រើននៅក្នុងប្រទេសកម្ពុជា ដោយសារតែកម្ពុជា មានសក្តានុពលលើវិស័យសេដ្ឋកិច្ច កម្លាំងពលកម្ម និងស្ថិរភាពនយោបាយ ព្រមទាំងមានច្បាប់វិនិយោគត្រឹមត្រូវ ដែលផ្តល់ទំនុកចិត្តដល់វិនិយោគិន បរទេសមកបណ្តាក់ទុន[30]។ ក្រុមពាណិជ្ជករថៃកំពុងសម្លឹងឱកាសបង្កើនគម្រោងវិនិយោគដោយផ្ទាល់នៅកម្ពុជាបន្ថែមទៀត។ ក្នុងរយៈពេល ១១ ខែ នៅក្នុងឆ្នាំ២០១៨ ការដោះដូរពាណិជ្ជកម្មរវាងប្រទេសថៃ និងកម្ពុជា មានទឹកប្រាក់សរុប ៨,០០០លានដុល្លារ ខណៈដែលរាជរដ្ឋាភិបាលប្រទេសទាំងពីរ បានកំណត់ផែនការជំរុញគោលដៅពាណិជ្ជកម្មទ្វេភាគីឱ្យបាន១៥ពាន់លានដុល្លារ នៅឆ្នាំ២០២០។

គួរបញ្ជាក់ផងដែរថា សព្វថ្ងៃក្រុមហ៊ុនដែលមានឈ្មោះបោះសម្លេងរបស់ប្រទេសថៃដែលធ្វើការវិនិយោគនៅកម្ពុជារួមមាន ក្រុមហ៊ុន CP ដែលបានអភិវឌ្ឍន៍សមត្ថភាពអាជីវករ និងអាជីវកម្មសំខាន់ៗដូចជាផ្នែកចំណីសត្វ ចម្ការ ចំណីអាហារ និងផលិតផលលក់រាយនៅក្នុងប្រទេសកម្ពុជា។ នាពេលបច្ចុប្បន្ននេះក្រុមហ៊ុនបានពង្រីងចម្ការចំណីសត្វធំៗចំនួន ២ នៅទីក្រុងភ្នំពេញ និងនៅក្រុងប៉ៃលិន (Feed Mill Plantation) គឺស្របពេលនឹងការអភិវឌ្ឍនៅក្នុងវិស័យកសិកម្មចិញ្ចឹមសត្វនៅក្នុងប្រទេសកម្ពុជា។ អាជីវកម្មចំណីសត្វនេះផ្តោតសំខាន់ទៅលើការបង្កើតចំណីដែលមានគុណភាព និងស្របទៅតាមស្តង់ដារសុវត្ថិភាពអន្តរជាតិព្រមទាំងកាត់បន្ថយផលប៉ះពាល់ទៅដល់បរិស្ថាន។ មិនតែប៉ុណ្ណោះក្រុមហ៊ុនស៊ីភី (CP) របស់ថៃ ចាប់អារម្មណ៍លើការផលិតគ្រាប់កាហ្វេ

[29] ទិន្នន័យរបស់នាយកដ្ឋានពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្មថៃ ដែលដកស្រង់ដោយស្ថានទូតកម្ពុជា ប្រចាំប្រទេសថៃ
[30] (tmeytmey, 2019) ដកស្រង់ចេញពីសារព័ត៌មានថ្មីៗ បោះផ្សាយថ្ងៃ ២៧ មករា ២០១៩

នៅកម្ពុជា ដើម្បីនាំចូលទៅប្រទេសថៃ ខណៈបច្ចុប្បន្នតម្រូវការគ្រាប់កាហ្វេកំពុងមានកម្រិតខ្ពស់នៅ ថៃ ដែលទំហំនៃការផលិត មិនទាន់អាចផ្គត់ផ្គង់គ្រប់ក្នុងប្រទេសថៃ[31]។ ចំណែកឯក្រុមហ៊ុនដែលល្បីឈ្មោះមួយទៀតគឺក្រុមហ៊ុន PTT ដែលត្រូវបានគេស្គាល់ថាជាក្រុមហ៊ុនលក់ប្រេងឥន្ធនៈ និងមានកាហ្វេ Amazon ដ៏ឈ្មុយឆ្ងាញ់នោះដែលក្រុមហ៊ុននេះ នឹងផ្ដោតការយកចិត្តទុកដាក់លើការពង្រីកស្ថានីយចាក់ប្រេងនិងសាខាកាហ្វេ Amazon នៅក្នុងប្រទេសកម្ពុជាអោយកាន់តែច្រើនបន្ថែមទៀតនៅក្នុងឆ្នាំ ២០២១។

## ២.៣.ស្ថានភាពប្រទេសវៀតណាម

សាធារណរដ្ឋសង្គមនិយមវៀតណាមគឺជាប្រទេសមួយនៅអាស៊ីអាគ្នេយ៍ ហើយវាស្ថិតនៅចុងខាងកើតនៃឧបទ្វីបឥណ្ឌូចិនហើយត្រូវបានបែងចែកជា ៥៨ ខេត្តនិងក្រុងចំនួន ៥ ដែលមានផ្ទៃដី ៣៣១.៦៩៩ គីឡូម៉ែត្រក្រឡា មានប្រជាជនជាង ៩៦ លាននាក់ធ្វើឱ្យប្រទេសនេះក្លាយជាប្រទេសដែលមានប្រជាជនច្រើនជាងគេទីដប់ប្រាំបីក្នុងពិភពលោក។ ប្រទេសវៀតណាមមានព្រំដែនជាប់ជាមួយប្រទេសចិននៅភាគខាងជើងប្រទេសឡាវនិងប្រទេសកម្ពុជានៅភាគខាងលិច។ ខណៈពេលដែលរក្សាព្រំដែនសមុទ្រជាមួយប្រទេសថៃតាមរយៈឈូងសមុទ្រថៃនិងហ្វីលីពីនឥណ្ឌូនេស៊ីនិងម៉ាឡេស៊ីតាមរយៈសមុទ្រចិនខាងត្បូង ហើយរដ្ឋធានីរបស់វាគឺហាណូយនិងទីក្រុងធំបំផុតរបស់វាគឺទីក្រុងហូជីមិញ[32]។ នៅក្នុងឆ្នាំ ២០១៩ ប្រទេសវៀតណាមមាន GDP សរុប ២៦១ ពាន់លានដុល្លារ[33]។ នៅទូទាំងប្រវត្តិសាស្ត្រនៃប្រទេសវៀតណាមសេដ្ឋកិច្ចរបស់ខ្លួនពឹងផ្អែកភាគច្រើនលើកសិកម្មជាពិសេសការដាំដុះស្រូវសើម។ Bauxite ដែលជាវត្ថុធាតុដើមសំខាន់ក្នុងការផលិតអាលុយមីញ៉ូមត្រូវបានជីកយករ៉ែនៅភាគកណ្តាលប្រទេសវៀតណាម។

ចាប់តាំងពីការបង្រួបបង្រួមសេដ្ឋកិច្ចរបស់ប្រទេសត្រូវបានរៀបចំឡើងជាចម្បងដោយផលិតផលក្នុងស្រុកសរុបតាមរយៈផែនការ ៥ ឆ្នាំដែលបានសំរេចនៅសម័យប្រជុំពេញអង្គនៃគណៈកម្មាធិការកណ្តាលនិងសមាជជាតិ។ ការប្រមូលផ្តុំកសិដ្ឋានរោងចក្រនិងទំនិញមូលធនត្រូវបានអនុវត្តជាផ្នែកមួយនៃការបង្កើតផែនការកណ្តាលដោយមានមនុស្សរាប់លាននាក់កំពុងធ្វើការឱ្យសហគ្រាសរដ្ឋ។ ក្រោមការគ្រប់គ្រងរបស់រដ្ឋយ៉ាងតឹងរឹងសេដ្ឋកិច្ចរបស់ប្រទេសវៀតណាមនៅតែបន្តញាំញីដោយភាពគ្មានប្រសិទ្ធភាពអំពើពុករលួយនៅក្នុងសហគ្រាសរដ្ឋដែលមានគុណភាពអន់និងមិនដំណើរការ។

ការអភិវឌ្ឍន៍របស់ប្រទេសវៀតណាមក្នុងរយៈពេលជាង ៣០ ឆ្នាំកន្លងមកគួរឱ្យកត់សម្គាល់។ កំណែទម្រង់សេដ្ឋកិច្ចនិងនយោបាយក្រោមការគ្រប់គ្រងរបស់អាយមីដែលបានបង្កើតឡើងក្នុងឆ្នាំ ១៩៨៦ បានជំរុញ

[31] ( ក្រសួងព័ត៌មាន បោះផ្សាយថ្ងៃ ២៧ មករា 2020 )

[32] ដកស្រង់ចេញពី Vietnamese: Cộng hòa Xã hội chủ nghĩa Việt Nam

[33] ដកស្រង់ចេញពី Worldbank.com, GDP Growth of Vietnam

កំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័សដោយផ្លាស់ប្តូរអ្វីដែលពេលនោះជាប្រទេសក្រីក្របំផុតមួយរបស់ពិភពលោក ទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប។ នៅចន្លោះឆ្នាំ ២០០២ និង ២០១៨ ផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់បានកើនឡើង ២,៧ ដងដោយឈានដល់ជាង ២៧០០ ដុល្លារក្នុងឆ្នាំ ២០១៩ ហើយប្រជាជនជាង ៤៥ លាននាក់ត្រូវបានគេដកចេញពីភាពក្រីក្រ។ អត្រាភាពក្រីក្របានធ្លាក់ចុះយ៉ាងខ្លាំងពីជាង ៧០ ភាគរយមកនៅក្រោម ៦ ភាគរយ។ ភាគច្រើននៃប្រជាជនក្រីក្រដែលនៅសេសសល់របស់វៀតណាមគឺ ៨៦ ភាគរយជាជនជាតិភាគតិច។

### ២.៣.១.កិច្ចព្រមព្រៀងពាណិជ្ជកម្មជាមួយវៀតណាម

ប្រទេសកម្ពុជា មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងប្រទេសវៀតណាម ពោលគឺភាគីទាំងពីរធ្លាប់បានចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មជាមួយគ្នាជាច្រើន ដើម្បីបង្កនូវលក្ខណៈងាយស្រួលក្នុងការធ្វើពាណិជ្ជកម្ម។ កាលពីឆ្នាំ ២០១៩ កន្លងទៅប្រទេសទាំងពីរទើបតែបានចុះនូវកិច្ចព្រមព្រៀងមួយបន្ថែមទៀត ហើយកិច្ចសម្របសម្រួលនេះ មានកំណត់បញ្ជីរាយមុខទំនិញដែលមានដើមកំណើតនៅប្រទេស ហត្ថលេខីណាមួយត្រូវបានទទួលភាពអនុគ្រោះពន្ធ ពេលនាំចូលទៅក្នុងទឹកដីរបស់ភាគីហត្ថលេខីម្ខាងទៀត។ ក្រៅពីមុខទំនិញកំណត់ក្នុងកិច្ចសម្របសម្រួលនេះ បណ្តាមុខទំនិញដែលមានដើមកំណើតនៅ ប្រទេស ភាគីហត្ថលេខីណាមួយ ពេលនាំចូលទៅទឹកដីភាគីហត្ថលេខីម្ខាងទៀត ត្រូវអនុលោមតាមច្បាប់ និង បទប្បញ្ញត្តិនៃការនាំចេញ-នាំចូលរបស់ភាគីហត្ថលេខីម្ខាងទៀតដូចបានអនុវត្តលើមុខទំនិញលក់ដូរធម្មតា ឆ្លងកាត់ ព្រំដែនរវាងប្រទេសទាំងពីរ។ មិនតែប៉ុណ្ណោះ ចំពោះមុខទំនិញកសិផល មានដើមកំណើតនៅកម្ពុជាដែលអាជីវករនាំចូលទៅប្រទេសវៀតណាម ដើម្បី ធ្វើការនាំចេញបន្តទៅទីផ្សារផ្សេងទៀត នឹងត្រូវអនុវត្តតាមយន្តការនាំចូលបណ្តោះអាសន្នរបស់រដ្ឋាភិបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងកិច្ចព្រមព្រៀងតំបន់។ (ពិនិត្យក្នុងឧបសម្ព័ន្ធទី ២ )

### ២.៣.២.ការនាំចូលទំនិញពីប្រទេសវៀតណាម

ប្រទេសកម្ពុជាយើងក៏មានទំនាក់ទំនងល្អជាមួយវៀតណាមក្នុងការធ្វើពាណិជ្ជកម្មផងដែរ ពោលគឺក្នុងមួយឆ្នាំៗប្រទេសកម្ពុជាបានធ្វើការនាំចូលនូវទំនិញជាមុខពីប្រទេសវៀតណាម ដែលសុទ្ធសឹងជាទំនិញដ៏មានសារៈសំខាន់។ ទំនាក់ទំនងកម្ពុជា និងវៀតណាមធ្វើឡើងក្នុងទម្រង់នៃទំនាក់ទំនងទ្វេភាគីរវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋសង្គមនិយមវៀតណាម។ ប្រទេសទាំងពីរគឺជាសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ។ ចាប់តាំងពីទសវត្សឆ្នាំ ១៩៩០ ទំនាក់ទំនងរវាងប្រទេសទាំងពីរបានចាប់ផ្តើមមានភាពប្រសើរឡើង។ ទាំងប្រទេសវៀតណាមនិងប្រទេសកម្ពុជាគឺជាសមាជិកនៃអង្គការតំបន់ពហុភាគីដូចជាអាស៊ាននិងកិច្ចសហប្រតិបត្តិការមេគង្គ ហើយប្រទេសទាំងពីរបានបើកនិងអភិវឌ្ឍពាណិជ្ជកម្មឆ្លងកាត់ព្រំដែននិងស្វែងរកបន្ធូរបន្ថយបទប្បញ្ញត្តិទិដ្ឋាការដល់ទីបញ្ចប់។

តាមរបាយការណ៍របស់ក្រសួងពាណិជ្ជកម្មបានគូសបញ្ជាក់ថា ផលិតផលសំខាន់ៗ ដែលវៀតណាមនាំចូលកម្ពុជា មានដូចជា ដែក និងដែកថែប ប្រេងសាំង ផលិតផលវាយនភណ្ឌ និងសម្លៀកបំពាក់ និងផលិតផលកសិកម្មជាច្រើនទៀត ដូចជាត្រីសាច់ និងបន្លែផ្លែឈើ ព្រមជាមួយនឹងសម្ភារៈប្រើប្រាស់ផ្សេងៗ ជាច្រើនទៀត។ ការធ្វើពាណិជ្ជកម្មរបស់កម្ពុជាជាមួយនឹងប្រទេសវៀតណាមគឺមានលក្ខណៈងាយស្រួលជាងដោយសារតែការយោគយល់គ្នាទៅវិញទៅមក និងការចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មនានា។

តារាងទី ២.៤ ៖ បង្ហាញពីទិន្នន័យនៃទឹកប្រាក់ទៅតាមមុខទំនិញនីមួយៗដែលនាំចូលពីប្រទេសវៀតណាមមកកាន់ប្រទេសកម្ពុជា ៖

| | 2017 | 2018 | 2019 |
|---|---|---|---|
| Product Group | Import (US$ Thousand) | | |
| Capital goods | 99651.74 | 128107.36 | 193473.88 |
| Consumer goods | 721367.16 | 986535.21 | 1153506.14 |
| Intermediate goods | 818831.93 | 1079249.52 | 1343287.76 |
| Raw materials | 42409.16 | 27038.08 | 34228.28 |
| Animal | 12633.39 | 3136.02 | 3357.83 |
| Chemicals | 181798.84 | 213910.16 | 218822.39 |
| Food Products | 87302.53 | 101360.61 | 122329.75 |
| Footwear | 60287.97 | 61201.23 | 82197.39 |
| Fuels | 429029.57 | 610445.5 | 693335.11 |
| Hides and Skins | 39588.58 | 64388.81 | 79039.02 |
| Mach and Elec | 83574.45 | 98744.16 | 118918 |
| Metals | 159655.63 | 225712.12 | 306539.25 |
| Minerals | 7545.55 | 7646.66 | 13816.03 |
| Miscellaneous | 33829.17 | 48408.63 | 81199.48 |
| Plastic or Rubber | 68770.49 | 81358.22 | 115640.19 |
| Stone and Glass | 14467.02 | 19417.53 | 31736.76 |
| Textiles and Clothing | 377821.32 | 521132.78 | 621184.08 |
| Transportation | 46876.28 | 63353.9 | 89440.23 |
| Vegetable | 17567.98 | 22726.87 | 25958.28 |
| Wood | 61539.13 | 78024.67 | 121332.56 |

ប្រភព ៖ (Worldbank)

តាមរយៈតារាងខាងលើគេសង្កេតឃើញថា មុខទំនិញដែលមានការកើនឡើងយ៉ាងខ្លាំងនោះមានដូចជា ទំនិញប្រើប្រាស់ ទំនិញពាក់កណ្ដាលសម្រេច ទំនិញដែលប្រើសម្រាប់ផលិតទំនិញផ្សេងទៀត សត្វ ថ្នាំពេទ្យ ម្ហូបអាហារ ស្បែកជើង ផ្លាស្ទិក បន្លែ ផ្លែឈើ និងគ្រឿងសង្ហារិម ។ ក្នុងនោះផងដែរទំនិញប្រើប្រាស់ដែលមានទំហំទឹកប្រាក់នាំចូលសរុបក្នុងឆ្នាំ ២០១៩ មានទឹកប្រាក់ប្រមាណ ១,១៥៣,៥០៦.១៤ ពាន់ដុល្លារដែលមានការកើនគួរអោយកត់សម្គាល់ឡើងប្រមាណ ១៧% ធៀបនឹងឆ្នាំ ២០១៨ ហើយចំនួននេះអាចនឹងមានការកើនឡើងនៅឆ្នាំបន្ទាប់ផងដែរ ។ កាលពីឆ្នាំ ២០២០ កន្លងទៅប្រទេសវៀតណាម នាំចូលទំនិញមកកាន់កម្ពុជា ក្នុងទំហំទឹក

ប្រាក់ចំនួន ២,៦៣៣,៨០៦,២២៣ ដុល្លារ ហើយតាមរយៈការប៉ាន់ស្មាន នៅក្នុងឆ្នាំ ២០២១នេះ គឺការនាំចូលទំនិញពីប្រទេសវៀតណាមមានចំនួនទឹកប្រាក់សរុប ២,៩០៤,៩៨០,៧៦១ ដុល្លារ ។

ក្រាហ្វិកទី ២.១ ៖បង្ហាញពីការនាំចូលពីប្រទេសវៀតណាមមកកម្ពុជា




ប្រភព ៖ (Economics, 2021)

### ២.៣.៣.ការដាក់ពន្ធទំនិញនាំចូលពីប្រទេសវៀតណាម

ដូចដែលបានដឹងហើយថា ការធ្វើពាណិជ្ជកម្មរបស់កម្ពុជា និងវៀតណាមគឺមានទំហំទឹកប្រាក់ដ៏ច្រើនសន្ធឹកសន្ធាប់ ក៏ដោយសារតែប្រទេសទាំងពីរមានទំនាក់ទំនងជាមួយគ្នាយ៉ាងស្អិតរមួត។ បើទោះបីជាមានកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគីយ៉ាងណាក្តី ក៏ភាគីកម្ពុជានៅតែមានការដាក់ពន្ធទៅលើទំនិញនាំចូល ដោយសារតែកម្ពុជាជាប្រទេសកំពុងអភិវឌ្ឍន៍។ សម្រាប់ការនាំចូលទំនិញមកកាន់ប្រទេសកម្ពុជា គឺតម្រូវអោយផ្តល់ឯកសារមួយចំនួនដូចខាងក្រោមនៅពេលទំនិញមកដល់ ៖

- សេចក្តីប្រកាសនាំចូលគយ
- វិក័យប័ត្រពាណិជ្ជកម្ម
- បញ្ជីវេចខ្ចប់
- ឯកសារដឹកជញ្ជូនតាមផ្លូវគោក (ប្រសិនបើទៅដល់តាមផ្លូវគោក)
- វិក័យប័ត្រនៃការ Lading (ប្រសិនបើមកដល់សមុទ្រ)
- ការអនុញ្ញាតនាំចូល
- វិញ្ញាបនប័ត្រធានារ៉ាប់រង
- វិញ្ញាបនប័ត្រពន្ធ
- វិញ្ញាបនប័ត្រប្រភពដើម និង
- ការចុះឈ្មោះក្រុមហ៊ុន។ (Dunseith, 2017)

**ក.ផលិតផលកសិកម្ម**

ប្រទេសវៀតណាម គឺជាសក្ខីកម្មនៃអំណាចក្នុងការធ្វើកំណែទម្រង់កសិកម្ម។ ក្នុងរយៈពេលពីរទសវត្ស ចុងក្រោយនេះ ក្រោយពីបានងើបឡើងពីគ្រោះទុរភិក្ស វៀតណាមក្លាយទៅជាប្រទេសនាំចេញអង្ករធំលំដាប់ទី ២ នៅលើពិភពលោក។ ដំណាំចំណីអាហារសំខាន់ៗផ្សេងទៀតគឺមាន អំពៅ ពោត ដំឡូង និងដំឡូងជ្វា ខណៈ ដែលដំណាំសាច់ប្រាក់រួមមានកាហ្វេ គ្រាប់ស្វាយចន្ទី សណ្តែក ម្រេច តែ ថ្នាំជក់ កៅស៊ូ និងដូង។ ជ្រូកមាន់និង គោគឺជាសត្វចិញ្ចឹមចម្បងដែលបានធ្វើការនាំចេញយ៉ាងច្រើនផងដែរ ។ ហេតុដូចនេះដើម្បីការពារផលិតករកម្ពុ ជា គឺប្រទេសកម្ពុជាបានធ្វើការដាក់ពន្ធទៅលើផលិតផលនាំចូលពីប្រទេសវៀតណាមដូចជា ផលិតផលកសិកម្ម ចំនួន ៧% ស្មើរគ្រប់ទំនិញ និងមានតិចជាងនេះផងដែរ។ (ក្រសួងពាណិជ្ជកម្ម, 2021)

**ខ.ផលិតផលឧស្សាហកម្ម**

ឧស្សាហកម្មធំៗ នៅក្នុងប្រទេសវៀតណាមរួមមាន ការកែច្នៃម្ហូបអាហារ សម្លៀកបំពាក់ វាយនភណ្ឌ ស្បែកជើង ម៉ាស៊ីន ការរុករករ៉ែ ធ្យូងថ្ម ដែកថែប ស៊ីម៉ងត៍ ជីគីមី កែវ សំបកកង់ ប្រេង ទូរស័ព្ទដៃ ហើយអត្រា កំណើនផលិតកម្មឧស្សាហកម្មគឺកើន ៤ ភាគរយ (ឆ្នាំ ២០១២)[34]។ នៅក្នុងនោះផងដែរ វិស័យផលិតកម្មឈាន មុខគេដូចជា ការកែច្នៃម្ហូបអាហារ បារី ថ្នាំជក់ វាយនភ័ណ្ឌគីមី និងទំនិញអគ្គិសនីទទួលបានកំណើនយ៉ាងឆាប់ រហ័ស ហើយស្មើរតែមួយភាគបីនៃសកម្មភាពផលិតកម្មនិងការលក់រាយត្រូវបានប្រមូលផ្តុំនៅទីក្រុងហូជីមិញ។ ប្រទេសវៀតណាមក៏បានធ្វើការនាំចេញនូវទំនិញឧស្សាហកម្មជាច្រើនមុខចូលមកក្នុងប្រទេសកម្ពុជាជារៀងរាល់ ឆ្នាំ ដែលមាននូវទំនិញសំខាន់ៗដូចជា ម្ហូបអាហារកែច្នៃ សម្លៀកបំពាក់ ម៉ាស៊ីន ជីគីមីជាដើម ដែលប្រទេសកម្ពុ ជាបានសម្រេចកំណត់យកពន្ធយ៉ាងច្រើនបំផុតត្រឹម ១៥%។ (ក្រសួងពាណិជ្ជកម្ម, 2021)

**២.៣.៤.ការនាំចេញទំនិញទៅប្រទេសវៀតណាម**

ទំនិញដែលប្រទេសកម្ពុជាបាននាំចេញទៅវៀតណាមមានច្រើនប្រភេទ ហើយពីមួយឆ្នាំទៅមួយឆ្នាំ គឺ មានការកើនឡើង។ កត្តាដែលបណ្តាលអោយប្រទេសកម្ពុជានាំចេញទំនិញយ៉ាងច្រើនទៅប្រទេស វៀតណាម គឺដោយសារតែ កត្តាតម្រូវការ ការដឹកជញ្ជូន និងការកើនឡើងនៃសង្វាក់ផលិតកម្មផលិតរបស់កម្ពុជា ដែលជា កម្លាំងរុញច្រានអោយពាណិជ្ជកម្មរបស់កម្ពុជាកាន់តែមានសន្ទុះកើនឡើង។ ការនាំចេញទំនិញភាគច្រើនទៅ ប្រទេសវៀតណាមជាផលិតផលកសិកម្ម សាច់ សម្ភារៈប្រើប្រាស់ ឈើ ជាដើម។ មិនតែប៉ុណ្ណោះប្រទេសកម្ពុជា មានគម្រោងក្នុងការបង្កើនការនាំចេញទៅប្រទេសវៀតណាមអោយបានកាន់តែច្រើនបន្ថែមទៀតនៅឆ្នាំ ២០២២ ដែលជាសញ្ញាល្អនៃការរីកច្រើនរបស់ពាណិជ្ជកម្មកម្ពុជា។

[34] INDUSTRIES IN VIETNAM, 2012

តារាងទី២.៥ ៖ ទិន្នន័យនៃការនាំចេញរបស់កម្ពុជាទៅប្រទេសវៀតណាម

| | 2017 | 2018 | 2019 |
|---|---|---|---|
| Product Group | Export (US$ Thousand) | | |
| Capital goods | 26019.11 | 11046.29 | 12641.04 |
| Consumer goods | 76743.24 | 86121.24 | 86994.45 |
| Intermediate goods | 43887.31 | 74269.27 | 55518.1 |
| Raw materials | 179037.19 | 190109.57 | 203358.92 |
| Animal | 663.4 | 9743.63 | 4756.78 |
| Chemicals | 6241.65 | 376.02 | 61.75 |
| Food Products | 52280.36 | 72843 | 62561.28 |
| Footwear | 2346.77 | 3356.11 | 10170.56 |
| Fuels | 0 | 24.37 | 0.25 |
| Hides and Skins | 365.14 | 17966 | 1208.77 |
| Mach and Elec | 28505.05 | 21021.83 | 18580.26 |
| Metals | 16040.66 | 7618.84 | 5645.74 |
| Minerals | 0.05 | 15.33 | 9.88 |
| Miscellaneous | 7108.76 | 7754.88 | 10542.2 |
| Plastic or Rubber | 150982.11 | 119024.58 | 131793.54 |
| Stone and Glass | 19461.07 | 44630.51 | 23793.02 |
| Textiles and Clothing | 20889.85 | 25118.4 | 37683.91 |
| Transportation | 1187.17 | 882.08 | 1035.32 |
| Vegetable | 15569.49 | 28762.27 | 49306.75 |
| Wood | 4189.33 | 2677.69 | 2045.68 |

ប្រភព ៖ ( Worldbank )

តាមរយៈទិន្នន័យដែលបង្ហាញខាងលើ គេសង្កេតឃើញថា ប្រទេសកម្ពុជាបាននាំចេញនូវវត្ថុធាតុដើមច្រើននៅឆ្នាំ ២០១៩ គិតជាទឹកប្រាក់ប្រមាណ ២០៣៣៥៨.៩២ ពាន់ដុល្លារ មានការកើនឡើងជាងឆ្នាំ ២០១៨ ចំនួន ១៣២៤៩.៣៥ ពាន់ដុល្លារ និងច្រើនជាងឆ្នាំ ២០១៧ ចំនួន ២៤៣២១.៧៣ ពាន់ដុល្លារ។ ចំណែកឯស្បែកជើងវិញគេសង្កេតឃើញថាមានការកើនឡើងគួរអោយកត់សម្គាល់ពោលគឺនៅឆ្នាំ ២០១៩ មានទំហំទឹកប្រាក់ប្រមាណ ១០១៧០.៥៦ ពាន់ដុល្លារ គឺមានការកើនឡើងចំនួន ២០៣.០៤% ធៀបនឹងឆ្នាំ ២០១៨ ហើយមានការកើនឡើងចំនួន ៣៣៣.៣៨% ធៀបនឹងឆ្នាំ ២០១៧។ អ្វីដែលគួរអោយកត់សម្គាល់ជាងនេះទៅទៀតគឺការនាំចេញបន្លែគឺមានការកើនឡើងយ៉ាងខ្លាំងពោលគឺកើនឡើង ៧១.៤២% ធៀបនឹងឆ្នាំ ២០១៨ ហើយមានការកើនឡើង ២១៦.៦៨ % ធៀបនឹងឆ្នាំ ២០១៧។

### ២.៣.៥.ការអនុគ្រោះពន្ធក្នុងការនាំចូលនៅប្រទេសវៀតណាម

ទំនាក់ទំនងរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាមគឺមានលក្ខណៈល្អប្រសើរ ដោយសារតែមានការយោគយល់ទៅវិញទៅមក។ ប្រទេសវៀតណាមក៏បានធ្វើការអនុគ្រោះដល់កម្ពុជា ក្នុងការនាំចូលទំនិញទៅកាន់ប្រទេសវៀតណាមក្នុងអត្រាពន្ធសូន្យភាគរយផងដែរ ដែលនេះជាប្រយោជន៍មួយយ៉ាងសំខាន់ដល់ប្រទេសកម្ពុជាក្នុងការធ្វើពាណិជ្ជកម្ម។ មិនតែប៉ុណ្ណោះប្រទេសវៀតណាមនឹងបន្តអនុវត្តកិច្ចសម្របសម្រួលជំរុញពាណិជ្ជកម្មទ្វេភាគី មិនយកពន្ធលើមុខទំនិញនាំចេញ ៣១មុខរបស់កម្ពុជា រហូតដល់ឆ្នាំ២០២២។ មុខទំនិញមិនគិតពន្ធ ឬទទួលបានភាពអនុគ្រោះពន្ធសូន្យភាគរយទាំងនោះ ភាគច្រើន គឺជាផលិតផលកសិកម្ម ដែលមានដូចជា សាច់បសុបក្សី ផ្លែឈើ ស្រូវ អង្ករ និង ថ្នាំជក់ ជាដើម [35]។ ( ពិនិត្យមើលលំអិតក្នុងឧបសម្ព័ន្ធទី៣ និងទី៤ )

### ២.៣.៦.ការវិនិយោគផ្ទាល់ពីវៀតណាម

ប្រទេសកម្ពុជា បានក្លាយជាទិសដៅវិនិយោគលំដាប់ទី២ របស់ប្រទេសវៀតណាម បន្ទាប់ពីសហរដ្ឋអាមេរិក ដោយគិតក្នុងរយៈពេល ៤ខែ ដំបូងនៅឆ្នាំ២០២១នេះ ប្រទេសវៀតណាម បានវិនិយោគនៅកម្ពុជាក្នុងទំហំទឹកប្រាក់ប្រមាណជិត ៩០ លានដុល្លារអាមេរិក។ ប្រទេសវៀតណាម នៅក្នុងពេល៤ខែដើមឆ្នាំនេះ បានធ្វើការវិនិយោគនៅក្រៅប្រទេសសរុបជាង ៥៤៥ លានដុល្លារអាមេរិក។ ក្នុងនោះ ការវិនិយោគនៅអាមេរិកឈរលើកំពូលតារាង មានដល់ទៅជាង៣០០លានដុល្លារ គឺស្មើនឹងជាង ៥៥%ទៅហើយ នៃការវិនិយោគសរុប ខណៈដែលកម្ពុជាឈរលំដាប់ទី២ មានជិត៩០លានដុល្លារ និងត្រូវបានតាមពីក្រោយដោយប្រទេសបារាំង កាណាដា អាល្លឺម៉ង់ និងប្រទេសហូឡង់។ (ក្រសួងផែនការ និងវិនិយោគវៀតណាម, 2021)

ការបោះទុនវិនិយោគរបស់ប្រទេសវៀតណាមនៅកម្ពុជា មិនមានច្រើនបើធៀបនឹងបណ្ដាប្រទេសផ្សេងទៀតក៏ពិតមែន តែកំណើនទំហំវិនិយោគរបស់វៀតណាមនៅកម្ពុជា គឺបានកើនពីមួយឆ្នាំទៅមួយឆ្នាំ ហើយការកើនឡើងនេះក៏ដោយសារតែប្រទេសទាំងពីរ ជាប្រទេសជិតខាងគ្នាផង នៅក្នុងក្របខណ្ឌអាស៊ានជាមួយគ្នាផង នៅក្នុងប្រទេសកម្ពុជា គេសង្កេតឃើញមានក្រុមហ៊ុនដែលមានឈ្មោះបោះសម្លេងដូចជា ក្រុមហ៊ុនទូរស័ព្ទមិត្តហ្វូន ដែលជាក្រុមហ៊ុនរបស់ប្រទេសវៀតណាមដែលបម្រើសេវាកម្មសេវាទូរស័ព្ទ និងអ៊ីនធឺណែតក្នុងប្រទេសកម្ពុជា។ គួបញ្ជាក់ផងដែរថា ក្រុមហ៊ុន មិត្តហ្វូន (Metfone) ប្រកាសចាប់ផ្តើមនូវ បច្ចេកវិទ្យាថ្មី 4.5G LTE ជាមួយនឹងស្លាកសញ្ញាថ្មីផងដែរ ដើម្បីបម្រើដល់អតិថិជនជាង ៨លាននាក់ជារៀងរាល់ថ្ងៃ ហើយក្រុមហ៊ុនមិត្តហ្វូនបានវិនិយោគទុនទឹកប្រាក់ចំនួន ៦០០រយលានដុល្លារ ដើម្បីបង្កើតបណ្តាញប្រតិបត្តិករលំដាប់ពិភពលោកមួយដែលអាចជឿទុកចិត្តបាន នៅកម្ពុជា។ មួយវិញទៀតគឺ ក្រុមហ៊ុនជីកសិកម្មអន្តរជាតិផ្កាយប្រាំ ដែលមានទីតាំងស្ថិតនៅស្រុកកៀនស្វាយ ខេត្តកណ្តាល ដែលជារោងចក្រផលិតជីកសិកម្មអន្តរជាតិរបស់វៀតណាម នោះ គឺ

[35] ដកស្រង់ចេញពីគេហទំព័រ RFA ថ្ងៃទី ៣០ មីនា ២០២១

អាចមានសមត្ថភាពផលិតជីកសិកម្មឈ្មោះ អ៊ុនប៉េកា (NPK) ចំនួនជាង ៣៥ម៉ឺនតោនក្នុងមួយឆ្នាំនៅជំហានដំបូងសំរាប់លក់ឲ្យកសិករខ្មែរ ប៉ុន្តែរោងចក្រនេះមានផែនការផលិតជីកសិកម្មនេះឲ្យដល់ចំនួនជាង ៥០ម៉ឺនតោនក្នុងមួយឆ្នាំនៅថ្ងៃអនាគត។ រោងចក្រផលិតជីកសិកម្មអន្តរជាតិនេះ ត្រូវបានសាងសង់អស់តម្លៃជាង ៨០លានដុល្លារអាមេរិក នៅគ្រាដែលរដ្ឋាភិបាលកម្ពុជា កំពុងតែមានផែនការផលិតស្រូវឲ្យមានគុណភាពខ្ពស់ និងបរិមាណច្រើន ដើម្បីនាំចេញអង្ករចំនួនជាង ១លានតោនទៅទីផ្សារអន្តរជាតិ នៅឆ្នាំ២០១៥។

ការផលិតជីកសិកម្មនៅក្នុងប្រទេសកម្ពុជានេះ ត្រូវបានមន្ត្រីជាន់ខ្ពស់រដ្ឋាភិបាលបានពណ៌នាថាគឺជាការកាត់បន្ថយ នូវការចំណាយប្រាក់ច្រើនលានដុល្លារអាមេរិកក្នុងការទិញជីកសិកម្មច្រើនម៉ឺនតោនពីបរទេសចូលមកកម្ពុជាជារៀងរាល់ឆ្នាំ។ (សេរី, 2018)

## ២.៤.ស្ថានភាពប្រទេសឡាវ

ប្រទេសឡាវ គឺជារដ្ឋសង្គមនិយម និងជាប្រទេសដែលមានដែនដីនៅតំបន់អាស៊ីអាគ្នេយ៍។ ប្រទេសនេះនៅចំកណ្តាលឧបទ្វីបឥណ្ឌូចិន និងមានព្រំប្រទល់ជាប់ប្រទេសមីយ៉ាន់ម៉ា និងចិននៅភាគពាយព្យប្រទេសវៀតណាមនៅភាគខាងកើត ប្រទេសកម្ពុជានៅភាគអាគ្នេយ៍ និងប្រទេសថៃនៅភាគខាងលិចនិងនិរតី។ រាជធានី និងទីក្រុងធំជាងគេគឺ វៀងច័ន្ទ[36]។ សេដ្ឋកិច្ចឡាវពឹងផ្អែកលើការវិនិយោគ និងពាណិជ្ជកម្មជាមួយប្រទេសជិតខាងគឺថៃ វៀតណាមនិងជាពិសេសនៅភាគខាងជើងប្រទេសចិន។ Pakxe ជាតំបន់កមានបទពិសោធន៍រីកចម្រើនដោយផ្អែកលើពាណិជ្ជកម្មឆ្លងកាត់ព្រំដែនជាមួយថៃនិងវៀតណាម។ នៅក្នុងឆ្នាំ ២០១៦ ប្រទេសចិនគឺជាវិនិយោគិនបរទេសធំបំផុតនៅក្នុងសេដ្ឋកិច្ចរបស់ប្រទេសឡាវដោយបានវិនិយោគទឹកប្រាក់ចំនួន ៥,៣៩៥ ពាន់លានដុល្លារចាប់តាំងពីឆ្នាំ ១៩៨៩ នេះបើយោងតាមរបាយការណ៍របស់ក្រសួងផែនការនិងវិនិយោគឡាវឆ្នាំ ១៩៨៩-២០១៤។ ប្រទេសថៃ បានវិនិយោគ ៤,៤៨៩ ពាន់លានដុល្លារ និងវៀតណាម បានវិនិយោគ ៣,១០៨ ពាន់លានដុល្លារ គឺជាវិនិយោគិនធំទី ២ និងទី ៣ រៀងៗខ្លួន។ សេដ្ឋកិច្ចទទួលបានជំនួយអភិវឌ្ឍន៍ពីមូលនិធិរូបិយវត្ថុអន្តរជាតិធនាគារអភិវឌ្ឍន៍អាស៊ីនិងប្រភពអន្តរជាតិដទៃទៀត និងការទទួលវិនិយោគផ្ទាល់ពីបរទេសសម្រាប់ការអភិវឌ្ឍសង្គមឧស្សាហកម្មវារីអគ្គិសនីនិងរ៉ែ (ជាពិសេសទង់ដែងនិងមាស) ។

ប្រទេសឡាវ មានផលិតផលក្នុងស្រុកសរុបជាង ១៨ ពាន់លានដុល្លារនៅក្នុងឆ្នាំ ២០១៩ និងផ្តល់ការងារបាន ៨០%[37]។ ប្រទេសឡាវមានដីតែ ៤% នៃផ្ទៃប្រទេសប៉ុណ្ណោះដែលជាដីដែលអាចដាំដំណាំបាននិងមានត្រឹមតែ ០.៣% ប៉ុណ្ណោះដែលត្រូវបានប្រើជាដីដំណាំអចិន្ត្រៃយ៍ (ភាគរយទាបបំផុតនៅក្នុងអនុតំបន់មេគង្គ) ផ្ទៃដីស្រោចស្រពមានផ្ទៃដីដាំដុះត្រឹមតែ ២៨% នៃផ្ទៃដីដាំដុះសរុបតែ ១២% នៃផ្ទៃដីកសិកម្មទាំងអស់ក្នុងឆ្នាំ

[36] Asia Pacific Parliamentary Forum. Government of Laos.
[37] ដកស្រង់ចេញពី data.worldbank.org, Laos gdp growth

២០១២។ ស្រូវមានឥទ្ធិពលលើកសិកម្មដែលមានប្រហែល ៨០% នៃផ្ទៃដីដែលអាចដាំដំណាំបានប្រើសម្រាប់ដាំដំណាំ ហើយប្រមាណជា ៧៧% នៃគ្រួសារកសិកម្មរបស់ឡាវគឺមានអង្ករគ្រប់គ្រាន់សំរាប់ខ្លួនឯង។ ប្រទេសឡាវអាចមានចំនួនពូជស្រូវច្រើនបំផុតនៅក្នុងមហាអនុតំបន់មេគង្គ។ រដ្ឋាភិបាលឡាវបាននិងកំពុងធ្វើការជាមួយវិទ្យាស្ថានស្រាវជ្រាវស្រូវអន្តរជាតិនៃប្រទេសហ្វីលីពីនដើម្បីប្រមូលសំណាកគ្រាប់ពូជនៃពូជស្រូវរាប់ពាន់ដែលត្រូវបានរកឃើញនៅក្នុងប្រទេសឡាវ។

### ២.៤.១.ការធ្វើពាណិជ្ជកម្មអន្តរជាតិរបស់កម្ពុជាជាមួយឡាវ

សេដ្ឋកិច្ចឡាវពឹងផ្អែកខ្លាំងទៅលើការវិនិយោគ និងពាណិជ្ជកម្មជាមួយប្រទេសជិតខាង ដែលធំជាងនិងមានជាង។ សេដ្ឋកិច្ចឡាវទទួលជំនួយពីមូលនិធិរូបិយប័ណ្ណអន្តរជាតិ និងប្រភពអន្តរជាតិដទៃទៀត និងពីការវិនិយោគទុនពីបរទេសក្នុងវិស័យកែច្នៃអាហារនិងរ៉ែ (ជាពិសេស ទង់ដែង និងមាស) ។ ចំណែកឯប្រទេសកម្ពុជាវិញក៏បានធ្វើពាណិជ្ជកម្មជាមួយនឹងប្រទេសឡាវផងដែរ តែការធ្វើពាណិជ្ជកម្មរវាងប្រទេសទាំងពីរនៅមានកម្រិតនៅឡើយ។ ដោយសារតែទំហំពាណិជ្ជកម្មនៅមានកម្រិត គឺនៅឆ្នាំ ២០១៨ ដើម្បីទាញយកអត្ថប្រយោជន៍ អតិបរមាពីការធ្វើសមាហរណកម្មក្នុងតំបន់ ខណៈដែលទំហំពាណិជ្ជកម្មទ្វេភាគីកម្ពុជា-ឡាវ នៅមានកម្រិតនៅឡើយ ភាគីទាំងពីរបានយល់ព្រមពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគីលើវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគទេសចរណ៍ អប់រំ សន្តិសុខតាមព្រំដែន និងវិស័យដទៃទៀត ដែលភាគីទាំងពីរធ្លាប់បានធ្វើកិច្ចសហប្រតិបត្តិការជាមួយគ្នា នាពេលកន្លងមកឱ្យកាន់តែប្រសើរឡើងបន្ថែមទៀត។ ក្នុងនោះកម្ពុជាក៏បានស្នើឱ្យភាគីឡាវ ជួយសម្រួលការធ្វើពាណិជ្ជកម្ម និងវិនិយោគឆ្លងកាត់ព្រំដែន ព្រមទាំងបានជំរុញវិស័យឯកជនប្រទេសទាំងពីរ បង្កើនកិច្ចសហការទ្វេដង ដើម្បីទាញយកអត្ថប្រយោជន៍អតិបរមាពីការធ្វើសមាហរណកម្មក្នុងតំបន់ ខណៈដែលទំហំពាណិជ្ជកម្មទ្វេភាគីកម្ពុជា-ឡាវ នៅមានកម្រិតនៅឡើយ គឺបានកើនឡើងតិចតួច ពីទឹកប្រាក់ ២៥,៦២ លានដុល្លារ ក្នុងឆ្នាំ២០១៥ ដល់ ២៧,២៥លានដុល្លារ នៅឆ្នាំ២០១៧ [38]។

### ២.៤.២.ការនាំចូលទំនិញពីប្រទេសឡាវ

ប្រទេសឡាវ ជាប្រទេសដែលមានព្រំប្រទល់ជាប់នឹងប្រទេសកម្ពុជា ដូចថៃ និងវៀតណាមដែរ ក៏ប៉ុន្តែគេសង្កេតឃើញថា នៅក្នុងការធ្វើពាណិជ្ជកម្មរវាងប្រទេសទាំងពីរគឺមានទំហំតូចនៅឡើយបើប្រៀបធៀបជាមួយនឹងប្រទេសថៃ និងវៀតណាម។ មូលហេតុនេះក៏ដោយសារតែប្រទេសកម្ពុជា និងប្រទេសឡាវមានលក្ខណៈផលិតកម្មស្រដៀងគ្នា និងផលិតនូវផលិតផលដូចគ្នាភាគច្រើន ដែលជាហេតុបណ្តាលអោយប្រទេសទាំងពីរមិនសូវមាននូវសកម្មភាពពាណិជ្ជកម្មជាមួយគ្នា។ បើទោះបីជាយ៉ាងណាក៏ដោយ ក៏ប្រទេសកម្ពុជាបាននាំចូលទំនិញមួយចំនួនពីប្រទេសឡាវផងដែរ សម្រាប់បំពេញតម្រូវការក្នុងស្រុក។

[38] អត្ថបទរបស់ ជុំ ជោគជាតា បោះផ្សាយថ្ងៃ ៦ ធ្នូ 2018 ស្តីពី កម្ពុជា-ឡាវ ពង្រីកបន្ថែមការធ្វើពាណិជ្ជកម្មជាមួយគ្នា

តារាងទី២.៦ ៖ទិន្នន័យនៃការនាំចូលទំនិញពីប្រទេសឡាវពីឆ្នាំ ២០១៧ ដល់ ២០១៩

| | 2017 | 2018 | 2019 |
|---|---|---|---|
| Product Group | Import (US$ Thousand) | | |
| Capital goods | 12.61 | 1.71 | 1109.94 |
| Consumer goods | 1640.36 | 1248.59 | 2062.07 |
| Intermediate goods | 2511.33 | 190.99 | 4036.07 |
| Raw materials | 309.11 | 238.46 | 380.51 |
| Chemicals | 345.09 | 206.01 | 1684.45 |
| Food Products | 286.23 | 258.32 | 447.3 |
| Footwear | 0 | 0 | 0.2 |
| Fuels | 0 | 0 | 2364.55 |
| Mach and Elec | 15.89 | 1.71 | 2.32 |
| Minerals | 0 | 116.58 | 250.97 |
| Miscellaneous | 20.59 | 14.69 | 7.57 |
| Plastic or Rubber | 6.77 | 0 | 7.11 |
| Textiles and Clothing | 0 | 0.53 | 0.42 |
| Transportation | 2340.84 | 0 | 1107.55 |
| Vegetable | 1329.6 | 1096.59 | 1718.67 |
| Wood | 0 | 0 | 3.72 |
| Metal | 149 | 0 | 0 |

ប្រភព ៖ (Worldbank)

តាមរយៈទិន្នន័យដែលបានបង្ហាញខាងលើ គេសង្កេតឃើញថានៅឆ្នាំ ២០១៩ ប្រទេសកម្ពុជានាំចូលទំនិញសរុបពីប្រទេសឡាវប្រមាណ ១៥,១៨៣,៤២០ ដុល្លារ ដែលក្នុងនោះប្រទេសកម្ពុជានាំចូលនូវទំនិញពាក់កណ្តាលសម្រេចច្រើនជាងគេដែលមានរហូតទៅដល់ ២៦.៥៨% និងនាំចូលនូវប្រេងឥន្ធនៈរហូតដល់ ១៥.៥៧% និងទំនិញប្រើប្រាស់ចំនួន ១៣.៥៨%។ ចំណែកឯនៅឆ្នាំ ២០១៨ ការនាំចូលនូវទំនិញប្រើប្រាស់មានទំហំទឹកប្រាក់ច្រើនជាងគេ គឺប្រមាណ ១,២៤៨,៥៩០ ដុល្លារ ស្មើនឹង ៣៧% នៃទំនិញនាំចូលសរុប និង វាយនភណ្ឌត្រូវបាននាំចូលតិចជាង ដោយសារប្រទេសកម្ពុជាកំពុងតែរីកច្រើននឹងវិស័យនេះ ដែលជាហេតុធ្វើ អោយមានការនាំចូលតិចតួច។ ដោយឡែកនៅឆ្នាំ ២០១៧ វិញប្រទេសកម្ពុជានាំចូលនូវទំនិញពាក់កណ្តាលសម្រេចច្រើនជាងគេ ប្រមាណ ២៨% នៃទំនិញនាំចូលសរុប និងបន្ទាប់មកគឺមធ្យោបាយដឹកជញ្ជូនដែលមានទំហំប្រមាណ ២៦.១០% ហើយទំនិញដែលនាំចូលតិចជាងគេគឺផលិតផលប្លាស្ទិក និងកៅស៊ូ ដែលមានត្រឹមចំនួន ០.០៧៥% ប៉ុណ្ណោះ។

### ២.៤.៣.ការនាំចេញទំនិញទៅប្រទេសឡាវ

ការនាំចេញទំនិញទៅប្រទេសឡាវ ក៏ដូចជាការនាំចូលដែរគឺមិនសូវមានទំហំទឹកប្រាក់ច្រើនទេ ពោលគឺមានតិចតួចជាងការនាំចូលទៅទៀត។ នៅឆ្នាំ ២០១៧ ប្រទេសកម្ពុជាបាននាំចេញមុខទំនិញធំៗទៅប្រទេសឡាវចំនួន ១២ មុខសំខាន់ៗ ប៉ុន្តែនៅឆ្នាំ ២០១៨ និង ២០១៩ ការនាំចេញធ្លាក់សល់ត្រឹម ១១ មុខ។

តារាងទី២.៧៖មុខទំនិញនិងទំហំទឹកប្រាក់ក្នុងការនាំចេញរបស់កម្ពុជាទៅប្រទេសឡាវពីឆ្នាំ២០១៧ដល់ ២០១៩

| | 2017 | 2018 | 2019 |
|---|---|---|---|
| Product Group | Export (US$ Thousand) | | |
| Capital goods | 1602.29 | 1562.6 | 1203.84 |
| Consumer goods | 3857.83 | 5124.57 | 425.65 |
| Intermediate goods | 165.25 | 657.27 | 812.95 |
| Animal | 143.49 | 412.87 | 49.99 |
| Chemicals | 722.76 | 305.67 | 11.22 |
| Food Products | 368.41 | 459.94 | 269.02 |
| Mach and Elec | 1.19 | 657.27 | 353.05 |
| Metals | 165.51 | 56.84 | 780 |
| Miscellaneous | 109.63 | 1.28 | 21.02 |
| Textiles and Clothing | 222.64 | 18.44 | 74.4 |
| Transportation | 4189.09 | 5457.84 | 904.78 |
| wood | 1.69 | 0 | 0 |

ប្រភព ៖ (Worldbank)

ការនាំចេញទៅប្រទេសឡាវគេសង្កេតឃើញថាមានធ្លាក់ចុះយ៉ាងខ្លាំងនៅឆ្នាំ ២០១៩ ពោលគឺធ្លាក់ចុះស្ទើរតែគ្រប់មុខទំនិញ។ នៅឆ្នាំ ២០១៩ ការនាំចេញនូវ Capital goods បានធ្លាក់ចុះដល់ ១,២០៣,៨៤០ដុល្លារ គឺធ្លាក់ចុះប្រមាណ ២៤.៨៦% ធៀបនឹងឆ្នាំ ២០១៧។ ចំណែកឯទំនិញប្រើប្រាស់នៅឆ្នាំ ២០១៩ វិញធ្លាក់ចុះប្រមាណ ៨៨.៨៩% ធៀបនឹងឆ្នាំ ២០១៧ និងធ្លាក់ចុះ ៩១.៦៩% ធៀបនឹងឆ្នាំ ២០១៨ និងទំនិញជាច្រើនទៀតសុទ្ធតែមានការធ្លាក់ចុះ។ ទោះបីជាយ៉ាងណាការធ្វើពាណិជ្ជកម្មរវាងប្រទេសទាំងពីរ ត្រូវបានគេប៉ាន់ប្រមាណថានឹងកើនឡើង ដោយសារតែកម្ពុជា និងឡាវ បានសន្យានឹងជំរុញទំនាក់ទំនងពាណិជ្ជកម្មទ្វេភាគីឱ្យមានទំហំកាន់តែធំបន្ថែមទៀត ខណៈកាលពីឆ្នាំ ២០២០ ទំហំពាណិជ្ជកម្មរវាងប្រទេសទាំង ២ បានកើនឡើងប្រមាណ ៩៤០ ភាគរយ។ ( សេចក្តីប្រកាសព័ត៌មាននៃជំនួបសន្ទនារវាងប្រមុខរាជរដ្ឋាភិបាលកម្ពុជា និងឡាវ ថ្ងៃ ១២ មេសា ២០២១ )

## ២.៥.ច្រកពាណិជ្ជកម្មសំខាន់ៗ

ប្រទេសកម្ពុជាមានច្រករបៀងសំខាន់ៗពីរ ដែលកំពុងបម្រើការធ្វើចរាចរណ៍ គឺច្រកពីខាងកើតដល់ខាងលិច កាត់ប្រទេសកម្ពុជា ថៃឡង់ដ៏ និងវៀតណាម តាមរយៈផ្លូវជាតិលេខ ១ ៥ ៦ និង៧។ ឯរបៀងសេដ្ឋកិច្ចជើង-

ត្បូង ភ្ជាប់ប្រទេសឡាវ ជាមួយឈូងសមុទ្រថៃ និងវៀតណាម តាមរយៈផ្លូវជាតិលេខ ៧ ៣ ៤ និង២។ [39]

**២.៥.១.ច្រកបាវិត**

ខេត្តស្វាយរៀងជាខេត្តមួយក្នុងចំណោមខេត្តតូចបំផុតរបស់ប្រទេសកម្ពុជា ប៉ុន្តែមានផ្លូវជាតិដែលពេញទៅដោយចរាចរណ៍មមាញឹកបំផុតកាត់តាមទីប្រជុំជន។ ផ្លូវជាតិលេខ១ភ្ជាប់ពីភ្នំពេញទៅទីក្រុងហូជីមិញរបស់ប្រទេសវៀតណាមបន្ទាប់ពីឆ្លងទន្លេមេគង្គតាមរយៈស្រឡាងអ្នកលឿង។ ទីនេះជាច្រកចូលអន្តរជាតិតាមច្រកបាវិតទៅកាន់ប្រទេសវៀតណាម។ វាជាក្រុងមួយដ៏រីកចម្រើនដែលបានទទួលផលពីចរាចរណ៍ពាណិជ្ជកម្មតាមព្រំដែន។ ទីនោះមានទីផ្សារដ៏មមាញឹក ហើយប្រជាជនមានភាពរស់រាយរាក់ទាក់។ នៅជិតទន្លេវ៉ៃកូ ក៏មានវាលភក់ដ៏ធំនិងមានទេសភាពស្អាតផ្តល់ជាបរិយាកាសយ៉ាងល្អសម្រាប់ការថតរូប។ នៅមិនឆ្ងាយប៉ុន្មានពីទីក្រុង មានស្ពានមួយឆ្លងទន្លេវ៉ៃកូដែលផ្តល់ជូនជាចំណងដៃពី សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន។ ភាពស្រស់ស្អាតនៃខេត្តនេះមិនមែនដោយសារតែភាពងាយស្រួលរបស់ខេត្តនេះប៉ុណ្ណោះទេប៉ុន្តែ ក៏មានធម្មជាតិ និងតំបន់បឹងព្រៃបាសាក់នៅក្រៅក្រុង និងប្រាសាទដែលគួរឈប់សម្រាកដើម្បីទស្សនាផងដែរ។ ខេត្តស្វាយរៀងមិនស្ថិតនៅក្នុងផែនទីទេសចរណ៍ទេ ប៉ុន្តែពិសេសបំផុតសម្រាប់អ្នកដែលចង់នៅស្គាល់ជីវិតជនបទនៃប្រទេសកម្ពុជា។ ក្រុងស្វាយរៀងស្ថិតនៅក្នុងខេត្តស្វាយរៀង ដែលមានព្រំប្រទល់ ខាងជើងទល់នឹងស្រុករំដួល និងស្រុកស្វាយជ្រុំ ខាងត្បូងទល់នឹងស្រុកកំពង់រោទិ៍ និងស្រុកស្វាយជ្រុំ ខាងកើតទល់នឹងស្រុកស្វាយជ្រុំ ខាងលិចទល់នឹងស្រុកស្វាយទាប។ ហើយក្រុងស្វាយរៀងមានក្រឡាផ្ទៃដីសរុប ៨២,៧៤គម$^{២}$ ដែលមាន ០៧ សង្កាត់ រួមមាន សង្កាត់ស្វាយរៀង សង្កាត់ចេក សង្កាត់គយត្របែក សង្កាត់សង្ឃ័រ សង្កាត់ស្វាយតឿ សង្កាត់ព្រៃឆ្លាក់ និងសង្កាត់ពោធិ៍តាហោ។ ចំណែកឯមានប្រជាជនមានចំនួន ៤៦.៨២២ នាក់ ត្រូវជា ១០.៤២៤ គ្រួសារ។ ប្រជាជនភាគច្រើនប្រកបរបរជាកសិកម្ម ៣៩,០៨% សិប្បកម្ម ១,៣៧% សេវាកម្ម ១០,៤៣% ជាមន្ត្រីរាជការ និងបុគ្គលិកឯកជន ២៤,៨% និងមុខរបរបន្ទាប់បន្សំផ្សេងៗ ១៦,៣៥%។[40]

ច្រកទ្វារព្រំដែនបាវិតស្ថិតនៅចម្ងាយប្រមាណ ៤៨ គីឡូម៉ែត្រពីទីរួមខេត្តស្វាយរៀង និងបើកជារៀងរាល់ថ្ងៃចាប់ពីម៉ោង ៧ ព្រឹកដល់ ៦ ល្ងាចដើម្បីអាចអោយប្រជាជនអាចឆ្លងកាត់ និងទិញទំនិញបាន។ ទំនិញហាមឃាត់ ឬដាក់កម្រិតដែលមិនអនុញ្ញាតអោយដឹកចេញនោះ គឺផលិតផលរបស់ប្រទេសទីបី (ភាគច្រើនគឺថៃនិងម៉ាឡេស៊ី)។ ការធ្វើពាណិជ្ជកម្មឆ្លងកាត់ច្រកព្រំដែនបាវិតភាគច្រើនមកពីខាងវៀតណាម ហើយការនាំចេញរបស់កម្ពុជាមានតិចតួច និងជាទូទៅត្រូវបានអនុវត្តក្នុងទ្រង់ទ្រាយតូច។ មុខទំនិញសំខាន់ៗដែលត្រូវបានជួញដូរឆ្លងកាត់ក្រុងបាវិត គឺមានដូចជា ប្លាស្ទិក ក្រណាត់ ដែក សារធាតុគីមីសម្រាប់បន្សុទ្ធទឹក ចំណីសត្វ បន្លែស្រស់ ទៀន

[39] ដកស្រង់ចេញពីគេហទំព័រ http://serd-cam.adb.org/, 2011-2013

[40]ដកស្រង់ចេញពីគេហទំព័រ visitcambodia.travel

ស្បែកជើង និងសៀវភៅ។ កិច្ចព្រមព្រៀងព្រំដែនរវាងប្រទេសទាំងពីរ បានអនុញ្ញាតឱ្យអ្នករស់នៅតាមព្រំដែនអាចផ្លាស់ទីឆ្លងកាត់ព្រំដែនដោយសេរីដោយប្រើអត្តសញ្ញាណប័ណ្ណពិសេស។ នៅតាមច្រកព្រំដែនភាគច្រើនគឺជាភ្ញៀវទេសចរ អ្នកទៅពិនិត្យជំងឺ អ្នកទិញទំនិញសម្រាប់ប្រើប្រាស់ និងអាជីវករជាដើម។ មិនតែប៉ុណ្ណោះប្រជាជនវៀតណាមក៏ឆ្លងកាត់មកប្រទេសកម្ពុជាដើម្បីចូលរួមក្នុងសកម្មភាពពាណិជ្ជកម្មនានា និងបំពេញការងារកសិកម្មផងដែរ។

ភាគីខាងកម្ពុជា និងវៀតណាមក៏បានឯកភាពគ្នាបង្កើតក្រុមការងារចំពោះកិច្ចលើវិស័យដឹកជញ្ជូនផ្លូវគោក ដើម្បីដោះស្រាយបញ្ហាឲ្យបានទាន់ពេលវេលា នៅច្រកទ្វារព្រំដែនបាវិត-ម៉ុកបៃ (កម្ពុជា-វៀតណាម)។ ក្រុមការងារចំពោះកិច្ចរបស់ប្រទេសទាំងពីរ ត្រូវជួបប្រជុំពិភាក្សាជាទៀងទាត់ និងធ្វើរបាយការណ៍ប្រចាំខែ ជូននាយករដ្ឋមន្រ្តីរបស់ខ្លួនរៀងៗខ្លួនផងដែរ។ ការបង្កើតក្រុមការងារនេះ គឺដើម្បីពិភាក្សាលើបញ្ហាប្រឈម និងដំណោះស្រាយទាក់ទងនឹងការកកស្ទះចរាចរណ៍ នៅច្រកទ្វារព្រំដែនសំដៅឱ្យធ្វើពាណិជ្ជកម្ម ឆ្លងកាត់ព្រំដែន រវាងប្រទេសទាំងពីរកាន់តែមានភាពប្រសើរឡើង និងទំហំពាណិជ្ជកម្មកាន់តែកើនឡើង។ ( ក្រសួងសាធារណការ និងដឹកជញ្ជូន, 2020 )

**២.៥.២.ច្រកប៉ោយប៉ែត**

ខេត្តបន្ទាយមានជ័យ ជាខេត្តមួយនៃព្រះរាជាណាចក្រកម្ពុជាស្ថិតនៅចុងពាយ័ព្យដែលមានសេដ្ឋកិច្ចយ៉ាងសំខាន់មួយរបស់ប្រទេស។ មានព្រំប្រទល់ខាងកើត ជាប់ខេត្តឧត្តរមានជ័យ និង សៀមរាប ខាងត្បូងជាប់ខេត្តបាត់ដំបង និងមានព្រំដែនរួមអន្តរជាតិជាមួយថៃនៅខាងលិច។ ទីរួមខេត្ត និងទីក្រុងធំបង្អស់គឺក្រុងសិរីសោភ័ណ ហើយបន្ទាយមានជ័យ គឺជាខេត្តធំបង្អស់ទី១៣ នៃព្រះរាជាណាចក្រកម្ពុជា ដោយមានប្រជាជន ៦៧៨,០៣៣ នាក់ វាជាប់លេខជាខេត្តធំទី ១០ ប្រចាំប្រទេស[41]។ បន្ទាយមានជ័យ គឺជាខេត្តមួយក្នុងចំណោមខេត្តទាំងប្រាំបួនដែលជាប៉ែកភាគនៃដែនជំរកជីវមណ្ឌលទន្លេសាប។ ក្រុងប៉ោយប៉ែតនៅប៉ែកខាងលិចនៃខេត្ត គឺជាព្រំដែនអន្តរជាតិឆ្លងចូលទៅប្រទេសថៃ។ ប៉ោយប៉ែតមានទីតាំងនៅក្នុងស្រុកអូរជ្រៅ និងមានប្រជាជនច្រើនជាងជាង ១០០,០០០នាក់។ ច្រកទ្វារអន្តរជាតិប៉ោយប៉ែតមានទីតាំងនៅភូមិក្បាលស្ពានឃុំប៉ោយប៉ែតស្រុកអូរជ្រៅចម្ងាយ ៥០ គីឡូម៉ែត្រពីទីរួមខេត្តបន្ទាយមានជ័យ ហើយចំណុចព្រំដែនបានដំណើរការតាំងពីឆ្នាំ ១៩៩១ ប៉ុន្តែបានក្លាយជាផ្លូវការបន្ថែមទៀតតែនៅក្នុងឆ្នាំ ១៩៩៣ ជាមួយនឹងការបើកការិយាល័យគយនៅទីនោះ។ នៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៤ ប៉ោយប៉ែតដែលជាច្រកឆ្លងកាត់ត្រូវបានប្រកាសជាផ្លូវការថាជាច្រកទ្វារអន្តរជាតិ

[41]ដកស្រង់ចេញពី https://km.wikipedia.org/, ខេត្តបន្ទាយមានជ័យ

ប៉ោយប៉ែត។ ចាប់តាំងពីឆ្នាំ ១៩៩៨ មកសកម្មភាពឆ្លងកាត់ព្រំដែនបានពង្រីកយ៉ាងឆាប់រហ័ស ហើយប៉ុស្តិ៍ត្រួតពិនិត្យបើកជារៀងរាល់ថ្ងៃចាប់ពីម៉ោង ៧ ព្រឹកដល់ ៨ យប់សម្រាប់ប្រជាជនឆ្លងកាត់ និងទំនិញ។ ប្រជាជនក្នុងតំបន់អាចធ្វើដំណើរចេញចូលបានដោយទិញច្រកព្រំដែនក្នុងតម្លៃ ១០បាត/ម្នាក់ ដើម្បីធ្វើដំណើរទៅកាន់ផ្សាររ៉ុងក្លឿក្នុងទឹកដីថៃ ហើយភាគច្រើនជាកម្មករ និងពាណិជ្ជករ។

ច្រកទ្វារប៉ោយប៉ែតមានសារៈសំខាន់ណាស់សម្រាប់ប្រទេសកម្ពុជា។ ទំនិញសំខាន់ៗដែលបាននាំចូលរួមមានស៊ីម៉ងត៍ សម្ភារសំណង់ ឧបករណ៍កែច្នៃ ចំណីអាហារ គ្រឿងសំអាង ទំនិញប្រើប្រាស់ រថយន្ត និងជី។ គេសង្កេតឃើញថា សំភារៈសំណង់ និងស៊ីម៉ងត៍មានការកើនឡើងយ៉ាងឆាប់រហ័ស ខណៈដែលការនាំចូលផ្សេងទៀតបានកើនឡើងតិចតួច ហើយទំនិញសំខាន់ៗដែលនាំចេញទៅថៃ មាន ដែក អេតចាយ សម្លៀកបំពាក់ជជុះ សិប្បកម្ម និងត្រីកែច្នៃ។

### ២.៥.៣.ច្រកត្រពាំងគ្រៀល

ប្រទេសកម្ពុជា និងឡាវមានច្រកអន្តរជាតិរួមគ្នាតែមួយប៉ុណ្ណោះ គឺខេត្តស្ទឹងត្រែង ដែលមានព្រំប្រទល់ជាប់ទឹកដីខេត្តអាត់តាពើរបស់ប្រទេសឡាវ។ ខេត្តស្ទឹងត្រែង គឺជាខេត្តមួយនៅចុងខាងជើងនៃប្រទេសកម្ពុជា ឈ្មោះដើមហៅថា សៀងតេង។ ទីក្រុងរបស់ខេត្តស្ទឹងត្រែង មានឈ្មោះថា ទីក្រុងស្ទឹងត្រែង។ ខេត្តស្ទឹងត្រែងមានព្រំប្រទល់ខាងជើងទល់នឹង ព្រំប្រទល់ កម្ពុជា-ឡាវ។ ខាងត្បូងទល់នឹងស្រុកសៀមបូក និងស្រុកសេសាន។ ខាងកើតទល់នឹង ស្រុកសេសាន។ ឯខាងលិចទល់នឹងស្រុកថាឡាបរីវ៉ាត់ និងស្រុកសៀមបូក។ ក្រុងស្ទឹងត្រែងមានផ្ទៃក្រឡា ៦៩០ គ.ម$^២$ និងមានចំនួន ០៤ សង្កាត់ គឺសង្កាត់ស្ទឹងត្រែង សង្កាត់ស្រះឬស្សី សង្កាត់ព្រះបាទ និងសង្កាត់សាមគ្គី។[42]

ក្នុងចំណោមប្រទេសជិតខាងទាំងបីរបស់កម្ពុជា ប្រទេសឡាវ គឺជាអ្នកជិតខាងដែលមានទំនាក់ទំនងសេដ្ឋកិច្ចជាមួយកម្ពុជាតិចជាងគេ។ ទោះជាមានតិចតួចក្តី ក៏ចំណងសេដ្ឋកិច្ចនៃប្រទេសទាំងពីរត្រូវបានតភ្ជាប់តាមរយៈសកម្មភាពសេដ្ឋកិច្ចមួយចំនួន ដូចជាការដោះដូរពាណិជ្ជកម្ម និងលំហូរទេសចរណ៍។ តើទំនាក់ទំនងសេដ្ឋកិច្ចរវាងកម្ពុជា និងប្រទេសជិតខាងដែលស្ថិតនៅភាគខាងជើងមួយនេះមានលក្ខណៈគួរឲ្យ កត់សម្គាល់អ្វីខ្លះ? ដោយសារ ឡាវមិនមានផ្លូវ សមុទ្រ បម្រើឲ្យការដឹកជញ្ជូនទំនិញ ប្រទេសនេះកំពុងព្យាយាមអភិវឌ្ឍន៍វិស័យហេដ្ឋារចនាសម្ព័ន្ធ ដើម្បីភ្ជាប់ខ្លួននឹងសកម្មភាពពាណិជ្ជកម្មក្នុងតំបន់តាមរយៈការភ្ជាប់ខ្លួនជាមួយប្រទេសជិតខាង។ យ៉ាងណាក៏ដោយទំនាក់ទំនងក្នុងវិស័យសេដ្ឋកិច្ចរវាងឡាវ ជាមួយកម្ពុជាមិនមានភាពខ្លាំងក្លាដូចទំនាក់ទំនងរវាងឡាវ និងវៀតណាមនោះទេ។ ទំនាក់ទំនងសេដ្ឋកិច្ចរវាង កម្ពុជា និងឡាវកើតឡើងទាំងក្នុងក្របខ័ណ្ឌ

[42] ដកស្រង់ចេញពី https://visitcambodia.travel/ ខេត្តស្ទឹងត្រែង

ទ្វេភាគី ក្របខ័ណ្ឌត្រីភាគី ស៊ី.អិល.វី (CLV) រួមមាន កម្ពុជា ឡាវ និង វៀតណាម ក្របខ័ណ្ឌ ស៊ី.អិល.អឹម.វី (CLMV) កម្ពុជា ឡាវ មីយ៉ាន់ម៉ា និង វៀតណាម និង ក្របខ័ណ្ឌប្រទេសមហាអនុតំបន់ទន្លេមេគង្គ ដែល រួមមាន កម្ពុជា ឡាវ មីយ៉ាន់ម៉ា វៀតណាម ថៃ និង ចិន ដោយសារកម្ពុជា និងឡាវរក្សាបានកំណើនសេដ្ឋកិច្ច ខ្ពស់ធៀប នឹងប្រទេសដទៃក្នុងតំបន់ប្រទេសទាំងពីរនេះ បានក្លាយជាទីតាំងទាក់ទាញបំផុតសម្រាប់ វិនិយោគិន ទាំងវិនិយោគិន ពីប្រទេសសមាជិកអាស៊ានដូចគ្នា ទាំងវិនិយោគិនពីប្រទេសក្រៅតំបន់។ ប្រទេសកម្ពុជា និងឡាវត្រូវបានប្រទេសមហាអំណាច ដូចជាសហរដ្ឋអាមេរិក ចិន ឥណ្ឌា ជប៉ុន ចាត់ ទុកជាមូលដ្ឋានសម្រាប់ការពង្រីកឥទ្ធិពលរៀងៗខ្លួន។ ជាក់ស្តែងវត្តមានមហាអំណាចឥណ្ឌាក្នុងការបង្កើន សកម្មភាពក្នុងតំបន់នេះផ្អែកលើគោលនយោបាយ «ឆ្ពោះ មក ទិស ខាង កើត» របស់ខ្លួនជាឧទាហរណ៍ស្រាប់។ ខណៈប្រទេសកម្ពុជា និងឡាវសុទ្ធសឹងតែជាប្រទេសទន់ខ្សោយក្នុងវិស័យឧស្សាហកម្ម សកម្មភាពពាណិជ្ជកម្ម ទ្វេភាគីក៏ស្ថិតក្នុងបរិមាណតិចតួចនៅឡើយ។

ទោះបីជារដ្ឋាភិបាលប្រទេសសមាជិកអាស៊ានទាំងពីរនេះបានចុះ កិច្ចព្រមព្រៀងសហប្រតិបត្តិការលើវិស័យពាណិជ្ជកម្មតាំងពីឆ្នាំ១៩៩៨ មកក្តីក៏ការអនុវត្តតាមកិច្ចព្រមព្រៀង ហាក់ដូចជាមិនសូវទទួលបានប្រសិទ្ធភាពឡើយ។ ជាក់ស្តែងពាណិជ្ជកម្មទ្វេភាគី កាលពីឆ្នាំ២០១០ ស្ថិតក្នុង ទំហំទឹកប្រាក់ប្រមាណ ១០លានដុល្លារប៉ុណ្ណោះ។ ភាគីទាំងពីររំពឹងថានឹងជំរុញឲ្យទំហំពាណិជ្ជកម្មនេះ កើនដល់ ២០លានដុល្លារ នៅឆ្នាំ ២០១៥ ក្នុងការជំរុញលំហូរពាណិជ្ជកម្មរវាង កម្ពុជា និងឡាវរដ្ឋាភិបាលទាំងពីរបាន ចុះអនុស្សរណៈយោគយល់គ្នាបង្កើតគណៈកម្មាធិការពាណិជ្ជកម្ម រួមមានកម្ពុជា-ឡាវ កាលពីខែមេសា ឆ្នាំ ២០១៣[43]។ សកម្មភាពពាណិជ្ជកម្ម រវាងប្រទេសឡាវ និងប្រទេសសមាជិកអាស៊ានដទៃ ភាគច្រើនធ្វើឡើង ជាមួយប្រទេស ថៃ និងវៀតណាម។ សកម្មភាពទាំងនោះមាន ទាំងក្នុងរូបភាពនៃការនាំចេញ នាំចូលការវិនិយោគ និងលំហូរទេសចរណ៍។ ប៉ុន្តែរវាងកម្ពុជា និងឡាវលំហូរវិនិយោគរវាងប្រទេសទាំងពីរហាក់ដូចជាមិនមាន សកម្មភាពអ្វីសោះឡើយ។ ប្រទេសទាំងពីរសុទ្ធសឹងតែជាប្រទេសដែលបានទទួលគម្រោងវិនិយោគពីប្រទេសដទៃ។ ចំពោះលំហូរទេសចរណ៍វិញតួលេខបានពីក្រសួងទេសចរណ៍ កម្ពុជាបង្ហាញថាចំនួនភ្ញៀវទេសចរ ជនជាតិឡាវមក កម្ពុជាកើនឡើងជាលំដាប់។ ចំនួនភ្ញៀវ ជនជាតិឡាវ កើនពីជាង ៤១ម៉ឺននាក់ នៅឆ្នាំ ២០១៣ ដល់ជាង ៤៦ម៉ឺន នាក់ នៅឆ្នាំ ២០១៤ ក្នុងអត្រាកំណើន ១១ ភាគរយ[44]។ បន្ទាប់ពីទេសចរ ជនជាតិវៀតណាម និងចិន គឺទេសចរ ជនជាតិឡាវនេះហើយ ដែលមកទស្សនាកម្ពុជាច្រើនជាងគេ។ តួលេខពីក្រសួងព័ត៌មាន វប្បធម៌ និងទេសចរណ៍ នៃប្រទេសឡាវវិញ បង្ហាញថា នៅចន្លោះឆ្នាំ ២០១៣ និងឆ្នាំ ២០១៤ ភ្ញៀវទេសចរកម្ពុជា ទៅប្រទេសឡាវមាន កំណើនជិត ២៦% (២៥,៩៦%) ពោលគឺ

[43] ដកស្រង់ចេញពី https://www.postkhmer.com/

[44]ដកស្រង់ចេញពី https://opendevelopmentcambodia.net

កើនពីប្រមាណ ១ម៉ឺន២ពាន់នាក់ ក្នុងឆ្នាំ ២០១៣ ដល់ជាង ១ម៉ឺន ៥ ពាន់នាក់ ក្នុងឆ្នាំ ២០១៤។ យ៉ាងណាក៏ដោយតួលេខភ្ញៀវទេសចរពីកម្ពុជា ទៅប្រទេសឡាវស្ថិតក្នុងចំនួនតិចតួចនៅឡើយ។ វិស័យទេសចរណ៍ គឺជាវិស័យចម្បងមួយសម្រាប់ប្រទេសទាំងពីរ ដោយរួមចំណែកជាង ១០ ភាគរយ ដល់ផលិតផលក្នុងស្រុកសរុប។ កិច្ចសហប្រតិបត្តិការ ក្នុងការជំរុញកំណើន ក្នុងវិស័យនេះធ្វើឡើង តាមរយៈ យុទ្ធនាការ «ប្រទេសបី គោលដៅតែមួយ» របស់ប្រទេសកម្ពុជា ឡាវ និងវៀតណាម បូករួមនឹងក្របខ័ណ្ឌ ប្រទេសស៊ី.អិល.អឹម.វី (CLMV) ដែលរួមមាន កម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម និងក្របខ័ណ្ឌប្រទេសមហាអនុតំបន់ទន្លេមេគង្គជាដើម។ ខណៈប្រទេសដែលជាសមាជិកនៃអាស៊ានទាំង ១០ប្រទេសបាននឹងកំពុងត្រៀមខ្លួនសម្រាប់សមាហរណកម្មសេដ្ឋកិច្ចនៅចុងឆ្នាំ ២០១៥ ដែលកម្ពុជា និងឡាវត្រូវបានអ្នកសិក្សាស្រាវជ្រាវមើលឃើញថាជាប្រទេសដែលអាចនឹងចាញ់ប្រៀបប្រទេសដទៃទៀតក្នុងអាស៊ាន ដែលមានអំណាចសេដ្ឋកិច្ចខ្លាំងជាង ដោយសារភាពទន់ខ្សោយ ស្ទើរគ្រប់វិស័យ។ ទោះយ៉ាងណាក៏ដោយប្រទេសកូនពៅរបស់អាស៊ានទាំងពីរនេះក៏កំពុងព្យាយាមពង្រឹងសក្តានុពលសេដ្ឋកិច្ចរបស់ខ្លួនដើម្បីទាញយកប្រយោជន៍ ពីដំណើរការនៃសមាហរណកម្មនេះ ដែលក្នុងនោះប្រទេសទាំងពីរសុទ្ធតែមើលឃើញពីភាពចាំបាច់នៃការបន្តពង្រឹងទំនាក់ទំនងសេដ្ឋកិច្ចទ្វេភាគី។

## ២.៦.មធ្យោបាយនៃការដឹកជញ្ជូនក្នុងការធ្វើពាណិជ្ជកម្ម

អនុវិស័យគមនាគមន៍/ដឹកជញ្ជូនសំខាន់ៗ មានចំនួន ២ គឺផ្លូវគោក និងផ្លូវដែក។ កំពង់ផែ ទាំងទឹកសាប (ភ្នំពេញ) និងឆ្នេរសមុទ្រ (ក្រុងព្រះសីហនុ) ក៏ដូចនឹងអាកាសយានដ្ឋានអន្តរជាតិ ទាំងបី(រាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តសីហនុ) ក៏បំពេញតួនាទីសំខាន់នៅក្នុងសេដ្ឋកិច្ចផងដែរ។ តម្រូវការក្នុងស្រុក គឺមានផ្លូវប្រើប្រាស់ និងការភ្ជាប់ទំនាក់ទំនងជាមួយនឹងទីជនបទ។ ដោយឡែកតម្រូវការក្នុងតំបន់ គឺសម្របសម្រួលការភ្ជាប់ទំនាក់ទំនង និងពាណិជ្ជកម្ម នៅក្នុងក្របខ័ណ្ឌមហាអនុតំបន់ទន្លេមេគង្គ(GMS) និងជាមួយប្រទេសដែលជាសមាជិកអាស៊ាន។

ការដឹកជញ្ជូនប្រកបដោយប្រសទ្ធិភាព មានសារៈសំខាន់យ៉ាងខ្លាំងចំពោះការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមនៅក្នុងប្រទេសកម្ពុជា។ វិស័យទេសចរណ៍ពឹងផ្អែកលើការដឹកជញ្ជូនក្នុងស្រុកតាមផ្លូវគោក និងការធ្វើដំណើរអន្តរជាតិតាមផ្លូវអាកាស។ វិស័យសំណង់ពឹងផ្អែកលើកំពង់ផែផ្លូវទឹក និងការដឹកជញ្ជូនតាមផ្លូវគោកសម្រាប់វត្ថុធាតុដើម។ ចំណែកឯទីផ្សារនាំចេញឧស្សាហកម្ម(ជាពិសេស ផលិតផលកាត់ដេរ) និងកសិកម្មពឹងផ្អែកលើការដឹកជញ្ជូនតាមផ្លូវគោក និងផ្លូវទឹក។ ការមានមធ្យោបាយដឹកជញ្ជូនមិនគ្រប់គ្រាន់ និងសេវាដឹកជញ្ជូនដែលមានភាពយឺតយ៉ាវ និងចំណាយខ្ពស់ អាចធ្វើអោយស្ថានភាពពាណិជ្ជកម្មមានល្បឿនទាប។

### ២.៦.១.ប្រភេទនៃមធ្យោបាយដឹកជញ្ជូន

#### ក.ផ្លូវគោក

បណ្តាញផ្លូវថ្នល់នៅក្នុងប្រទេសកម្ពុជាមានជិត ៤០.០០០គីឡូម៉ែត្រ នៃផ្លូវដែលបានក្រាលកៅស៊ូ និងមិនទាន់បានរៀបចំដែលមានលើផ្លូវជាតិ និងអន្តរជាតិចម្ងាយជាង ៥.០០០ គីឡូម៉ែត្រ។ ផ្លូវខេត្តមានចម្ងាយ ៦.២០០ គីឡូម៉ែត្រ ហើយក្រសួងសាធារណការការងារនិងដឹកជញ្ជូន (MPWT) បានបង្កើតការថែរក្សាផ្លូវថ្នល់ នូវរាល់សកម្មភាពដែលដឹកនាំដោយភាគីពាក់ព័ន្ធ និងកម្មវិធីប្រតិបត្តិការដើម្បីការពារទ្រព្យសម្បត្តិផ្លូវរបស់ខ្លួន។ ការងារថែទាំ គឺត្រូវថែរក្សាតាមកាលកំណត់ ហើយការអភិវឌ្ឍបណ្តាញផ្លូវនៅកម្ពុជាគឺដោយផ្អែកលើការតភ្ជាប់មជ្ឈមណ្ឌលលូតលាស់ធំៗ នៅទូទាំងប្រទេសជាមួយប្រព័ន្ធបណ្តាញផ្លូវថ្នល់មូល។ ប្រទេសកម្ពុជាបានជ្រើសរើសតំបន់ចំនួន ៦ (ភ្នំពេញ ក្រុងព្រះសីហនុ ខេត្តបាត់ដំបង សៀមរាប ស្ទឹងត្រែង និងកំពង់ចាម) ជាមណ្ឌលសំខាន់សម្រាប់កំណើនសេដ្ឋកិច្ច។ ភ្នំពេញជារដ្ឋធានី និងជាមជ្ឈមណ្ឌលនៃបណ្តាញនេះហើយត្រូវបានភ្ជាប់តាមរយៈអ័ក្សផ្លូវសរសៃឈាម (NR 1 ដល់ NR 7)។

រូបភាពទី២.១ ៖ ទិដ្ឋភាពទូទៅនៃបណ្តាញផ្លូវនៅក្នុងប្រទេសកម្ពុជា




ប្រភព ៖ (ក្រសួងសាធារណការ និងដឹកជញ្ជូន ឆ្នាំ 2017)

បណ្តាញផ្លូវសរសៃឈាមធំៗរួមបញ្ចូលភាគខាងត្បូងនៃមហាអនុតំបន់ទន្លេមេគង្គ GMS ខាងត្បូងច្រករបៀងដែលជាច្រករបៀងអនុតំបន់ទន្លេមេគង្គ ( រួមទាំងច្រករបៀងភ្នំពេញ - ព្រះសីហនុ ) និងច្រករបៀងតាមឆ្នេរភាគខាងត្បូងនៃមហាអនុតំបន់មេគង្គ។ គួរឱ្យកត់សម្គាល់ផងដែរថា ការរីកចម្រើនត្រូវបានធ្វើឡើងនៅលើផ្លូវអាស៊ានបណ្តាញ ដែលមានគោលបំណងដើម្បីបង្កើតឱ្យមានប្រសិទ្ធិភាព និងការរួមបញ្ចូលការដឹកជញ្ជូនក្នុងតំបន់ប្រកបដោយសុវត្ថិភាព ហើយច្រករបៀងនានា ភ្ជាប់រាល់បណ្តារដ្ឋសមាជិកអាស៊ានទាំងអស់ទៅនឹងប្រទេសជិតខាងៗ។ ស្ពានអ្នកលឿងត្រូវបានសម្ពោធ និងដាក់ឱ្យដំណើរការចាប់តាំងពី ខែ មេសា ឆ្នាំ ២០១៥ ហើយផ្លូវក្រវ៉ាត់

ក្រុងដែលទើបសាងសង់ថ្មីនៅជុំវិញរាជធានីភ្នំពេញ ត្រូវបានគេរំពឹងថានឹងជួយសម្រួលដល់ឡានដឹកទំនិញដែលត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ផ្លូវក្នុងកំឡុងពេលថ្ងៃជាមួយយានជំនិះប្រភេទផ្សេងទៀត ហើយនឹងលែងមាននៅការកកស្ទះ ឬត្រូវវាងក្នុងការឆ្លងកាត់ភ្នំពេញដើម្បីដឹកចេញទៅតំបន់ផ្សេងទៀត ហើយវានឹងជួយកាត់បន្ថយចរាចរណ៍ទូទៅដែលកកស្ទះនៅភ្នំពេញ។[45]

**ខ.ផ្លូវដែក**

ប្រទេសកម្ពុជា មានបណ្តាញផ្លូវដែកសំខាន់ៗ ២ខ្សែ ដែលបណ្តាញផ្លូវភាគខាងជើងប្រវែង ៣៨៦គីឡូម៉ែត្រ ភ្ជាប់រាជធានីភ្នំពេញជាមួយនឹងទីក្រុងប៉ោយប៉ែតដែលជាប់ព្រំប្រទល់នឹងប្រទេសថៃ តាមរយៈខេត្តពោធិសាត់ និងខេត្តបាត់ដំបង និងបណ្តាញផ្លូវនៅភាគខាងត្បូងប្រវែង ២៦៦ គីឡូម៉ែត្រ តភ្ជាប់រាជធានីភ្នំពេញ ទៅខេត្តព្រះសីហនុ។ការប្រើប្រាស់ប្រព័ន្ធផ្លូវដែកបានកើនឡើងខ្ពស់ នៅឆ្នាំ១៩៧០ ប៉ុន្តែសង្គ្រាមស៊ីវិលដែលចេះតែបន្ត និងការមិនយកចិត្តទុកដាក់រាប់ទសវត្សរ៍ បានធ្វើអោយផ្លូវដែកស្ថិតក្នុងសភាពទ្រុឌទ្រោម។ ចំណែកឯសេវាផ្លូវដែកបានចាប់ផ្តើមសារជាថ្មីឡើងវិញ នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៨០ ប៉ុន្តែសេវាសម្រាប់អ្នកធ្វើដំណើរបានបញ្ចប់នៅត្រឹមឆ្នាំ ២០០៨។[46]

នៅឆ្នាំ២០០៦ គម្រោងស្តារផ្លូវដែកតម្លៃ ១៤៣លាន ដុល្លារអាមេរិក ត្រូវបានដាក់សម្ពោធដោយរាជរដ្ឋាភិបាលកម្ពុជា ជាមួយនឹងការគាំទ្រពីម្ចាស់ជំនួយក្រៅប្រទេសជាច្រើន។ គម្រោងខ្សែផ្លូវដែកភាគខាងត្បូងត្រូវបានបញ្ចប់រួចរាល់ និងបើកបម្រើសម្រាប់ប្រតិបត្តិការដឹកជញ្ជូន នៅខែសីហា ឆ្នាំ២០១៣[47]។ កាលពីដើមឆ្នាំ ២០១៦នេះ ខ្សែផ្លូវដែកភាគខាងត្បូងបានដាក់ឱ្យប្រើប្រាស់សម្រាប់ការដឹកជញ្ជូនប្រេងឥន្ធនៈ ធ្យូងថ្ម ស៊ីម៉ង់ត៍ និងកុងតឺន័រសម្រាប់ដឹកជញ្ជូនតាមកាប៉ាល់ ដោយឡែកសេវាសម្រាប់អ្នកដំណើរ ត្រូវបានប្រកាសឱ្យដំណើរការនៅក្នុងឆ្នាំតែមួយ។[48] នៅក្នុងខែមេសា ឆ្នាំ២០១៩ ប្រព័ន្ធផ្លូវដែកប្រទេសកម្ពុជា និងប្រទេសថៃ ត្រូវបានតភ្ជាប់គ្នាឡើងវិញនៅក្បែរក្រុងប៉ោយប៉ែត បន្ទាប់ពីពីបានកាត់ផ្តាច់គ្នាកាលពីក្នុងឆ្នាំ ១៩៧៤។ នាយករដ្ឋមន្ត្រីនៃប្រទេសទាំងពីរបានមានវត្តមាននៅក្នុងពិធីសម្ពោធ និងបានធ្វើដំណើរឆ្លងកាត់ព្រំប្រទល់តាមរយៈរថភ្លើងនោះជាមួយគ្នាផងដែរ។ [49] រដ្ឋាភិបាលនៃប្រទេសកម្ពុជា បានបង្ហាញចេតនាកសាងបណ្តាញផ្លូវដែកបន្ថែមទៀត ហើយប្រទេស

[45] ការសិក្សារបស់JICAស្តីពីការអភិវឌ្ឍបណ្តាញផ្លូវថ្នល់

[46] ម៉ូលី, "ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវដែក នៅកម្ពុជា: យុទ្ធសាស្ត្ររយៈពេលវែង." ឯកសារពិភាក្សារបស់វិទ្យាស្ថានអភិវឌ្ឍសេដ្ឋកិច្ច លេខ ១៥០. វិទ្យាស្ថានអភិវឌ្ឍសេដ្ឋកិច្ច ឆ្នាំ២០០៨

[47] ដកស្រង់ចេញពីកាសែតភ្នំពេញប៉ុស្តិ៍ "ផ្លូវដែកសម្រាប់ការនាំអង្ករចេញរួចរាល់" គីមសាយ, ៩ សីហា ២០១៥

[48] ដកស្រង់ចេញពីកាសែតGuardian"សេវារថភ្លើងកម្ពុជាពេញនិយមឡើងវិញចន្លោះផ្លូវពីភ្នំពេញ និងខេត្តព្រះសីហនុ" Peter Ford, 5 មិថុនា 2016

[49] ដកស្រង់ចេញពីកាសែតខ្មែរថាមស៍ "ប្រទេសកម្ពុជា និងប្រទេសថៃភ្ជាប់បណ្តាញផ្លូវដែកជាមួយគ្នា" ជា វណ្ណៈ, ២៣ មេសា ២០១៩

ថៃ ប្រទេសជប៉ុន និង ប្រទេសចិន បានបង្ហាញពីចំណាប់អារម្មណ៍ ក្នុងការធ្វើកិច្ចការលើគម្រោងទាំងនេះ សំដៅពង្រីកសេវាផ្លូវដែកឆ្លងកាត់តាមប្រទេសកម្ពុជា។[50]

រូបភាពទី ២.២ ៖ ស្ថានីយរថភ្លើងនៅកម្ពុជា



ប្រភព ៖ (Khmerpost, 2018)

**គ.ផ្លូវទឹក**

ប្រវែងផ្លូវទឹកនៃប្រទេសកម្ពុជា មានប្រមាណជា ១,៧៥០ គីឡូម៉ែត្រ ក្នុងនោះ ៨៥០គីឡូម៉ែត្រ អាចធ្វើចរាចរបាន នៅក្នុងរដូវប្រាំង។កំពង់ផែស្វយ័តក្រុងព្រះសីហនុ គឺជាផែអន្តរជាតិសមុទ្រទឹកជ្រៅ និងជាកំពង់ផែពាណិជ្ជកម្មតែមួយគត់របស់ប្រទេសកម្ពុជា។ កំពង់ផែនេះគ្របដណ្តប់នៅលើផ្ទៃដី ១២៥ ហិកតា។ អស់រយៈពេលប្រាំឆ្នាំ ពី២០១៤-២០១៨ ចំនួនកុងតឺន័រដែលផ្ទុកនៅកំពង់ផែនេះបានកើនឡើងជាមធ្យម ១១ % ក្នុងមួយឆ្នាំៗ។ [51]

នៅដើមឆ្នាំ ២០១៩នេះ កំពង់ផែមានជម្រៅ ១១ ម៉ែត្រ ហើយអាចផ្ទុកបាន ៤,៥៦០ កុងតឺន័រ យ៉ាងណាមិញកំពង់ផែននេះក៏មានផែនការដើម្បីបង្កើនចំនួនផ្ទុកកុងទីន័ររបស់ខ្លួនបន្ថែមទៀតផងដែរ។ មួយវិញទៀតការពង្រីកនេះនឹងផ្តល់នៅចំណតថ្មីមួយទៀត ដែលមានជម្រៅរហូតដល់ ១៤,៥ ម៉ែត្រជាមួយនឹងទំហំ៣៥០ ម៉ែត្រ ដែលអាចទទួលផ្ទុកកាប៉ាល់បានជាង ៩០% នៃកាប៉ាល់ទាំងឡាយនៅក្នុងតំបន់។ គម្រោងនេះនឹងបញ្ចប់នៅក្នុងឆ្នាំ ២០២៣។ គម្រោងនេះនឹងធ្វើអោយកំពង់ផែព្រះសីហនុ ក្លាយជាកំពង់ផែស្តង់ដារមធ្យមជាមួយនឹង

[50] ក្រសួងសាធារណការ និងដឹកជញ្ជូន, ទិដ្ឋភាពទូទៅនៃហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូននៅព្រះរាជាណាចក្រកម្ពុជា,បោះពុម្ពលើកទី៤ របាយការណ៍ប្រចាំឆ្នាំ២០១៣

[51] ដកស្រង់ចេញពី សមាគមអ្នកសាងសង់កម្ពុជា, ៧ មីនា ២០១៩ ប្រទេសជប៉ុននឹងផ្តល់កម្ចី ២០៩លានដុល្លារដើម្បីពង្រីកផែសមុទ្រទឹកជ្រៅក្រុងព្រះសីហនុ

សមត្ថភាពផ្ទុកច្រើនជាង ១,២៩ លាន TEUs ក្នុងមួយឆ្នាំ។ (នៅចុងឆ្នាំ ២០១៨ សមត្ថភាពផ្ទុកមានទំហំ ៥៣៧,១០៧TEUs)។[52]

នៅក្នុងឆ្នាំ ២០១៨ ទំហំផ្ទុកសរុបនៃកំពង់ផែព្រះសីហុបានកើនឡើង រហូតដល់ ៥,១ លានតោន ស្មើនឹងកំណើន ១៨ % ដែលក្នុងនោះ ៣,៨ លានតោនជាទំហំទំនិញនាំចេញ ហើយ ១,៣ លានតោនជាទំហំទំនិញនាំចូល។ មានការលើកឡើងថា កំពង់ផែសមុទ្រនៃប្រទេសកម្ពុជា គឺជាកំពង់ផែមានតម្លៃសេវាថ្លៃបំផុតនៅអាស៊ី ហើយនៅក្នុងឆ្នាំ ២០១៩ រដ្ឋាភិបាលកម្ពុជាបាននិយាយថា ខ្លួននឹងធ្វើការកាត់បន្ថយតម្លៃសេវាដើម្បីឱ្យកំពង់ផែព្រះសីហនុអាចប្រកួតប្រជែងនៅក្នុងទីផ្សារ។

កំពង់ផែស្វយ័តភ្នំពេញរបស់រដ្ឋ នៅស្រុកកៀនស្វាយនៃទឹកដីខេត្តកណ្តាល ដែលមានចម្ងាយ ៣០ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ គឺជាកំពង់ផែធំបង្អស់ទី២ របស់កម្ពុជា។ នៅខែមករា ឆ្នាំ២០១៣ កំពង់ផែ បានបើកឱ្យដំណើរការ ស្ថានីយកុងតឺន័រ តម្លៃ២៨លាន ដុល្លារអាមេរិក ក្រោមជំនួយថវិកាពីរដ្ឋាភិបាលនៃប្រទេសចិន។ ផលិតផលសម្លៀកបំពាក់ និងកសិកម្ម (ជាពិសេសស្រូវអង្ករ) គឺជាទំនិញនាំចេញឆ្លងកាត់កំពង់ផែនេះ ខណៈដែលសម្ភារៈសំណង់ គ្រឿងម៉ាស៊ីនប្រើក្នុងវិស័យកសិកម្ម វត្ថុធាតុដើមសម្រាប់ឧស្សាហកម្មវាយនភ័ណ្ឌ សម្លៀកបំពាក់ និងទំនិញប្រើប្រាស់ គឺជាផលិតផលនាំចូលសំខាន់ៗ[53]។ ក្នុងរយៈពេល ៥ឆ្នាំ ចាប់ពីឆ្នាំ ២០១៣មក ចរាចរណ៍កុងតឺន័រឆ្លងកាត់កំពង់ផែភ្នំពេញបានកើនឡើងជាមធ្យម ១៤,៤% ក្នុងមួយឆ្នាំ [54]។ នៅក្នុងដំណាក់កាលទី១ និងទី២ នៃការអភិវឌ្ឍ កំពង់ផែនេះបានបង្កើនសមត្ថភាពផ្ទុករបស់ខ្លួនបានរហូតដល់ ៣០០,០០០ TEUs ក្នុងរយៈពេលមួយឆ្នាំ។ នៅដំណាក់កាលទី៣នៃការពង្រីកបន្ថែមនេះ មានគោលបំណងបង្កើនសមត្ថភាពផ្ទុកកុងតឺន័រឱ្យបានរហូតដល់៥០០,០០០TEUsក្នុងមួយឆ្នាំ។

កំពង់ផែស្ងួតភ្នំពេញ គឺជាកំពង់ផែទឹកទន្លេ ដែលមានចម្ងាយ ៣៣០គីឡូម៉ែត្រ ពីសមុទ្រ។ កប៉ាល់ផ្ទុកទំនិញនៅទីនេះ អាចបម្រើដល់គោលដៅអន្តរជាតិជាច្រើន ដូចជា ប្រទេសសិង្ហបុរី ជាដើម។ ផែសមុទ្រតូចៗ ដទៃទៀត នៅខេត្តកោះកុង និងខេត្តកំពត ត្រូវបានប្រើសម្រាប់កាប៉ាល់តូចៗ។ កំពង់ផែទន្លេ ដូចជានៅខេត្តកំពង់ចាម បម្រើឱ្យកាប៉ាល់ក្នុងស្រុកប៉ុណ្ណោះ។

ផ្លូវទឹក ដែលមានការប្រកួតប្រជែងបំផុតសម្រាប់ការដឹកជញ្ជូន គឺឆ្លងកាត់ទន្លេមេគង្គពីភ្នំពេញទៅកំពង់ផែ Cai Mep ប្រទេសវៀតណាម។ ការចរាចរណ៍ឆ្លងកាត់ PPAP បាននឹងកំពុងកើនឡើងនៅប៉ុន្មានឆ្នាំថ្មីៗ

[52] ដកស្រង់ចេញពីកាសែតខ្មែរថាមស៍"ចរាចរណ៍កុងតឺន័រតាមផ្លូវសមុទ្រមានការកើនឡើងខ្លាំង"ជា វណ្ណៈ, ១០ មករា ២០១៩

[53] ដកស្រង់ចេញពីកាសែតភ្នំពេញប៉ុស្តិ៍"បរិមាណទំនិញនៅផែស្ងួតភ្នំពេញកើនឡើង៣០%"ហ៊ា គីមសាយ, ១៨ មេសា ២០១៩

[54] ដកស្រង់ចេញពីកាសែតភ្នំពេញប៉ុស្តិ៍"ការពង្រីកកំពង់ផែភ្នំពេញដើម្បីជម្រុញការដឹកជញ្ជូនតាមផ្លូវទឹកនៅប្រទេសកម្ពុជា"ហ៊ិន ពិសី, ១២ ធ្នូ ២០១៨

នេះ ហើយនេះបណ្តាលមកពីការតភ្ជាប់ទៅកំពង់ផែ Cai Mep នៅប្រទេសវៀតណាម ដោយទូកដឹកទំនិញដែលជាជំរើសមួយដែលផ្តល់ការតភ្ជាប់អន្តរជាតិ ទាំងកំពង់ផែក្រុងព្រះសីហនុនិងហូជីមិញ។ ការដឹកទំនិញតាមដងទន្លេពីភ្នំពេញទៅ Cai Mep និងអាចភ្ជាប់ទៅនឹងនាវាសមុទ្រជ្រៅទៅសហរដ្ឋអាមេរិក គឺវាមានតម្លៃថោកជាង ២០០ ដុល្លារក្នុងមួយកុងតឺន័រ និងពីរថ្ងៃខ្លីជាងបើកបរពីភ្នំពេញ និងតភ្ជាប់តាមរយៈក្រុងហូជីមីញ។

### ២.៦.២.ទំហំនៃការដឹកជញ្ជូន

នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ចំណុចដែលពិសេសនោះ គឺរាល់ការដឹកជញ្ជូននូវទំនិញ គឺតម្រូវ អោយមានបរិមាណកំណត់ ដោយសារតែខ្លាចខូចខាតហេដ្ឋារចនាសម្ព័ន្ធរបស់ប្រទេស ព្រមទាំងអាចបណ្តាលអោយមានភាពអវិជ្ជមានក្នុងការធ្វើពាណិជ្ជកម្មផងដែរ ។ ខាងក្រោមនេះជាទំហំនៃការដឹកជញ្ជូនរបស់ប្រទេសនីមួយៗ

| តារាងទី ២.៨ ៖ បង្ហាញពីទំហំនៃការដឹកជញ្ជូនរបស់ប្រទេសជិតខាង | | | |
|---|---|---|---|
| | ប្រទេសឡាវ ( Max ) | ប្រទេសថៃ ( Max ) | ប្រទេសកម្ពុជា ( Max ) |
| ទំងន់សរុបត្រូវបានអនុញ្ញាត (ឡានកង់១៨) | 39 | 45 | 40 |

ប្រភព ៖ (ក្រសួងពាណិជ្ជកម្ម, Cambodia Trade Integration Strategy 2014-2018, 2014)

ហេតុផលសំខាន់ដែលតម្រូវអោយគោរពតាមការក្នុងការដឹកជញ្ជូនដោយសារតែមូលហេតុសំខាន់ចំនួន ៣ គឺ ៖

- ការប្រកួតប្រជែង ៖ ដោយសារតែមានការយល់ឃើញថា ការដឹកលើសទំងន់គឺអាចមានផលប៉ះពាល់ទៅដល់ការប្រកួតប្រជែង ពោលគឺប្រទេសដែលអាចដឹកបានច្រើន គឺនឹងទទួលបាននូវអត្ថប្រយោជន៍ពីការធ្វើពាណិជ្ជកម្មជាង។
- លទ្ធភាព និងសមត្ថភាព ៖អ្នកផលិតឡានដឹកទំនិញនៅបរទេសមានសមត្ថភាពផលិតយានយន្តធំ និងខ្ពស់ដើម្បីកាត់បន្ថយថ្លៃដើម តួយ៉ាងដូចប្រទេសថៃ គឺគេមានសមត្ថភាពអាចរកនូវឡានដឹកទំនិញធំៗបាន ដែលជាលក្ខខណ្ឌអំណោយផលសម្រាប់គេ តែសម្រាប់ប្រទេសកម្ពុជាវិញគឺមិនអាចប្រើប្រាស់ និងអនុញ្ញាតអោយរថយន្តប្រភេទនេះអាចចរាចរបានទេ ដោយសារតែទំហំ និងទម្ងន់បន្ថែមរថយន្តដឹកទំនិញមិនសមនឹងផ្លូវថ្នល់នៅប្រទេសកម្ពុជា។ ជាក់ស្តែង នៅក្នុងកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីការសម្របសម្រួលទំនិញ និងការឆ្លងកាត់ ប្រទេសកម្ពុជា និងថៃ បានព្រមព្រៀងក្នុងការមានរថយន្តដឹកទំនិញចំនួន ១៥០គ្រឿង ក្នុងមួយប្រទេស ដើម្បីជួយសម្រួលដល់ការដឹកជញ្ជូនឆ្លងកាត់ព្រំដែនទ្វេភាគី

ទោះយ៉ាងណាក៏ដោយ ប្រទេសកម្ពុជាមានរថយន្តដឹកទំនិញចំនួនតែ ៥០គ្រឿងប៉ុណ្ណោះ ខណៈដែលប្រទេសថៃបានឈានទៅដល់គោលដៅចំនួន ១៥០គ្រឿង។ ប្រទេសកម្ពុជា និងវៀតណាមព្រមព្រៀងគ្នាក្នុងការមានរថយន្តដឹកទំនិញចំនួន ៥០០គ្រឿងឆ្លងកាត់ ខណៈដែលប្រទេសកម្ពុជា-ឡាវ មានចំនួនត្រឹមតែ ៤គ្រឿងប៉ុណ្ណោះក្នុងចំណោមរថយន្តទាំង ៤០ ដែលបានព្រមព្រៀង។ [55]

- តម្រូវការនៃទំនិញ ៖ ប្រទេសកម្ពុជា គឺជាប្រទេសកំពុងអភិវឌ្ឍន៍ ហេតុដូចនេះប្រជាជនមានតម្រូវការលើផលិតផលច្រើនមុខ ដែលធ្វើអោយប្រទេសនាំចូលចង់បង្កើនការផ្គត់ផ្គង់កាន់តែច្រើនថែមទៀត ដូចនេះហើយ គឺតម្រូវអោយមានការកំណត់ទំហំនៃការដឹកជញ្ជូន ដើម្បីជៀសវាងការដឹកចូលលើសកម្រិត។

**២.៦.៣.បញ្ហានៃមធ្យោបាយដឹកជញ្ជូន**

បើទោះបីជាពាណិជ្ជកម្មរវាងប្រទេសនៅតំបន់អាស៊ានមានលក្ខណៈកាន់តែប្រសើរ ក៏ប៉ុន្តែនៅតែមាននូវឧបសគ្គមួយចំនួនដែលរារាំងដល់ការដឹកជញ្ជូនពីប្រទេសមួយទៅប្រទេសមួយ។ បញ្ហានៃការដឹកជញ្ជូនដែលកើតមានឡើងមានដូចជា ៖

- ថ្លៃដើមខ្ពស់ ៖ ប្រេងរថយន្តមានតម្លៃថ្លៃ។ ប្រតិបត្តិករចាត់ទុកថាថ្លៃដើមឥន្ធនៈខ្ពស់គឺជាកត្តាអវិជ្ជមានធំបំផុតដែលជំរុញឱ្យមានការចំណាយសរុបកើនឡើង។ ឡានដឹកទំនិញ ១ គ្រឿងត្រូវបានក្រុមហ៊ុនរាយការណ៍ថាប្រេងឥន្ធនៈមានរហូតដល់ ៧០ ភាគរយនៃថ្លៃដឹកជញ្ជូនសរុប។ សមាមាត្រនេះបង្ហាញថា ការចំណាយលើឥន្ធនៈធៀបទៅនឹងថ្លៃដើមផ្សេងទៀតគឺ ស្របនឹងរបាយការណ៍ពីប្រទេសឡាវ និងថៃ ដែលថ្លៃដើមប្រេងក៏ត្រូវបានរាយការណ៍ថាជាឧបសគ្គដ៏ធំមួយ។
- គុណភាពនៃសេវាដឹកជញ្ជូនទាប ៖ បញ្ហាដឹកជញ្ជូនទូទៅត្រូវបានកំណត់នៅក្នុងច្បាប់ចរាចរណ៍ផ្លូវគោកដែលមានស្រាប់ រួមមានការចុះឈ្មោះសម្រាប់ការទទួលបានអាជ្ញាប័ណ្ណប្រតិបត្តិករ និងការហាមឃាត់ក្នុងការដឹកទំនិញលើសទម្ងន់ដែលអាចបណ្តាលអោយប៉ះពាល់ដល់ហេដ្ឋារចនាសម្ព័ន្ធ និងសុវត្ថិភាពចរាចរណ៍។ ក្នុងករណីខ្លះអ្នកបើកបរមិនមានវិជ្ជាជីវៈ ដោយពួកគេគ្រាន់តែចុះឈ្មោះ និងបំពេញនៅតម្រូវការរដ្ឋបាល ដើម្បីទទួលបានអាជ្ញាប័ណ្ណបើកបរដោយពុំមានការរៀនបើកបរ និងប្រឡងអោយបានត្រឹមត្រូវ ដែលជាហេតុបណ្តាលអោយខ្វះខាតបទបញ្ញត្តិសំខាន់ៗ និងច្បាប់ទាក់ទងនឹងសុវត្ថិភាព។
- ការប្រកួតប្រជែងខ្សោយនៅក្នុងវិស័យដឹកទំនិញ ៖ ការប្រកួតប្រជែងក្នុងចំណោមក្រុមហ៊ុនដឹកទំនិញភាគច្រើន គឺកើតឡើងនៅក្នុងស្រុក ហើយឡានដឹកទំនិញរបស់បរទេសត្រូវបានរឹតត្បិតពីប្រតិបត្តិការ

[55] ដកស្រង់ចេញពីកាសែតខ្មែរថាមស៍ "វិស័យភស្តុភារ និងដឹកជញ្ជូនត្រូវបានពិនិត្យឡើងវិញនៅក្នុងកិច្ចប្រជុំអាស៊ានលើកទី៤០" សុខ ចាន់, ២៩ មីនា ២០២១

ចូលមកក្នុងប្រទេសកម្ពុជា ដូច្នេះការប្រកួតប្រជែងអន្តរជាតិមិនមានឥទ្ធិពលលើកម្ពុជានោះទេ ប៉ុន្តែប្រទេសកម្ពុជានៅមានកម្រិតនៅឡើយក្នុងការដឹកជញ្ជូន ដោយមិនសូវមានការប្រកួតប្រជែងនោះទេ ដែលជាហេតុបណ្តាលអោយការដឹកជញ្ជូនមិនទាន់មានស្តង់ដា និងមានតម្លៃថ្លៃ។

- ច្បាប់ និងបទបញ្ញត្តិ ៖ ការបង់ប្រាក់មិនទៀងទាត់ និងថ្លៃសេវាក្រៅផ្លូវការក្នុងការទទួលបានលិខិតអនុញ្ញាតវិញ្ញាបនប័ត្រ និងអធិការកិច្ចសម្រាប់ពាណិជ្ជករ និងអ្នកផ្តល់សេវា នៅតែជាបញ្ហាដ៏ធ្ងន់ធ្ងរ បើទោះបីជាមានការធ្វើទំនើបកម្មគយ និងស្វ័យប្រវត្តិកម្មក៏ដោយ ក៏បន្ទុកនៃនីតិវិធីគយនៅតែខ្ពស់។
- ហេដ្ឋារចនាសម្ព័ន្ធ ៖ ផ្លូវគោកមិនមានភាពធន់គ្រប់គ្រាន់សម្រាប់ទ្រទ្រង់នូវឡានដឹកទំនិញធំៗ ដោយករណីភាគច្រើន គឺក្រុមអ្នកសាងសង់មិនមានបច្ចេកវិទ្យាទំនើប និងវិធីសាស្ត្រសាងសង់មានតម្លៃទាប ហើយជាញឹកញយផ្លូវថ្នល់ដែលត្រូវបានសាងសង់ដោយក្រុមកម្មករគ្មានវិជ្ជាជីវៈ និងខ្វះការត្រួត ពិនិត្យណែនាំ[56]។ ចំពោះផ្លូវដែក ដោយសារភាពមានកម្រិតក្នុងការដឹកជញ្ជូន ពោលគឺផ្លូវដែកមិនមានឥទ្ធិពលលើតម្លៃ និងការប្រកួតប្រជែងក្នុងទីផ្សារសេវាកម្មដឹកជញ្ជូនឡើយ។
- កង្វះនិរន្តរភាពបណ្តាញគមនាគមន៍ ៖ ដោយសារសមត្ថភាពជួសជុលថែទាំនៅមានកម្រិតទាប ការដឹកហួសទម្ងន់កំណត់របស់យានយន្ត ភាពធន់ទៅនឹងបម្រែបម្រួលអាកាសធាតុមានកម្រិតទាប និងសុវត្ថិភាពចរាចរណ៍នៅទាប ជាលទ្ធផល ធ្វើអោយទំនាក់ទំនងជាមួយសេវាកម្ម និងទីផ្សារមានមិនគ្រប់គ្រាន់ និងការបាត់កាលានុភាពសេដ្ឋកិច្ច ការចំណាយលើការដឹកជញ្ជូនខ្ពស់ ការជួសជុលថែទាំ និងភស្តុភារមានកម្រិតខ្ពស់ និងភាពប្រកួតប្រជែងទាប ហើយហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ពុំមានសុវត្ថិភាព។

### ២.៦.៤.ផែនការអភិវឌ្ឍន៍ប្រព័ន្ធដឹកជញ្ជូននៅកម្ពុជា

តាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីក្លាយជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងជាប្រទេសមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ ២០៥០ ប្រទេសកម្ពុជាត្រូវតភ្ជាប់ទៅនឹងសមាហរណកម្មនៅក្នុងសមាគមន៍សេដ្ឋកិច្ចអាស៊ានប្រកបដោយនិរន្តរភាព ហើយត្រូវគិតគូរពីតម្រូវការខ្សែសង្វាក់តម្លៃ និងគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម កាត់បន្ថយការប៉ះពាល់បរិស្ថាន និងបំពេញបន្ថែមការតភ្ជាប់ជាមួយនឹងអាស៊ាន តាមរយៈការផ្លាស់ប្តូរ និងធ្វើទំនើបកម្មវិស័យដឹកជញ្ជូន និងភស្តុភាររបស់ប្រទេស ពីវិស័យដែលចំណាយខ្ពស់ យឺត និងគ្មានប្រសិទ្ធិភាព ទៅជាមានតម្លៃសមរម្យ ល្បឿនលឿន និងមានប្រសិទ្ធិភាព។

**ក.គោលដៅ**

- ដើម្បីប្រែក្លាយប្រព័ន្ធដឹកជញ្ជូនមិនគ្រប់គ្រាន់ ទៅជាប្រព័ន្ធដឹកជញ្ជូនថ្នាក់ជាតិដែលមានការអភិវឌ្ឍពេញលេញ និងប្រកបដោយចីរភាព ដើម្បីឆ្លើយតបទៅនឹងកំណើនប្រជាជន និង

[56] ដកស្រង់ចេញពីកាសែតភ្នំពេញប៉ុស្តិ៍"ប្រទេសកម្ពុជាត្រូវប្រឈមនឹងបញ្ហាទ្វេដងស្តីពីការស្ថាបនាផ្លូវថ្នល់"រូប៊ីនស្ពីស, ១២ ធ្នូ ២០១៧)

កំណើនការងារ

- លើកកម្ពស់សមាហរណកម្មតំបន់ក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ពិភពលោកតាមរយៈ ការដឹកជញ្ជូនលឿនរហ័ស និងការតភ្ជាប់ខ្ពស់នៅក្នុងអនុតំបន់មេគង្គ
- លើកកម្ពស់ការប្រកួតប្រជែងផ្នែកឧស្សាហកម្ម តាមរយៈបណ្តាញផលិតកម្មកាន់តែខ្លាំង និងបណ្តាញដឹកជញ្ជូនល្អបំផុត និងមានប្រសិទ្ធិភាព
- លើកកម្ពស់ការប្រកួតប្រជែងផ្នែកភស្តុភារ តាមរយៈសេវាកម្មដែលដឹកជញ្ជូនចម្រុះដែលមានគុណភាពខ្ពស់ និងប្រសិទ្ធិភាពដើម្បីឆ្លើយតបនឹងតម្រូវការផ្សេងៗ
- ដើម្បីចូលរួមកាត់បន្ថយភាពក្រីក្រ និងរួមចំណែកដល់សម្មិផលនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព តាមរយៈការសម្របសម្រួលចលនាទំនិញ និងសេវាកម្មរបស់ប្រជាជនដោយជម្រុញទីផ្សារក្នុងស្រុក លើកកម្ពស់វិស័យទេសចរណ៍ និងការអភិវឌ្ឍជនបទ
- ដើម្បីលើកកម្ពស់សុខុមានភាព និងជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាតាមរយៈការតភ្ជាប់សេដ្ឋកិច្ចក្នុងប្រទេសនឹងភាពចល័តសម្រាប់មធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទអោយកាន់តែប្រសើរឡើង។

**ខ.គោលបំណង**

ដើម្បីសម្រេចគោលដៅខាងលើ ត្រូវកំណត់គោលបំណងដូចជា ៖

- កំណត់គម្រោងដឹកជញ្ជូនអាទិភាពដែលត្រូវអនុវត្តរយៈពេលខ្លី មធ្យម និងវែង ដើម្បីថែរក្សា និងគ្រប់គ្រងបណ្តាញដឹកជញ្ជូននៅកម្ពុជាអោយបានត្រឹមត្រូវ
- ផ្តល់អាទិភាពខ្ពស់ដល់ការលើកកម្ពស់បណ្តាញផ្លូវខេត្ត និងជនបទ តភ្ជាប់ទៅគ្រប់តំបន់នៃប្រទេស និងប្រទេសជិតខាង
- ដើម្បីអភិវឌ្ឍន៍ ថែទាំ និងគ្រប់គ្រងបណ្តាញដឹកជញ្ជូនអោយមានដំណើរការល្អ ដោយមានប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃទៀងទាត់
- ផ្តោតការយកចិត្តទុកដាក់ទៅលើសុវត្ថិភាពចរាចរណ៍ និងវិធានការតឹងរឹងប្រឆាំងនឹងបទល្មើសដឹកជញ្ជូន រួមទាំងអ្នកដឹកជញ្ជូនលើសទម្ងន់
- ដើម្បីដាក់ចេញនូវគោលនយោបាយយុទ្ធសាស្ត្រក្របខ័ណ្ឌច្បាប់ និងបទបញ្ញត្តិសម្រាប់ការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធ ប្រកបដោយប្រសិទ្ធភាព
- ដើម្បីបង្កើតប្រព័ន្ធដឹកជញ្ជូនប្រកបដោយប្រសិទ្ធភាព និងចំណាយតិចដែលអាចឆ្លើយតបទៅនឹងតម្រូវការសេដ្ឋកិច្ចបច្ចុប្បន្ន និងអនាគត

- ជម្រុញការផ្លាស់ប្តូរនៅក្នុងប្រព័ន្ធភស្តុភារតាមលំដាប់ទាំង ៣ដំណាក់កាល ៖

  ១.លុបបំបាត់ឧបសគ្គខាងភស្តុភារបច្ចុប្បន្នរយៈពេលខ្លី

  ២.ឈានដល់ស្តង់ដារពិភពលោក ក្នុងរយៈពេលមធ្យម

  ៣.ធ្វើអោយសកម្មក្នុងមូលដ្ឋានអាជីវកម្មដឹកជញ្ជូនរយៈពេលវែង។

**គ.គោលការណ៍**

គោលការណ៍សំខាន់ៗមានដូចខាងក្រោម៖

- ជួយពន្លឿនការបញ្ចប់គម្រោងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូននិងដឹកជញ្ជូនដែលមានស្រាប់
- ធានាឱ្យមានការជាប់ទាក់ទងគ្នានៃយុទ្ធសាស្ត្រដឹកជញ្ជូននិងភស្តុភារផ្សេងៗតាមផែនការដែលបង្កើតឡើងដោយដៃគូអភិវឌ្ឍន៍
- ខិតខំធ្វើឱ្យមានតុល្យភាពរវាងគំរូការដឹកជញ្ជូន និងដឹកជញ្ជូនជាតិ និងមហាអនុតំបន់មេគង្គ និងសហគមន៍សេដ្ឋកិច្ចអាស៊ាន
- អាចធ្វើទៅបាននៅក្នុងការអនុវត្តជាក់ស្តែងជាមួយនឹងគំរូនៃការកៀរគរហិរញ្ញវត្ថុច្បាស់លាស់រួមទាំងការចូលរួមពីវិស័យឯកជន
- ធានាឱ្យមានអន្តរាគមន៍ពីសាធារណៈសម្រាប់គំរូការកែលំអភ័ស្តុភារផ្អែកលើ៖

  ១.ការពង្រីកនិងរបៀបដឹកជញ្ជូនច្រើនប្រភេទ

  ២.ការកាត់បន្ថយពេលវេលានិងថ្លៃដើមនៃភ័ស្តុភារ

  ៣.ការប្រកួតប្រជែងមានមុខងារនៅក្នុងអ្នកផ្តល់សេវាដឹកជញ្ជូន ដើម្បីប្រើប្រាស់យ៉ាងពេញលេញនូវការដឹកជញ្ជូនតាមរថយន្តដឹកជញ្ជូនការដឹកជញ្ជូនតាមផ្លូវទឹក និងការដឹកជញ្ជូនតាមផ្លូវដែក។

## ២.៧.លក្ខខណ្ឌពិសេសនៅលើទំនិញក្នុងការធ្វើពាណិជ្ជកម្ម

### ២.៧.១.ទំនិញដែលត្រូវបានលើកលែងពន្ធ និងអាករ

ការលើកលែងពន្ធ និងអាករ ត្រូវបានផ្តល់ជូនចំពោះទំនិញ និងអ្នកនាំចូល ដែលមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

ក. ទំនិញសម្រាប់បេសកកម្មការទូត ឬ បេសកកម្មកុងស៊ុលបរទេស អង្គការអន្តរជាតិ និងភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេស របស់រដ្ឋាភិបាលផ្សេងទៀត ដើម្បីប្រើប្រាស់ក្នុងការិយកិច្ចនៃមុខងារជាផ្លូវការ ដោយមានការបញ្ជាក់ពីប្រធាន បេសកកម្ម និងពីក្រសួងការបរទេស និងសហប្រតិបត្តិការ អន្តរជាតិ

ខ. ទំនិញសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួនរបស់បុគ្គលិកផ្លូវការនៃបេសកកម្ម និងអង្គការដូចបានរៀបរាប់នៅក្នុង វាក្យខណ្ឌ ក នៃប្រការនេះ។ ការអនុវត្តនូវវាក្យខណ្ឌនេះ និងវាក្យខណ្ឌ ក នៃប្រការនេះត្រូវផ្អែកលើ គោលការណ៍ច្បាប់អន្តរជាតិ និងគោលការណ៍បដិការ រវាង រដ្ឋាភិបាលពាក់ព័ន្ធ

គ. ទំនិញមានដើមកំណើតកម្ពុជា ឬ ទំនិញនាំចូលដែលបានបង់ពន្ធ និងអាករួច ដែលចេញពីដែនគយ ហើយត្រូវនាំចូលត្រឡប់ ពីបរទេសមកវិញដោយពុំមានការបង្កើនតម្លៃ

ឃ. ទំនិញដែលត្រូវលើកលែងពន្ធ និងអាករក្រោមបញ្ញត្តិនៃច្បាប់ផ្សេងទៀតរបស់ព្រះរាជាណាចក្រកម្ពុជា

ង. ទំនិញជាអំណោយសម្រាប់មនុស្សធម៌ ទំនិញសម្រាប់ការស្រាវជ្រាវ និងគោលបំណងវិទ្យាសាស្ត្រ ទំនិញគំរូ និងទំនិញតាំងពិព័រណ៍ដែលគ្មានតម្លៃពាណិជ្ជកម្ម មឈូសដែលមានសាកសពមនុស្ស

ច. ទំនិញនាំចូលដែលមានតម្លៃ និងបរិមាណច្បាស់លាស់មួយចំនួនតាមការកំណត់របស់អគ្គនាយកនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ដែលនាំចូលដោយអ្នកដំណើរ អ្នកបម្រើការតាមមធ្យោបាយ ដឹកជញ្ជូន និងជនទាំងឡាយដែលឆ្លងកាត់ព្រំដែន

ឆ. ទំនិញដែលចូលក្នុងដែនគយសម្រាប់ឆ្លងកាត់ ឬ ផ្ទេរមធ្យោបាយដឹកជញ្ជូន

ញ. សម្ភារប្រើប្រាស់ក្នុងផ្ទះ សម្ភារប្រើប្រាស់ផ្ទាល់ខ្លួន និងទ្រព្យសម្បត្តិផ្សេងទៀតលើកលែងតែយានយន្តដែលនាំចូលដោយ បុគ្គលដែលផ្លាស់ប្តូរលំនៅស្ថានមកកម្ពុជាក្នុងបរិមាណដែលកំណត់ដោយអគ្គនាយកនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

ឈ. បរិក្ខារឧស្សាហកម្ម និងសម្ភារផ្សេងទៀតដែលជាតម្រូវការសម្រាប់ប្រតិបត្តិការ និងការថែរក្សាបរិក្ខារ ទាំងនេះ ដែលប្រើប្រាស់នៅក្នុងសមុទ្រសម្រាប់ការរុករក និងទាញយកផលិតផលតេលសិលា និង សារធាតុខនិជនិងសរីរាង្គផ្សេង ទៀតតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ញ. ទំនិញផ្សេងទៀតតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**២.៧.២.ការគ្រប់គ្រងទំនិញដែលបានលើកលែងពន្ធ និងអាករ**

ទំនិញនាំចូលដោយលើកលែងពន្ធ និងអាករនាំចូលក្រោមបញ្ញត្តិនៃវាក្យខណ្ឌ ក កថាខណ្ឌទី ១ មាត្រា ២៦ នៃច្បាប់ស្តីពីគយ សម្រាប់បេសកកម្មការទូត ឬ បេសកកម្មកុងស៊ុលបរទេស អង្គការអន្តរជាតិ និងភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលផ្សេងទៀត ដើម្បីប្រើប្រាស់ក្នុងកិច្ចការនៃមុខងារជាផ្លូវការ របស់ខ្លួន និងបុគ្គលិករបស់អង្គការទាំងនេះ ត្រូវនាំចេញទៅវិញបន្ទាប់ពីបញ្ចប់បេសកកម្មរបស់ខ្លួន។

ទំនិញទាំងនេះព្រមទាំងទំនិញផ្សេងទៀតក្រោមបញ្ញត្តិកថាខណ្ឌទី ១ មាត្រា ២៦ នៃច្បាប់ស្តីពីគយ មិនត្រូវបានអនុញ្ញាតឲ្យលក់ ផ្ទេរ បង្វែរទៅប្រើប្រាស់អ្វីផ្សេងពីគម្យដ្ឋានដែលបានអនុគ្រោះ ឬ បោះបង់ចោលដោយគ្មានការអនុញ្ញាតជាមុនពីរដ្ឋបាលគយឡើយ។

អង្គការ ឬបុគ្គលនានាដែលមានបំណងលក់ ផ្ទេរ បង្វែរទៅប្រើប្រាស់អ្វីផ្សេងពីគម្យដ្ឋានដែលបានអនុគ្រោះ ឬបោះបង់ចោលទំនិញដែលបាននាំចូលដោយលើកលែង ឬ លើកលែងជាភាគនូវពន្ធ និងអាករនាំចូលត្រូវស្នើសុំការអនុញ្ញាតជាមុនពីរដ្ឋបាលគយស្របតាមនីតិវិធីដូចខាងក្រោម ៖

- ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតមករដ្ឋបាលគយ ដោយបញ្ជាក់ឲ្យបានច្បាស់លាស់ពីរបៀបនៃការប្តូរគម្យដ្ឋាន ឬ ការប្តូរកម្មសិទ្ធិលើទំនិញនេះ។ ច្បាប់ចម្លងនៃពាក្យស្នើសុំនេះត្រូវផ្ញើជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឬ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាសម្រាប់ទំនិញដែលនាំចូលក្រោមបញ្ញត្តិ កថាខណ្ឌទី ១ ប្រការ ១ នៃប្រកាសលេខ ១០៥ សហវ.ប្រក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងទំនិញដែលត្រូវបានលើកលែងពន្ធ និងអាករ
- ពាក្យស្នើសុំត្រូវអមដោយបញ្ជីទំនិញ និងឯកសារនាំចូលព្រមទាំងឯកសារផ្សេងទៀតប្រសិនបើមាន។ ទំនិញមិនត្រូវបានអនុញ្ញាតឲ្យលក់ ផ្ទេរ ឬបង្វែរ មុនពេលទទួលបានការអនុញ្ញាតពីរដ្ឋបាលគយឡើយ
- កម្មសិទ្ធិករថ្មីត្រូវទទួលខុសត្រូវលើការបង់ពន្ធ និងអាករជូនរដ្ឋបាលគយតាមនីតិវិធីគយជាធរមាន ហើយទំនិញមិនត្រូវបានប្រគល់ជូនកម្មសិទ្ធិករថ្មី ដោយគ្មានការអនុញ្ញាតជាមុនពីរដ្ឋបាលគយ និងមុនពេលបង់ពន្ធ និងអាករដែលជាប់ ឬ ទទួលបានការលើកលែងពន្ធជាថ្មីពីស្ថាប័នមានសមត្ថកិច្ច
- រដ្ឋបាលគយត្រូវគិតគូរពីល័ក្ខខ័ណ្ឌជាក់ស្តែង និងសភាពនៃទំនិញទាំងនោះនាពេលប្រគល់ទទួល និងអាចកែសម្រួលតម្លៃគិតពន្ធគយតាមនេះ។

### ២.៧.៣.គោលបំណងក្នុងការហាមឃាត់ការនាំចេញ និងនាំចូល

ទំនិញហាមឃាត់និងទំនិញជាប់កម្រិតកំណត់ គឺជាទំនិញដែលស្ថិតក្រោមលក្ខខណ្ឌលើការនាំចេញ ឬ នាំចូល ក្នុងគោលបំណងណាមួយដូចជា៖

- ការការពារសន្តិសុខជាតិ
- ការការពារសណ្តាប់ធ្នាប់សាធារណៈ និងស្តង់ដារនៃសុភាវធម៌ និងសីលធម៌

- ការការពារសុខភាព និងជីវិតមនុស្ស សត្វ ឬ រុក្ខជាតិ
- ការការពារបេតិកភណ្ឌជាតិ ដែលមានតម្លៃខាងសិល្បៈ ប្រវត្តិសាស្ត្រ ឬ បុរាណវត្ថុវិទ្យា
- ការអភិរក្សធនធានធម្មជាតិ
- ការតម្រូវតាមបញ្ញត្តិនានានៃច្បាប់ណាមួយជាធរមាននៃព្រះរាជាណាចក្រកម្ពុជា
- ការបំពេញកាតព្វកិច្ចក្រោមធម្មនុញ្ញសហប្រជាជាតិ ។ (ពិនិត្យមើលក្នុងឧបសម្ព័ន្ធទី ៥ )

## ២.៨.ឥទ្ធិពលនៃការធ្វើពាណិជ្ជកម្មអន្តរជាតិជាមួយនឹងអាស៊ាន

ពាណិជ្ជកម្មអន្តរជាតិអាចត្រូវបានគេកំណត់ថា ជាការផ្លាស់ប្តូរមូលធន សេវាកម្ម ឫទំនិញឆ្លងកាត់ព្រំដែនអន្តរជាតិ។ វាមានគុណសម្បត្តិសំខាន់ៗជាច្រើនសម្រាប់ប្រទេសក៏ដូចជាសម្រាប់ក្រុមហ៊ុននានា និងជាសសរស្តម្ភដ៏សំខាន់មួយក្នុងការធានា និងកែលម្អកម្រិតទ្រព្យសម្បត្តិពិភពលោករបស់យើងបន្ថែមទៀត។ តាមរយៈដំណើរការសេរីភាវូបនីយកម្មក្នុងរយៈពេលប៉ុន្មានសតវត្សចុងក្រោយនេះការធ្វើពាណិជ្ជកម្មមានសារៈសំខាន់ណាស់ក្នុងការរក្សាបាននូវកម្រិតជីវភាពខ្ពស់នៅទូទាំងប្រទេស។ បើទោះបីជាការធ្វើពាណិជ្ជកម្មជាមួយប្រទេសផ្សេងទៀតមានគុណសម្បត្តិច្រើនយ៉ាងណាក៏ដោយ ក៏មានបង្កប់នូវបញ្ហាមួយចំនួនផងដែរ។ ដូចនេះរដ្ឋាភិបាលត្រូវធ្វើកិច្ចសហប្រតិបត្តិការជាលក្ខណៈអន្តរជាតិដើម្បីបង្កើតក្របខ័ណ្ឌដើម្បីឱ្យមនុស្សគ្រប់គ្នាអាចទទួលបានអត្ថប្រយោជន៍ពីពាណិជ្ជកម្មពិភពលោក។

### ២.៨.១.ឥទ្ធិពលវិជ្ជមាន

- មានជម្រើសច្រើន ៖ ផលិតផលមានច្រើនប្រភេទ ធ្វើអោយប្រជាជនមានឱកាសជ្រើសរើសផលិតផលផ្សេងៗកាន់តែច្រើន ដូច្នេះការធ្វើពាណិជ្ជកម្មជាមួយប្រទេសដទៃ គឺជាឱកាសដ៏ល្អដែលធានាបាននូវមុខទំនិញជាច្រើន ក្នុងការប្រកួតប្រជែងនៅលើទីផ្សារអន្តរជាតិ។
- ចំណាយតិចក្នុងផលិតកម្ម ៖ នៅពេលដែលមានការនាំចេញទៅក្រៅប្រទេស ការផលិតនូវផលិតផលក៏កាន់តែច្រើន ធ្វើអោយថ្លៃដើមក្នុងកត្តាផលិតកម្មកាន់តែទាប។ ការធ្លាក់ចុះនូវតម្លៃទំនិញ ធ្វើអោយអំណាចទិញរបស់អ្នកប្រើប្រាស់កើនឡើង ហើយបង្កើនទំហំទីផ្សារ។
- បង្កើនការប្រកួតប្រជែង ៖ មានការប្រកួតប្រជែងទាំងគុណភាព និងតម្លៃ ហើយលុបបំបាត់ចោលនូវការបង្កើតភាពផ្តាច់មុខ ដែលនាំអោយកើតមានភាពបរាជ័យក្នុងទីផ្សារ។
- ប្រសិទ្ធិភាពផលិតកម្មតាមរយៈSpecialization ៖ ការធ្វើពាណិជ្ជកម្មក្រៅប្រទេស គឺដើម្បីស្វែងរកប្រាក់ចំនេញ និងជំនាញជាក់លាក់ក្នុងការផលិតផលិតផល ។ ប្រាក់ចំនេញរបស់ដៃគូរពាណិជ្ជកម្ម ផ្តោតទៅលើការចំណាយប្រៀបធៀបរបស់ពួកគេ។ ក្រុមហ៊ុននៃដៃគូរពាណិជ្ជកម្មទាំងពីរផ្តោតលើការផលិតទំនិញដែលពួកគេចំណាយទាប ក្នុងការផលិត (specialization gain) ធ្វើអោយអ្នកនាំចេញ នាំចេញ

ទំនិញកាន់តែច្រើន (មានតម្លៃថោក) ហើយនាំចូលទំនិញផ្សេងទៀតក្នុងតម្លៃទាប (ប្រាក់ចំណេញពាណិជ្ជកម្មចាប់តាំងពីតម្លៃធ្លាក់ចុះក្នុងផលិតកម្ម និងការនាំចូល)។

- លំហូរគំនិតកាន់តែខ្លាំង ៖ ពាណិជ្ជកម្មអន្តរជាតិមានទំនាក់ទំនងជាមួយការផ្ទេរចំណេះដឹង និងគំនិត រួមទាំងជម្រុញការរីកចម្រើនផ្នែកបច្ចេកវិទ្យា។
- ធ្វើអោយមានកំណើនសេដ្ឋកិច្ច ៖ ពាណិជ្ជកម្មនាំអោយមានផលិតកម្មខ្ពស់ជាងមុនជាហេតុដែលធ្វើអោយត្រូវប្រើប្រាស់ពលកម្មជំនាញដែលជាប់ទាក់ទងច្រើន ដូចនេះក៏បង្កើនឱកាសការងារ និងកម្រិតជីវភាពរបស់ប្រជាជនផងដែរ។
- ដៃគូរពាណិជ្ជកម្មអាចពឹងពាក់គ្នាទៅវិញទៅមក ៖ ក្នុងករណីដែមមានការលំបាកផ្នែកហិរញ្ញវត្ថុ ក្រុមហ៊ុនដែលធ្វើពាណិជ្ជកម្មជាមួយគ្នា នៅលើកិច្ចព្រមព្រៀងរយៈពេលវែង ក៏អាចមានឆន្ទៈជួយគ្នាអោយរួចផុតពីវិបត្តិសេដ្ឋកិច្ច ឬពីការក្ស័យធន ដូចនេះ ពាណិជ្ជកម្មអន្តរជាតិ អាចបញ្ចៀសក្រុមហ៊ុនពីហានិភ័យកម្រិតខ្ពស់ និងរក្សានូវសន្តិសុខប្រឆាំងនឹងវិបត្តិហិរញ្ញវត្ថុធ្ងន់ធ្ងរ។
- ពង្រឹងទំនាក់ទំនងនយោបាយ ៖ បញ្ហានាំចេញ នាំចូលអាចជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ទំនាក់ទំនងនយោបាយ ជាពិសេសប្រសិនបើពួកគេពឹងផ្អែកតែលើសេដ្ឋកិច្ចរួម។
- ចំណូលពន្ធខ្ពស់ ៖ ដោយសារពាណិជ្ជកម្មអន្តរជាតិ នឹងបង្កើនកម្រិតសុខុមាលភាពទូទៅនៅក្នុងប្រទេសជាច្រើន បរិមាណពន្ធដែលប្រមូលបានពីអ្នកទិញកំពុងកើនឡើង ប្រាក់ចំណូលពន្ធនៅក្នុងប្រទេសទាំងនោះក៏នឹងកើនឡើងផងដែរ។ ដូច្នេះ រដ្ឋមានថវិការច្រើនដែលអាចយកទៅប្រើប្រាស់ ដើម្បីលើកកម្ពស់សុខុមាលភាពសាធារណៈ ហើយប្រាក់ចំណូលពន្ធខ្ពស់នេះ អាចត្រូវបានប្រើដើម្បីកែលម្អហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន។ តាមរយៈការធ្វើដូចនេះគុណភាពជីវិតទូទៅរបស់ប្រជាជនក្នុងតំបន់អាចត្រូវបានកែលម្អបន្ថែមទៀត ហើយរដ្ឋមានថវិការច្រើនដែលអាចយកទៅប្រើប្រាស់ដើម្បីលើកកម្ពស់សុខុមាលភាពសាធារណៈ។
- ក្រុមហ៊ុនអាចពង្រីកទីផ្សារគោលដៅ ៖ ការពឹងផ្អែកតែលើទីផ្សារក្នុងស្រុកតែមួយមុខ គឺជាការប្រថុយប្រថាន ព្រោះបើមានវិបត្តិសេដ្ឋកិច្ច ឬជួបនឹងបញ្ហាផ្សេងៗនៅក្នុងស្រុក ក្រុមហ៊ុនអាចនឹងជួបប្រទះបញ្ហាហិរញ្ញវត្ថុធ្ងន់ធ្ងរ ដូចនេះការមានទិសដៅទីផ្សារផ្សេងៗគ្នាតាមរយៈការធ្វើពាណិជ្ជកម្មជាមួយនឹងបណ្តាប្រទេសដទៃ ធ្វើអោយក្រុមហ៊ុនអាចធ្វើពិពិធកម្មហានិភ័យអាជីវកម្មភូមិសាស្ត្ររបស់ពួកគេ។ ផ្តល់ឱកាសអោយក្រុមហ៊ុនពង្រីកទីផ្សារគោលដៅរបស់ពួកគេដោយផ្អែកលើសមត្ថភាពផលិត ផ្គូលដៃគូរប្រកួតប្រជែងក្នុងស្រុក ហើយអាចរកប្រាក់ចំនេញបានច្រើនតាមរយៈការប្រកួតប្រជែងជាមួយទីផ្សារបរទេស ដោយមិនចាំបាច់ពឹងផ្អែកតែលើទីផ្សារក្នុងស្រុក។ (Andreas, 2020)

**២.៨.២.ឥទ្ធិពលអវិជ្ជមាន**

- បង្ខំអោយមានជម្លោះ ៖ ដោយសារការអាស្រ័យពឹងពាក់សេដ្ឋកិច្ចលើប្រទេសដទៃ ប្រទេសខ្លះអាចត្រូវបានបង្ខំអោយចូលរួមក្នុងជម្លោះ បើទោះបីជាពួកគេមិនចង់ក៏ដោយ។
- ភាពមិនស្មើគ្នាក្នុងការទទួលផលប្រយោជន៍សេដ្ឋកិច្ច ៖ ទោះបីជាពាណិជ្ជកម្មជាមួយបណ្ដាប្រទេសផ្សេងទៀតមានសក្ដានុពលក្នុងការកែលម្អជីវភាពរស់នៅរបស់មនុស្សរាប់លាននាក់ ដោយសារការទទួលបានសុខុមាលភាពក៏ដោយ ក៏ការចែកចាយផលប្រយោជន៍ទៅលើប្រទេសទាំងនោះនៅតែមិនស្មើភាពគ្នា។ ស្របពេលដែលបណ្ដាប្រទេសខ្លះទទួលបានប្រាក់ចំនេញយ៉ាងច្រើនពីការធ្វើពាណិជ្ជកម្ម ប្រទេសខ្លះទៀតក៏អាចនឹងខាតបង់ ដោយសារពួកគេមិនអាចប្រកួតប្រជែងនៅក្នុងទីផ្សារបរទេស ហើយប្រជាជនក្នុងតំបន់នឹងទទួលរងគ្រោះ។
- និកម្មភាពនៅក្នុងតំបន់ ៖ ពាណិជ្ជកម្មសកលអាចនាំអោយភាពអត់ការងារធ្វើនៅក្នុងស្រុកកើតមានឡើង។ នៅពេលដែលសេដ្ឋកិច្ចនៃប្រទេសខ្លះមានស្ថានភាពល្អ ហើយក្រុមហ៊ុនអាចបង្កើតការងារបានច្រើន នោះប្រទេសខ្លះទៀតក៏អាចនឹងទទួលរងគ្រោះដោយសារការបាត់បង់សមត្ថភាពប្រកួតប្រជែង ជាហេតុនាំអោយមានការបាត់បង់ការងារនៅក្នុងប្រទេសនោះ។
- ក្រុមហ៊ុនខ្នាតតូចអាចនឹងត្រូវដួលរលំ ៖ ក្រុមហ៊ុនដែលមានទំហំខុសៗគ្នា ទទួលរងផលប៉ះពាល់ពីពាណិជ្ជកម្មខុសៗគ្នា។ ឧទាហរណ៍ ខណៈពេលដែលក្រុមហ៊ុនធំៗ ច្រើនតែទទួលបានប្រាក់ចំនេញពីពាណិជ្ជកម្មអន្តរជាតិ ដោយសារពួកគេមានលទ្ធភាពពង្រីកទីផ្សាររបស់ពួកគេ ក្រុមហ៊ុនតូចៗ បែរជាមិនមានឱកាសក្នុងការពង្រីកទីផ្សារនោះទេ ដោយសារត្រូវចំណាយច្រើន ហើយធនធានហិរញ្ញវត្ថុរបស់ពួកគេមានកម្រិត។ ដូច្នេះក្រុមហ៊ុនតូចៗអាចនឹងជួបប្រទះនូវបញ្ហាហិរញ្ញវត្ថុធ្ងន់ធ្ងរ ឬបាត់បង់សម្ថភាពប្រកួតប្រជែង និងអាចឈានដើងចេញពីអាជីវកម្មផងដែរ។
- ផលប៉ះពាល់ខាងក្រៅទាក់ទងនឹងការបំពុល ៖ នៅពេលដែលការប្រកួតប្រជែងកើនឡើង ក្រុមហ៊ុនទាំងអស់ធ្វើការពង្រីក និងពន្លឿនការផលិតរបស់ពួកគេ ដើម្បីទទួលបានបរិមាណច្រើន និងរហ័ស ដោយមិនគិតពីភាពអវិជ្ជមាននៃការបំភាយឧស្ម័ននោះទេ ជាលទ្ធផលបង្កអោយការបំភាយឧស្ម័នពុលប៉ះពាល់ដល់ឧស្ម័នផ្ទះកញ្ចក់ធ្ងន់ធ្ងរ និងឡើងកម្ដៅផែនដី។
- ការថយចុះធនធាន ៖ សម្រាប់ការផលិតទំនិញមួយចំនួន ត្រូវប្រើប្រាស់នូវធនធានកម្រ ដើម្បីចូលរួមក្នុងដំណើរការផលិតកម្ម។ ការផលិតកាន់តែច្រើន ដើម្បីធ្វើពណិជ្ជកម្មបណ្ដាលអោយធនធានទាំងនោះបាត់បង់បន្តិចម្ដងៗ និងអាចឈានទៅដល់ការរលាយសាបសូន្យ។

- ច្បាប់ និងបទបញ្ញត្តិ ៖ ពាណិជ្ជកម្មជាមួយប្រទេសផ្សេងក៏បញ្ជាក់អំពីតម្រូវការក្នុងការកែលម្អសកម្មភាពអាជីវកម្មដើម្បីគោរពតាមច្បាប់របស់ប្រទេសដទៃ។ ក្រុមហ៊ុនដែលចូលរួមទីផ្សារជាតិ គ្រាន់តែត្រូវគោរពតាមច្បាប់ក្នុងស្រុក ខណៈដែលក្រុមហ៊ុនដែលចូលរួមក្នុងទីផ្សារអន្តរជាតិ ត្រូវគោរពតាមក្របខ័ណ្ឌរបស់ប្រទេសដែលជាដៃគូរ។
- ស្ថិរភាពហិរញ្ញវត្ថុរបស់សមភាគីអាចចោទជាបញ្ហា ៖ ការចូលរួមក្នុងពាណិជ្ជកម្មអន្តរជាតិក៏មានហានិភ័យសមភាគីផងដែរ។ គេមិនអាចវាយតម្លៃស្ថានភាពហិរញ្ញវត្ថុនៅបរទេសបានទេ ប្រសិនបើសមភាគីនោះក្ស័យធន ក្រុមហ៊ុននឹងត្រូវមានបញ្ហាធ្ងន់ធ្ងរ ដោយការខ្ចីបុលពីភាគីម្ខាងទៀតដែលជាដៃគូរ។
- កម្មករដែលមានជំនាញចាកចេញពីប្រទេសកំណើត ៖ សាកលភាវូបនីយកម្ម និងពាណិជ្ជកម្មអន្តរជាតិអាចធ្វើអោយកម្មករដែលមានជំនាញចាកចេញពីប្រទេសកំណើតដោយសារតែប្រាក់ឈ្នួលនៅប្រទេសផ្សេងថ្លៃជាង ហើយបន្សល់ទុកកម្មករគ្មានជំនាញនៅក្នុងប្រទេស ដែលជាហេតុធ្វើអោយមិនមានសក្តានុពលគ្រប់គ្រាន់ក្នុងការរីកចម្រើនសេដ្ឋកិច្ចរយៈពេលវែង។
- អត្រាប្តូរប្រាក់ខុសគ្នាតាមពេលវេលា ៖ ក្នុងការធ្វើពាណិជ្ជកម្ម គឺផ្សារភ្ជាប់នឹងការមានហានិភ័យក្នុងអត្រាប្តូរប្រាក់។ ពេលខ្លះគេត្រូវចំណាយច្រើនក្នុងដំណើរការផលិតកម្ម ប៉ុន្តែទំរាំតែទំនិញទៅដល់បរទេសអាត្រាប្តូរប្រាក់ស្រាប់តែធ្លាក់ចុះ ដូចនេះអាចនឹងធ្វើអោយក្រុមហ៊ុនក្នុងស្រុកជួបបញ្ហានាពេលខាងមុខ។ (Arkolakis, 2020)

# ជំពូកទី ៣

# ពិភាក្សា និងវិភាគលទ្ធផល

## ៣.១.ការកំណត់ និងពន្យល់អថេរវិភាគ

គោលបំណងនៃការសិក្សានេះ គឺដើម្បីវិភាគអោយឃើញពីឥទ្ធិពលនៃការនាំចេញ និងនាំចូលរបស់កម្ពុជាជាមួយបណ្តាប្រទេសអាស៊ាន មកលើកំណើនសេដ្ឋកិច្ចនៅប្រទេសកម្ពុជា ។ ការសិក្សានេះយើងបានជ្រើសរើសអថេរពន្យល់ចំនួន ២ រួមមាន X និង M ហើយអថេរអាស្រ័យដើម្បីសិក្សាពីឥទ្ធិពលនៃអថេរពន្យល់ គឺកំណើនផលិតផលក្នុងស្រុកសរុប ( GDP Growth ) ។

ដើម្បីសិក្សាពីទំនាក់ទំនងនេះ យើងនឹងយកទិន្នន័យនៃ ការនាំចេញ និងនាំចូល ជាមួយនឹងប្រទេសទាំងបីពីឆ្នាំ ២០១០ ដល់ ឆ្នាំ ២០២០ មកពន្យល់ និងបង្ហាញពីឥទ្ធិពលរាល់ឆ្នាំនីមួយៗ ដែល ៖

X : ជាទំហំទឹកប្រាក់នៃការនាំចេញសរុបរបស់កម្ពុជាប្រចាំឆ្នាំ

M : ជាទំហំទឹកប្រាក់នៃការនាំចូលសរុបរបស់កម្ពុជាប្រចាំឆ្នាំ

GDP : ជាកំណើនផលិតផលក្នុងស្រុកសរុបប្រចាំឆ្នាំ

## ៣.២.ការវិភាគទិន្នន័យ

### ៣.២.១.វិភាគទំហំពាណិជ្ជកម្មរបស់កម្ពុជាជាមួយបណ្តាប្រទេសទាំងបី

រាល់បណ្តាទិន្នន័យខាងក្រោមនេះ ជាតារាងទិន្នន័យសម្រាប់ធ្វើការពន្យល់ និងវិភាគ ដែលរាល់ទិន្នន័យគឺដកស្រង់ចេញពី ធនាគារពិភពលោក និង ក្រសួងពាណិជ្ជកម្មរបស់ប្រទេសកម្ពុជា នៅចន្លោះពីឆ្នាំ ២០១០ រហូតដល់ឆ្នាំ ២០២០ ។

តារាងទី៣.១ ៖ ទិន្នន័យនៃការនាំចេញ និងនាំចូលសរុបរបស់កម្ពុជាជាមួយនឹងប្រទេសថៃ ( លានដុល្លារ )

| | 2010 | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | 2020 |
|---|---|---|---|---|---|---|---|---|---|---|---|
| X | 149.91 | 190.22 | 96.36 | 221.22 | 49.99 | 346.20 | 419.85 | 431.15 | 313.44 | 502.1 | 650.67 |
| M | 993.43 | 725.52 | 1001.13 | 1086.08 | 1047.40 | 1561.49 | 1910.04 | 2355.67 | 3222.08 | 3222.44 | 2835.56 |
| X-M | -843.5 | -535.3 | -904.7 | -864.86 | -997.4 | -1215.2 | -1490.1 | -1924.5 | -2908.6 | -2720.3 | -2184.8 |

ប្រភព៖ ក្រសួងពាណិជ្ជកម្ម

• នៅក្នុងឆ្នាំ ២០១០ ការនាំចេញសរុបរបស់ប្រទេសកម្ពុជាមានចំនួន ១៤៩.៩១ លានដុល្លារ ហើយការនាំចូលសរុបមានចំនួន ៩៩៣.៤៣ លានដុល្លារ នេះបានបញ្ជាក់អោយឃើញថាប្រទេសកម្ពុជាមានឱនភាពពាណិជ្ជកម្មដែលគិតជាទឹកប្រាក់ប្រមាណ ៨៤៣.៥ លានដុល្លារ។

• នៅក្នុងឆ្នាំ ២០១៣ ការធ្វើពាណិជ្ជកម្មរបស់កម្ពុជាមានការកើនឡើង ដែលក្នុងនោះការនាំចេញសរុបមានចំនួន ២២១.២២ លានដុល្លារ ហើយការនាំចូលមកវិញមានចំនួន ១០៨៦.០៨ លានដុល្លារ ពោលគឺការនាំចេញនៅមានចំនួនតិចតួចនៅឡើយ ដែលជាហេតុបានធ្វើអោយឱនភាពពាណិជ្ជកម្មកើនឡើងរហូតដល់ ៨៦៤.៨៦ លានដុល្លារ។

• នៅក្នុងឆ្នាំ ២០១៦ ប្រទេសកម្ពុជាបាននាំចេញទៅប្រទេសថៃចំនួន ៤១៩.៨៥ លានដុល្លារ ហើយការនាំចូលមកវិញក៏មានចំនួនច្រើនសន្ធឹកសន្ធាប់ផងដែរពោលគឺកើនឡើងរហូតដល់ ១៩១០.០៤ លានដុល្លារ និងបានធ្វើអោយឱនភាពពាណិជ្ជកម្មហក់ឡើងដល់ ១៤៩០.១ លានដុល្លារ។

• ចំណែកឯនៅក្នុងឆ្នាំ ២០១៩ ប្រទេសកម្ពុជាបានបន្តបង្កើនការនាំចេញរហូតដល់ ៥០២.១ លានដុល្លារ ហើយការនាំចូលមកវិញមានចំនួន ៣២២២.៤៤ លានដុល្លារ ដែលធ្វើអោយឱនភាពពាណិជ្ជកម្មរបស់កម្ពុជាមានចំនួន ២៧២០.៣ លានដុល្លារ។

តារាងទី៣.២ ៖ ទិន្នន័យនៃការនាំចេញ និងនាំចូលសរុបរបស់កម្ពុជាជាមួយនឹងប្រទេសវៀតណាម (លានដុល្លារ)

| | 2010 | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | 2020 |
|---|---|---|---|---|---|---|---|---|---|---|---|
| X | 96.03 | 148.63 | 111.66 | 103.75 | 96.80 | 185.65 | 230.84 | 325.83 | 361.81 | 335.82 | 385.79 |
| M | 501.17 | 881.76 | 1,055.16 | 982.29 | 870.14 | 926.97 | 1,415.99 | 1,682.29 | 2220.96 | 2718.19 | 2633.81 |
| X-M | -405.1 | -733.1 | -943.5 | -878.5 | -773.3 | -741.3 | -1185.1 | -1356.4 | -1859.1 | -2382.3 | -2248.0 |

ប្រភព៖ ក្រសួងពាណិជ្ជកម្ម

• នៅក្នុងឆ្នាំ ២០១០ ប្រទេសកម្ពុជាបានធ្វើការនាំចេញទៅកាន់ប្រទេសវៀតណាមបានចំនួន ៩៦.០៣ លានដុល្លារ ហើយធ្វើការនាំចូលមកវិញចំនួន ៥០១.១៧លានដុល្លារ ដែលនៅក្នុងឆ្នាំនោះ ប្រទេសកម្ពុជាមានឱនភាពពាណិជ្ជកម្ម ៤០៥.១ លានដុល្លារ។

• ក្នុងឆ្នាំ ២០១៣ កម្ពុជាបានបង្កើនការនាំចេញទៅប្រទេសវៀតណាមបានចំនួន ១០៣.៧៥ លានដុល្លារ ស្របពេលដែលការនាំចូលក៏មានទំហំទឹកប្រាក់ច្រើនដូចគ្នាគឺមានចំនួន ៩៨២.២៩ លានដុល្លារ ហើយឱនភាពពាណិជ្ជកម្មបានកើនរហូតដល់ ៨៧៨.៥ លានដុល្លារ។

• បីឆ្នាំបានកន្លងផុតទៅពោលគឺនៅឆ្នាំ ២០១៦ ប្រទេសកម្ពុជាបាននាំចេញក្នុងចំនួនទឹកប្រាក់ ២៣០.៨៤ លានដុល្លារ និងធ្វើការនាំចូលមកវិញចំនួន ១៤១៥.៩៩ លានដុល្លារ ដែលបានធ្វើអោយឱនភាពពាណិជ្ជកម្មបន្តកើនឡើងរហូតដល់ ១១៨៥.១ លានដុល្លារ។

• នៅក្នុងឆ្នាំ ២០១៩ ប្រទេសកម្ពុជាបាននាំចេញទៅកាន់ប្រទេសវៀតណាមក្នុងទំហំទឹកប្រាក់ ៣៣៥.៨២ លានដុល្លារ និងបានធ្វើការនាំចូលមកវិញក្នុងទំហំទឹកប្រាក់ចំនួន ២៧១៨.១៩ លានដុល្លារ ដែលធ្វើអោយពាណិជ្ជកម្មមានឱនភាពចំនួន ២៣៨២.៣ លានដុល្លារ។

តារាងទី៣.៣ ៖ ទិន្នន័យនៃការនាំចេញ និងនាំចូលសរុបរបស់កម្ពុជាជាមួយនឹងប្រទេសឡាវ ( លានដុល្លារ )

| | 2010 | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | 2020 |
|---|---|---|---|---|---|---|---|---|---|---|---|
| X | 0.88 | 1.23 | 1.85 | 0.58 | 0.11 | 5.45 | 5.70 | 5.78 | 7.3 | 7.59 | 43.5 |
| M | 1.50 | 0.92 | 4.63 | 5.37 | 6.76 | 20.17 | 21.48 | 4.49 | 1.69 | 15.18 | 60.5 |
| X-M | -0.62 | 0.31 | -2.78 | -4.79 | -6.65 | -14.72 | -15.78 | 1.29 | 5.61 | -7.59 | -17 |

ប្រភព៖ ក្រសួងពាណិជ្ជកម្ម

• នៅក្នុងឆ្នាំ ២០១០ ប្រទេសកម្ពុជាបានធ្វើការនាំចេញទៅប្រទេសឡាវក្នុងទំហំទឹកប្រាក់ ០.៨៨ លានដុល្លារ និងបានធ្វើការនាំចូលមកវិញក្នុងទំហំទឹកប្រាក់ ១.៥០ លានដុល្លារ ដែលកម្ពុជាមានឱនភាពតិចតួចប៉ុណ្ណោះគឺចំនួន ០.៦២ លានដុល្លារ។

• នៅក្នុងឆ្នាំ ២០១៣ ប្រទេសកម្ពុជាបានធ្វើការនាំចេញតិចតួចប៉ុណ្ណោះគឺមានទឹកប្រាក់ប្រមាណ ០.៥៨ លានដុល្លារ តែការនាំចូលបែរជាមានការកើនឡើងរហូតដល់ ៥.៣៧ លានដុល្លារ ដែលបានធ្វើអោយជញ្ជីងពាណិជ្ជកម្មកម្ពុជាមានឱនភាពចំនួន ៤.៧៩ លានដុល្លារ។

• នៅក្នុងឆ្នាំ ២០១៦ ការនាំចេញបានកើនរហូតដល់ ៥.៧០ លានដុល្លារ ក៏ប៉ុន្តែការនាំចូលបែរជាមានច្រើនលើសលប់ ពោលគឺមានទឹកប្រាក់សរុបចំនួន ២១.៤៨ លានដុល្លារ ដែលបានធ្វើអោយឱនភាពពាណិជ្ជកម្មកើនឡើងរហូតដល់ ១៥.៧៨ លានដុល្លារ។

• នៅក្នុងឆ្នាំ ២០១៩ ប្រទេសកម្ពុជាបាននាំចេញក្នុងទឹកប្រាក់សរុបចំនួន ៧.៥៩ លានដុល្លារ និងបានកាត់បន្ថយការនាំចូលសល់ត្រឹម ១៥.១៨ លានដុល្លារ ដែលនេះជាសញ្ញាល្អ និងបានធ្វើអោយឱនភាពពាណិជ្ជកម្មធ្លាក់ចុះមកត្រឹម ៧.៥៩ លានដុល្លារ។

សរុបមកការធ្វើពាណិជ្ជកម្មរបស់ប្រទេសកម្ពុជា ជាមួយនឹងបណ្តាប្រទេសទាំងបីគឺមានទំហំកើនឡើងជា

រៀងរាល់ឆ្នាំ ក៏ប៉ុន្តែគេសង្កេតឃើញថា ប្រទេសកម្ពុជាបានធ្វើការនាំចេញនៅក្នុងទំហំទឹកប្រាក់តិចតួចប៉ុណ្ណោះ ហើយការនាំចូលគឺមានទំហំទឹកប្រាក់ច្រើនជារៀងរាល់ឆ្នាំ ដែលជាហេតុបណ្ដាលអោយប្រទេសកម្ពុជាមានឱនភាពពាណិជ្ជកម្ម។ បើទោះបីជាការនាំចេញ មានទំហំតិចតួច ក៏ប្រទេសកម្ពុជានៅតែព្យាយាមបង្កើនការនាំចេញ និងកាត់បន្ថយនូវការនាំចូល ដើម្បីធ្វើអោយជញ្ជីងពាណិជ្ជកម្មរបស់កម្ពុជាមានឧត្តមភាពនៅពេលអនាគត។

**៣.៣.២.វិភាគទំហំពាណិជ្ជកម្មជាមួយប្រទេសទាំងបី ជាមួយនឹងទំហំពាណិជ្ជកម្មសរុបរបស់កម្ពុជា**

នៅក្នុងការប្រៀបធៀបនេះ គឺគោលបំណងសំខាន់គឺចង់បង្ហាញអោយឃើញថា តើការធ្វើពាណិជ្ជកម្មរបស់កម្ពុជាជាមួយនឹងប្រទេសទាំងបីមានទំហំប៉ុណ្ណា បើយើងធៀបជាមួយនឹងទំហំពាណិជ្ជកម្មសរុបរបស់ប្រទេសកម្ពុជា ព្រមទាំងបង្ហាញអោយឃើញពីកំណើនពាណិជ្ជកម្មចាប់ពីឆ្នាំ ២០១០ ដល់ ២០២០។

ទិន្នន័យដែលបានបង្ហាញខាងក្រោមនេះ បានមកពីការបូកបញ្ចូលទិន្នន័យខាងលើ ហើយធ្វើការគណនាតាមរយៈ Excel

| ឆ្នាំ | ទំហំពាណិជ្ជកម្មសរុបរបស់កម្ពុជា(លានដុល្លារ) | ទំហំពាណិជ្ជកម្មជាមួយប្រទេសទាំងបី(លានដុល្លារ) | ភាគរយ |
|---|---|---|---|
| 2010 | 10,506.81 | 1,742.92 | 16.59% |
| 2011 | 12,830.58 | 1,948.28 | 15.18% |
| 2012 | 13,262.98 | 2,270.79 | 17.12% |
| 2013 | 14,897.45 | 2,399.29 | 16.11% |
| 2014 | 16,548.43 | 2,071.2 | 12.52% |
| 2015 | 19,211.35 | 3,045.93 | 15.85% |
| 2016 | 22,444.14 | 4,003.9 | 17.84% |
| 2017 | 25,562.67 | 4,805.21 | 18.80% |
| 2018 | 24,985.00 | 6,127.28 | 24.52% |
| 2019 | 34,918.9 | 6,801.32 | 19.48% |
| 2020 | 35,805.85 | 6,609.83 | 18.46% |

- នៅក្នុងឆ្នាំ ២០១០ គេឃើញថាទំហំពាណិជ្ជកម្មរបស់កម្ពុជាមានរហូតដល់ ១០៥០៦.៨១ លានដុល្លារ ដែលនៅក្នុងនោះការធ្វើពាណិជ្ជកម្មរបស់កម្ពុជា ជាមួយប្រទេសទាំងបីមានចំនួន ១៧៤២.៩២ លានដុល្លារ បើយើងគិតជាភាគរយមានប្រមាណ ១៦.៥៩%។
- នៅឆ្នាំ ២០១៣ ទំហំពាណិជ្ជកម្មរបស់កម្ពុជាបានបន្តកើនឡើងរហូតដល់ ១៤៨៩៧.៤៥ លានដុល្លារ ហើយនៅក្នុងនោះមានការចូលរួមចំណែកចំនួន ១៦.១១% ពីការធ្វើពាណិជ្ជកម្មជាមួយប្រទេសទាំងបី
- នៅឆ្នាំ ២០១៦ គេសង្កេតឃើញថាការធ្វើពាណិជ្ជកម្មរបស់កម្ពុជាបានលោតដល់ ២២៤៤៤.១៤ លានដុល្លារ ហើយការធ្វើពាណិជ្ជកម្មជាមួយប្រទេសជាប់ព្រំទល់មានចំនួន ៤០០៣.៩ លានដុល្លារ ដែលគិតជាភាគរយមានចំនួន ១៧.៨៤%។
- នៅក្នុងឆ្នាំ ២០១៩ ប្រទេសកម្ពុជាមានទំហំពាណិជ្ជកម្មសរុបចំនួន ៣៤៩១៨.៩ លានដុល្លារ ហើយការធ្វើពាណិជ្ជកម្មជាមួយប្រទេសជិតខាងបានកើនដល់ ៦៨០១.៣២ លានដុល្លារ ដែលគិតជាភាគរយមានប្រមាណ ១៩.៤៨%។

ដូចនេះសរុបមកគេសង្កេតឃើញថា ការធ្វើពាណិជ្ជកម្មអន្តរជាតិរបស់ប្រទេសកម្ពុជាពិតមានកើនឡើងតាមរយៈការធ្វើពាណិជ្ជកម្មជាមួយប្រទេសជិតខាង ពោលគិតជាមធ្យមគឺមានការចូលរួមចំនួន ១៧.៥% ជារៀងរាល់ឆ្នាំ ដែលនេះជាសញ្ញាល្អនៃទំនាក់ទំនងខាងផ្នែកពាណិជ្ជកម្ម និងធ្វើអោយពាណិជ្ជកម្មកម្ពុជាកាន់តែមានភាពប្រសើរឡើង។

### ៣.៣.៣.ការវិភាគពាណិជ្ជកម្មជាមួយប្រទេសទាំងបីជាមួយពាណិជ្ជកម្មសរុបរបស់អាស៊ាន

នៅក្នុងផ្នែកនេះ យើងនឹងធ្វើការប្រៀបធៀបនៃការធ្វើពាណិជ្ជកម្មរបស់ប្រទេសកម្ពុជាជាមួយប្រទេសទាំងបី ជាមួយនឹងការធ្វើពាណិជ្ជកម្មសរុបរបស់អាស៊ាន។ បើទោះបីជាយើងបានដឹងហើយថា ការធ្វើពាណិជ្ជកម្មរបស់ប្រទេសកម្ពុជា នៅមានកម្រិតនៅឡើយ ក៏ប៉ុន្តែកំណើនក៏ចេះតែមានការកើនឡើងជារៀងរាល់ឆ្នាំ។

| ឆ្នាំ | ទំហំពាណិជ្ជកម្មសរុបរបស់អាស៊ាន | ទំហំពាណិជ្ជកម្មជាមួយប្រទេសទាំងបី | ភាគរយ |
|---|---|---|---|
| 2010 | 502,863.80 | 1,742.92 | 0.347% |
| 2011 | 582,937.90 | 1,948.28 | 0.334% |
| 2012 | 605,640.20 | 2,270.79 | 0.375% |
| 2013 | 617,751.70 | 2,399.29 | 0.388% |
| 2014 | 608,113.80 | 2,071.20 | 0.341% |
| 2015 | 535,380.40 | 3,045.93 | 0.569% |
| 2016 | 517,954.40 | 4,003.90 | 0.773% |
| 2017 | 589,116.70 | 4,805.21 | 0.816% |
| 2018 | 648,785.30 | 6,127.28 | 0.944% |
| 2019 | 632,604.30 | 6,801.32 | 1.075% |

ទិន្នន័យខាងលើ ជាការបង្រួមបញ្ចូលគ្នានៃតារាង( នៅក្នុងឧបសម្ព័ន្ធទី ៩) និងត្រូវបានធ្វើការគណនាតាមរយៈ Excel ដោយគិតជាភាគរយនៃទំហំពាណិជ្ជកម្មជាមួយប្រទេសទាំងបី ធៀបនឹងទំហំពាណិជ្ជកម្មរបស់អាស៊ាន។

- នៅក្នុងឆ្នាំ ២០១០ គេសង្កេតឃើញថា ទំហំពាណិជ្ជកម្មសរុបរបស់អាស៊ានមានចំនួន ៥០២៨៦៣.៨ លានដុល្លារ ហើយទំហំពាណិជ្ជកម្មរបស់កម្ពុជាជាមួយប្រទេសជិតខាងមានចំនួន ១៧៤២.៩២ លានដុល្លារ គិតជាភាគរយប្រមាណ ០.៣៤៧%។
- នៅក្នុងឆ្នាំ ២០១៣ ទំហំពាណិជ្ជកម្មរបស់អាស៊ានបានកើនឡើងរហូតដល់ ៦១៧៧៥១.៧ លានដុល្លារ ហើយទំហំពាណិជ្ជកម្មរបស់កម្ពុជាជាមួយប្រទេសទាំងបីមានចំនួន ០.៣៨៨% ពោលគឺបានកើនឡើងចំនួន ០.០៤១%។
- ក្នុងឆ្នាំ ២០១៦ ទំហំពាណិជ្ជកម្មអាស៊ានបានធ្លាក់ចុះមកត្រឹម ៥១៧៩៥៤.៤ លានដុល្លារ ពោលគឺមានការធ្លាក់ចុះប្រមាណជា ១៦.១៥%ធៀបនឹងឆ្នាំ ២០១៣ ក៏ប៉ុន្តែទំហំពាណិជ្ជកម្មរបស់កម្ពុជាជាមួយប្រទេសជិតខាងនៅតែបន្តកើនឡើងគឺមានប្រមាណ ០.៧៧៣%។
- នៅក្នុងឆ្នាំ ២០១៩ ទំហំពាណិជ្ជកម្មអាស៊ានបានងើបឡើងមកវិញដល់ ៦៣២៦០៤.៣ លានដុល្លារ ដែលចំនួននេះមានការកើនឡើងប្រមាណ ២២% ហើយទំហំពាណិជ្ជកម្មរបស់កម្ពុជាជាមួយប្រទេសទាំងបីក៏បានកើនឡើងដល់ ១.០៧៥%។

សរុបមកបើទោះបីជា ទំហំពាណិជ្ជកម្មរបស់ប្រទេសកម្ពុជាជាមួយនឹងប្រទេសជាប់ព្រំប្រទល់នៅមានទំហំតូច បើប្រៀបធៀបជាមួយនឹងទំហំពាណិជ្ជកម្មសរុបរបស់អាស៊ាន ក៏ប៉ុន្តែគេសង្កេតឃើញថាការធ្វើពាណិជ្ជកម្មរបស់កម្ពុជាបាននឹងបន្តកើនឡើងជារៀងរាល់ឆ្នាំ ដែលនេះជាសញ្ញាល្អមួយបង្ហាញអោយឃើញពីសក្តានុពលពាណិជ្ជកម្មរបស់ប្រទេសកម្ពុជា ហើយគេជឿជាក់ថាការធ្វើពាណិជ្ជកម្មរបស់កម្ពុជានឹងរីកចម្រើននាពេលអនាគត។

### ៣.៤.ឥទ្ធិពលនៃកូវីដ-១៩មកលើពាណិជ្ជកម្មកម្ពុជា

ជំងឺកូវីដ-១៩ បានគម្រាមកំហែងយ៉ាងខ្លាំងទៅលើសកម្មភាពសេដ្ឋកិច្ចទៅលើវិស័យផ្សេងៗនៃការអភិវឌ្ឍរបស់ប្រទេសកម្ពុជា ខណៈដែលវិស័យទេសចរណ៍ ផលិតកម្មសម្រាប់ការនាំចេញ និងវិស័យសំណង់ត្រូវបានគេមើលឃើញថាជាវិស័យដែលបានរងផលប៉ះពាល់ខ្លាំងបំផុត។ ជាការពិត នៅពេលរួមបញ្ចូលគ្នាវិស័យទាំងបីខាងលើនេះបានចូលរួមចំណែកច្រើនជាង ៧០ ភាគរយនៃកំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា និងបង្កើតការងារប្រហែលជា ៣៩,៥ ភាគរយនៃការងារសរុបនៅក្នុងឆ្នាំ ២០១៩។

ការផ្ទុះឡើងនៃជំងឺកូវីដ-១៩ បានធ្វើឲ្យការនាំចេញរបស់កម្ពុជាលើវិស័យវាយណភ័ណ្ឌ ស្បែកជើង និង

ទំនិញសម្រាប់ធ្វើដំណើរបានកើនឡើងត្រឹមតែ ៧,៥ ភាគរយប៉ុណ្ណោះ ក្នុងរយៈពេល ៣ ខែដំបូងនៃឆ្នាំ ២០២០ ដែលស្មើនឹងការធ្លាក់ចុះ ១៧,៧ ភាគរយបើប្រៀបធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ ២០១៩។ ការធ្លាក់ចុះនេះកើតឡើងដោយសារការធ្លាក់ចុះ ០,៥ ភាគរយនៃការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងទំនិញសម្រាប់ការធ្វើដំណើរទៅកាន់ទីផ្សារអឺរ៉ុប (រួមទាំងចក្រភពអង់គ្លេស) ដែលនេះជាការធ្លាក់ចុះជាលើកដំបូងចាប់តាំងពីវិបត្តិហិរញ្ញវត្ថុពិភពលោកឆ្នាំ ២០០៨-២០០៩។ ខណៈដែលកំណើនក្នុងវិស័យឧស្សាហកម្មត្រូវបានគេព្យាករណ៍ថានឹងថយចុះមកនៅត្រឹម ៦,៥ ភាគរយ ក្នុងឆ្នាំ ២០២០ ជាមួយនឹងការធ្លាក់ចុះនៃផលិតកម្មសម្លៀកបំពាក់សម្រាប់ការនាំចេញ និងសំណង់។ ការណ៍នេះជាលទ្ធផលនៃកំណើនដ៏យឺតយ៉ាវនៅក្នុងសេដ្ឋកិច្ចនៃបណ្ដាប្រទេសជឿនលឿនធំៗ និងការធ្លាក់ចុះសេដ្ឋកិច្ចយ៉ាងខ្លាំងនៃសាធារណរដ្ឋប្រជាមានិតចិន និងជាពិសេសការដកផ្នែកខ្លះនៃប្រព័ន្ធអនុគ្រោះពន្ធពាណិជ្ជកម្មរបស់សហភាពអឺរ៉ុបពីប្រទេសកម្ពុជាដែលបានចាប់ផ្ដើមនៅដើមខែសីហាក្នុងឆ្នាំ ២០២០[57]។ ជាការពិតណាស់ លំហូរចូលនៃវិនិយោគដោយផ្ទាល់ពីបរទេស (FDI) មានជាង ៥0 ភាគរយនៃវិនិយោគសរុបនៅកម្ពុជាភាគច្រើនផ្ដោតលើវិស័យសំណង់ ដែលមានប្រភពមកពីប្រទេសចិន (រួមទាំងហុងកុង) និងតៃវ៉ាន់ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។ ទោះជាយ៉ាងណាក៏ដោយ បន្ទាប់ពីការរីករាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងប្រទេសចិនមក ការវិនិយោគផ្ទាល់ពីបរទេសមានការធ្លាក់ចុះយ៉ាងខ្លាំង។ ជាក់ស្ដែងកាលពីឆ្នាំ ២០១៩ កំណើននៃការវិនិយោគមានប្រមាណជា ១១ ពាន់លានដុល្លារ ពោលគឺកើនឡើងជិតទ្វេដងពី ៥,៥ ពាន់លានដុល្លារនៅក្នុងឆ្នាំ ២០១៨។ យ៉ាងណាក៏ដោយ យោងតាមរបាយការណ៍ចុងក្រោយរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឱ្យដឹងថា ការរាតត្បាតនៃជំងឺកូវីដ-១៩បាននាំឱ្យការវិនិយោគមានអត្រាធ្លាក់ចុះចំនួន ៥,៣ ភាគរយក្នុងឆ្នាំ ២០២០ ដោយសារតែការថមថយនៃការវិនិយោគផ្ទាល់ពីប្រទេសចិន។[58]

វិបត្តិសេដ្ឋកិច្ចនេះនឹងបន្តឱ្យមានផលប៉ះពាល់រយៈពេលមធ្យមលើភាពក្រីក្រ និងសុខុមាលភាព ជាពិសេសក្នុងចំណោមជនងាយរងគ្រោះនៅក្នុងសង្គម និងអ្នកដែលធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ ជំងឺរាតត្បាតកូវីដ-១៩នឹងធ្វើឱ្យក្រុមជនងាយរងគ្រោះជាក់លាក់មួយចំនួន រួមមានស្ត្រី កុមារ ជនជាតិដើមភាគតិច និងពលករចំណាកស្រុករងផលប៉ះពាល់កាន់តែធ្ងន់ធ្ងរ ដោយសារតែភាពអត់ការងារធ្វើ និងកង្វះការងារសម្រាប់អ្នកប្រកបរបរនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ[59]។ យោងតាមអង្គការពលកម្មអន្តរជាតិ (ILO) បានប៉ាន់ប្រមាណថា កម្មករធ្វើការនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធជិត ១,៦ ពាន់លាននាក់បានរងផលប៉ះពាល់ទៅលើសមត្ថភាពក្នុងការរកចំណូល

---

[57] ធនាគារអភិវឌ្ឍន៍អាស៊ី(ADB)"ទស្សនវិស័យអភិវឌ្ឍន៍អាស៊ីឆ្នាំ២០២០៖ផលប៉ះពាល់នៃការផ្ទុះឡើងនៃជំងឺកូវីដ១៩ និងការធ្វើបច្ចុប្បន្នភាព", ខែមេសា ឆ្នាំ២០២០

[58] "វិស័យសំណង់ទទួលរងផលប៉ះពាល់ពីកូវីដ១៩"ឈុត ប៊ុនធឿន, ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២០

[59] អង្គការស្បៀងអាហារ និងកសិកម្មនៃអង្គការសហប្រជាជាតិ(FAO) "ផលប៉ះពាល់នៃកូវីដ១៩ទៅលើសេដ្ឋកិច្ចក្រៅប្រព័ន្ធ", ថ្ងៃទី៨ ខែមេសា ឆ្នាំ២០២០

ដោយសារតែការវិធានការណ៍បិទប្រទេស និងវិធានការណ៍ផ្សេងៗទៀតក្នុងការបង្ការការរីករាលដាលនៃជំងឺកូវីដ-១៩ និងដោយសារតែពួកគេធ្វើការនៅក្នុងវិស័យដែលរងគ្រោះខ្លាំងបំផុតស្រាប់[60]។ ចំពោះប្រទេសកម្ពុជា ស្ថានភាពកាន់តែមានលក្ខណៈពិបាកនៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ពីព្រោះកម្មករកាត់ដេរបានរួមចំណែកខ្លាំងក្នុងការជំរុញសេដ្ឋកិច្ចដល់អ្នកលក់អាហារតាមចិញ្ចើមថ្នល់ ហាងកាត់សក់ និងអ្នកផ្តល់សេវាដឹកជញ្ជូន។ តាមការសិក្សាកន្លងមកបានប៉ាន់ប្រមាណថាប្រាក់ឈ្នួលដែលកម្មករទទួលបាននៅក្នុងវិស័យកាត់ដេរអាចធ្វើការគាំទ្រសកម្មភាពសេដ្ឋកិច្ចមនុស្សពី ៥ ទៅ ៦ នាក់ក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធតាមរយៈការជំរុញសេដ្ឋកិច្ចក្នុងស្រុក

ដូច្នេះភាពអត់ការងារធ្វើរបស់កម្មកររោងចក្របានធ្វើឲ្យប៉ះពាល់បន្តដល់អ្នកប្រកបរបរនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធគួរឱ្យកត់សម្គាល់។ ស្របពេលគ្នានេះដែរ ការផ្ទេរប្រាក់ពីបរទេសមានការថយចុះយ៉ាងខ្លាំង។ យោងតាមក្រុមហ៊ុន Emerging Markets Consulting (EMC)ប្រទេសកម្ពុជាអាចខាតបង់ប្រហែលជា ៩០ លានដុល្លារសម្រាប់ការផ្ទេរប្រាក់របស់ពលករខ្មែរពីប្រទេសថៃក្នុងរយៈពេល ៦ ខែ។ ខណៈទិន្នន័យត្រីមាសទី ១ ឆ្នាំ ២០២០ ពីធនាគារអេស៊ីលីដាភីអិលស៊ីបង្ហាញថា ការផ្ញើប្រាក់របស់ពលករខ្មែរដែលធ្វើការនៅសាធារណរដ្ឋកូរ៉េមានចំនួន ៣,៥ លានដុល្លារដោយមានចំនួនប្រតិបត្តិការ ១.៣៧៣ ក្នុងឆ្នាំ២០២០ ធ្លាក់ចុះជិតពាក់កណ្តាលពី ៦,២ លានដុល្លារដោយមានប្រតិបត្តិការចំនួន ២.២៧០ ក្នុងរយៈពេលដូចគ្នាកាលពីឆ្នាំមុន[61]។ បន្ទាប់ពីកំណើនសេដ្ឋកិច្ចល្អក្នុងរយៈពេលពីរទសវត្ស កំណើនសេដ្ឋកិច្ចប្រទេសកម្ពុជាត្រូវបានរំពឹងថានឹងធ្លាក់ចុះវិញនៅឆ្នាំ ២០២០ នេះ។ ការធ្លាក់ចុះនេះ ដោយសារតែផលប៉ះពាល់នៃការរីករាលដាលជំងឺកូវីដ-១៩ និងមួយផ្នែកទៀតដោយសារតែការធ្លាក់ចុះសេដ្ឋកិច្ចនៃប្រទេសមានសេដ្ឋកិច្ចជឿនលឿន និងសាធារណរដ្ឋប្រជាមានិតចិន បូករួមជាមួយការធ្លាក់ចុះនៃការនាំចេញទៅកាន់ទីផ្សារនាំចេញទៅអឺរ៉ុបនេះបើយោងតាមធនាគារអភិវឌ្ឍនអាស៊ី។[62]

យោងតាមការបង្ហាញខាងលើនេះ អ្នកដែលធ្វើការសិក្សាស្រាវជ្រាវជំនាន់ក្រោយៗទៀតអាចលើកយកនូវប្រធានបទមួយចំនួនមកធ្វើការសិក្សាស្រាវជ្រាវ ដែលទាក់ទងទៅនឹង ៖

- ឥទ្ធិពលនៃកូវីត ១៩ ទៅលើសេដ្ឋកិច្ចប្រទេសសមាជិកអាស៊ាន
- ស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជានាសម័យកូវីត ១៩
- ការស្តារសេដ្ឋកិច្ចឡើងវិញក្រោយពីសម័យកូវីត ១៩ ។

[60] អង្គការពលកម្មអន្តរជាតិ(ILO)"ដោយសារការបាត់បង់ការងារចេះតែកើនឡើងស្ទើពាក់កណ្តាលនៃកម្លាំងពលកម្មពិភពលោកនឹងមានហានិភ័យលើជីវភាពរស់នៅ",ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២០

[61] VietnamPlus"ការផ្ទេរប្រាក់ពីបរទេសមកកម្ពុជាមានការធ្លាក់ចុះយ៉ាងខ្លាំងដោយសារកូវីដ១៩", ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០

[62] ធនាគារអភិវឌ្ឍន៍អាស៊ី(ADB)"កំណើនសេដ្ឋកិច្ចរបស់កម្ពុជាមានសភាពយឺតនៅឆ្នាំ២០២០ ហើយរំពឹងថានឹងមានសន្ទុះងើបលើងវិញនៅឆ្នាំ២០២១", ថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ១.សេចក្តីសន្និដ្ឋាន

តាមរយៈការសិក្សាស្រាវជ្រាវពី "នយោបាយពាណិជ្ជកម្មអន្តរជាតិរបស់កម្ពុជាជាមួយអាស៊ាន" ក្នុងដែនកំណត់លើករណីសិក្សារបស់ប្រទេសកម្ពុជាជាមួយនឹងប្រទេស ថៃ ឡាវ និងវៀតណាម យើងសង្កេតឃើញថា ការធ្វើពាណិជ្ជកម្មជាមួយប្រទេសទាំងបីនេះ គឺដើម្បីទទួលបានផលប្រយោជន៍ និងផលចំនេញសេដ្ឋកិច្ច។ ការនាំចេញ នាំចូលត្រូវតែមានកិច្ចព្រមព្រៀងច្បាស់លាស់ និងការប្រើប្រាស់ឧបករណ៍នយោបាយត្រឹមត្រូវ។ ជាក់ស្តែងការធ្វើពាណិជ្ជកម្ម តែងមានចំនេញ មានខាតប្រៀបដូចជាអាជីវកម្មទូទៅដូច្នោះដែរ។ ប៉ុន្តែគ្រាន់តែយុទ្ធសាស្ត្រ និងគោលនយោបាយដែលកំណត់ដោយរាជរដ្ឋាភិបាល ដើរតួនាទីយ៉ាងសំខាន់ក្នុងការកំណត់ជោគជតាសេដ្ឋកិច្ចពាណិជ្ជកម្មរបស់ប្រទេស ដែលខុសពីអាជីវកម្មទូទៅដែលម្ចាស់ជាអ្នកកំណត់ដោយខ្លួនឯងផ្ទាល់។ ក្នុងដំណើរការនៃការធ្វើពាណិជ្ជកម្មជាមួយអាស៊ាន ទាក់ទងទៅនឹងកិច្ចព្រមព្រៀងពាណិជ្ជកម្ម ការនាំចូល ការដាក់ពន្ធលើទំនិញនាំចូល ការនាំចេញ និងការវិនិយោគផ្ទាល់ពីបរទេស សុទ្ធតែជាការចូលរួមចំណែកយ៉ាងខ្លាំងក្លាពីសំណាក់រដ្ឋាភិបាល និងបណ្តាប្រទេសដែលជាដៃគូរពាណិជ្ជកម្ម ដោយធ្វើយ៉ាងណាដើម្បីទទួលបាននូវកិច្ចសហប្រតិបត្តិការដ៏រឹងមាំ និងយូរអង្វែង ដើម្បីធ្វើអោយសេដ្ឋកិច្ចរបស់ប្រទេសមានភាពរីកចម្រើនទៅមុខ និងធ្វើអោយកម្រិតជីវភាពរស់នៅរបស់ប្រជាជនមានភាពប្រសើរឡើង។ កំណើននៃទំហំពាណិជ្ជកម្មកើតមកពីការនាំចេញ-នាំចូលរវាងប្រទេសនឹងប្រទេស។ ការបង្កើននូវការនាំចេញបានជួយសម្រួលដល់ការប្រើប្រាស់ទំនិញ និងសេវាកម្ម ធ្វើអោយកម្រិត GDP របស់ប្រទេសមានការកើនឡើង ចំណែកឯការនាំចូលច្រើនលើសលុបបណ្តាលអោយកើតមាននូវឱនភាពពាណិជ្ជកម្ម។ បើទោះបីជាទការមានផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមានយ៉ាងណាក្តី ក៏គេចង់អោយមានទំនាក់ទំនងដោះដូរគ្នាទៅវិញទៅមកដែរ ព្រោះពាណិជ្ជកម្មប្រៀបបានទៅនឹងជីវិតមនុស្ស បើចង់ដើរលឿនត្រូវដើរទៅម្នាក់ឯង តែបើចង់ដើរបានឆ្ងាយហើយទទួលបានជោគជ័យគឺត្រូវតែមានដៃគូរ។ ដៃគូរពាណិជ្ជកម្មជាកាតាលីករយ៉ាងសំខាន់ក្នុងការជម្រុញល្បឿនសេដ្ឋកិច្ច និងបង្កើនភាពរីកចម្រើន។

សរុបមក ការធ្វើពាណិជ្ជកម្មរបស់កម្ពុជា ជាមួយនឹងបណ្តាប្រទេសទាំងបីពិតជាបានជួយជ្រោមជ្រែងដល់កំណើនពាណិជ្ជកម្មកម្ពុជាមួយភាគធំ ពោលគឺមានចំនួនស្មើនឹង ១៧.៥%នៃពាណិជ្ជកម្មសរុបជារៀងរាល់ឆ្នាំ។ មិនតែប៉ុណ្ណោះការធ្វើពាណិជ្ជកម្មរបស់កម្ពុជា ទោះបីមានទំហំតិចតួចក្តីបើប្រៀបធៀបនៅក្នុងបណ្តាប្រទេសអាស៊ាន ក៏កម្ពុជានៅតែបន្តនូវពាណិជ្ជកម្មរបស់ខ្លួនជារៀងរាល់ឆ្នាំ។ មួយវិញទោះជាបីជាប្រទេសកម្ពុជាធ្វើការនាំចូលច្រើនជាងការនាំចេញក៏ពិតមែន តែកំណើននៃកម្រិត GDP ក្នុងស្រុកចេះតែបន្តកើនឡើងបន្តិចម្តងៗ ដែលវាជាសក្ខីភាពនៃការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលនៅក្នុងប្រទេស។ នៅក្នុងឆ្នាំ២០២០កម្រិតGDPរបស់កម្ពុជា មានការធ្លាក់ចុះក៏បណ្តាលមកពីឥទ្ធិពលនៃ Covid-19 ដែលជាជំងឺរាតត្បាតយ៉ាងកាចសាហាវ ធ្វើអោយ

គ្រប់បណ្តាលប្រទេសទាំងអស់លើសកលលោកទទួលរងនូវផលប៉ះពាល់ទៅលើសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរ។ មួយវិញទៀត ការធ្វើពាណិជ្ជកម្មរបស់កម្ពុជាជាមួយប្រទេសបីនៅមានទំហំតិចតួចនៅឡើយ បើយើងធៀបទៅនឹងទំហំពាណិជ្ជកម្មសរុបរបស់អាស៊ាន ក៏ប៉ុន្តែការធ្វើពាណិជ្ជកម្មក៏ចេះតែមានកំណើនជារៀងរាល់ឆ្នាំ ដែលនេះជាសញ្ញាល្អសម្រាប់ពាណិជ្ជកម្មកម្ពុជា។ មិនតែប៉ុណ្ណោះការនាំចេញរបស់កម្ពុជាបែរជាមានកំណើនច្រើនជាងឆ្នាំមុនៗ នេះសបញ្ជាក់អោយឃើញថា ទោះបីជាជួបប្រទះនឹងឧបសគ្គយ៉ាងណាក៏ដោយ ក៏ប្រទេសកម្ពុជានូវតែជម្នះ និងខិតខំអភិវឌ្ឍន៍ខ្លួន ប្រៀបបាននឹងដើមឈើដែលខំស្រាក់ឫសជ្រៀតខ្លួនដុះចេញពីថ្ម នៅប្រាសាទតាព្រហ្ម (ខេត្តសៀមរាប)ដូច្នោះដែរ។ តាំងពីសម័យបុរេប្រវត្តិមកកម្ពុជា គឺជាអ្នកតស៊ូ ពុះពារ មិនរាថយ ឬចុះញម នឹងបញ្ហានោះទេ ដរាបណានៅតែមានផ្លូវនោះប្រទេសកម្ពុជានៅតែបន្តដំណើរឆ្ពោះទៅរកភាពជោគជ័យអោយខានតែបាន។

## ២.អនុសាសន៍

យោងតាមការបកស្រាយទិន្នន័យចំណុចទី ៣.២.១ នៅក្នុងជំពូកទី៣ គេសង្កេតឃើញថាការនាំចេញរបស់កម្ពុជាគឺមានចំនួនតិចតួចនៅឡើយ បើធៀបនឹងការនាំចូលជាមួយនឹងបណ្តាប្រទេសទាំងបី។ ដូចេះដើម្បីចូលរួមជាបច្ច័យក្នុងការធ្វើអោយមានកំណើនពាណិជ្ជកម្ម ការស្រាវជ្រាវនេះបានបង្ហាញអនុសាសន៍មួយចំនួនដូចខាងក្រោម ៖

- ពង្រឹងខ្សែសង្វាក់ផលិតកម្ម និងពង្រីកទីផ្សារក្នុងស្រុក ដើម្បីបង្កើនការនាំចេញ
- ធ្វើអោយមានភាពប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធដែលភ្ជាប់ច្រកព្រំដែនរវាងប្រទេសនីមួយៗ ដើម្បីសម្រួល និងជម្រុញដល់ការនាំចេញ-នាំចូល
- ការលើកទឹកចិត្តដល់ការបង្កើតនូវការច្នៃប្រឌិត និងជួយសម្រួលដល់ការទទួលបានឥណទាន
- ជម្រុញទីផ្សារជនបទចំពោះផលិតករតូចតាច និងពាណិជ្ជកម្មខ្នាតតូច រួមទាំងធ្វើសហប្រត្តិការជាមួយស្ថាប័នពាក់ព័ន្ធផ្សេងៗ ដើម្បីកាត់បន្ថយចំណាយថ្លៃដឹកជញ្ជូន
- ត្រូវស្វះស្វែងបន្ថែមនូវមធ្យោបាយដឹកទំនិញអោយកាន់តែសម្បូរបែប និងគ្រប់តាមចំនួនដែលមាននៅក្នុងកិច្ចព្រមព្រៀង ដើម្បីពន្លឿន និងបង្កើនទំហំដឹកជញ្ជូន

មួយវិញទៀត តាមរយៈការបកស្រាយចំណុចចុងក្រោយនៃជំពូកទី៣ យើងសង្កេតឃើញថា ទំហំនៃការធ្វើពាណិជ្ជកម្មរបស់កម្ពុជាជាមួយប្រទេសទាំងបី នៅមានទំហំតិចតួចនៅឡើយ ហេតុដូចនេះរដ្ឋាភិបាលគួរតែពិចារណា និងដោះស្រាយទៅលើបញ្ហាមួយចំនួនដូចខាងក្រោម ៖

- កែសម្រួល បង្កើន និងជម្រុញការធ្វើពាណិជ្ជកម្មជាមួយនឹងប្រទេសទាំងបី ដើម្បីពង្រឹងចំណងមិត្តភាព និងភាពស្និតស្នាល

- រៀបចំយុទ្ធសាស្ត្រ ប្រាប់ពីតម្រូវការទីផ្សារដល់ក្រុមហ៊ុន សហគ្រាស ដើម្បីជម្រុញដល់ការផលិតនូវផលិតផល និងចំណាយថ្លៃដើមទាប(ផលិតច្រើនថ្លៃដើមក្នុងមួយឯកតាថយចុះ)
- ជម្រុញការថែរក្សាកម្មសិទ្ធិបញ្ញាពាក់ព័ន្ធនឹងពាណិជ្ជកម្មដូចជា ផ្លាកសញ្ញាពាណិជ្ជកម្ម និងការបញ្ជាក់ពីទីតាំងភូមិសាស្ត្រដែលផលិត
- ជម្រុញការវិនិយោគក្រៅប្រទេស ក៏ដូចជាកែសម្រួលច្បាប់បញ្ញត្តិក្នុងប្រទេសអោយកាន់តែងាយស្រួលដើម្បីទាក់ទាញវិនិយោគទុនផ្ទាល់ពីបរទេស
- ជម្រុញសេដ្ឋកិច្ចពាណិជ្ជកម្មអោយឆ្ពោះទៅរកសមាហរណកម្មស៊ីជម្រៅជាងមុន ដើម្បីកាត់បន្ថយចំណាយប្រតិបត្តិការ និងពង្រឹងការប្រកួតប្រជែង
- បង្កើតប្រព័ន្ធសម្របសម្រួលដល់ការគ្រប់គ្រងរូបិយវត្ថុបរទេស ដែលមានអំណោយផលដល់ស្ថេរភាពហិរញ្ញវត្ថុ និងការអភិវឌ្ឍសេដ្ឋកិច្ចពាណិជ្ជកម្ម។

# ឯកសារយោង

## ឯកសារបរទេស


Sen Sunanda. (November, 2010). Levy Economics Institute of Bard College

Schumacher. *University of Potsdam, Germany (Adam Smith´s theory of absolute advantage)*

Keuschnigg. (1999)*. (Comparative Advantage in International Trade)*

Association of Southeast Asian Nations (ASEAN). (20 November 2007). Charter of the Association of Southeast Asian Nations.

Pushpanathan. (2020) Deputy Secretary-General of ASEAN for ASEAN Economic Community

Bradley Dunseith. (2017). *Import and Export Procedures in Cambodia – Best Practices.*

J. W. Creswell. (2013). *Research design: Qualitative, quantitative, and mixed methods approaches. Sage publications.* Texas.

Andreas. (2020). The Pros & Cons of International Trade

Asia Pacific Parliamentary Forum. Government of Laos.(2017)

Arkolakis, C., S. Demidova, P. J. Klenow, and A. Rodriguez-Clare. (2020). Endogenous variety and the gains from trade.

Lindsay Maizland and Eleanor Albert. (2020, November 24). *What is ASEAN?*

Trading Economics. (2021). *Cambodia imports from Vietnam.*

World Bank. (2018-2019). *World Bank national accounts data.*

World Bank. *Merchandise trade statistics data for Cambodia.*


## ឯកសារជាភាសាខ្មែរ


ឡុង ម៉ាមីឌី. (២០១៣) *សេដ្ឋកិច្ចអន្តរជាតិ.*

Khmerpost. (2018). *ក្រសួងបង្ហាញវិធីការពារគ្រោះថ្នាក់៦ចំណុច ចំពោះការបើកបរកាត់ផ្លូវរថភ្លើង. Phnom Penh.*

ក្រសួងពាណិជ្ជកម្ម. (2014). *Cambodia Trade Integration Strategy 2014-2018.*

ជុំ ជោគជាតា. (៦ ធ្នូ 2018). *ស្តីពី កម្ពុជា-ឡាវ ពង្រីកបន្ថែមការធ្វើពាណិជ្ជកម្មជាមួយគ្នា.*

នាយកដ្ឋានគោលនយោបាយពាណិជ្ជកម្មនៃអគ្គនាយកដ្ឋានជម្រុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម. *ដំណើរវិវត្តន៍នៃសហគមន៍សេដ្ឋកិច្ចអាស៊ាន.*

អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា. (2017). *តារាងពន្ធគយឆ្នាំ ២០១៧.*

សាគូ សាម៉ុត. (2015). *ភូមិសាស្ត្រ ប្រទេសកម្ពុជា.* Phnom Penh: Angkor Phnom Penh Printer.

ក្រសួងពាណិជ្ជកម្ម. (2011).*ការអភិវឌ្ឍវិស័យពាណិជ្ជកម្ម និងជំនួយសម្រាប់ពាណិជ្ជកម្មកម្ពុជា.*

ក្រសួងសាធារណការ និងដឹកជញ្ជូន. (2017). *បណ្តាញផ្លូវគោកនៅកម្ពុជា .*

ហង់ ជួនណារ៉ុន. (២០១៥). *សេដ្ឋកិច្ចកម្ពុជា.*

ម៉ូលី. (២០០៨). *ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវដែក នៅកម្ពុជា: យុទ្ធសាស្ត្ររយៈពេលវែង ឯកសារពិភាក្សារបស់វិទ្យាស្ថានអភិវឌ្ឍសេដ្ឋកិច្ច លេខ ១៥០. វិទ្យាស្ថានអភិវឌ្ឍសេដ្ឋកិច្ច .*

ក្រសួងសាធារណការ និងដឹកជញ្ជូន. (២០១៣). *ទិដ្ឋភាពទូទៅនៃហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូននៅព្រះរាជាណាចក្រកម្ពុជា,បោះពុម្ពលើកទី៤ របាយការណ៍ប្រចាំឆ្នាំ.*

ជា វណ្ណៈ.(២៣ មេសា ២០១៩). *ប្រទេសកម្ពុជា និងប្រទេសថៃភ្ជាប់បណ្តាញផ្លូវដែកជាមួយគ្នា.*

Peter Ford. (5 មិថុនា 2016). *សេវារថភ្លើងកម្ពុជាពេញនិយមឡើងវិញចន្លោះផ្លូវពីភ្នំពេញ និងខេត្តព្រះសីហនុ*

ហ៊ិន ពិសី. (១២ ធ្នូ ២០១៨). *ការពង្រីកកំពង់ផែភ្នំពេញដើម្បីជម្រុញការដឹកជញ្ជូនតាមផ្លូវទឹកនៅប្រទេសកម្ពុជា.*

សុខ ចាន់. (២៩ មីនា ២០២១). *វិស័យកស្ទុការ និងដឹកជញ្ជូនត្រូវបានពិនិត្យឡើងវិញនៅក្នុងកិច្ចប្រជុំអាស៊ានលើកទី៤០.*

វ្សប៊ីនស្តីស.(១២ ធ្នូ ២០១៧).*ប្រទេសកម្ពុជាត្រូវប្រឈមនឹងបញ្ហាទ្វេដងស្តីពីការស្តាបនាផ្លូវថ្នល់.*

អង្គការស្បៀងអាហារ និងកសិកម្មនៃអង្គការសហប្រជាជាតិ(FAO). (៨ ខែមេសា ឆ្នាំ២០២០). *ផលប៉ះពាល់នៃកូវីដ១៩ទៅលើសេដ្ឋកិច្ចក្រៅប្រព័ន្ធ.*

អង្គការពលកម្មអន្តរជាតិ(ILO). (២៩ ខែមេសា ឆ្នាំ២០២០).*ដោយសារការបាត់បង់ការងារចេះតែកើនឡើងស្មើពាក់កណ្តាលនៃកម្លាំងពលកម្មពិភពលោកនឹងមានហានិភ័យលើជីវភាពរស់នៅ.*

Amarthalingam,S.(១៤ ខែឧសភា ឆ្នាំ២០២០). *ការបាត់បង់ការងារ ការកាត់ប្រាក់ខែ បង្ខំអោយប្រជាជនជំពាក់បំណុល.*

VietnamPlus.(២៨ មេសា ឆ្នាំ២០២០).*ការផ្ញើរប្រាក់ពីបរទេសមកកម្ពុជាមានការធ្លាក់ចុះយ៉ាងខ្លាំងដោយសារកូវីដ១៩*

ធនាគារអភិវឌ្ឍន៍អាស៊ី(ADB).(៣មេសាឆ្នាំ២០២០).*កំណើនសេដ្ឋកិច្ចរបស់កម្ពុជាមានសភាពយឺតនៅឆ្នាំ២០២០ ហើយរំពឹងថានឹងមានសន្ទុះងើបលើងវិញនៅឆ្នាំ២០២១*

## ឯកសារពីគេហទំព័រ

Asian's diversity ដកស្រង់ចេញពី https://www.cfr.org (ចូលទស្សនាថ្ងៃទី ៥ ឧសភា ២០២១)

Asean. (2017). ដកស្រង់ចេញពី asean.org(ចូលទស្សនាថ្ងៃទី ៧ ឧសភា ២០២១)

Cambodia data,2021, data.wto.org.(ចូលទស្សនាថ្ងៃទី ៦ មិថុនា ២០២១)

International Trade Theory, Chapter 2 (International Trade and FDI) (ចូលទស្សនាថ្ងៃទី ៥ ឧសភា ២០២១) https://saylordotorg.github.io/, 2011)

ពាណិជ្ជកម្មនៅក្នុងស្រុក,2021,ដកស្រង់ចេញពី Investopedia.com(ចូលទស្សនាថ្ងៃទី ១៩ ឧសភា ២០២១)

Dr.Tabrez Ahmad. (2011, January 11). ទាញយកពី Slideshare.net. (ចូលទស្សនាថ្ងៃទី ៥ ឧសភា ២០២១)

Demographic of Thailand 2009, ដកស្រង់ចេញពី Wekipedia.com, (ចូលទស្សនាថ្ងៃទី ១២ កក្កដា ២០២១)

Jisunfoo. (2014, May 21). ទាញយកមកពី Slideshare.net. (ចូលទស្សនាថ្ងៃទី ៥ ឧសភា ២០២១)

បរិមាណនាំចេញ និងនាំចូលឆ្នាំ ២០១៩,ដកស្រង់ចេញពី ធនាគារជាតិនៃកម្ពុជា. nbc.org.kh (ចូល ទស្សនាថ្ងៃទី ៧ ឧសភា ២០២១)

YUKAKO ONO. (១៨ កុម្ភៈ ២០១៨), Thailand's GDP grows at fastest pace in 5 years in 2017ដកស្រង់ចេញពី NIKKIE Asia.com ចូលទស្សនាថ្ងៃទី ១២ កក្កដា ២០២១

ច្រកទ្វារព្រំដែនបារិត, ២០១៨,ដកស្រង់ចេញពីvisitcambodia.travel.(ចូលទស្សនាថ្ងៃទី ២៩ មិថុនា ២០២១)

ក្រសួងពាណិជ្ជកម្ម. (២០១៩). កិច្ចព្រមព្រៀងពាណិជ្ជកម្មអន្តរជាតិ. http://www.moc.gov.kh/ (ចូលទស្សនាថ្ងៃទី ៧ មិថុនា ២០២១)

ក្រសួងពាណិជ្ជកម្ម. (2021). ព្រឹត្តិបត្រពាណិជ្ជកម្ម. http://www.moc.gov.kh/ (ចូលទស្សនាថ្ងៃទី ១៩ មិថុនា ២០២១)

ក្រុមហ៊ុនថៃបង្កើនការវិនិយោគនៅកម្ពុជា(២៧ មករា 2020).ក្រសួងព័ត៌មាន.www.info.gov.kh (ចូលទស្សនាថ្ងៃទី ២៥ មិថុនា ២០២១)

សុខ សេរី,2018, រោងចក្រផលិតជីកសិកម្មវៀតណាមនៅកម្ពុជា.ដកស្រង់ចេញពី www.rfa.org (ចូលទស្សនាថ្ងៃទី ៩ មិថុនា ២០២១)

## ឧបសម្ព័ន្ធទី២៖ កិច្ចព្រមព្រៀងពាណិជ្ជកម្មរវាងប្រទេសកម្ពុជាជាមួយប្រទេសវៀតណាម











ឧបសម្ព័ន្ធទី៣ ៖ មុខបញ្ជីទំនិញទាំង ៣១ មុខដែលបានអនុគ្រោះពន្ធសូន្យភាគរយក្នុងការនាំចូលទៅប្រទេសវៀតណាម

| No | Tariff Code (AHTN 2017) | បរិយាយមុខទំនិញ |
|---|---|---|
| | **01.05** | បសុបក្សីរស់ សំដៅលើ បក្សីអម្បូរ Gallus domesticus ទា ក្ងាន មាន់បារាំង និងបក្សីគីណា |
| | | - ដែលមានទម្ងន់មិនលើសពី ១៨៥ក្រាម |
| | **0105.11** | - - បក្សីអម្បូរ Gallus domesticus ៖ |
| 1 | 0105.11.90 | - - - ផ្សេងទៀត |
| | **0105.99** | - -ផ្សេងទៀត |
| 2 | 0105.99.20 | - - - សត្វទាផ្សេងទៀត |
| | **02.07** | សាច់និងបំណែកសាច់ដែលអាចបរិភោគបានរបស់បសុបក្សី នៅទីតាំងលេខ ០១.០៥ ស្រស់ ត្រជាក់ ឬបង្កក |
| | | - នៃបក្សីអម្បូរ Gallus domesticus ៖ |
| 3 | 0207.11.00 | - - មិនកាត់ជាដុំ, ស្រស់ឬត្រជាក់ |
| 4 | 0207.12.00 | - - មិនកាត់ជាដុំ, បង្កក |
| 5 | 0207.13.00 | - - សាច់កាប់ និងបំណែកសាច់ ស្រស់ ឬត្រជាក់ |
| | **0207.14** | - - សាច់កាប់ និងបំណែកសាច់ បង្កក ៖ |
| 6 | 0207.14.10 | - - - ស្លាប |
| 7 | 0207.14.20 | - - - ភ្លៅ |
| 8 | 0207.14.30 | - - - ថ្លើម |
| | | - - - ផ្សេងទៀត |
| 9 | 0207.14.91 | សាច់ដែលត្រូវបានយកឆ្អឹងចេញ ដោយម៉ាស៊ីន |
| 10 | 0207.14.99 | - - - - ផ្សេងទៀត |
| | **08.05** | ផ្លែឈើពពួកក្រូចស្រស់ ឬក្រៀម |

| No | Tariff Code (AHTN 2017) | បរិយាយមុខទំនិញ |
|---|---|---|
| | **0805.50** | - ក្រូចឆ្មា (Citrus limon, Citrus limonum) and limes (Citrus aurantifolia, Citrus latifolia) : |
| 11 | 0805.50.10 | - - ក្រូចឆ្មា (Citrus limon, Citrus limonum) |
| 12 | 0805.50.20 | - - ក្រូចឆ្មា (Citrus aurantifolia, Citrus latifolia) |
| 13 | 0805.90.00 | - ផ្សេងទៀត |
| | **10.06** | ស្រូវ |
| | **1006.10** | - ស្រូវ មិនទាន់បកសម្បក និងបកសម្បក ៖ |
| 14 | 1006.10.10 | - - សមស្របសម្រាប់សាបព្រោះ |
| 15 | 1006.10.90 | - - ផ្សេងទៀត |
| | **1006.20** | - អង្ករស្រូប ៖ |
| 16 | 1006.20.10 | - - អង្ករហូមម៉ាលី |
| 17 | 1006.20.90 | - - ផ្សេងទៀត |
| | **16.02** | សាច់ សំណល់សាច់ ឬឈាមដែលត្រូវបានរក្សាទុក ឬកែច្នៃផ្សេងទៀត |
| | **1602.10** | - អាហារច្នៃស្មើសាច់ : |
| 18 | 1602.10.10 | - - មានជាតិសាច់ជ្រូក ក្នុងប្រអប់បិទជិតសម្រាប់លក់រាយ |
| | **19.05** | នំប៉័ង នំប៉ាស្ទ្រី (នំបន្ទះ) នំខេក ប៊ីស្គី គ្រឿងសម្រាប់ធ្វើនំផ្សេងទៀតទោះបីជាមាន ឬគ្មានជាតិកាកាវក៏ដោយ; នំក្រាប សម្បកដែលស្តើងដែលយកប្រើសម្រាប់ផ្ទុកថ្នាំពេទ្យ(ថ្នាំគ្រាប់កងទ្រវែង) នំស្តើងៗ បន្ទះធ្វើពីម្សៅអង្ករសម្រាប់រុំ និងផលិតផលស្រដៀងគ្នា |
| | **1905.90** | -ផ្សេងទៀត |
| 19 | 1905.90.30 | - - នំខេក |
| 20 | 1905.90.80 | - - ផលិតផលនំស្រួយផ្សេងទៀត |
| 21 | 1905.90.90 | - - ផ្សេងទៀត |
| | **24.01** | ថ្នាំជក់ឆៅ សំណល់ថ្នាំជក់ |
| | **2401.10** | - ថ្នាំជក់មិនទាន់កាត់ធាង/ញៀក : |
| 22 | 2401.10.10 | - - ថ្នាំជក់វើជីនីញ៉ា អប់ផ្សេង |
| 23 | 2401.10.20 | - - ថ្នាំជក់វើជីនីញ៉ា ក្រៅពីអប់ផ្សេង |

| No | Tariff Code (AHTN 2017) | បរិយាយមុខទំនិញ |
|---|---|---|
| 24 | 2401.10.40 | - - ប្រភេទ Burley |
| 25 | 2401.10.50 | - - ផ្សេងទៀត អប់ផ្សេង |
| 26 | 2401.10.90 | - - ផ្សេងទៀត |
| | **2401.20** | - ថ្នាំជក់ កាត់ធាង/ញៀកដោយផ្នែក ឬទាំងស្រុង : |
| 27 | 2401.20.10 | - - ថ្នាំជក់វើជីនីញ៉ា អប់ផ្សេង |
| 28 | 2401.20.20 | - - ថ្នាំជក់វើជីនីញ៉ា ក្រៅពីអប់ផ្សេង |
| 29 | 2401.20.30 | - - ប្រភេទ Oriental |
| 30 | 2401.20.40 | - - ប្រភេទ Burley |
| 31 | 2401.20.50 | - - ផ្សេងទៀត អប់ផ្សេង |
| 32 | 2401.20.90 | - - ផ្សេងទៀត |

ឧបសម្ព័ន្ធទី៤ ៖ បញ្ជីរាយនាមទំនិញ និងលេខកូដដែលទទួលបានការអនុគ្រោះពន្ធសូន្យភាគរយក្នុងការនាំទំនិញពីប្រទេសវៀតណាមចូលមកកម្ពុជា

| No. | Tariff Code (AHTN 2017) | បរិយាយមុខទំនិញ |
|---|---|---|
| | **02.07** | សាច់និងបំណែកសាច់ដែលអាចបរិភោគបានរបស់បសុបក្សី នៅទីតាំងលេខ ០១.០៥ ស្រស់ ត្រជាក់ ឬបង្កក |
| | | - នៃបក្សីអម្បូរ Gallus domesticus |
| 1 | 0207.11.00 | - - មិនកាត់ជាដុំ, ស្រស់ ឬត្រជាក់ |
| 2 | 0207.12.00 | - - មិនកាត់ជាដុំ, បង្កក |
| 3 | 0207.13.00 | - - សាច់កាប់ និងបំណែកសាច់ ស្រស់ ឬត្រជាក់ |
| | **0207.14** | - - សាច់កាប់ និងបំណែកសាច់ បង្កក ៖ |
| 4 | 0207.14.10 | - - - ស្លាប |
| 5 | 0207.14.20 | - - - ភ្លៅ |
| 6 | 0207.14.30 | - - - ថ្លើម |
| | | - - - ផ្សេងទៀត ៖ |
| 7 | 0207.14.91 | - - - - សាច់ដែលត្រូវបានយកឆ្អឹងចេញ ដោយម៉ាស៊ីន |
| | | - - - - នៃសត្វទា |
| 8 | 0207.41.00 | - - មិនកាត់ជាដុំ, ស្រស់ឬ ត្រជាក់ |
| 9 | 0207.42.00 | - - មិនកាត់ជាដុំ, បង្កក |
| 10 | 0702.00.00 | - - ប៉េងប៉ោះ ស្រស់ ឬត្រជាក់ |
| | **07.04** | ស្ពៃក្តោប ផ្កាខាត់ណា ខាត់ណាមើមមូល kohlrabi ស្ពៃក្រញាញ់ kale និងបន្លែស្ពៃ ដែលអាចបរិភោគបានស្រដៀងនេះ ស្រស់ ឬត្រជាក់ |
| | **0704.10** | - ផ្កាខាត់ណា និងខាត់ណាខៀវប្រូកូលី ៖ |
| 11 | 0704.10.20 | - - ផ្កាស្ពៃប្រូកូលី |

| No. | Tariff Code (AHTN 2017) | បរិយាយមុខទំនិញ |
|---|---|---|
| | **07.06** | មើមការ៉ុត(មើមស្ពូច) មើមស្ពៃ(មើមកំប៉ោង) មើមឆៃថាវ មើមស្ពៃក្រហម មើមផ្កាពុកមាត់ពពែ មើមគិនឆាយ មើមរ៉ាឌី និងមើមអាចបរិភោគបាន ស្រដៀងនេះ ស្រស់ ឬត្រជាក់ |
| | **0706.10** | - មើមការ៉ុត(មើមស្ពូច) មើមស្ពៃ(មើមកំប៉ោង) ៖ |
| 12 | 0706.10.20 | - - មើមស្ពៃ |
| 13 | 0706.90.00 | - ផ្សេងទៀត |
| 14 | 0707.00.00 | ត្រសក់ និងត្រសក់ស្រូវ ស្រស់ ឬត្រជាក់ |
| | **07.08** | បន្លែពពួកសណ្តែក គ្មានសម្បកឬមានសម្បក ស្រស់ ឬត្រជាក់ |
| | **0708.20** | - សណ្តែក (Vigna spp., Phaseolus spp.)៖ |
| 15 | 0708.20.10 | - - សណ្តែកបារាំង |
| 16 | 0708.20.20 | - - សណ្តែកកួរ |
| 17 | 0708.20.90 | - - ផ្សេងទៀត |
| | **07.09** | បន្លែផ្សេងទៀត ស្រស់ ឬ ត្រជាក់ |
| | | ផ្សេងទៀត |
| 18 | 0709.93.00 | - - ផ្លែល្ពៅ ផ្លែ squash និងផ្លែឃ្លោក (Cucurbita spp.) |
| | **08.04** | ផ្លែល្មើ ល្វា ម្នាស់ ផ្លែអាវូកាដូ ត្របែក ស្វាយ មង្ឃុត ស្រស់ ឬក្រៀម |
| 19 | 0804.30.00 | - ម្នាស់ |
| | **0804.50** | - ត្របែក ស្វាយ និងមង្ឃុត ៖ |
| 20 | 0804.50.20 | - - ស្វាយ |
| 21 | 0804.50.30 | - - មង្ឃុត |
| | **08.05** | ផ្លែឈើពពួកក្រូចស្រស់ ឬក្រៀម |
| | 0805.10 | - ក្រូចពោធិ៍សាត់ ៖ |
| 22 | 0805.10.20 | - ក្រៀម |
| | **08.07** | ផ្លែមីឡុង(រាប់បញ្ចូលទាំងផ្លែឪឡឹក) និងផ្លែល្ហុង ស្រស់ |
| | | - ផ្លែមីឡុង(រាប់បញ្ចូលទាំងឪឡឹក) ៖ |
| 23 | 0807.11.00 | - - ផ្លែឪឡឹក |

## ឧបសម្ព័ន្ធទី ៥ ៖ បញ្ជីរាយទំនិញដែលហាមឃាត់ក្នុងការនាំចូល

| ល.រ | លេខកូដ | ពិពណ៌នាមុខទំនិញ |
|---|---|---|
| 1 | 2620.11.00 | [illegible] |
| 2 | 2620.19.00 | -- ផ្សេងទៀត |
| 3 | 2620.21.00 | [illegible] |
| 4 | 2620.29.00 | -- ផ្សេងទៀត |
| 5 | 2620.30.00 | [illegible] |
| 6 | 2620.40.00 | [illegible] |
| 7 | 2620.60.00 | [illegible] |
| 8 | 2620.91.00 | [illegible] |
| 9 | 2620.99.10 | [illegible] |
| 10 | 2620.99.90 | --- ផ្សេងទៀត |
| 11 | 2621.10.00 | [illegible] |
| 12 | 3006.92.10 | [illegible] |
| 13 | 3604.90.20 | [illegible] |
| 14 | 3824.71.90 | --- ផ្សេងទៀត |
| 15 | 3825.10.00 | [illegible] |
| 16 | 3825.20.00 | [illegible] |
| 17 | 3825.30.10 | [illegible] |
| 18 | 3825.30.90 | -- ផ្សេងទៀត |
| 19 | 3825.41.00 | [illegible] |
| 20 | 3825.49.00 | -- ផ្សេងទៀត |
| 21 | 3825.50.00 | [illegible] |
| 22 | 3825.61.00 | [illegible] |
| 23 | 3825.69.00 | -- ផ្សេងទៀត |
| 24 | 3825.90.00 | - ផ្សេងទៀត |
| 25 | 3915.20.10 | [illegible] |
| 26 | 3915.20.90 | -- ផ្សេងទៀត |
| 27 | 3915.30.10 | [illegible] |
| 28 | 3915.30.90 | -- ផ្សេងទៀត |
| 29 | 3915.90.00 | [illegible] |
| 30 | 4707.90.00 | [illegible] |
| 31 | 7001.00.00 | [illegible] |
| 32 | 7503.00.00 | [illegible] |
| 33 | 7802.00.00 | [illegible] |
| 34 | 8002.00.00 | [illegible] |
| 35 | 8102.97.00 | -- កាកសំណល់ និងកម្ទេច |
| 36 | 8103.30.00 | - កាកសំណល់ និងកម្ទេច |
| 37 | 8104.20.00 | - កាកសំណល់ និងកម្ទេច |
| 38 | 8105.30.00 | - កាកសំណល់ និងកម្ទេច |
| 39 | 8106.00.10 | [illegible] |
| 40 | 8107.30.00 | - កាកសំណល់ និងកម្ទេច |
| 41 | 8108.30.00 | - កាកសំណល់ និងកម្ទេច |
| 42 | 8109.30.00 | - កាកសំណល់ និងកម្ទេច |
| 43 | 8110.20.00 | - កាកសំណល់ និងកម្ទេច |
| 44 | 8111.00.10 | - កាកសំណល់ និងកម្ទេច |
| 45 | 8111.00.90 | - ផ្សេងទៀត |
| 46 | 8112.13.00 | -- កាកសំណល់ និងកម្ទេច |
| 47 | 8112.22.00 | -- កាកសំណល់ និងកម្ទេច |
| 48 | 8112.52.00 | -- កាកសំណល់ និងកម្ទេច |
| 49 | 8112.92.00 | [illegible] |
| 50 | 8113.00.00 | [illegible] |
| 51 | 8548.10.13 | [illegible] |
| 52 | 8548.10.19 | --- ផ្សេងទៀត |
| 53 | 8548.10.20 | [illegible] |
| 54 | 8548.10.30 | [illegible] |
| 55 | 8548.10.91 | [illegible] |
| 56 | 8548.10.92 | [illegible] |
| 57 | 8548.10.99 | --- ផ្សេងទៀត |

## ឧបសម្ព័ន្ធទី៦ ៖ ទិន្នន័យសរុបនៃការនាំចេញ នាំចូលសរុបរបស់កម្ពុជាជាមួយប្រទេសទាំងបី

| ឆ្នាំ | GDP | X | M | ទំហំពាណិជ្ជកម្ម | ឱនភាពពាណិជ្ជកម្ម |
|---|---|---|---|---|---|
| 2010 | $ 11,242.27 | 246.82 | 1496.1 | 1742.92 | -1249.28 |
| 2011 | $ 12,829.54 | 340.08 | 1608.2 | 1948.28 | -1268.12 |
| 2012 | $ 14,054.44 | 209.87 | 2060.92 | 2270.79 | -1851.05 |
| 2013 | $ 15,227.99 | 325.55 | 2073.74 | 2399.29 | -1748.19 |
| 2014 | $ 16,702.61 | 146.9 | 1924.3 | 2071.2 | -1777.4 |
| 2015 | $ 18,049.95 | 537.3 | 2508.63 | 3045.93 | -1971.33 |
| 2016 | $ 20,016.74 | 656.39 | 3347.51 | 4003.9 | -2691.12 |
| 2017 | $ 22,158.20 | 762.76 | 4042.45 | 4805.21 | -3279.69 |
| 2018 | $ 24,444.00 | 682.55 | 5444.73 | 6127.28 | -4762.18 |
| 2019 | $ 26,728.00 | 845.51 | 5955.81 | 6801.32 | -5110.3 |
| 2020 | $ 25,888.47 | 1079.96 | 5529.87 | 6609.83 | -4449.91 |

ឧបសម្ព័ន្ធទី៧ ៖ GDP សរុបរបស់ប្រទេសកម្ពុជាចាប់ពីឆ្នាំ ២០១០ ដល់ ២០២០

| ឆ្នាំ | GDP ( លានដុល្លារ ) |
|---|---|
| ២០១០ | 11,242.275 |
| ២០១១ | 12,829.541 |
| ២០១២ | 14,054.443 |
| ២០១៣ | 15,227.991 |
| ២០១៤ | 16,702.610 |
| ២០១៥ | 18,049.954 |
| ២០១៦ | 20,016.747 |
| ២០១៧ | 22,158.209 |
| ២០១៨ | 24,444.000 |
| ២០១៩ | 26,728.000 |
| ២០២០ | 25,888.473 |

ឧបសម្ព័ន្ធទី៨ ៖បង្ហាញពីទំហំពាណិជ្ជកម្មសរុបរបស់ប្រទេសកម្ពុជាពីឆ្នាំ ២០១០ ដល់ ២០២០(លានដុល្លារ)

| ឆ្នាំ | ទំហំពាណិជ្ជកម្មសរុប |
|---|---|
| 2010 | 10,506.81 |
| 2011 | 12,830.58 |
| 2012 | 13,262.98 |
| 2013 | 14,897.45 |
| 2014 | 16,548.43 |
| 2015 | 19,211.35 |
| 2016 | 22,444.14 |
| 2017 | 25,562.67 |
| 2018 | 24,985 |
| 2019 | 34,918.90 |
| 2020 | 35,805.85 |

ឧបសម្ព័ន្ធទី៩ ៖ បង្ហាញពីទំហំពាណិជ្ជកម្មសរុបរបស់អាស៊ានពីឆ្នាំ ២០១០ ដល់ ២០១៩(គិតជា លានដុល្លារ)

| ឆ្នាំ | ការនាំចេញសរុបរបស់អាស៊ាន | ការនាំចូលសរុបរបស់អាស៊ាន | ទំហំពាណិជ្ជកម្មសរុបរបស់អាស៊ាន |
|---|---|---|---|
| 2010 | 264,398.20 | 238,465.60 | 502,863.80 |
| 2011 | 316,017.70 | 266,920.20 | 582,937.90 |
| 2012 | 328,023.50 | 277,616.70 | 605,640.20 |
| 2013 | 338,613.40 | 279,138.30 | 617,751.70 |
| 2014 | 330,209.50 | 277,904.30 | 608,113.80 |
| 2015 | 287,106.40 | 248,274 | 535,380.40 |
| 2016 | 277,896.30 | 240,058.10 | 517,954.40 |
| 2017 | 311,825.30 | 277,291.40 | 589,116.70 |
| 2018 | 344,506.50 | 304,278.80 | 648,785.30 |
| 2019 | 332,311.90 | 300,292.40 | 632,604.30 |